## ពាក្យផ្ដើម

*ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថាៈ*

*អ្នកទាំងឡាយចូរឃើញភ័យក្នុងសេចក្ដីខ្ជិល ចូរឃើញនូវការប្រារព្ធព្យាយាមថា ជាផ្លូវនៃសេចក្ដីសុខក្សេមក្សាន្ត ហើយប្រារព្ធនូវសេចក្ដីព្យាយាមចុះ នេះជាពាក្យទូន្មានប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ៗ ព្រះអង្គ ។*

*អ្នកទាំងឡាយចូរឃើញក្នុងការវិវាទ ចូរឃើញការមិនមានវិវាទថា ជាផ្លូវនៃសេចក្ដីសុខក្សេមក្សាន្ត ហើយចូរពោលវាចាទន់ភ្លន់ផ្អែមល្ហែម ប្រកបដោយការព្រមព្រៀងគ្នាចុះ នេះជាការទូន្មានប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធទាំងគ្រប់ៗព្រះអង្គ ។*

*អ្នកទាំងឡាយ ចូរឃើញក្នុងសេចក្ដីប្រមាទ ចូរឃើញការមិនប្រមាទថា ជាផ្លូវនៃសេចក្ដីសុខក្សេមក្សាន្ត ហើយចូរចម្រើននូវមគ្គប្រកបដោយអង្គ ៨ ប្រការចុះ នេះជាពាក្យទូន្មានប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ៗ ព្រះអង្គ ។*

*សូមអនុមោទនា !!!*

# មាតិកា

**ចំណងជើងអត្ថបទ** **លេខទំព័រ**

សេចក្ដីផ្ដើម------------------------------------------------------------------------------------------ក
បត្តិទានគាថា -----------------------------------------------------------------------------------------ខ
ប្រវត្តិរូបសង្ខេប ឧបាសក ថាប់ ណាម---------------------------------------------------------------ង
អ្នកជួយកែសម្រួល និងពិនិត្យអក្ខរាវិរុទ្ធ---------------------------------------------------------ដ
នាមអ្នកជួយក្នុងការសាងធម្មទាន ---------------------------------------------------------------ឋ
មាតិកា---------------------------------------------------------------------------------------------ណ
ពុទ្ធជយមង្គលគាថា---------------------------------------------------------------------------------១

ជ័យជំនះលើកទី១-----------------------------------------------------------------------------------១
ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើមារាធិរាជ---------------------------------------------១
ជ័យជំនះលើកទី២--------------------------------------------------------------------------------៣០
ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើអាឡវកយក្ស-----------------------------------------៣០
លោកពោលថា សំលេងដែលបានឮទីទៅពេញទាំង
ជម្ពូទ្វីបទាំង ៤ គឺ------------------------------------------------------------------------------៤៤

គេធ្លាប់ពោលថា នៅក្នុងលោកនេះ មានអាវុធដ៏ប្រសើរ ៤ យ៉ាងគឺ------------------------------------------------------------------------------------------៤៩
ជ័យជំនះលើកទី ៣------------------------------------------------------------------------------------៨៤
ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើដំរីឈ្មោះនាឡាគីរី-------------------------៨៤
ជ័យជំនះលើកទី ៤-------------------------------------------------------------------------------១០៣
ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើអង្គុលីមាលចោរ------------------------១០៣
ជ័យជំនះលើកទី ៥-------------------------------------------------------------------------------១៣៦
ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើនាងចិញ្ចមាណវិកា--------------------១៣៦
ជ័យជំនះលើកទី ៦-------------------------------------------------------------------------------១៦០
ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើសច្ចកនិគ្រន្ថ------------------------------១៦០
ជ័យជំនះលើកទី ៧-------------------------------------------------------------------------------២២៨
ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើនន្ទោបនន្ទនាគរាជ----------------------២២៨
ជ័យជំនះលើកទី ៨-------------------------------------------------------------------------------២៤២
ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើមហាព្រហ្មឈ្មោះពកា-----------------២៤២
គាថាសំដែងអំពីអានិសង្ស-------------------------------------------------------------២៥៣

# ពុទ្ធជយមង្គលគាថា

## (គាថា ៨ បទ មានពាហុំគាថាជាដើម)

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## ជ័យជំនះលើកទី១

## ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើមារាធិរាជ

**ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ**
**គ្រីមេខលំ ឧទិតឃោរសសេនមារំ**
**ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេជយមង្គលានិ។**

*(ប្រែថា)៖ ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ*
*និម្មិតដៃមួយពាន់ កាន់សាស្ត្រាវុធនានា។*
*ជិះគ្រីមេខលជាតិ កោញ្ចនាទខ្ទរពសុជា*
*ព្រមដោយមានសេនា ពន្ទឹកលន់កងស័ព្ទស៊ាន ។*
*ដោយធម្មវិធី ទានបារមីជាប្រធាន*
*ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា។*
*វីជ័យមង្គល ចូរមានដល់អ្នកពល់គ្នា*
*ដោយតេជៈជ័យា ព្រះឈ្នះមារគ្រោនោះហោង ។*

រឿងដំបូងគឺរឿងឈ្នះស្តេចមារ ព្រោះស្តេចមារបានតាមរំខានព្រះពុទ្ធជាម្ចាស់ជារឿងរហូតមក ចាប់តាំងពីទ្រង់ចេញបួស, តែជ័យជំនះដែលព្រះអង្គទ្រង់ឈ្នះស្តេចមារក្នុងពេលមុនត្រាស់ដឹង គឺក្នុងថ្ងៃដែលត្រាស់ដឹងនុ៎ះ គឺជាជ័យជំនះយ៉ាងធំក្រៃលែងជាជ័យជំនះយ៉ាងសម្ខាន់ ព្រោះទ្រង់បង្ក្រាបបានទាំងស្តេចមារសេនាមារនិងធីតាមារ ដែលក្នុងដីការពាហុំបានពោលរួមគ្នា មិនបានពោលឲ្យច្បាស់ថា ព្រះពុទ្ធអង្គ ទ្រង់ឈ្នះស្តេចមារក្នុងពេលណា ឈ្នះសេនាមារក្នុងពេលណា និងឈ្នះធីតាមារក្នុងពេលណា ព្រោះដូច្នោះ សូមរៀបរាប់តាមលំដាប់ដូចតទៅថា តើព្រះអង្គឈ្នះអ្នកណាពេលណាតាមដូចដែលលោកពោលទុកក្នុងប្រសូត្រខ្វះ ក្នុងអដ្ឋកថាខ្វះ តាមដីកាខ្វះ បញ្ចូលគ្នា ។

ចាប់ផ្តើមមុនថ្ងៃត្រាស់ដឹង ពោលគឺស្តេចមារឈ្មោះ វសវត្តីមារ ជាទេវតានៅជាន់បរនិម្មិតវសវត្តី មានសេចក្តីឃើញយល់ខុសគឺមិនត្រូវការឲ្យ សត្វទាំងឡាយទៅផុតអំពីសង្សារវដ្តនេះ កាលបានឃើញ ព្រះមហាបុរស គឺព្រះចៅសិទ្ធត្ថៈ ទ្រង់នឿយណាយក្នុងកាមសុខ បានស្តេចយាងចេញសាងព្រះផ្នួស ស្វែងរកមោក្ខធម៌ដែលកើតអំពីនេក្ខម្មសុខ ក៏កើតទុក្ខ បានគិតរកផ្លូវធ្វើឲ្យព្រះមហាបុរស

ធ្លាក់នៅក្នុងអំណាចរបស់ខ្លួនរហូតទៅ ទើបសង្កេតតាមដានឃ្លាំមើលជាប់ជានិច្ច ។ ក្នុងថ្ងៃដែលព្រះអង្គត្រាស់ដឹងនោះ ព្រះមហាបុរសទ្រង់គង់ ប្រថាប់នៅក្រោមដើមអស្សត្ថព្រឹក្ស ដែលយើងនាំគ្នាហៅថា **ដើមពោធិ៍** ព្រះអង្គទ្រង់តាំងព្រះទ័យដាច់ខាតថា ព្រះអង្គមិនក្រោកឡើងឡើយ ទោះបីសាច់ឈាមក្នុងសរីរៈស្ងួតហួតហែងអស់រលីងនៅសល់តែស្បែក សរសៃ ឆ្អឹង ក៏ដោយចុះ, បើទ្រង់មិនបាន លុះនូវព្រះសម្មាសម្ពោធិញាណជាបណា ព្រះអង្គមិនក្រោកឡើងចាកទីប្រថាប់ជាដាច់ខាត ពេលនោះពួកទេវតាទាំងឡាយក៏មានចិត្តរីករាយសោមនស្ស បាននាំគ្នាមកចោមរោមពទ្ធ័ជុំវិញព្រះមហាបុរស ។

ចំណែកស្ដេចមារឃើញដូច្នោះ ក៏ក្រោធខឹង ទ្រាំពុំបានគិតថា គ្រានេះ បើអញមិនទំលាយសេចក្ដីតាំងចិត្តរបស់ព្រះមហាបុរសឲ្យបានទេ ព្រះអង្គនឹងផុតអំពីអំណាចកណ្ដាប់ដៃរបស់អញពុំខានទើបបានប្រមូលរួបរួមកងពលសេនាមារទាំងអស់ លើកទ័ពមកដើម្បីបង្ក្រាបព្រះមហាបុរស ដោយនិម្មិតជារូបផ្សេងៗគ្នា សុទ្ធតែគួរឲ្យខ្លាច កាន់សស្ត្រាវុធដ៏កាចសាហាវឃោរឃៅ បាននាំគ្នាមកកាន់ទីប្រថាប់របស់ព្រះមហាបុរស រីឯតួស្ដេចមារនោះ បាននិម្មិតដៃមួយពាន់កាន់សស្ត្រាវុធ ទ្រង់ជិះដំរីឈ្មោះ ***គ្រីមេខលៈ*** មានកំពស់២២០

យោជន៍ ដឹកនាំមុខពួកពលសេនា នាំគ្នាស្រែកសន្ធាប់សំលេង គឹកកងញាប់ញ័រប្រើថពីដល់ ៦០យោជន៍ ជាទីគួរឲ្យខ្លាចពន់ពេកណាស់ បណ្ដាពួកទេវតាទាំងឡាយ ដែលហែហមចោមរោមព័ទ្ធមហាបុរសម្នាក់ៗ ភិតភ័យញាប់ញ័រខ្លាចឫទ្ធិរបស់ស្ដេចមារព្រមទាំងបរិវារ បាននាំគ្នា ផ្អើលរត់ចោលព្រះមហាបុរសទៅអស់រលីង នៅសល់តែព្រះមហាបុរសម្នាក់ឯង ស្ដេចមារ ទើបបញ្ជាពលឲ្យចូលចាប់ព្រះមហាបុរស សម្លាប់ចោល ។

ព្រះមហាបុរស លុះត្រូវគេបោះបង់ចោល ស្ដេចគង់នៅតែម្នាក់ឯង ត្រមង់ត្រមោចរកអ្នកណាជាទីពឹងក៏គ្មាន ទើបព្រះអង្គរំលឹកនឹកដល់ព្រះបារមី ១០ ប្រការដែលព្រះអង្គបានបំពេញមកគឺ ទាន, សីល, នេក្ខម្ម, បញ្ញា, វិរិយ, ខន្ដិ, សច្ចៈ, អធិដ្ឋាន, មេត្តា និង ឧបេក្ខា ដែលបំបែកចេញជាបារមី ១០, ឧបបារមី ១០, បរមត្ថបារមី ១០ រួមត្រូវជាបារមី ៣០ គត់ ព្រះអង្គទ្រង់រំលឹកដល់ព្រះបារមីទាំង ៣០ នេះហើយទ្រង់តាំងព្រះទ័យមាំ ព្រះអង្គមិនបានស្ដេចក្រោកឡើងចាកទីប្រថាប់នុ៎ះ គឺព្រះអង្គមិនបានញាប់ញ័រខ្លាចអានុភាពរបស់ស្ដេចមារ និងសេនាមារឡើង ។

ឯពួកសេនាមារ កាលបានទទួលពាក្យបញ្ជា ពីស្តេចមារហើយ ក៏មិនអាចទៅជិតព្រះមហាបុរសបានឡើយ ដោយអំណាចព្រះបារមី ទោះបីចង់ធ្វើក៏ពុំសម្រេចឡើយ ឯព្រះមហាបុរសក៏គង់ប្រថាប់នៅដូចដើម មិនបានញាប់ញ័រឡើយ ។

ស្តេចមារឃើញដូច្នោះ គឺឃើញថា ពួកសេនាមិនអាចធ្វើអ្វីឲ្យអន្តរាយដល់ព្រះមហាបុរសបាន ក៏ក្រោធខឹង គិតថាអញនឹងប្រើអាវុធ ៩ ប្រការ ធ្វើឲ្យមហាបុរសភ័យខ្លាចហើយរត់ទៅ គិតដូច្នោះហើយក៏បណ្តាលឲ្យកើតជាព្យុះសង្ឃរាបក់មកអំពីទិសខាងកើត ព្យុះសង្ឃរាមានកំលាំងខ្លាំងអាចរម្ងើងភ្នំខ្ពស់ពី ១ យោជន៍, ២ យោជន៍ បានដោយឫទ្ធិរបស់ខ្លួន តែកាលខ្យល់នុ៎ះបក់មកដល់ ក៏មិនអាចប៉ះពាល់ជាយចីវររបស់ព្រះមហាបុរសនុ៎ះឲ្យកំរើក បានឡើយ ។

លំដាប់នោះ ក្រុងមារក៏បណ្តាលឲ្យមហាមេឃតាំងឡើង ធ្វើភ្លៀងឲ្យធ្លាក់ចុះ ទឹកភ្លៀងហូរជន់លិចទូទៅ តែមិនអាចធ្វើឲ្យចីវររបស់ព្រះមហាបុរសទទឹកភ្លៀង សូម្បីតែមួយតំណក់គ្មានឡើយ ។

ស្តេចមារ ទើបបណ្តាលឲ្យភ្លៀងជាដុំសិលា ធ្លាក់ចុះមកទំលាយកំពូលភ្នំតូចធំ កើតជាអណ្តាតភ្លើង មានផ្សែងហុយឡើងទៅកណ្តាល

អាកាស តែលុះមកដល់ព្រះមហាបុរសក៏ក្លាយជាបុប្ផាទិព្វ បូជាព្រះអង្គទៅវិញ ។

ស្តេចមារ ទើបបណ្តាលឲ្យភ្លៀងអាវុធផ្សេងៗធ្លាក់ចុះហើយឆេះជាភ្លើង លុះមកដល់ព្រះកាយព្រះមហាបុរស ក៏ក្លាយជាបុប្ផាទិព្វបូជាព្រះមហាបុរសទៀត ។

ស្តេចមារឃើញដូច្នោះ ក៏បណ្តាលឲ្យភ្លៀងរងើកភ្លើងធ្លាក់ចុះមករងើកភ្លើងនុ៎ះ មានពណ៌ក្រហមក្តៅប្រហែលនឹងភ្លើងនរកគ្មាន អណ្តាត និងផ្សែង ឯភ្លៀងរងើកភ្លើងនោះ ក៏ក្លាយជាទិព្វមាលាធ្លាក់ចុះមកបូជាព្រះមហាបុរស ។

លំដាប់អំពីនោះ ទើបបណ្តាលឲ្យភ្លៀងផេះក្តៅយ៉ាងខ្លាំងធ្លាក់ចុះមក ភ្លៀងផេះនោះ ក៏ក្លាយជាលំអិតខ្លឹមចន្ទន៍ក្រស្នាទិព្វ ធ្លាក់ចុះមករោយរាយបូជាព្រះមហាបុរសទៀត ។

ស្តេចមារឃើញដូច្នោះ ទើបបណ្តាលឲ្យធ្លាក់ភ្លៀងខ្សាច់ក្រុតដ៏ល្អិតជាផ្សែង និងអណ្តាតភ្លើង តែភ្លៀងខ្សាច់ក្រុតនោះ ក្លាយជាបុប្ផានិងកែវមណី ធ្លាក់ជុំវិញបរិវេណព្រះស្រីមហាពោធិព្រឹក្ស ។

តមកស្ដេចមារបណ្ដាលឲ្យភ្លៀងដីភក់ ក្ដៅធំដោយអណ្ដាតភ្លើងធ្លាក់ចុះមក ភ្លៀងដីភក់នោះ ប្រែក្លាយជាគ្រឿងសំអាងមានក្លិនក្រអូបធ្លាក់បូជាទៀបព្រះបាទ ។

តអំពីនោះ ទើបបណ្ដាលឲ្យកើតងងឹតអន្ធការ ដែលប្រកបព្រមដោយអង្គ ៤ ដោយសង្ឃឹមថា ព្រះមហាបុរសកើតភ័យខ្លាចហើយនឹងរត់ចេញទៅ តែប្រាកដមានពន្លឺព្រះអាទិត្យមកលុបលាងងងឹតនោះ ឲ្យបាត់ទៅ ។

កាលស្ដេចមារ មិនអាចធ្វើអ្វីឲ្យអន្តរាយដល់ព្រះមហាបុរសដោយឫទ្ធិរបស់ខ្លួន ក៏កើតក្រោធខឹងយ៉ាងក្រៃលែង បង្ខំឲ្យពួករេហ៍ពល ចូលទៅចាប់ព្រះមហាបុរសមកសម្លាប់ចោល តួស្ដេចមារខ្លួនឯងបង្ខំឲ្យដំរីគ្រីមេខលៈ ចូលទៅជិតដើមពោធិ៍នោះបណ្ដើរ គ្រវីអាវុធបណ្ដើរ ស្រែកប្រកាសថា នែចៅសិទ្ធត្ថៈ អ្នកឯងក្រោកចេញពីបល្ល័ងនេះទីនាំង គឺបល្ល័ង្កនេះ មិនសមគួរដល់អ្នកឯងទេ គឺសមគួរដល់យើង ។

រីឯព្រះមហាបុរស ទ្រង់អាងយកបុញ្ញាធិការដែលព្រះអង្គទ្រង់សន្សំមកជាអនេកប្បការ មកនិយាយឲ្យស្ដេចមារស្ដាប់ ហើយទើបត្រាស់ថា បល្ល័ង្កនេះ កើតឡើងដោយបុណ្យរបស់ព្រះអង្គ ។

ស្តេចមារឆ្លើយបដិសេធថា បល្ល័ង្កនេះកើតឡើងដោយបុណ្យរបស់ខ្លួន មិនមែនដោយបុណ្យរបស់ព្រះមហាបុរសទេ ព្រោះហេតុនោះ សូមឲ្យព្រះ មហាបុរសចុះចេញទៅ ។

ព្រះមហាបុរសត្រាស់សួរថា តើអ្នកណាជាសាក្សីរបស់លោក? ឯស្តេចមារ សំលឹងមើលបរិវាររបស់ខ្លួនហើយពោលថា ជនទាំងអស់នេះជាសាក្សីរបស់យើង ឯពួកមារជាបរិវារ ក៏នាំគ្នាទទួលអាងធ្វើជាសាក្សីកុហកដោយសំឡេងឮសូរស័ព្ទកងរំពង ។

ព្រះមហាបុរសត្រាស់សួរថា តើបល្ល័ង្កនេះមានមកពីមុនឬ? ស្តេចមារទូលថា ពីមុនមិនមានទេ ។ ព្រះមហាបុរសទើបត្រាស់ថា បើពីមុនមិនមាន ម្តេចបានជាលោកអះអាងថា បល្ល័ង្កនេះជារបស់លោកទៅវិញ តើលោកបានបំពេញកុសលអ្វី ទើបបល្ល័ង្កនេះកើតឡើងដល់លោក? ស្តេចមារពោលថា យើងបានបំពេញទានមកច្រើនណាស់ ទើបបល្ល័ង្កនេះកើតដល់យើង ។ ព្រះមហាបុរស ទើបសួរកេសាក្សី ។ ស្តេចមារអាងយកបរិស័ទរបស់ខ្លួនធ្វើជាសាក្សី ។ ព្រះមហាបុរសទើបត្រាស់ថា ត្រង់ដែលលោកអាងថា បានបំពេញទានមកនោះ ចូរលើកទុកសិនចុះ សូមសួរថា លោកបានតាំងសច្ចាអធិដ្ឋានដើម្បីឲ្យបល្ល័ង្កនេះ កើតឡើងពីកាលណា? ព្រះមហាបុរសបញ្ជាក់

បន្ថែមទៀតថា បល្ល័ង្កនេះកើតឡើងដោយបុណ្យរបស់យើង មិនមែនកើតឡើងព្រោះបុណ្យរបស់អ្នកឯងទេ ព្រោះហេតុនោះ ទើបយើងមិនក្រោកចេញពីបល្ល័ង្កនេះ ។

ស្ដេចមារពោលថា លោកមិនដឹងកំលាំងរបស់យើង យើងមានកងពលយោធាជាច្រើន មានអាវុធគ្រប់ដៃ ។ រីឯខ្លួនលោកមានតែម្នាក់ឯងគត់ គ្មានយោធា គ្មានអាវុធ នៅហ៊ានមកចង់សាកល្បងកំលាំងជាមួយយើងឬ? ។

ព្រះមហាបុរសត្រាស់តបថា ម្នាលស្ដេចមារ លោកឯងក៏មិនដឹងកំលាំងរបស់យើង យើងបានចិញ្ចឹមយោធាកងពលទុកជាច្រើនព្រមទាំងមានអាវុធគ្រប់ដៃ ព្រោះដូច្នោះទើបយើងមិនខ្លាចលោកឯង ។

ស្ដេចមារបានស្ដាប់ដូច្នោះ ក៏គិតថា អញបានស្ដាប់មកថា ចៅសិទ្ធត្ថនេះ ជាកំពូលលើទេវតា និងមនុស្សទាំងឡាយ ព្រោះពោលតែពាក្យសច្ចៈ តែឥឡូវនេះចៅសិទ្ធត្ថពោលពាក្យមិនពិតទៅវិញ ទើបពោលថា ចៅសិទ្ធត្ថ អ្នកឯងមានតែខ្លួនមួយម្នាក់ឯងគត់ ម្ដេចទើបពោលថា លោកមានកងពលយោធាជាច្រើន មានអាវុធគ្រប់ដៃហេតុអ្វីទើបយើងមើលមិនឃើញយោធារបស់លោក ? ។

ព្រះមហាបុរសត្រាស់តបថា ម្នាលមារ យើងមិនបានពោលពាក្យមុសាទេ មហាយោធារបស់យើងមានពិត គឺបារមី ៣០ គត់ទ្ទុំ៖ ឯង ជាយោធារបស់យើង បញ្ញាដ៏មុតស្រួច ជាអាវុធរបស់យើង គឺយើងបានសន្សំមកជាយូរយារហើយ អាចយកទៅប្រើការបានទាន់ចិត្តភ្លាមៗ ព្រោះតែហេតុ តែយើងបានសន្សំបារមីមកអស់កាលដ៏យូររាប់ប្រមាណពុំបាន ទើបបល្ល័ង្កនេះ កើតឡើងដល់យើង ចំណែកលោកពោលពាក្យមុសាថា **ជា របស់លោក** ។

ស្តេចមារ បានស្តាប់ព្រះមហាបុរសថា ខ្លួនមុសាដូច្នោះ ក៏កើតខ្ញាល់ក្រោធខឹងយ៉ាងខ្លាំង បានគ្រវីចក្រាវុធដោយបំណងនិងធ្វើឲ្យអន្តរាយព្រះជន្មព្រះមហាបុរស ហើយចោលសំដៅទៅព្រះមហា-បុរស ឯចក្រាវុធនោះ ក៏ក្លាយជាពិតានបាំងការពារព្រះមហាបុរសពីខាងលើ ចំណែកសេនាមារ ក៏ចោលអាវុធតូចធំទៅទៀត អាវុធទាំងអស់នេះ ក៏ក្លាយជាបុប្ផាធ្លាក់នៅលើប្រឹថពី ដោយតេជានុភាពនៃព្រះមហាបុរស ។

ពពួកទេវតាទាំងឡាយ ដែលភិតភ័យនាំគ្នារត់គេចទៅនៅឯកណ្តាប់ចក្រវាឡ ក្នុងពេលស្តេចមារលើកទ័ពមកច្បាំងនឹងព្រះមហា

បុរស ម្នាក់ៗនាំគ្នាពោលថា គួរណាស់តែព្រះមហាបុរសមានជ័យជំនះប្រាកដ ព្រោះព្រះអង្គមិនតក់ស្លុត មិនខ្លាចស្តេចមារឡើយ ពោលដូច្នោះហើយក៏នាំគ្នា ពោលថ្វាយព្រះពរជ័យដល់ព្រះមហាបុរស ឲ្យឈ្នះមារដោយចិត្តសោមនស្ស ។

ព្រះមហាបុរសត្រាស់ នឹងស្តេចមារថា លោកពោលថា ខ្លួនលោកបានបំពេញកុសលមក ទើបរតនបល្ល័ង្កនេះ តើអ្នកណាជាសាក្សីរបស់លោក ស្តេចមារអាងយកបរិស័ទរបស់ខ្លួន ហើយពួកមារម្នាក់ៗអាងធ្វើជាសាក្សីឲ្យនាយចៅហ្វាយរបស់ខ្លួន ។ ស្តេចមារសួរប្រាសមកមហាបុរសវិញថា សាក្សីដែលបានដឹង បានឃើញនូវការធ្វើកុសលរបស់យើងមិនមាន គឺមានតប្រឹថពីដែលគ្មានវិញ្ញាណនេះជាសាក្សីរបស់យើង ព្រោះថា ពេលយើងបំពេញបារមីមកមានការបរិច្ចាគមហាទានជាដើម ផែនប្រឹថពីនេះក៏កក្រើកញាប់ញ័រមកជាច្រើនដង គ្រាន់តែក្នុងជាតិព្រះវេស្សន្តរប៉ុណ្ណោះ ផែនដីញ័រ ៧ដង កាលព្រះមហាបុរសត្រាស់ដូច្នេះ រីផែនប្រឹថពី ក៏ញាប់ញ័រឡើងដូចជាទទួលធានារ៉ាប់រងព្រះតម្រាស់របស់ព្រះមហាបុរស ។

ក្នុងច្បាប់ជាច្រើនពោលថា ព្រះនាងគង្ហីងធរណី មិនអាចទ្រាំនៅបាន កាលត្រូវព្រះមហាបុរសពោលអាងធ្វើជាសាក្សី ទើបបណ្តាល

ជារូបនារីម្នាក់ផុសឡើងអំពីផែនដី ឈរនៅចំពោះព្រះភក្ត្រព្រះមហាបុរស ហើយស្រែកប្រកាសថា បពិត្រព្រះមហាបុរស ខ្ញុំព្រះអង្គបានជ្រាបនូវបុណ្យដែលព្រះអង្គបានសន្សំតាំងអំពីដើមមក ព្រោះថា **ទឹកក្សិណោទក** (ទឹកស្នោទក់) ដែលព្រះអង្គស្រោចលើប្រឹថពីនោះបានដក់នៅក្នុងផ្នូងសក់របស់ខ្ញុំព្រះអង្គជាច្រើន នឹងប្រមាណពុំបានខ្ញុំព្រះអង្គនឹងប្រាប់ស្បូតទឹកក្នុងផ្នូងសក់ ឲ្យហូរចេញមកឲ្យឃើញច្បាស់នឹងភ្នែកក្នុងពេលឥឡូវនេះ ថាហើយ ក៏ប្រាប់ទឹកក្នុងផ្នូងសក់ឲ្យហូរចេញមកទឹកនុ៎ះច្រើនណាស់ ហូរដោរជន់លិចសេនាមារទាំងឡាយឲ្យអណ្តែតរសាត់ទៅ សូម្បីតែដំរីគ្រីមេខលះ ក៏មិនអាចឈរទប់ខ្លួននៅបាន ក៏អណ្តែតរសាត់ទៅ ទាល់តែដល់មហាសមុទ្រឯទង់និងឆ័ត្រជ័យចាមរទាំងឡាយក៏បាក់ខ្ទេចខ្ទីអស់ ។

ស្តេចមារបានឃើញអានុភាពអស្ចារ្យដូច្នោះ ក៏ញាប់ញ័រក្នុងចិត្ត គ្រានុ៎ះផែនប្រឹថពីដ៏ធំ ក៏រញ្ជួយកក្រើកឃ្លេងឃ្លោងចង់ក្រឡាប់ផ្កាប់ផ្ងារ រីមហាមេឃក៏លាន់ឬគគ្រឹកគគ្រេងចង់បាក់ទាំងភ្នំ រលំទាំងថ្មសិលា រីឯពួកទេវតាទាំងឡាយក៏នាំគ្នាប្រគុំតន្ត្រី សូរស័ព្ទទ្រហឹងទូទាំងចក្រវាឡ កើតកោលាហល ។

ពេលនោះ ផ្គរលាន់ ផ្ទេកបន្ទោរពុំជួរកាល ដាលប្រវាត់រន្ទះ អសនីបាតលាន់ឬទ្រហឹងក្ងីព្រោងព្រាត ពួកមារទាំងឡាយតក់ស្លុត ខ្លាចព្រះពុទ្ធានុភាព បាននាំគ្នារត់ខ្វាត់ខ្វាយ រីឯស្តេចមារ ក៏កោត ក្រែងព្រះបារមីមហាបុរស បានរត់គេចទៅលាក់ពួនសម្ងំ ដោយ សេចក្តីខ្វូចចិត្ត បានហាមាត់ពោល ពាក្យសរសើតេជានុភាពព្រះ មហាបុរស លើកហត្ថាប្រណម្យអញ្ជលីនមស្សការថា បុគ្គលឯណា ក្នុងលោក និងទេវលោក ពុំស្មើនិងព្រះអង្គឡើយ ព្រះអង្គត្រាស់ ដឹងនូវសម្មាសម្ពោធិញ្ញាណ មានតេជៈគ្របសង្កត់នូវពួកមារ ព្រះ អង្គជាសំពៅដឹកជញ្ជូនសត្វឲ្យឆ្លងផុតចាកឱឃកន្តារ លុះដល់ត្រើយ មហានិព្វានដ៏ក្សេមក្សាន្តជាប្រាកដ ។

ដោយអំណាចការពោលសរសើរ ព្រះគុណរបស់ព្រះមហាបុរស ក្នុងគ្រានោះលោកពោលថា ស្តេចមារនឹងបានសម្រេចព្រះសម្មា-សម្ពោធិញ្ញាណមួយព្រះអង្គក្នុងកាលអនាគត ។

កាលស្តេចមារ រត់គេចទៅកាន់ទេវស្ថានជាទីលំនៅរបស់ខ្លួន ហើយ ក្នុងខណៈនោះព្រះអាទិត្រនៅមិនទាន់អស់ស្តង្កតនៅឡើយទេ ព្រះមហាបុរស ក៏មានព្រះទ័យសោមនស្សអង់អាច ទ្រង់ស្ថិតនៅ

លើរតនបល្ល័ង្កនោះ ដោយព្រះហឫទ័យយ៉ាងខ្ជាប់ខ្ជួន មិនរាយមាយ ទាល់តែចិត្តជាសមាធិតាំងមាំ មិនញាប់ញ័រ ឯពួកទេវតាទាំងឡាយ បានឃើញស្តេចមារបរាជ័យរត់បែកខ្ចាត់ខ្ចាយទៅអស់ ក៏ថ្វាយពរជ័យ ស័ព្ទសាធុការ ពោលសរសើរព្រះគុណសូរស័ព្ទទ្រហឹងអឺងកង រំពងថា ព្រះសិទ្ធត្ថជាមនុស្សអង់អាចក្លាហាន យកជ័យជំនះលើពួកមារទាល់តែបាន អានុភាពឃើញជាក់ស្តែងនេះ គួរតែមនុស្សលោកបង្អោនសិរសាបូជាព្រះអង្គដែលព្រះអង្គទៀតតែងនិងបានជាព្រះបរមសាស្តាចារ្យរបស់មនុស្ស និងទេវតាទាំងឡាយ លុះព្រះអាទិត្យកំបាំងនឹងដើងមេឃហើយព្រះចន្ទ្រក៏រះភ្លឺស្វាងត្រចះត្រចង់ជុំនួស ក្នុងខណៈដែលព្រះមហាបុរសកំពុងធ្វើសេចក្តីព្យាយាមដោយមិនរួញរា ។

រីព្រះពុទ្ធជាម្ចាស់របស់យើង ទ្រង់មានជ័យជំនះលើស្តេចមារ និងសេនាមារ តាំងតែពីមិនទាន់បានត្រាស់ជាព្រះពុទ្ធ ការឈ្នះមារគ្រានេះរាប់ថា ជាការឈ្នះយ៉ាងធំធេងជាដំបូង ក្នុងជ័យមង្គលគាថាគឺបទពាហុំនេះ លុះកាលព្រះអង្គត្រាស់ដឹងហើយ ទើបទ្រង់ឈ្នះមារធីតាទាំង៣នាក់ផងដូចពោលជាលំដាប់តទៅៈ

កាលព្រះមហាបុរសឈ្នះមារហើយ ទ្រង់បំពេញព្យាយាមដោយមិនរួញរាក្នុងវេលាបឋមយាម ក៏បានទ្រង់លុះ**បុព្វេនិវាសានុ-**

***បុព្វេនិវាសានុស្សតិញាណ*** រលឹកជាតិក្នុងកាលកន្លងទៅហើយបានថា តើក្នុងជាតិនោះៗ ព្រះអង្គបានទៅកើតក្នុងទីណា? កើតជាអ្វី? មានឈ្មោះ

និងគោត្រដូចម្ដេច? ជាដើមក្នុងវេលាមជ្ឈិមយាម ទ្រង់បានលុះ ***ចុតូបបាតញាណ***ដឹងកាចុតិ និងឧប្បត្តិរបស់សត្វទាំងឡាយថាសត្វនោះៗ ធ្វើកម្មអ្វី ស្លាប់ហើយទើបទៅកើតក្នុងទីនោះៗ ។ ក្នុងវេលាបច្ឆិមយាម ទ្រង់តបានលុះ***អាសវក្ខយញ្ញាណ*** ញុំាងអាសវៈឲ្យអស់បានលុះជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រមនិងអរុណរៀងរះក្នុងថ្ងៃថ្មីថ្ងៃដែលព្រះអង្គត្រាស់ដឹងជាថ្ងៃពេញបូណ៌មី ខែវិសាខ កាលត្រាស់ដឹងហើយ ទ្រង់ប្រថាប់សោយវិមុត្តិសុខនៅបរិវេណនោះ អស់ពេល ៧ សប្ដាហ៍ គឺសប្ដាហ៍ទី ១ គង់នៅលើពោធិបល្ល័ង្គ, សប្ដាហ៍ទី ២ គង់នៅអនិមិស្សចេតិយ, សប្ដាហ៍ទី ៣ គង់នៅរតនចង្ក្រមចេតិយ, សប្ដាហ៍ទី ៤ គង់នៅរតនឃរចេតិយ, សប្ដាហ៍ទី ៥ គង់នៅដើមអជបាលនិគ្រោធ, សប្ដាហ៍ទី ៦ គង់នៅ ក្រោមដើមមុច្ចលិន្ទ, សប្ដាហ៍ទី ៧ គង់នៅក្រោមដើមរាជាយតនៈ ។ ក្នុងពេលនោះ មារបានតាមបៀតបៀនរំខានព្រះពុទ្ធអង្គជាច្រើនដង ដូចមានរឿងដំណាលនៅក្នុងមារសំយុត្ត ក្នុងសំយុត្តនិកាយ សគាថវគ្គជាដើមថា សម័យ

មួយព្រះដ៏មានព្រះភាគបានត្រាស់ដឹងថ្មីៗ បានគង់ប្រថាប់នៅក្រោមអជបាលនិគ្រោធ ជិតឆ្នេរស្ទឹងនេរញ្ជរា ក្នុងតំបន់ឧរុវេលាសេនានិគម ទ្រង់ព្រះតម្រិះថា ព្រះអង្គជាអ្នកផុតចាកទុក្ករកិរិយា ដែលមិនប្រកបដោយប្រយោជន៍ ជាសត្វដែលបានលុះព្រះពោធិញាណហើយ ចំណែកមារអ្នកមានបាប បានជ្រាបសេចក្តីត្រិះរិះរបស់ព្រះដ៏មានព្រះភាគជាម្ចាស់តាមផ្លូវចិត្ត ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ ពោលគាថា ថា:

***បុគ្គល រមែងបរិសុទ្ធដោយការបំពេញតបៈ តែលោកបានជៀសចេញអំពីតបៈនុ៎ះហើយ ជាអ្នកមិនបរិសុទ្ធ ហើយមកសំគាល់ខ្លួនថា ជាអ្នកបរិសុទ្ធ លោកបានភ្លាំងភ្លាត់អំពីផ្លូវនៃសេចក្តីបរិសុទ្ធហើយ ។***

ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា នុ៎ះគឺមារ ទើបត្រាស់ថា តថាគតដឹងហើយថា តបៈយ៉ាងណាៗ មិនប្រកបដោយប្រយោជន៍ តបៈទាំងអស់មិន អំណោយប្រយោជន៍ឲ្យទេ ដូចដោលទូកលើគោក (មិនអាចធ្វើទូកឲ្យកំរើកបាន) ដូច្នោះតថាគត ទើបចំរើនមគ្គ គឺ សីល សមាធិ បញ្ញា ដើម្បីសេចក្តីត្រាស់ដឹង ជាអ្នកបានលុះសេចក្តីបរិសុទ្ធិ

យ៉ាងកំពូល ម្នាលមារអ្នកធ្វើនូវទីបំផុត ខ្លួនលោកគឺតថាគត កំចាត់ចេញហើយ ។

មារបានស្ដាប់ព្រះពុទ្ធដីកាដូច្នោះ ក៏កើតទុក្ខ ខូចចិត្តថា ព្រះដ៏មានព្រះភាគជាម្ចាស់ ស្គាល់អញ ទើបអន្តរធានបាត់ទៅអំពីទីនោះ នេះគ្រាន់តែជាគ្រាមួយ ក្នុងបណ្ដាគ្រាជាច្រើន ដែលមារតាមផ្ចាញ់ព្រះដ៏មានព្រះភាគ កាលព្រះអង្គត្រាស់ដឹងថ្មីៗ ។

សម័យមួយ នៅអជលបាលនិគ្រោធ មារអ្នកតាមដានព្រះដ៏មានព្រះភាគដល់ ៧ ឆ្នាំ បានចូលគាល់ព្រះដ៏មានព្រះភាគ ក្រាបទូលថា (សត្តវស្សសូត្រ សំយុត្តនិកាយ សគាថវគ្គ) លោកត្រូវសេចក្ដីសោកគ្របសង្កត់ឬ ទើបបានមកស្រងូតស្រងាត់នៅក្នុងព្រៃនេះ លោកវិនាសចាកទ្រព្យជាគ្រឿងរីករាយចិត្ត ឬកំពុងតែប្រាថ្នាលោកបានធ្វើសេចក្ដីអាក្រក់ផ្សេងៗទុក្ខក្នុងផ្ទះឬ ហេតុម្ដេចទើបលោកមិនធ្វើជាមិត្តជាមួយជនទាំងឡាយ បែរជាមកនៅម្នាក់ឯងឬក៏លោកធ្វើជាមិត្តជាមួយអ្នកណាៗ មិនបានសម្រេច ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមារ អ្នកមានផៅពង្សជាបុគ្គលអ្នកប្រមាទហើយ តថាគតដីកឫសគល់របស់សេចក្ដីសោក

ទាំងអស់ហើយមិនមានសេចក្តីអាក្រក់ មិនសោកសៅ តថាគតឈ្នះសេចក្តីជាប់ណែន ពោលគឺសេចក្តីលោភក្នុងភពទាំងអស់ ជាអ្នកមិនមានអាសវៈ ។

មារទូលថា បើចិត្តរបស់អ្នកជំពាក់នៅក្នុងរបស់ដែលជនទាំងឡាយពោលថា របស់នេះជារបស់អញ ឯរបស់នេះជាអញ សមណៈអ្នកមិនផុតពីយើងទៅបានឡើយ ។

ព្រះដ៏មានព្រះភាគត្រាស់ថា របស់ដែលជនទាំងឡាយពោលថា ជារបស់អញនោះ រមែងមិនមែនជារបស់អញ និងរបស់ដែលជនទាំងឡាយពោលថាជាអញនោះក៏មិនមែនជាអញដូចគ្នា, ម្នាលមារ! អ្នកចូរជ្រាបយ៉ាងនេះ សូម្បីតែលោកឯង ក៏មិនឃើញផ្លូវរបស់តថាគត ។

កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះ មារបានទូលថា បើលោកដឹងផ្លូវដែលផុតភ័យ ដែលជាទីទៅកាន់អមតមហានិព្វាន ក៏ចូរចៀសចេញទៅតែម្នាក់ឯងចុះ ចាំនៅប្រដៅអ្នកឯទៀតធ្វើអ្វី !។

*ព្រះដ៏មានព្រះភាគត្រាស់ថា ជនទាំងឡាយឯណា ប្រាថ្នាទៅកាន់ត្រើយ រមែងដល់ព្រះនិព្វាន ដែលមិនមែនជាឱកាសរបស់មារ, តថាគតកាលត្រូវជនទាំងឡាយសួរហើយ តថាគតនឹងប្រាប់ថា របស់ណាជារបស់ពិត របស់នុ៎ះមិនមានឧបធិកិលេសទេ។*

*ស្ដេចមារទូលថា បពិត្រព្រះអង្គដ៏ចំរើន ឧទាហរណ៍ថា មានស្រះបោក្ខរណីមួយ ដែលនៅមិនឆ្ងាយអំពីភូមិស្រុក, ក្នុងស្រះនោះមានក្ដាម ពេលនោះ មានកូនក្មេងប្រុសស្រីជាច្រើនចេញពីភូមិស្រុកទៅកាន់ស្រះបោក្ខរណីនោះ បានចាប់ក្ដាមស្រង់ពីក្នុងទឹកដាក់លើគោក ឯក្ដាមនោះលាដង្កៀបច្រូងឡើងច្រងាង ពួកក្មេងទាំងនោះចាប់រឹតដង្កៀបនោះចោល ដោយប្រើ ឈើ ឬដុំថ្ម ឯក្ដាមនោះមានដង្កៀប និងជើងកាច់បាក់អស់ហើយ មិនអាចឈានជើងចុះទៅកាន់ស្រះបោក្ខរណីបានដូចពីមុនយ៉ាងណាមិញ អារម្មណ៍គ្រប់ប្រភេទដែលជាវិស័យរបស់មារ ធ្វើឱ្យសត្វសេពខុស ធ្វើឲ្យសត្វក្ដៅក្រហាយអារម្មហ៍នោះទាំងអស់ ដែលព្រះដ៏មានព្រះភាគកាច់ផ្ដាច់ញាំញីអស់ហើយ ឥឡូវនេះខ្ញុំព្រះអង្គចាំតែឱកាស ដែលមិនអាចចូលទៅជិតព្រះដ៏មានព្រះភាគបានទៀតឡើយ ។*

រួចហើយមារបានពោលគាថា ដែលជាទីតាំងនៃសេចក្ដីនឿយណាយ ក្នុងសំណាក់ព្រះដ៏មានព្រះភាគថា ហ្វូងក្អែកបានឃើញដុំថ្មដែលមានពណ៌ដូចខ្លាញ់ខាប់ទើបហើរចូលទៅជិត ដោយសំគាល់ថា យើងទាំងឡាយនឹងបាននូវអាហារក្នុងទីនេះជាប្រាកដ សេចក្ដីត្រេកអរគប្បីមានពិតប្រាកដ កាលព្យាយាមមិនបានអាហារដូចបំណងក្នុងទីនោះ ទើបហើរគេចទៅ បពិត្រព្រះគោតម ខ្ញុំព្រះអង្គដូចក្អែកមកជួបដុំសិលាដូច្នោះ ទើបសុំចៀសចេញទៅ លុះពោលរួចហើយក៏ចៀសចេញទៅពីទីនោះ ទៅអង្គុយពែននៅលើផែនដីមិនឆ្ងាយពីព្រះដ៏មានព្រះភាគ សំកុកអៀនខ្មាស ឈ្ងោកមុខស្រងូតស្រងាត់ទ័លប្រាជ្ញ កំពុងយកឈើគូសផែនដី ព្រោះហេតុតែមារមានសេចក្ដីសោកសៅ មិនអាចធ្វើអ្វីនឹងព្រះដ៏មានព្រះភាគបាននេះឯង ជាហេតុឲ្យធីតាមារគិតជួយមារជាបិតា ពីព្រោះការជួយបិតានោះឯង ធីតាមារទើបចាញ់ព្រះដ៏មានព្រះភាគ ដូចមានដំណាលនៅក្នុងមារធីតុសូត្រ សំយុត្តនិកាយ សគាថវគ្គថា គ្រានោះ ធីតាមារទាំង ៣ នាក់ គឺនាងតណ្ហា នាងអរតី និងនាងរាគា នាំគ្នាទៅរកស្ដេចមារដល់ទីលំនៅ ហើយសួរថា បពិត្រលោកឪពុក តើលោកឪពុកខូចចិត្តពីរឿងអ្វីទៅ? ឬសៅសោកអំពីបុរសណា ខ្ញុំព្រះអង្គនិងចាប់បុរស

នោះចងដោយខ្សែអន្ទាក់គឺរាគៈយកមកថ្វាយព្រះអង្គ ដូចបុគ្គលចង ដំរីដែលបានមកអំពីព្រៃដូច្នោះ បុរសនោះនឹងធ្លាក់នៅក្នុងកណ្ដាប់ដៃ របស់ព្រះបិតា ស្ដេចមារពោលថា "បុរសនោះ ជាព្រះអរហន្តជាអ្នក មានដំណើរល្អក្នុងលោក មិនអាចអ្នកណានាំមកដោយរាគៈងាយៗ បានទេ ឈានកន្លងអន្ទាក់មារទៅហើយ ព្រោះដូច្នោះ ទើបបិតាសោក សៅ" ។

គ្រានោះមារធីតាទាំង ៣ បានទៅគាល់ព្រះដ៏មានព្រះភាគដល់ ទីប្រថាប់ ហើយបានក្រាបទូលថា "បពិត្រព្រះសមណៈ ពួកនាងខ្ញុំ សូមមកបំរើព្រះអង្គ" ព្រះដ៏មានព្រះភាគមិនបានយកព្រះទ័យទុក ដាក់នឹងពាក្យរបស់ធីតាមារទាំងនោះទេ ព្រោះព្រះអង្គកំពុងបង្អោន ទៅក្នុងសេចក្ដីអស់ឧបធិកិលេសយ៉ាងកំពូល, លំដាប់នោះ ធីតាមារ បានចេញទៅប្រឹក្សាគ្នាថា សេចក្ដីប្រាថ្នារបស់បុរសមិនដូចគ្នា បើ ដូច្នោះ អញគួរនិម្មិត្ត ភេទជាកុមារិកាម្នាក់១០០ៗ ហើយក៏បានធ្វើ តាមគំនិតនុ៎ះ គឺនិម្មិតភេទជាកុមារិកាម្នាក់១០០ៗ ចូលទៅគាល់ព្រះ ដ៏មានព្រះភាគ ក្រាបទូលសូមបំរើព្រះអង្គ តែព្រះដ៏មានព្រះភាគពុំ បានយកព្រះទ័យទុកដាក់ ព្រោះទ្រង់បង្អោនព្រះទ័យទៅក្នុងសេចក្ដី អស់ឧបធិកិលេសយ៉ាងកំពូល ។ ធីតាមារទាំង ៣ កាលមិនឃើញ

ព្រះដ៏មានព្រះភាគយកព្រះទ័យទុកដាក់ នឹងនាងកុមារិកាដែលខ្លួននិម្មិត

នុ៎ះ ទើបគេចចេញទៅប្រឹក្សាថា យើងគួរប្លែងភេទជាស្ត្រីដែលមិនទាន់សម្រាលបុត្រ១០០ៗ ចូលទៅគាល់ព្រះដ៏មានព្រះភាគ តែកាលធ្វើតាមគំនិតព្រះដ៏មានព្រះភាគ ក៏មិនបានចាប់អារម្មណ៍ ព្រោះទ្រង់បង្អោនព្រះទ័យទៅក្នុងសេចក្ដីអស់ឧបធិកិលេសយ៉ាងកំពូល ។

ចំណែកនាងធីតាទាំង ៣ ក៏ប្រឹក្សាគ្នានឹងប្លែងភេទជាស្ត្រីសម្រាលបុត្រ ២ ដង ម្នាក់១០០ៗ ចូលទៅគាល់ព្រះដ៏មានព្រះភាគ កាលបានឃើញព្រះដ៏មានព្រះភាគមិនសព្វព្រះទ័យដូចមុន តមកក៏និម្មិតភេទស្ត្រី កណ្ដាលមនុស្សម្នាក់១០០ៗ និម្មិតជាស្ត្រីវ័យចាស់ម្នាក់១០០ៗ តាមលំដាប់ ព្រះដ៏មានព្រះភាគមិនសព្វព្រះទ័យ ព្រោះទ្រង់បង្អោនព្រះទ័យទៅក្នុងការអស់ឧបធិកិលេសយ៉ាង កំពូល ។

លំដាប់នោះធីតាមារទាំង ៣ ទើបនិយាយគ្នាថា រឿងនេះពិតដូច ព្រះបិតាយើងនិយាយថា បុរសនោះជាព្រះអរហន្ត អ្នកមានដំណើរទៅល្អហើយក្នុងលោក មិនមានអ្នកណាអូសទាញមកដោយរាគៈបានឡើយ បុរសនោះឈានកន្លងអន្ទាក់មារទៅផុតហើយ ទើប

យើងសោយសោក បើពួកយើងប្រលោមសមណៈ ឬព្រាហ្មណ៍

ពួកណា ដែលនៅមិនទាន់អស់រាគៈ ដោយសេចក្ដីព្យាយាមយ៉ាងនេះ ហឫទ័យរបស់សមណៈ ឬព្រាហ្មណ៍ពួកនោះ ត្រូវបែក ឬខ្ចុរចេញលោហិតតាមមាត់ ឬក្រឡុកចិត្តកើតឆ្កួត ឬកើតចិត្តរាយមាយ ដូចដើមអំពៅស្រស់ ត្រូវខ្យល់បក់បោកបាក់ទៅ រមែងហួតហែងយ៉ាងណាមិញ សមណៈព្រាហ្មណ៍នោះ រមែងហួតហែងទៅដូចគ្នាហើយ នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ឈរនៅក្នុងទីមួយដ៏សមគួរ ។

នាងតណ្ហាធីតាមារ បានពោលគាថាថា ទូលព្រះដ៏មានព្រះភាគជាម្ចាស់ថា ព្រះអង្គត្រូវសេចក្ដីសោកគ្របសង្កត់ឬ ទើបបានមកអង្គុយស្រង្វូតស្រងាត់នៅក្នុងព្រៃនោះ លោកវិនាសចាកទ្រព្យជាគ្រឿងរីករាយចិត្តអស់ឬ ឬដែលកំពុងប្រាថ្នា លោកបានធ្វើសេចក្ដីអាក្រក់ផ្សេងៗទុកក្នុងផ្ទះឬ ព្រោះហេតុអ្វី ទើបលោកមិនធ្វើជាមិត្តជាមួយជនទាំងពួង ឬថាលោកធ្វើជាមិត្តជាមួយអ្នកណា មិនបានសម្រេច? ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា តថាគតឈ្នះសេនាមារ គឺ**បិយរូប** គឺ**មនាបរូប** គឺរូបជាទីស្រលាញ់ និងរូប ជាទី

ពេញចិត្តហើយកំពុងសំលឹងកសិណា បានដឹង បានលុះនូវប្រយោជន៍

និងសេចក្តីស្ងប់ហឫទ័យជាសុខ ព្រោះដូច្នោះ ទើបតថាគតមិនធ្វើជាមិត្តជាមួយជនទាំងពួង និងជាមិត្តមួយអ្នកណា ព្រោះមិនអំណោយជាប្រយោជន៍ដល់តថាគត ។

លំដាប់នោះ នាងអរតីធីតាមារ បានទូលសួរព្រះដ៏មានព្រះភាគថា ភិក្ខុក្នុងសាសនានេះ មានប្រក្រតីរស់នៅដោយធម៌ជាគ្រឿងរស់នៅយ៉ាងណា ទើបឆ្លងឱឃៈទាំង ៥ បាន ពេលនេះបានឆ្លងឱឃៈទី៦ រួចហើយកាមសញ្ញាទាំងឡាយ រមែងហែហាមចោមរោម មិនបាននូវបុគ្គលអ្នកមានឈានយ៉ាងណាដោយច្រើន? ក្នុងពាក្យពោលរបស់មារធីតានេះ មានពាក្យដែលគួរពិចារណាមួយមាត់ គឺពាក្យថា ឆ្លងឱឃៈទាំង ៥ និងឱឃៈទាំង ៦ បានហើយ។ ពាក្យថា ឱឃៈទាំង ៥ លោកកែថា បានដល់កិលេសឱឃៈ ដែលកើតតាម ទ្វារទាំង ៥ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត និងកាយ ។ ចំណែកឱឃៈទី ៦ បានដល់ឱឃៈដែលកើតតាមមនោទ្វារ គឺផ្លូវចិត្ត ។ម្យ៉ាងទៀតគប្បីជ្រាបថា ឱរម្ភាគិយសំយោជនៈ៥ លោកហៅថា ឱឃៈទាំង៥ ចំណែកឧទ្ធម្ភាគិយសំយោជនៈ៥ លោកហៅថា ឱឃៈទី ៦ ។

ក្នុងពាក្យសួរនោះ ព្រះដ៏មានព្រះភាគត្រាស់តបថា បុគ្គលមានកាយស្ងប់ហើយ មានចិត្តសណ្តកហើយ ជាអ្នកមិនមានអ្វីៗ ជាគ្រឿងតាក់តែង មានសតិ មិនមានសេចក្តីអាល័យ បានដឹងនូវធម៌ មានប្រក្រតី សំលឹងនូវឈានទាំង ៤ ដែលគ្មានវិតក្កៈ រមែងមិនកំរើក មិនជ្រួតជ្រាប ជាអ្នកមិនរួញរា, ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រក្រតីរស់នៅដោយធម៌ដោយច្រើន ទើបឆ្លងឱឃៈទាំង៥បាន ឥឡូវនេះឆ្លងឱឃៈទី៦ហើយ កាមសញ្ញាទាំងឡាយ រមែងចោមរោមហែហមពុំបាននូវភិក្ខុអ្នកសំលឹងឈានយ៉ាងច្រើន ក្នុងព្រះពុទ្ធតម្រាស់នេះ មានមានន័យថា បុគ្គលអ្នកស្ងប់កាយ មានចិត្តសណ្តកហើយនោះ គឺបុគ្គលជាព្រះអរហន្តមិនមានសង្ខារ៣ គឺ **បុញ្ញាភិសង្ខារ** អភិសង្ខារគឺបុណ្យ បានដល់ចេតនាក្នុងមហាកុសល ៨ រូបាវចរកុសល ៥, **អបុញ្ញាភិសង្ខារ** អភិសង្ខារគឺបាប បានដល់ចេតនាក្នុងអកុសលចិត្ត ១២ និង**អនេញ្ជាភិសង្ខារ** អភិសង្ខារគឺអនេញ្ជា បានដល់ចេតនាក្នុងអរូបាវចរឈានកុសល ៤ ជាគ្រឿងតាក់តែង មិនមានសេចក្តីអាល័យគឺមិនមានតណ្ហា បានចាក់ធ្លុះនូវធម៌ គឺអរិសច្ច ៤ ហើយ មានប្រក្រតីរស់នៅដោយចតុត្ថជ្ឈាន គឺឈានទី៤ ដែលមិនមានវិតក្កៈ ព្រោះវិតក្កៈលះបានហើយតាំងពីទុតិយជ្ឈាន ឈានទី២ ជា

*អ្នកមិនកំរើក ដោយអកុសលគឺរាគៈ ទោសៈ មោហៈ ព្រះដ៏មានព្រះភាគទ្រង់សំដែងថាព្រះអរហន្ត អ្នកប្រហារនីវរណៈទាំងឡាយបានអស់ហើយ ភិក្ខុជាព្រះអរហន្ត អ្នករស់នៅក្នុងឈានទី៤ នេះ កាមសញ្ញាទាំងឡាយ រមែងហែហមចោមរោមមិនបាន កាលព្រះដ៏មានព្រះភាគត្រាស់ដូច្នេះហើយ នាងរាគាធីតាមារទី ៣ បានក្រាបទូលព្រះដ៏មានព្រះភាគថា ព្រះសាស្តាជាប្រធាន ថែរក្សាគណៈសង្ឃបានកាត់ផ្តាច់តណ្ហាដាច់ហើយ ឯជនអ្នកមានសទ្ធាជាច្រើនប្រព្រឹត្តតាមបានពិតប្រាកដ ព្រះសាស្តាជាអ្នកមិន មានអាល័យ បានកាត់ផ្តាច់អំពីដៃមច្ចុរាជ ហើយនាំជនជាច្រើនទៅកាន់ ត្រើយព្រះនិព្វាន ។*

*ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតមានសេចក្តីក្លៀវក្លាខ្លាំងបាននាំសត្វទៅដោយព្រះសទ្ធម្ម កាលតថាគតនាំសត្វទៅដោយធម៌ដូចម្តេចបានជាសេចក្តីឫស្សាកើតមានដល់លោកអ្នកចេះដឹងទៅវិញ ។*

*កាលព្រះដ៏មានព្រះភាគត្រាស់ដូច្នេះ ធីតាមារទាំង ៣ គឺ នាងតណ្ហា នាងអរតី នាងរាគា បាននាំគ្នាទៅរកស្តេចមារដល់ទីលំនៅ ស្តេចមារបានឃើញធីតាមកអំពីឆ្ងាយ ទើបនិយាយចំអកឲ្យធីតាជាគាថា ថា ពួកមនុស្សល្ងង់ នាំគ្នាទំលាយភ្នំដោយដើមឈូក*

ដីកក្តិ៍ដោយក្រចក ខាំទំពាដែកដោយធ្មេញទាំងឡាយ នាងទាំងឡាយធ្វើឲ្យព្រះសមណគោតមឲ្យនឿយណាយ ទាល់តែចៀសចេញខ្លួនឯងទៅវិញ ដូចបុគ្គលដាក់ដុំថ្មលើក្បាលហើយជ្រែកដីទៅក្នុងបាតាល ឬដូចបុគ្គលយកទ្រូងអុកទង្គិចនឹងទង្គត់ឈើដូច្នោះ ។ នេះជាពាក្យ ចំអកឡកឡឺយរបស់ស្តេចមារ ដែលចំអកឲ្យធីតាថា ជាមនុស្សល្ងង់ខ្លៅនាំគ្នាទៅទំលាយភ្នំ គឺព្រះដ៏មានព្រះភាគអ្នកមិនញាប់ញ័រនឹងដើមឈូក រីឯដើមឈូកនោះ មានតែបែកធ្លាយខ្លួនឯងទៅប៉ុណ្ណោះ រីឯភ្នំនោះនៅតាំងមាំ ដូចនាងមារធីតាទាំង ៣ ដែលចាញ់ព្រះយ៉ាងខ្ទេចខ្ទាំ ព្រោះព្រះដ៏មានព្រះភាគតាំងមាំ មិនញាប់ញ័រដូចភ្នំ ដោយហេតុនេះ ព្រះដ៏មានព្រះភាគទើបបណ្តេញ នាងតណ្ហា នាងអរតី នាងរាគា អ្នកមានរូបស្រស់ល្អគួរឲ្យគយគន់យ៉ាងក្រៃលែង ដែលមកកាន់ទីនោះឲ្យចៀសចេញទៅ ដូចខ្យល់បក់ផាត់ប៉ុយគទៅដូច្នោះ ។

នេះជាជ័យជំនះគ្រាដំបូង របស់ព្រះដ៏មានព្រះភាគក្នុងបទពាហុំ ដែលថា ព្រះដ៏មានព្រះភាគទ្រង់ឈ្នះស្តេចមារនឹងសេនាមារ ក្នុងថ្ងៃដែលព្រះអង្គត្រាស់ដឹងជាព្រះពុទ្ធ គឺកាលទ្រង់ឈ្នះមារហើយ ក៏បាន

*ទ្រង់ឈ្នះកិលេសបានជាព្រះពុទ្ធជាម្ចាស់ក្នុងយប់នេះឯង ចំណែកដែលទ្រង់ឈ្នះធីតាមារនោះ ទ្រង់បានជ័យជំនះក្រោយពីការត្រាស់ដឹង ព្រោះសំដែងអំពីភាពជាធំរបស់ព្រះអង្គថា អាចយកឈ្នះមារបានទាំងដែលព្រះអង្គនៅជាបុថុជ្ជននៅឡើយ លះកិលេសពុំទាន់បាន តែទ្រង់ក៏មិនញាប់ញ័រស្ញប់ស្ញែងនឹងអានុភាពស្តេចមារ និងបរិវាររាប់ថាអស្ចារ្យលើសពីកាលព្រះអង្គបានត្រាស់ជាព្រះពុទ្ធទៅទៀត ។*

**ចប់ពុទ្ធជ័យមង្គលទី ១**

*រូបភាព*

## ជ័យជំនះលើកទី២
## ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើអាឡវកយក្ស

**មារាតិរេកមភិយុជ្ឈិត សព្វរត្តឹ**
**ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ**
**ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ**
**តន្តេជសា ភវតុ តេ ជយមង្គលានិ។**

| | | |
|---|---|---|
| *<u>ប្រែថា:</u>* | *ព្រះមុនិន្ទពិននាយក:* | *ផ្ចាញ់អាឡវយក្ខឃោរឃៅ* |
| | *រឹងរូសមិនតាំងនៅ* | *ក្នុងខន្តីគុណសត្យា។* |
| | *រហូតអស់រាត្រី* | *ព្រះជិនស្រីទ្រង់យុទ្ធនា* |
| | *ក្រៃលែងក្រុងមារ* | *ក្នុងបឋមសម្ពោធិ។* |
| | *ដោយព្រះពិធីញាណ* | *ទ្រង់ទូន្មានដោយខន្តី* |
| | *ញុំាងចិត្តអសុរី* | *អោយបង់ព្យសន៍ចុះវន្ទា* |
| | *រីជយមង្គល* | *ចូរមានដល់អ្នករាល់គ្នា* |
| | *ដោយតេជៈជ័យា* | *ព្រះឈ្មោះអាឡវយក្ខហោង ។* |

ជ័យជំនះលើកទីពីរ គឺព្រះដ៏មានព្រះភាគទ្រង់ឈ្នះ អាឡវកយក្ខអ្នកមានឫទ្ធិច្រើន ក្នុងរឿងអាឡវយក្ខនេះ សូមយករឿងរ៉ាវរបស់អាឡវយក្ខ អំពីអាឡវកសូត្រ ក្នុងខុទ្ទកនិកាយ សុត្តនិបាត និងអដ្ឋកថា មកតំណាល ដូចតទៅ:

ដំណើរសេចក្ដីតាមអដ្ឋកថា ថា រឿងនេះកើតឡើងក្នុងសម័យដែលព្រះដ៏មានព្រះភាគ ស្ដេចយាងទៅប្រថាប់នៅលើវិមានរបស់អាឡវកយក្ខជិតក្រុងអាឡវី ឆ្ងាយពីក្រុងអាឡវី១០០សិន ក្រុងអាឡវីនេះ ជាក្រុងមួយក្នុងដែនអាឡវី ។

ក្នុងពេលនោះ មានរឿងដំណាលថា ព្រះរាជានៅក្រុងអាឡវី បានលះ បង់នូវរាជូបភោគ និងពួកនាងរបាំ ស្ដេចយាងទៅបរបាញ់សត្វក្នុងព្រៃចំនួន៧ ថ្ងៃ ដើម្បីទ្រង់កំចាត់ពួកចោរព្រៃ ១, ដើម្បីបំពេញសេចក្ដីព្យាយាមផ្សេងៗ ១, ថ្ងៃមួយទ្រង់បានតាំងកតិកាជាមួយពួកពលនិកាយថា បើសត្វរត់រួចចំមុខនរណា ត្រូវអ្នកនោះទទួលខុសត្រូវ គឺត្រូវអ្នកនុ៎ះឯងតាមប្រមាញ់យកសត្វនោះឯងយកមកឲ្យបាន ពេលនោះក្រុមព្រះអង្គបានហ៊ុំព័ទ្ធសត្វប្រើសនោះ បានឃើញចន្លោះមុខព្រះរាជាធំ ក៏ស្ទុះរត់ចេញទៅរួច ព្រះរាជាទ្រង់

សម្បូណ៌ដោយសព្វាវុធ និងជាអ្នកឈ្លាសវៃ ទ្រង់កាន់ធ្នូដេញតាមប្រើសនោះ អស់រយៈផ្លូវចម្ងាយ៣ យោជន៍ ឯប្រើសនោះរត់ចម្ងាយបាន ៣ យោជន៍ក៏អស់កម្លាំង ទើបឈប់ចុះផឹកទឹក ព្រះរាជាតាមទៅទាន់បានកាប់ប្រហារប្រើសនោះ ដាច់ជាពីរកំណាត់ ទោះបីថាព្រះអង្គមិនត្រូវការសាច់ក៏ពិតមែន តែព្រះអង្គទ្រង់រែកសាច់ប្រើសនុំះមក ដើម្បីកុំឲ្យគេថា ព្រះអង្គទ្រង់ចាប់ប្រើសមិនបាន ពេលនុំះព្រះរាជាបានទតឃើញដើមជ្រៃធំមួយដើម មានមែកស្លឹកត្រសាយត្រសុំសាខាម្ហប់ត្រជាក់ ទើបស្ដេចយាង់ចូលទៅសំរាកទៀបគល់ជ្រៃនោះ រីឯដើមជ្រៃនោះជាទីលំនៅរបស់អាឡវកយក្ស ដែលបានទទួលពរពីស្ដេចវេស្សវ័ណ្ណថា បើអ្នកណាចូលមកក្នុងបរិវេណម្លប់ជ្រៃនេះស្មើនឹងម្លប់ពេលថ្ងៃត្រង់ អ្នកនោះត្រូវអាឡវកយក្សចាប់ស៊ីបាន ដូច្នោះកាលព្រះរាជាស្ដេចចូលទៅក្នុងបរិវេណដែលស្ដេចវេស្សវ័ណ្ណឲ្យពរនោះ អាឡវកយក្សក៏ចាប់ ស្ដេចបានគិតនឹងស៊ី ។

ព្រះរាជាបានសន្យាជាមួយយក្សថា បើយក្សលែងឲ្យព្រះអង្គឲ្យរួចខ្លួននោះ ព្រះអង្គនឹងបញ្ជូនមនុស្សម្នាក់ និងអាហារមួយថាសមកឲ្យយក្សស៊ីរាល់ៗថ្ងៃ តែយក្សមិនព្រមលែង ហើយពោលថា

ព្រះអង្គជាព្រះរាជា បើព្រះអង្គរវល់តែស្រវឹងក្នុងរាជូបភោគហើយ ភ្លេចពាក្យសន្យា យើងក៏មិនអាចបានស៊ីមនុស្សនោះ ពោលគឺយើងមិនអាចស៊ីមនុស្ស ដែលនៅក្រៅបរិវេណម្លប់ជ្រៃ នាពេលពាក់កណ្ដាលថ្ងៃត្រង់បានឡើយ ព្រោះមិនទទួលពរអំពីស្ដេចវេស្សវ័ណ្ណ ព្រះរាជាត្រាស់ថា បើថ្ងៃណាយើងមិនបានបញ្ជូន មនុស្សមកឲ្យតាមពាក្យសន្យានេះ អ្នកចូលទៅចាប់យើងស៊ីចុះ កាលព្រះរាជាឲ្យសន្យាយ៉ាងនេះ ទើបអាឡវកយក្សដោះលែងព្រះរាជាឲ្យទៅព្រះអង្គក៏ ស្ដេចយាងត្រឡប់ទៅព្រះនគរ ឯពួកពលសេនាដែលរង់ចាំព្រះរាជានៅកណ្ដាលផ្លូវបានឃើញព្រះរាជាស្ដេចយាងមក ក៏ទូលសួរថា ព្រះអង្គទ្រង់នឿយហត់ ព្រោះមានភ័យពីរឿងអ្វីឬ? ព្រះរាជាបានត្រាស់ដំណាលរឿងឲ្យស្ដាប់ រួចស្ដេចយាងចូលរាជធានី ។

លុះថ្ងៃព្រឹកឡើង ទ្រង់សោយព្រះក្រយារួចហើយ ព្រះរាជាទ្រង់ត្រាស់ឲ្យអាមាត្យអ្នករក្សារាជធានីចូលគាល់ ទ្រង់ដំណាលរឿងដែលព្រះអង្គធ្វើកិច្ចសន្យាជាមួយយក្សឲ្យស្ដាប់ អាមាត្យទូលសួរថា ព្រះអង្គធ្វើកិច្ចសន្យា ជាមួយយក្សមានកំណត់ពេលវេលាដែរឬទេ? ព្រះរាជាត្រាស់ថា មិនបានកំណត់ទេ! អាមាត្យទូលថា ព្រះអង្គធ្វើ

ខុសហើយ ពួកអមនុស្សបានតែកំណត់ពេលវេលាឲ្យវាប៉ុណ្ណោះ បើព្រះអង្គមិនកំណត់ពេលឲ្យវាទេ សេចក្តីក្តៅក្រហាយមុខជានឹងកើតមានដល់មាតុភូមិពុំខាន ។ តែណ្ហើយចុះ សូមព្រះអង្គ ទុកព្រះទ័យចុះ ហើយសូមព្រះអង្គសោយសុខក្នុងរាជសម្បត្តិតទៅចុះ ចាំទូលព្រះបង្គំដោះស្រាយតាមការគួរ លុះក្រាបទូលដូច្នេះហើយ ទាំងព្រឹកព្រលឹមក៏ទៅកាន់ពន្ធនាគារ ទើបពោលថា អ្នកណាត្រូវសម្លាប់ខ្លះ, បើអ្នកណាចង់រស់មានជីវិត ចូរចេញមក, អាមាត្យធ្វើយ៉ាងនេះ ដើម្បីត្រូវការអ្នកទោសបញ្ជូនទៅឲ្យយក្ស គេមិនប្រាប់ត្រង់ៗទេ បើប្រាប់ត្រង់ៗគ្មានអ្នកណាទៅទេ ដូច្នោះអ្នកទោសណាឈានជើងចេញមកមុនគេក៏ទទួលយកអ្នកទោសនោះទៅផ្ទះរបស់គេ ឲ្យងូតទឹកបរិភោគអាហារ ហើយប្រើឲ្យកាន់ថាសដាក់អាហារទៅអោយយក្សដែលនៅដើមជ្រៃ កាលអ្នកទោសនោះទៅដល់ដើមជ្រៃ គេក៏ត្រូវយក្សចាប់ស៊ីជាអាហារ ដូចគេស៊ីមើមដំឡូង គឺថារាងកាយរបស់មនុស្សទាំងអស់រហូតដល់សរសៃសក់ ហាក់បីដូចជុំខ្ញាញ់ខាប់ ពីព្រោះតែអានុភាពរបស់យក្សនោះ។

មនុស្សទាំងឡាយ ដែលជូនដំណើរអ្នកទោសទៅនោះ បាន ឃើញជាក់ស្តែងនឹងភ្នែក និយាយប្រាប់មិត្តសំលាញ់របស់ខ្លួន តាំង ពីពេលនោះមក មនុស្សទាំងឡាយ ក៏នាំគ្នាឈប់ធ្វើចោរកម្ម ដោយ ដឹងថា ព្រះរាជាទ្រង់បញ្ជូនចោរទៅឲ្យយក្សស៊ី តមកនៅក្នុងគុកក៏ រ៉ាំងទទេ ព្រោះអ្នកទោសចាស់អស់រលីងមិនមានអ្នកទោសថ្មីចូល ជំនួស ទើបអាមាត្រក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ព្រះរាជាទ្រង់ បញ្ជាឲ្យយកទ្រព្យទៅចោលតាមកៀនកោះចន្លោះភ្នមិត្តូចធំ ក្រែង មានមនុស្សលោភ ចាប់កាន់យកទ្រព្យនោះ យើងក៏ចាប់យកមនុស្ស លោភនោះ ទៅឲ្យយក្សស៊ី តែកាលព្រះរាជាទ្រង់ឲ្យធ្វើដូច្នោះ ក៏ គ្មានអ្នកណាហ៊ានយកដៃឬជើង ទៅប៉ះពាល់ទ្រព្យនោះសោះឡើយ កាលព្រះរាជាទ្រង់រកចោរឲ្យយក្សស៊ីពុំបាន ក៏ប្រឹក្សាជាមួយពួក អាមាត្យ ពួកអាមាត្យក៏ក្រាបទូលថា ឲ្យបញ្ជូនមនុស្សចាស់ តាម លំដាប់ត្រកូលទៅឲ្យយក្សស៊ីមុន តែព្រះរាជាទ្រង់ហាមដោយខ្លាច កើតចលាចល មនុស្សទាំងឡាយនឹងចោទព្រះរាជាថា ព្រះរាជាទ្រង់ បញ្ជូនបិតារបស់គេទៅឲ្យយក្សស៊ី ឬថាព្រះរាជាទ្រង់បញ្ជូនជីតា របស់ទ្រង់ទៅឲ្យយក្សស៊ី អាមាត្យទើបក្រាបទូលថា បើដូច្នោះ សូមឲ្យ

បញ្ជូនក្មេងទារកដែលនៅដេកលើកែបទៅឲ្យយក្សស៊ី ទើបគ្មានអ្នកណារិះគន់ ឯព្រះរាជាក៏យល់ព្រម ។

ដោយហេតុនោះ ពួកអាមាត្យទើបបាននាំយកទារកដែលនៅដេកលើកែបបញ្ជូនទៅឲ្យយក្សស៊ី មាតារបស់ពួកទារកទាំងឡាយទើបនាំគ្នាយកទារកទាំងនោះទៅនៅនគរដទៃ លុះអាយុបាន១២ ឆ្នាំទើបនាំត្រឡប់មកចូលនគរវិញ, ក្នុងថ្ងៃមួយ ពួកអាមាត្យបានស្រាវជ្រាវទូទៅក្នុងនគរ ពុំបានជួបទារកសូម្បីតែម្នាក់ក៏គ្មានឡើយ ទើបក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិ ទេព នៅក្នុងព្រះនគរ គ្មានទារកសូម្បីតែម្នាក់សោះឡើយ មានតែអាឡវកកុមារ ជាព្រះរាជឱរសរបស់ព្រះអង្គម្នាក់ប៉ុណ្ណោះ ។

ព្រះរាជាត្រាស់ថា កូនជាទីស្រលាញ់របស់យើង តែអ្នកដែលស្រលាញ់អ្នកដទៃលើសពីខ្លួនឯង រមែងមិនទ្រង់ឲ្យព្រះកុមារស្រោចស្រង់ហើយ ទ្រង់ប្រដាប់តាក់តែងរាងកាយ និងស្លៀកពាក់សំពត់ដែលត្បាញដោយសំបកឈើ ឲ្យផ្ទំនៅលើព្រះភ្លៅមាតាដែលកំពុងគង់ប្រថាប់, ក្នុងខណៈដែលពួករាជបុរសដើរចូលមកយកព្រះរាជកុមារ តាមបញ្ជារបស់ព្រះរាជា ព្រះមាតានិងស្ត្រីគីលៀង នាំគ្នា

ស្រែកទ្រហោយំខ្សឹកខ្សួលថា ព្រះកុមារត្រូវបានជាអាហាររបស់យក្សក្នុងពេលព្រឹកនេះហើយ ។

ក៏ក្នុងថ្ងៃនោះ ព្រះបរមសាស្តាទ្រង់ប្រថាប់នៅឯព្រះជេតវនមហាវិហារ ស្តេចតើនឡើងត្រួតមើលសត្វលោក ក្នុងវេលាជិតភ្លឺដោយពុទ្ធចក្ខុ ទ្រង់ជ្រាបឧបនិស្ស័យនៃអនាគាមិផលរបស់អាឡវកកុមារ និងឧបនិស្ស័យ នៃសោតាបត្តិផលរបស់អាឡវកយក្ស និងការបានធម្មចក្ខុរបស់សត្វ ៨៤០០០ ក្នុងទីបំផុតនៃព្រះធម៌ទេសនា ព្រោះហេតុនោះ កាលរាត្រីកន្លងទៅហើយ ព្រះអាទិត្យឧទ័យ ព្រះពុទ្ធអង្គកាលទ្រង់ធ្វើបុរេភត្តកិច្ចរៀបរយហើយ ទើបស្តេចយាងតែមួយអង្គឯង ទ្រង់កាន់បាត្រ និងចីវរ ស្តេចចេញចាកពីក្រុងសាវត្ថីដោយព្រះបាទ ចម្ងាយផ្លូវ៣០០យោជន៍ ទៅកាន់ទៅលំនៅរបស់យក្សគឺដើមជ្រៃធំនោះឯង ។

ក្នុងវេលាដែលព្រះដ៏មានព្រះភាគ ស្តេចយាងទៅប្រថាប់ឈរនៅមាត់ទ្វារវិមានរបស់យក្ស ដែលព្រះអង្គអាចទតឃើញបានដូចយក្សជាម្ចាស់វិមាន តែមនុស្សធម្មតាមើលមិនឃើញនោះ អាឡវកយក្សមិននៅ ជាប់រវល់ទៅប្រជុំក្នុងទីសមាគមយក្សនៅហិមវន្ត

ប្រទេស ក្នុងទីនោះមានតែគទ្រភៈ យាមទ្វារ គទ្រភៈបានឃើញព្រះដ៏មានព្រះភាគស្តេចយាងមក ទើបចូលទៅ ថ្វាយបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ស្តេចយាងមកក្នុងវេលាវិកាល តើមានហេតុអ្វី? ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលគទ្រភៈ បើលោកមិនយល់ទាស់ទេ តថាគតសូមសំណាក់នៅក្នុងវិមានរបស់យក្ខបានមួយយប់ ។ គទ្រភៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនយល់ទាស់ទេ តែថាអាឡវកយក្សម្ចាស់វិមាននេះ ជាអមនុស្សកាច ឃោរឃៅ អាក្រក់ជួរជាតិ រមែងមិនធ្វើការគោរពអោនលំទោន មានការអភិវាទជាដើម សូម្បីតែមាតាបិតារបស់ខ្លួនក៏មិនក្រាបសំពះដែរ សូមព្រះដ៏មានព្រះភាគ កុំសព្វព្រះទ័យសំរាកនៅទីនេះឡើយ ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតដឹងច្បាស់ថា អាឡវកយកស្សអាក្រក់ជួរ ជាតិ តែថាតថាគតមិនមានគ្រោះថ្នាក់អ្វីពីយក្ស នោះទេ ដូច្នេះបើលោកមិនយល់ទាស់ទេ តថាគតសូមសំរាកនៅទីនេះ បានមួយយប់ ។

គទ្រភៈក្រាបទូលព្រះដ៏មានព្រះភាគជាលើកទីពីរថា បពិត្រព្រះអង្គដ៏ចម្រើន អាឡវកយក្សនោះ ជាអមនុស្សទោសៈក្តៅខ្លាំងដូចក្បៀងដែលដុតក្នុងឡមិនស្គាល់មាតាបិតា សមណព្រាហ្មណ៍ ឬធម្មៈ

រមែងធ្វើឲ្យមនុស្សទាំងឡាយដែលមកក្នុងទីនេះ ធ្វើឲ្យចិត្តរាយមាយ ខូចសតិស្មារតីខ្លះ ពុះយកបេះដូងខ្លះ ចាប់ជើងទាំងពីរគ្រវែងទៅត្រើយសមុទ្រខាងណោះ ឬត្រើយចក្រវាឡឯណោះផង ។

ព្រះដ៏មានព្រះភាគត្រាស់ជាលើកទីពីរថា តថាគតបានជ្រាបអំពីសេចក្តីអាក្រក់របស់យក្សនោះហើយ តែបើលោកមិនយល់ទាស់ទេ តថាគតសូមសំរាកនៅទីនេះបានមួយយប់ គទ្រភៈក្រាបទូលព្រះដ៏មានព្រះភាគអំពីសេចក្តីអាក្រក់ជួរជាតិរបស់អាឡវកយក្សជាលើកទីបីដែរ។

កាលព្រះដ៏មានព្រះភាគទ្រង់រក្សាពាក្យដើម ដែលសូមសំរាកនៅក្នុងទីនេះឲ្យទាល់តែបាន គទ្រភៈទើបទូលថា បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះ បង្គំមិនយល់ទាស់ទេ តែថា គឺខ្ញុំព្រះករុណាត្រូវទៅប្រាប់ឲ្យអាឡវកយក្សបានជ្រាបសិន បើមិនដូច្នោះទេ អាឡវកយក្សនឹងសម្លាប់នូវទូលព្រះបង្គំ ព្រះដ៏មានព្រះភាគត្រាស់ថា ចូរគទ្រភៈទៅប្រាប់ចុះ គទ្រភៈទើបចេញពីទីនោះ ទៅរកអាឡវកយក្សដែលនៅក្នុងហិមវន្តប្រទេស ។

ខណៈនោះទ្វារនៃគពរបស់យក្ស គឺទ្វារវិមានបានបើកឡើង ហើយ ព្រះដ៏មានព្រះភាគ ស្តេចបានយាងចូលទៅខាងក្នុងវិមាននោះ ទ្រង់គង់ប្រថាប់នៅលើរតនបល្ល័ង្កទិព្វ ដែលជារតនបល្ល័ង្ករបស់អាឡ-វកយក្ស ដែលអាឡវកយក្សប្រើប្រាស់អង្គុយ ក្នុងថ្ងៃធ្វើមង្គលផ្សេងៗ រីឯពួកស្ត្រីទាំងឡាយរបស់អាឡវកយក្ស កាលបានឃើញព្រះដ៏មានព្រះភាគ ហើយអង្គុយគាល់ជុំ វិញព្រះដ៏មានព្រះភាគៗ ទ្រង់សំដែងបកិណ្ណកធម៌ទាំងឡាយដល់នាងយក្សទាំងនោះ មានជាដើមថា ក្នុងកាលមុននាងទាំងឡាយបានឲ្យទាន សមាទានសីល បូជាដល់អ្នកដែលគួរបូជាក្នុងជាតិនេះ នាងទាំងឡាយទើបបានសម្បត្តិនេះ សូម្បីតែឥឡូវនេះ ក៏ត្រូវតែធ្វើដូចមុន នាងទាំងឡាយចូរកុំប្រណែនឫស្យានឹងគ្នាឡើយ ហើយកុំបណ្តោតបណ្តោយឲ្យសេចក្តីកំណាញ់ចូលមកគ្របសង្កត់ចិត្តបានឡើយ នាងយក្សទាំងឡាយបានស្តាប់ព្រះសូរសៀងដ៏ពីរោះរបស់ព្រះដ៏មានព្រះភាគ ក៏ឲ្យពរសាធុការមួយពាន់ដង ហើយក៏អង្គុយអមគាល់ព្រះដ៏មានព្រះភាគ ។

រីឯគទ្រភៈក៏ទៅកាន់ហិមវន្តប្រទេសដំណាលរឿងឲ្យអាឡវក-យក្សជ្រាបអាឡវកយក្សបានហាមគទ្រភៈមិនឲ្យនិយាយ គ្រាន់តែ

ប្រាប់ថា អញនឹងទៅធ្វើការដែលគួរធ្វើ រឿងនេះព្រោះហេតុថា អាឡវ-កយក្សមានសេចក្តី អៀនខ្មាសព្រោះមានៈរបស់ខ្លួន ទើបមិនចង់ឲ្យអ្នកណាដឹងរឿងនេះថា មានអ្នកបុករុកចូលទៅក្នុងវិមានរបស់ខ្លួនទន្ទឹមនឹងល្បីថា ខ្លួនមានឫទ្ធិច្រើន ។

គ្រានោះ ហេមវតយក្ស និងសាតាគិរីយក្សជាសំលាញ់នឹងគ្នាទាំងពីរនាក់ ជាព្រះសោតាបន្នតាំងពីថ្ងៃដែលព្រះដ៏មានព្រះភាគទ្រង់សំដែងបឋមទេសនាឯព្រៃឥសិបតនមិគទាយវ័ន ដែលកំពុងធ្វើដំណើរទៅប្រជុំឯទីសមាគមរបស់យក្សនៅឯហិមវន្តប្រទេស តែគេគិតថា យើងទៅថ្វាយបង្គំព្រះដ៏មានព្រះភាគជាម្ចាស់ឯវត្តជេតពនជាមុនសិន សឹមទៅប្រជុំ ទើបនាំបរិវារហោះមកតាមអាកាស ឆ្លងកាត់ទីលំនៅរបស់អាឡវកយក្ស ដែលនៅឆ្ងាយពីក្រុងសាវត្ថី៣០០យោជន៍ ដែលតាំងនៅលើប្រឹថពីត្រង់បរិវេណដើមជ្រៃធំ មិនអាចហោះឆ្លងទៅបាន ព្រោះព្រះដ៏មានព្រះភាគប្រថាប់នៅទីនោះ ។

ធម្មតាព្រះពុទ្ធទាំងឡាយប្រថាប់នៅក្នុងទីណា អ្នកណាក៏ដោយ សូម្បីតែកវគ្គព្រហ្មក៏មិនអាចហ៊ានឆ្លងទៅក្នុងទីខ្ពស់នោះ បានឡើយ ។ ព្រោះហេតុនោះ កាលយក្សទាំងពីរនាក់ មិនអាចហ៊ាន

ហោះឆ្លងកាត់វិមានរបស់ អាឡវកយក្សបាន ទើបចំលែកក្នុងចិត្តគិតថា តើវាមានរឿងអ្វីហ្នំ! ទើបហោះចុះមក បានប្រទះឃើញព្រះដ៏មានព្រះភាគ ទើបថ្វាយបង្គំហើយស្តាប់ព្រះធម៌ រួចហើយធ្វើប្រទក្សិណ ក្រាបទូលលាទៅកាន់ទីសមាគមយក្ស កាលទៅដល់អាឡវកយក្សមើលឃើញ ក៏ថយចេញទៅក្រៅហើយពោលថា លោកទាំងឡាយចូរអង្គុយក្នុងទីនេះចុះ, ឯហេមវតយក្ស និងសាតាគិរីយក្ស ក៏ពោលថា ម្នាលអាឡវកៈ! ជាលាភរបស់លោកហើយ ព្រោះព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងវិមានរបស់លោក លោកចូរទៅចុះ សូមចូលទៅអង្គុយជិតព្រះអង្គ ហើយសរសើរព្រះគុណរបស់ព្រះមានព្រះភាគជាម្ចាស់ ព្រះធម៌ និងព្រះសង្ឃ ។ ព្រោះហេតុការញុំាំងសទ្ធាឲ្យកើតមានដល់អ្នកដែលគ្មានសទ្ធា ជាការក្រដូចការសំដែងសីលឲ្យដល់អ្នកទ្រុស្តសីលស្តាប់ ព្រោះហេតុនោះ កាលអាឡវកយក្សបានស្តាប់ពាក្យសរសើរព្រះដ៏មានព្រះភាគ ក្នុងសំណាក់របស់យក្សទាំងឡាយដូច្នោះ ក៏ក្រោធខឹង មានចិត្តក្តៅក្រហាយដូចពោយអំបិលដាក់ក្នុងភ្លើងដូច្នោះ អាឡវកយក្សសួរថា អ្នកដែលចូលទៅក្នុងវិមានរបស់ខ្ញុំ ដែលឈ្មោះថា ព្រះដ៏មានព្រះភាគ នោះតើជាអ្នកណា? យក្សទាំងពីរក៏រៀបរាប់រឿងឲ្យស្តាប់តាំងពីដើម ។ គឺ

រៀបរាប់តាំងពីកើតបុព្វនិមិត្ត៣២ប្រការ ក្នុងថ្ងៃដែលព្រះដ៏មានព្រះភាគស្តេចយាងចុះកាន់ព្រះគភ៌ព្រះមាតា រហូតដល់ការសំដែងធម្មចក្ររួចហើយសួរអាឡវកយក្សថា ម្នាលអាវុសោ លោកមិនឃើញសេចក្តីអស្ចារ្យទាំងនេះខ្លះឬ? អាឡវកយក្ស ទោះបីបានឃើញសេចក្តីអស្ចារ្យទាំងនុ៎ះដែរ តែក៏តបថា ម្នាលលោកដ៏មានអាយុ ទោះបីលោកឃើញសេចក្តីអស្ចារ្យទាំងនុ៎ះក្តី មិនឃើញក្តី តើមានប្រយោជន៍អ្វីសម្រាប់លោក បើលោកមិនជ្រះថ្លាទេ តើលោកធ្វើអ្វីចំពោះព្រះសាស្តារបស់យើង បើលោកហ៊ានចូលទៅប៉ះពាល់ដល់ព្រះអង្គ ខ្លួនលោកបីដូចកូនគោដែលទើបសម្រាលក្នុងថ្ងៃនោះ ហើយនៅជិតគោឧសភរាជដ៏ធំនេះ ឬដូចកូនដំរីឈរនៅជិតដំរីចុះប្រេងដូច្នោះ លោកអញ្ជើញទៅចុះ លោកចង់ធ្វើ អ្វីចំពោះព្រះមានព្រះភាគ ក៏ចូរធ្វើចុះ កាលយក្សទាំងពីរពោលដូច្នោះ អាឡវកយក្សខឹងណាស់ ស្ទុះក្រោកឡើងឈរលើមនោសិលាដោយជើងឆ្វេង ឯជើងស្តាំជាន់លើកំពូលភ្នំកៃលាសដែលមានកំពស់ប្រមាណ ៦០ យោជន៍ព្រមទាំងពោលថា ចូរអ្នកឯងចាំមើលចុះ ឥឡូវនេះ តើព្រះសាស្តារបស់អ្នកឯងឬក៏យើងដែលមានអានុភាពខ្លាំងក្លា លុះពោលរួចហើយក៏ ស្រែក

ប្រកាសលាន់កង់រំពង់ថា "អញនេះហើយ គឺអាឡវកយក្ស!" រីឯសំលេងនោះ ក៏លាន់ឮទូទៅពេញទាំងជម្ពូទ្វីប ។

**លោកពោលថា សំលេងដែលបានឮទូទៅពេញទាំងជម្ពូទ្វិប មាន ៤ គឺ**

១-សំលេងរបស់បុណ្ណកយក្ស ដែលឈ្នះល្បែងភ្នាល់ដល់ព្រះចៅធនញ្ជ័យគោរព្យៈហើយទះដៃប្រកាសថា "អញឈ្នះហើយ" ។

២-សំលេងស្តេចសក្កៈ ជាកំពូលទេព្តា បានធ្វើឲ្យវិស្សុកម្មទេវបុត្រកើតជាសុនខ ក្នុងកាលព្រះពុទ្ធសាសនារបស់ព្រះកស្សបៈវិនាសដោយប្រកាសយ៉ាងកង់រំពង់ថា "អញនឹងទំពាស៊ីភិក្ខុបាប ភិក្ខុនីបាប ឧបាសក ឧបាសិកា និងមនុស្សជាអធម្មវាទីឲ្យអស់" ។

៣-សំលេងព្រះមហាបុរស ស្រែកប្រកាសយ៉ាងកង់រំពង់មាននៅក្នុងកុសជាតកថា "អញនេះហើយឈ្មោះសីហស្សរកុសមហារជ" ក្នុងកាលដែលក្សត្រ៧ អង្គចូលដណ្តើមយកព្រះនគរបាន ព្រោះហេតុនៃនាងបរភាវតី ហើយព្រះមហាបុរសទ្រង់បីពនាងបរភាវតីឡើងជិះលើដំរីចេញចាកពីនគរ ។

៤-សំលេងដែលអាឡវកយក្សឈរលើភ្នំកៃលាស ហើយស្រែកប្រកាសថា "អញនេះហើយ គឺអាឡវកយក្ស" ។

ក្នុងគ្រានោះ រីភ្នំហេមវន្ត ដែលមានប្រមាណ ៣ ពាន់យោជន៍ រមែងញាប់ញ័រដោយអានុភាពរបស់យក្ស គ្រានោះអាឡវកយក្សបានធ្វើខ្យល់ឲ្យតាំងឡើងដោយគិតថា អញនឹងញាំញីសមណៈនេះឲ្យស្គាល់ដៃម្តង ឯខ្យល់ដែលអាឡវកយក្សបណ្តាលនោះ មកពីទិសខាងកើតបានតាំងឡើងហើយ បានបំផ្លាញកំពូលភ្នំទាំងឡាយ ដែលមានប្រមាណកន្ទះយោជន៍ ២ យោជន៍ ៣ យោជន៍ សណ្តកឫសគល់ឈើនៅក្នុងព្រៃ សំដៅឆ្ពោះទៅកាន់ក្រុងអាឡវីនគរ ធ្វើទីទាំងឡាយ មានរោងដំរីចាស់ៗជាដើម ឲ្យបាក់បែករលំដួលប៉ើង ដំបូលជញ្ជាំងឥដ្ឋឲ្យរសាត់អណ្តែតទៅក្នុងអាកាស ។ ព្រះដ៏មានព្រះភាគទ្រង់អធិដ្ឋានថា សូមឲ្យភ័យវិបត្តិកុំឲ្យកើតមានដល់អ្នកណាៗឲ្យសោះ ។ រីឯខ្យល់នោះលុះ មកដល់ព្រះដ៏មានព្រះភាគ ក៏មិនអាចធ្វើជាយចីវររបស់ព្រះ អង្គឲ្យកំរើកបាន ។

តអំពីនោះអាឡវកយក្ស ធ្វើភ្លៀងផ្គរឲ្យធ្លាក់ដោយគិតថា អញនឹងធ្វើទឹកឲ្យជន់លិចឲ្យសមណៈលង់ស្លាប់ ភ្លៀងទាំងឡាយ

ដែលកកាញ់ដោយដុំពពករាប់រយរាប់ពាន់បានឡើងហើយ ក៏បង្អុរភ្លៀងចុះមកយ៉ាងរហ័ស ឯកំលាំងទឹកភ្លៀងធ្លាក់លើផែនដី បែកផែនដីជាប្រហោងមហាមេឃក៏តាំងឡើងលើដងព្រៃ ជន់លិចព្រៃព្រឹក្សា អាឡវកយក្សធ្វើខ្លាំងដូច្នោះ ក៏មិនអាចធ្វើដំណក់ទឹកភ្លៀង សូម្បីតែមួយតំណក់ឲ្យទទឹកចីវរព្រះដ៏មានព្រះភាគពុំមានឡើយ ។

តអំពីនោះ អាឡវកយក្ស ធ្វើភ្លៀងដុំថ្មឲ្យធ្លាក់ចុះមកលើកំពូលភ្នំធំៗ បែកខ្ចាយចេញផ្សែងហុយទ្រលោមមកតាមអាកាស លុះមកដល់ព្រះដ៏មានព្រះភាគ ក៏សម្រេចជាផ្កាទិព្វបូជាព្រះដ៏មានព្រះភាគ ។

តអំពីនោះមកអាឡវកយក្ស ធ្វើភ្លៀងសស្ត្រាវុធគ្រឿងប្រហារឲ្យធ្លាក់ចុះ សស្ត្រាទាំងឡាយដែលមានមុខមុតតែម្ខាង ដែលមានមុខមុតសងខាង មានដាវ លំពែង ប្បូក ស្នរ កាំបិតកោរជាដើម បាញ់ផ្សែងហុយទ្រលោមតាមអាកាស លុះមកដល់ព្រះដ៏មានព្រះភាគក៏ក្លាយជាបុប្ផាទិព្វបូជាព្រះអង្គ ។

តអំពីនោះ អាឡវកយក្សធ្វើភ្លៀងរងើកភ្លើងឲ្យធ្លាក់ចុះមក ឯរងើកភ្លើង មានពណ៌ក្រហមដូចផ្កាចារ៉ុ រសាត់មកតាមផ្លូវអាកាស

ហើយបានក្លាយជាផ្កាទិព្វធ្លាក់ចុះរៀងរាយ ក្នុងទីជិតព្រះបាទរបស់ព្រះដ៏មានព្រះភាគ ។

តអំពីនោះអាឡវកយក្ស ធ្វើភ្លៀងផេះហុយឡប់ឡើងលើអាកាស ឯភ្លៀងនោះ ក៏ក្លាយជាលំអិតខ្លឹមចន្ទន៍ក្រឹស្នាធ្លាក់ចុះទៀបព្រះបាទមូលនៃព្រះដ៏មានព្រះភាគ ។

តអំពីនោះអាឡវកយក្ស ធ្វើភ្លៀងដីខ្សាច់ឲ្យធ្លាក់ចុះ ឯដីខ្សាច់នោះល្អិតផង់យ៉ាងក្រៃលែង មានផ្សែងហុយទ្រលោមទៅតាមអាកាស បានក្លាយ ជាផ្កាទិព្វធ្លាក់ចុះទៀបព្រះបាទមូលនៃព្រះមានព្រះភាគ ។

តអំពីនោះ យក្សក៏ធ្វើភ្លៀងភក់ឲ្យធ្លាក់ចុះមក ភ្លៀងភក់នោះបានបាញ់ផ្សែងហុយទ្រលោមមកតាមអាកាស ក្លាយជាគ្រឿងក្រអូបដ៏ជាទិព្វធ្លាក់ចុះទៀបព្រះបាទានៃព្រះដ៏មានព្រះភាគ ។

តអំពីនោះយក្សបណ្តាលឲ្យកើតងងឹងអន្ធការ ដោយបំណងថា អញនឹងបន្លាចសមណៈអង្គនេះឲ្យខ្លាចហើយនឹងរត់ចេញទៅ ឯងងឹតនោះ ដូចងងឹតដែលប្រកបដោយអង្គ៤ គឺជាថ្ងៃឧបោសថខាងរនោច១, មានពពក គ្របដណ្តប់ផ្ទៃអាកាស១, នៅក្នុងព្រៃស្តុក១,

ពាក់កណ្ដាលអាធ្រាត្រ១ (កាឡបក្ខចាតុទ្ទសី អឌ្ឍរត្ត ឃនវនេ សណ្ឌមេឃ បដលេ ចាកសាមញ្ញផលសូត្រ អដ្ឋកថា)តែសេចក្ដីងងឹតនោះ លុះមកដល់សម័យព្រះដ៏មានព្រះភាគត្រាស់ដឹង ក៏អន្តរធានបាត់អស់ទៅបីដូចត្រូវកំចាត់ដោយពន្លឺព្រះអាទិត្យដូច្នោះ ។

យក្សនោះ កាលមិនអាចធ្វើឲ្យព្រះដ៏មានព្រះភាគខ្លាចរត់ទៅដោយតេជៈរបស់ខ្លួន ដូច្នោះទើបចូលទៅជិតព្រះដ៏មានព្រះភាគព្រមដោយសេនា៤ ពួក ដេរដាសទៅដោយពួកភូតខ្មោចបិសាច ដែលមានរូបរាងគួរឲ្យខ្លាច ក្នុងដៃកាន់សស្ត្រាវុធផ្សេងៗ តែពួកភូតទាំងនោះ មិនអាចចូកទៅជិតព្រះដ៏មានព្រះភាគបានឡើយ បីដូចរុយមិនអាចរោមដុំដែកដែលកំពុងឆេះក្រហមបាន បានត្រឹមតែគម្រាមកំហែងព្រះដ៏មានព្រះភាគប៉ុណ្ណោះ មិនអាចធ្វើឲ្យព្រះដ៏មានព្រះភាគញាប់ញ័របានឡើយ ។

លុះរំលងអាធ្រាត្រអាឡវកយក្សគិតថា អញនឹងដោះលែងសំពត់ទស្សាវុធ (សំពត់ឈ្នួត) ដែលពុំមានអ្នកណា យកជ័យជំនះលើអញបាន អាឡវកយក្សគិតដូច្នោះហើយ ទើបស្រាយទុស្សាវុធ កាន់លើកឡើងគ្រវីហោះធ្វេលជុំវិញព្រះដ៏មានព្រះភាគ ហើយលែង

*ទុស្សាវុធទៅក្នុងអាកាស រីឯទុស្សាវុធនោះមានសំលេងឮខ្លាំងគួរឲ្យភ័យខ្លាចនៅក្នុងអាកាស ដូចខ្សែផ្ទេកបន្ទោរ ហុយផ្សែងឆេះទ្រលោមលុះមកដល់ព្រះដ៏មានព្រះញភាគ ក៏ក្លាយជាសំពត់ជូតព្រះបាទ ធ្លាក់ចុះមកទៀបព្រះបាតមូលនៃព្រះដ៏មានព្រះភាគ អាឡវកយក្សឃើញដូច្នោះក៏អស់តេជៈអស់មានៈ បីដូចពស់ដែលត្រូវគេដក ចង្កូមចេញ ។ អាឡវកយក្សគិតថា តើអញត្រូវធ្វើដូចម្តេចហ្ន៎! សូម្បីតែទុស្សាវុធដែលមានឫទ្ធិរបស់អញក៏មិនអាចធ្វើឲ្យសមណៈនេះខ្លាចបានឡើយ ។*

***គេធ្លាប់ពោលថា នៅក្នុងលោកនេះ មានអាវុធដ៏ប្រសើរ ៤ យ៉ាង គឺ***

*១-វជិរាវុធរបស់ព្រះឥន្ទ*

*២-គទាវុធរបស់ស្តេចវេស្សវ័ណ្ណ*

*៣-នយនាវុធរបស់ស្តេចយមរាជ*

*៤-ទុស្សាវុធរបស់អាឡវកយក្ស*

កំលាំងដ៏សាហាវនៃអាវុធទាំងនេះ មានដំណាលថា បានឮមកថា ព្រះឥន្ទកាលទ្រង់ពិរោធ ទ្រង់បោកវជិរាវុធទៅលើភ្នំសិនេរុ វជិរាវុធនោះ ក៏ញុាំងភ្នំឲ្យកក្រើកញាប់ញ័រកំពស់ដល់១សែន ៦ម៉ឺន ៨ពាន់យោជន៍ ដល់ទៅ បាតភ្នំខាងក្រោម ។

ចំណែកគទាវុធរបស់ស្តេចវេស្សវ័ណ្ណ កាលណាចោលទៅក្នុងវេលាដែលលោកនៅជាបុថុជ្ជន បានធ្លាក់ទៅត្រូវក្បាលពួកយក្សជាច្រើនពាន់នាក់ រួចហើយត្រឡប់មកនៅលើដៃរបស់ស្តេចវេស្សវណ្ណវិញ ។

ចំណែកពួកកុម្ភណ្ឌជាច្រើនពាន់ គ្រាន់តែស្តេចព្រះយមរាជខឹងភ្វាម សំលឹងមើលដោយនយនាវុធ គឺភ្នែកប៉ុណ្ណោះ ក៏កើតភ្លើងឆេះវិនាស ដូចស្មៅ នឹងស្លឹកឈើក្រៀម នៅលើអំបែងក្បឿងដែលកំពុងក្តៅខ្លាំង ។

ចំណែកអាឡវកយក្សនោះ កាលណាក្រោធលែងទុស្សាវុធទៅក្នុងអាកាស ភ្លៀងនឹងរាំងអស់រយៈពេល ១២ ឆ្នាំ បើចោលទៅលើផែនដី ដើមឈើ និងស្មៅក្រៀមស្វិតស្រពោន មិនលូតលាស់

អស់រយៈពេល ១២ឆ្នាំ បើចោល ទៅក្នុងមហាសមុទ្រទឹក នឹងរីងខះ ដូចដំណក់ទឹកធ្លាក់លើអំបែងដែលកំពុងក្តៅ បើចោលទៅលើភ្នំ ដូច ភ្នំសុនេរុ ភ្នំនោះក៏បែកធ្លាយខ្ចាត់ខ្ចាយជាដុំតូចដុំធំ ដោយហេតុ ទុស្សាវុធរបស់អាឡវកយក្សមានអានុភាពខ្លាំងយ៉ាងនេះ ទើបអាឡវ-កយក្សអស់មានៈ អស់តេជៈ ដោយឃើញទុស្សាវុធនោះ មិនអាច ធ្វើអ្វី ឲ្យអន្តរាយដល់ព្រះដ៏មានព្រះភាគ ទើបត្រួតមើលថា ហេតុអ្វី ហ្ន៎! ទើបសមណៈនេះមិនខ្លាច ក៏ពិចារណាឃើញថា ព្រះដ៏មានព្រះ ភាគទ្រង់តាំងនៅដោយមេត្តាធម៌ទើបគិតថាណ្ហើយចុះ អញនឹងធ្វើ ឲ្យសមណៈនេះខឹង ឲ្យប្រាសចាកមេត្តា ដោយហេតុនេះ អាឡវក-យក្សទើបដេញព្រះដ៏មានព្រះភាគ ឲ្យចុះចេញពីបល្ល័ង្ក ដោយពាក្យថា "នៃសមណៈ ចូរចុះចេញពី បល្ល័ង្ក" ដែលមានន័យថា "ខ្ញុំព្រះករុណា ជាម្ចាស់វិមាន មិនបានអនុញ្ញាតឲ្យ លោកចូលទៅទេ លោកប្រើ របស់ដែលម្ចាស់គេមិនបានអនុញ្ញាត ហើយនៅច្របូកច្របល់ជាមួយ ស្ត្រីដូច្នេះ ជាការគួរសមដល់សមណៈដែរ ឬទេ?" ។

ពីដំបូងដែលអាឡវកយក្ស ត្រឡប់ពីសមាគមពួកយក្សនោះ បានឃើញ ព្រះដ៏មានព្រះភាគគង់ប្រថាប់នៅលើរតនបល្ល័ង្ករបស់ខ្លួន

ដោយមានពួកនាងយក្សទាំងឡាយចូលគាល់ចោមរោមជុំជិត ក៏កើតក្រោធខឹង ទើបសំដែងឫទ្ធិផ្សេងៗ ដើម្បីសំលាប់ព្រះដ៏មានព្រះភាគចោលតែមិនអាចធ្វើអ្វីឲ្យ អន្តរាយដល់ព្រះដ៏មានព្រះភាគឡើយ ព្រោះហេតុនោះកាលពិចារណាជ្រាបថា ព្រះដ៏មានព្រះភាគទ្រង់ប្រកបដោយមេត្តាធម៌ ទើបគិតធ្វើឲ្យព្រះដ៏មានព្រះភាគក្រោធខឹង នឹងបានវិនាសចាកមេត្តាធម៌ ទើបបានពោលចោទថា ព្រះដ៏មានព្រះភាគប្រើរបស់ដែលម្ចាស់មិនបានអនុញ្ញាត ហើយនៅច្របូកច្របល់ជាមួយស្ត្រី ដូចពោលហើយតែព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា យក្សនេះជាអ្នកឆ្មើងឆ្មៃ មិនអាចនរណាប្រៀនប្រដៅបាន បើតថាគតសំដែងអាការៈឆ្មើងឆ្មៃតបវិញមិនបានផលទេ ដូច្នេះកាលយក្សបញ្ជាឲ្យស្ដេចចុះចេញ ទើបព្រះដ៏មានព្រះភាគស្ដេចយាងចេញទៅដោយស្រួលឲ្យស្ដេចចុះចេញ ទើបព្រះដ៏មានព្រះភាគស្ដេចយាងចេញទៅដោយស្រួល ដោយត្រាស់ព្រះពុទ្ធដីកាយ៉ាងផ្អែមថាសាធុ អាវុសោ ហើយស្ដេចយាងចេញទៅ អាឡវកយក្សឃើញដូច្នោះ ក៏មានចិត្តទោរទន់គិតថា "សមណៈនេះប្រដៅងាយ អញបណ្ដេញពាក្យតែមួយម៉ាត់ក៏ចេញទៅភ្លាម អញអាចយកជ័យជំនះសមណៈ នេះ ដោយពាក្យត្រឹមប៉ុណ្ណឹង បង់កំលាំងទទេ ដោយមិនគប្បីអញប្រយុទ្ធជាមួយ

*សមណៈនេះ អស់ពាក់កណ្ដាលអាធ្រាត្រដោយអារុធយ៉ាងសាហាវ អញចង់ដឹងថា តើសមណៈនេះចេញទៅ ព្រោះជាអ្នកប្រដៅងាយ ឬព្រោះតែសេចក្ដីក្រោធខឹង បើដូច្នោះអញនឹងសាកល្បងមើលម្ដង ទៀត គិតហើយ ទើបពោលថា សមណៈ ចូរមកវិញ គ្រានោះព្រះ ដ៏មានព្រះភាគទ្រង់ប្រាថ្នាចង់ធ្វើឲ្យអាឡវកយក្ស មានចិត្តទន់ភ្លន់កាន់ តែខ្លាំងឡើង ទើបស្ដេចយាងចូលមកវិញ តាមពាក្យបញ្ជារបស់ យក្ស អាឡវកយក្សសាកល្បងបញ្ជាឲ្យចូលទៅ ហើយឲ្យចេញមក ធ្វើដូច្នេះ គ្រប់៣ដង ព្រះដ៏មានព្រះភាគធ្វើតាមពាក្យ ព្រោះថា ព្រះ ដ៏មានព្រះភាគទ្រង់ត្រិះរិះថាយក្សនេះជាអ្នករឹងត្អឹងស្រាប់ហើយ បើ តថាគតជំទាស់នឹងពាក្យបញ្ជារបស់យក្ស យក្សនុ៎ះឯងរឹតតែរឹងត្អឹង កាន់តែខ្លាំងឡើងមិនអាចទូន្មានបានឡើយ ហេតុនេះ ព្រះដ៏មានព្រះ ភាគ ទើបធ្វើតាមពាក្យបញ្ជារបស់យក្ស" ។*

*គ្រានោះអាឡវយកយក្ស កើតមានគំនិតអាក្រក់ថា សមណៈ នេះ អញប្រាប់ឲ្យចេញ ក៏ចេញភ្លាម, អញប្រាប់ឲ្យចូលក៏ចូលភ្លាម ម្ដងនេះអញនឹងធ្វើឲ្យសមណៈនេះលំបាករហូត១យប់ ដោយគ្រាន់ តែឲ្យចូលៗ ចេញៗដូច្នេះ ដល់ទីបំផុតអញនឹងចាប់ជើងទាំងពីរចោល*

ទៅត្រើយម្ខាងគង្គាខាងនោះ ដូច្នោះទើបបញ្ហាជាលើកទី៤ថាសមណៈចូរចេញ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបវារៈ ចិត្តរបស់យក្សនោះ ទើបត្រាស់ថា តថាគតមិនចេញទេ លោកចូរធ្វើ កិច្ចដែលលោកគប្បីធ្វើចុះដោយអាឡវកយក្សធ្លាប់សួរបញ្ហាជាមួយ តាបស ឬបរិព្វាជកអ្នកដែលមកកាន់វិមានរបស់ខ្លួន ក្នុងពេលដែលលោកទាំងនោះមកតាមផ្លូវអាកាសបានឃើញវិមានរបស់អាឡវកយក្ស ក៏ហោះចុះមកមើលថា វិមាននេះជាវិមានប្រាក់ឬវិមានមាស ឬថាជាវិមានកែវមណីអញចង់ចូលទៅមើល ដោយហេតុនេះ ទើបត្រូវអាឡវកយក្សចាប់ឲ្យឆ្លើយបញ្ហា គ្មានលោកណាឆ្លើយរួចឡើយ ទើបយក្សខ្លះយកបេះដូង របស់លោកទាំងនោះឈ្វីចោល ខ្លះចាប់ជើងទាំងពីរគ្រវែងទៅត្រើយម្ខាងគង្គាឯណោះ ខ្លះដោយគិតថា លោកអ្នកមានឫទ្ធិទាំងអស់នេះកុំឲ្យមកកាន់ទីលំនៅរបស់អញទៀត ។ អាឡវកយក្ស នឹកដល់បញ្ហាតាំងនេះបាន ទើបគិតចង់សួរបញ្ហានោះ នឹងព្រះដ៏មានព្រះភាគក្នុងពេលដែលឃើញ ព្រះដ៏មានព្រះភាគដែលព្រះអង្គមិនចេញទៅតាមពាក្យបញ្ហាលើកទី៤របស់ខ្លួន ។

<u>មានពាក្យសួរថា</u> តើអាឡវយកយក្សបានបញ្ហានោះមកពីណា?

*ឆ្លើយថា* បានឮមកថា មាតាបិតារបស់អាឡវយកយក្សនោះ ចូលគាល់ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ បានចងចាំបញ្ហា ៨ ខ ព្រមទាំងពាក្យឆ្លើយ អំពីសំណាក់របស់ព្រះកស្សបៈព្រះពុទ្ធជាម្ចាស់, កាលអាឡវយកយក្សនៅកម្លោះ មាតាបិតាបង្រៀនបញ្ហា ព្រមទាំងពាក្យឆ្លើយ តែពេលវេលាកន្លងទៅយូរ អាឡវយកយក្សភ្លេចពាក្យឆ្លើយអស់ តែគេក៏មិនត្រូវការឲ្យបញ្ហានោះសាបសូន្យទៅ ទើបគេសរសេរបញ្ហានោះទុកនៅលើសន្លឹកមាសការពារភ្លេចភ្លាំង ហើយទុកដាក់យ៉ាងល្អឯបញ្ហាទាំងនោះជាវិស័យព្រះពុទ្ធ ទើបឆ្លើយរួច ។ ក្រៅពីនេះគ្មាននរណាឆ្លើយរួចឡើយ បើអ្នកណាបានស្តាប់អំពីសំណាក់ព្រះពុទ្ធហើយ ទើបឆ្លើយរួច ។

ហេតុនោះ ទើបយក្សពោលថា នែសមណៈ ខ្ញុំនឹងសួរបញ្ហាចំពោះលោក បើលោកមិនឆ្លើយទេ ខ្ញុំនឹងខ្ទេះយកបេះដូងរបស់លោក ហើយខ្ញុំនឹងឈ្វីបេះដូងរបស់លោកចោល ឬចាប់ជើងទាំងពីររបស់លោក ហើយគ្រវែងទៅត្រើយម្ខាងគង្គា ។

ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតមើលមិនឃើញបុគ្គលដែលអាច ខ្ទេះយកបេះដូងរបស់តថាគត ឈ្វីចោល ឬបុគ្គលណា

ដែលអាចចាប់ជើងទាំងពីររបស់តថាគត គ្រវែងទៅត្រើយម្ខាងគង្គា នៅក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្ស, ម្នាលយក្សបើលោកប្រាថ្នាចង់សួរបញ្ហា ក៏សូមលោកសួរមកចុះ តថាគតនឹងឆ្លើយគ្រប់យ៉ាង? ។

ព្រះដ៏មានព្រះភាគទ្រង់ពោលយ៉ាងនេះ ព្រោះព្រះអង្គទ្រង់មានព្រះសព្វញ្ញូដែលបុគ្គលដទៃ សូម្បីតែព្រះបច្ចេកពោធិ៍ ក៏មិនមានផង ។

**កាលព្រះដ៏មានព្រះភាគ ទ្រង់បវារណាយ៉ាងនេះ ក្នុងការនឹងឆ្លើយបញ្ហា អាឡវកយក្សទើបទូលសួរថា:**

អ្វីជាទ្រព្យជាគ្រឿងរីករាយចិត្ត ដ៏ប្រសើរបំផុតរបស់បុរសក្នុងលោកនេះ?

អ្វីដែលបុគ្គលប្រព្រឹត្តល្អហើយ រមែងនាំសេចក្តីសុខមកឲ្យ?

អ្វីជារសញុះងប្រយោជន៍ឲ្យសម្រេច ជាងរសទាំងឡាយ?

*អ្នកប្រាជ្ញទាំងឡាយពោលថា ជីវិតរបស់បុគ្គលរស់នៅយ៉ាងណាថា ជា ជីវិតប្រសើរបំផុត?*

*ព្រះដ៏មានព្រះភាគត្រាស់តមថា សទ្ធាជាទ្រព្យ ជាគ្រឿងរីករាយចិត្តដ៏ប្រសើរបំផុតរបស់បុរសក្នុងលោកនេះ ។*

*ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ រមែងនាំសេចក្ដីសុខមកឲ្យ ។*

*សច្ចះនោះឯង ជារសញ៉ាំងប្រយោជន៍ឲ្យសម្រេចជាងរសទាំងឡាយ ។*

*អ្នកប្រាជ្ញទាំងឡាយពោលថា ជីវិតរបស់អ្នករស់នៅដោយបញ្ញាថាជាជីវិតប្រសើរបំផុត ។*

*ក្នុងពាក្យឆ្លើយនោះ មានអធិប្បាយថា ទ្រព្យជាគ្រឿងរីករាយចិត្ត បណ្ដាទ្រព្យដែលមានក្នុងលោកនេះ មានមាស និងប្រាក់ជាដើម រមែងនាំមកនូវសេចក្ដីសុខក្នុងការប្រើប្រាស់មកឲ្យ រមែងបំបាត់សេចក្ដីទុក្ខ មានសេចក្ដីស្រេកឃ្លានជាដើម រមែងធ្វើសេចក្ដីក្រខ្វត់ឲ្យស្ងប់ជាហេតុឲ្យបានកែវចិញ្ចៀន ប្រាក់ មាស ដោយនាំទាំងសេចក្ដីសុខលោកិយៈមកឲ្យ សេចក្ដី នេះយ៉ាងណាមិញ ទ្រព្យគឺសទ្ធា ទាំង*

លោកិយៈ ទាំងលោកុត្តរៈ រមែងនាំមកនូវវិបាកសុខ ទាំងលោកិយៈ ទាំងលោកុត្តរៈមកឲ្យតាមការគួរ រមែងរាំងរាសេចក្តីទុក្ខ មានជាតិ ជរាជាដើម ឲ្យដល់ជនទាំងឡាយដែលអាស្រ័យសទ្ធាធ្វើដំណើរទៅ រមែងញុំាងសេចក្តីក្រខ្សត់នៃគុណធម៌ឲ្យស្ងប់ទៅ គឺជាអ្នកច្រើនទៅ ដោយគុណធម៌ ព្រោះអាស្រ័យសទ្ធាជាហេតុឲ្យបាននូវរតនៈ គឺ ពោជ្ឈង្គជាដើម ។

ឯព្រះដ៏មានព្រះភាគត្រាស់ហៅ **សទ្ធា** ថាជាទ្រព្យ ជាគ្រឿងរីករាយចិត្ត ព្រោះនាំមកនូវតំណៃលោក ដូចបាលីថា **បុគ្គលអ្នកមានសទ្ធា សម្បូណ៌ដោយសីល ដល់ព្រមដោយយស និងភោគៈ ទៅកាន់ទីណាៗ បានទទួលការបូជាក្នុងទីនោះៗ** ។ ព្រោះទ្រព្យគឺសទ្ធានោះឯង ជាគុណធម៌ដែលជាប់តាមខ្លួនទៅបាន តែក៏មិនទូទៅដល់បុគ្គលដទៃ គឺអ្នកណាធ្វើអ្នកនោះបាន បើមិនធ្វើគឺមិនបាន ទាំងជាហេតុឲ្យបានទ្រព្យ ជាគ្រឿងរីករាយចិត្ត មានប្រាក់ និងមាសជាដើម ជាហេតុឱ្យបានសម្បត្តិគ្រប់យ៉ាង ទាំងលោកិយៈ និងលោកុត្តរៈ ព្រោះថាមនុស្សមានសទ្ធានុ៎ះ រមែងធ្វើបុណ្យ មានការឲ្យទានជាដើម កាលធ្វើបុណ្យ រមែងបានទទួលទ្រព្យជាគ្រឿងរីករាយចិត្ត ចំណែកទ្រព្យ

ជាគ្រឿងរីករាយចិត្តរបស់មនុស្ស ដែលមិនមានសទ្ធា រមែងប្រព្រឹត្តទៅដើម្បីរបស់ដែលមិនមានប្រយោជន៍តែប៉ុណ្ណោះ ព្រោះដូច្នោះ **សទ្ធា** ទើបលោកពោលថា ជាទ្រព្យគ្រឿងរីករាយចិត្ត ដ៏ប្រសើរបំផុតរបស់បុរសក្នុងលោកនេះ ។

ពាក្យថា **បុរស** នេះ មិនមែនមានន័យថា មនុស្សប្រុសតែម្យ៉ាងទេ គឺសំដៅយកជនទាំងអស់ ទាំងប្រុសទាំងស្រី ព្រោះថា**សទ្ធា** ជាទ្រព្យ វត្ថុជាទីរីករាយនៃចិត្តរបស់ជនទាំងឡាយទាំងពួង អ្នកណាមានហើយ ឈ្មោះថា មានទ្រព្យប្រសើរបំផុត កាលព្រះដ៏មានព្រះភាគត្រាស់ជាមួយអាឡវកយក្សដោយសេចក្តីជាក់ច្បាស់ ។ ដូច្នេះហើយអាឡវយកយក្សទូលសួរតទៅទៀតថា អ្វីដែលបុគ្គលប្រព្រឹត្តល្អហើយ នាំសេចក្តីសុខមកឲ្យ?

ព្រះដ៏មានព្រះភាគត្រាស់តបថា ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយនាំសេចក្តីសុខមកឲ្យ ។ ក្នុងពាក្យតបនេះ ពាក្យថា **ធម៌** បានដល់កុសលកម្មបថ ១០ ប្រការគឺ កាយសុចរិត ៣ មានការវៀរចាកការសំលាប់សត្វ ១, វៀរចាកកាន់យកទ្រព្យដែលម្ចាស់គេ មិនឲ្យបាន ១, វៀរចាកការប្រព្រឹត្តិខុសក្នុងកាម ១, និងវចីសុច្ចរិត៤

គឺមិននិយាយកុហក ១, មិននិយាយបំបែកបំបាក់ ១, មិនជេរប្រទេច ១, មិននិយាយពាក្យរោយរាយឥតប្រយោជន៍ ១ និងមនោ សុច្ចរិត ៣ គឺមិនសំលឹងរំពៃចង់បានទ្រព្យគេ១, មិនព្យាបាទគេ១, មិនមាន មិច្ឆាទិដ្ឋិ ១ ។ រួមត្រូវជា១០យ៉ាង ហៅថា កុសលកម្មបថ១០ ឬពោលថា ធម៌គឺ **ទាន, សីល, ភាវនា** ក៏បានដែរ បុគ្គលដែល ប្រព្រឹត្តធម៌ គឺ កុសលកម្មបថ ឬទាន សីល ភាវនា ដូច្នេះហើយ រមែងបានទទួល សេចក្តីសុខនៅក្នុងមនុស្សលោកនិងទេវលោក ដូច សេចក្តីសុខ របស់រដ្ឋបាលត្តេរជាដើម រមែងបានទទួលសេចក្តីសុខ ដ៏ជាទិព្វ ដូចសេចក្តីសុខរបស់ព្រះឥន្ទជាដើម និងរមែងនាំមកនូវ សេចក្តីសុខរបស់ព្រះអរិយៈ មានព្រះមហាបទុមៈជាដើម រួមសេចក្តី ជាធម៌ គឺកុសលធម៌ដែលបុគ្គល ប្រព្រឹត្តល្អរមែងនាំមកនូវសេចក្តី សុខទាំងលោកិយៈ និងលោកុត្តរៈ ។

សំនួរតទៅទៀតរបស់អាឡវយកយក្ស គឺអ្វីជារសញ៉ាំងប្រយោជន៍ឲ្យសម្រេច លើសរសទាំងឡាយ?

ព្រះមានព្រះភាគត្រាស់តបថា **សច្ចៈ** ជារសញ៉ាំងប្រយោជន៍ ឲ្យសម្រេច លើសរសទាំងឡាយ ។

ពាក្យឆ្លើយរបស់ព្រះដ៏មានព្រះភាគនេះ មានអត្ថាធិប្បាយគឺ ពាក្យថា **សច្ចៈ** នេះ លោកពោលមានច្រើនយ៉ាង ដូចវាចាសច្ចៈ វិរតិសច្ចៈ ទិដ្ឋិសច្ចៈ ព្រហ្មណសច្ចៈ បរមត្ថសច្ចៈ អរិយសច្ចៈ តែក្នុងទីនេះព្រះដ៏មានព្រះភាគសំដៅយកវាចាសច្ចៈ ជារសញ៉ាំងប្រយោជន៍ឲ្យសម្រេចលើសរសទាំងឡាយ ។ ជនទាំងឡាយរមែងធ្វើទឹកចិត្តឲ្យប្រព្រឹត្តទៅតាមអំណាចសច្ចៈ រមែងឆ្លងត្រើយនៃជាតិ ជរា មរណៈ បានដោយអានុភាពនៃវាចាសច្ចៈឯណា វាចាសច្ចៈនោះលោកប្រាថ្នាយកហើយ ព្រោះធ្វើបរមត្ថសច្ចៈ ឲ្យជាព្រះនិព្វាន ឬព្រោះធ្វើវិរតិសច្ចៈឲ្យជាខាងក្នុង ដូចពោលថា បុគ្គលត្រាច់ចរទៅកាន់សមុទ្រដោយវាចាសច្ចៈ បុគ្គលសំលាប់ថ្នាំពិសបានដោយសច្ចៈស្តេចទេវៈ រមែងធ្វើទឹកដោះឲ្យហូរចេញដោយសច្ចៈ បណ្ឌិតទាំងឡាយ រមែងតាំង នៅក្នុងសច្ចៈ រួចហើយរមែងប្រាថ្នានូវព្រះនិព្វាន ។

រសទាំងឡាយឯណា ដែលមាននៅក្នុងផែនដី សច្ចៈ រមែងញ៉ាំងប្រយោជន៍ឲ្យសម្រេច លើសរសទាំងឡាយនោះ រសទាំងឡាយ មានរសកើតអំពីឫសឈើជាដើម រមែងបំប៉នសរីរៈធ្វើឲ្យរាងកាយលូតលាស់ចំរើន ហើយនាំមកនូវសេចក្តីសុខដែលលាយដោយ

កិលេស ចំណែករសគឺ វិរតិសច្ចៈ និងវាចាសច្ចៈ រមែងបំប៉នចិត្ត ដោយគុណទាំងឡាយ មានសមថៈ និងវិបស្សនាជាដើម ព្រមទាំង នាំសេចក្តីសុខ ដែលមិនលាយដោយកិលេសមកឲ្យ **វិមុត្តិរស** ឈ្មោះថាញ៉ាំងប្រយោជន៍ឲ្យសម្រេច ព្រោះលោកអ្នកសោយរស នៃវិមុត្តិ អប់រំហើយដោយបរមត្ថសច្ចរស និងសច្ចៈ ដែលឈ្មោះថា ជាអត្ថរស និងធម្មរស ព្រោះអាស្រ័យអត្ថ និងធម៌ ដែលជាឧបាយ ឲ្យលុះបរមត្ថសច្ចរស គឺព្រះនិព្វាន ដោយហេតុនេះ ព្រះដ៏មានព្រះ ភាគទើបត្រាស់ថា សច្ចៈជារសដ៏ប្រសើរ ព្រោះញ៉ាំងប្រយោជន៍ ឲ្យ សម្រេច លើសរសទាំងឡាយ ។

សំនួរតទៅថា អ្នកប្រាជ្ញពោលថា ជីវិតអ្នករស់នៅដូចម្តេច ថាជាជីវិត ប្រសើរបំផុត?

ព្រះដ៏មានព្រះភាគត្រាស់តបអាឡវកយក្សថា អ្នកប្រាជ្ញពោល ថាជីវិតរបស់អ្នករស់នៅដោយបញ្ញា ថាជាជីវិតប្រសើរបំផុត ។

ក្នុងសេចក្តីនេះ លោកអធិប្បាយថា បណ្តាបុគ្គលដែលមាន ភ្នែកខ្វាក់ម្ខាង ខ្វាក់ទាំងពីរ ឬមានភ្នែកល្អទាំងឡាយ, បុគ្គលណាជា

គ្រហស្ថ មានភ្នែកល្អទាំងពីរ ត្រេកអរក្នុងធម៌បដិបត្តិរបស់គ្រហស្ថ មានការឧស្សាហ៍ប្រកបការងារទាំងឡាយ ចូលដល់សរណគមន៍ ត្រេកអរក្នុងការឲ្យទានរក្សាសីលឬ ធ្វើកិច្ចដ៏ក្រៃលែងជាងនេះ គ្រហស្ថនោះឈ្មោះថា ជាអ្នករស់នៅដោយបញ្ញា ជីវិតរបស់គ្រហស្ថដែលរស់នៅដោយបញ្ញា រមែងប្រសើរបំផុត ។

ចំណែកបព្វជិត គប្បីធ្វើកិច្ចរបស់បព្វជិត ពោលគឺតាំងខ្លួននៅក្នុងសីល មិនបង្កសេចក្តីក្តៅក្រហាយមកឲ្យពួកគណៈ ត្រេកអរក្នុងការបដិបត្តិ របស់បព្វជិត មានចិត្តវិសុទ្ធិជាដើមលើសពីនោះទៅទៀត, រស់ដោយបញ្ញា ជីវិតរបស់បព្វជិត អ្នករស់នៅដោយបញ្ញាជាជីវិតប្រសើរបំផុត ។

***កាលព្រះដ៏មានព្រះភាគឆ្លើយបញ្ហារបស់អាឡវកយក្សទាំង ៤ ចប់ហើយ អាឡវកយក្សទូលសួរបញ្ហា ៤ ដែលនៅសល់ថា***

បុគ្គល រមែងឆ្លងឱឃៈ បានដូចម្តេច?
បុគ្គល រមែងឆ្លងអណ្ណវៈ បានដូចម្តេច?
បុគ្គល រមែងកន្លងទុក្ខ បានដូចម្តេច?

បុគ្គល រមែងបរិសុទ្ធិ បានដូចម្តេច?

<u>ព្រះដ៏មានព្រះភាគ ត្រាស់តបថា:</u>

បុគ្គល រមែងឆ្លងឱឃៈ បានដោយសទ្ធា ។

បុគ្គល រមែងឆ្លងអណ្ណវៈ (សមុទ្រ) ដោយសេចក្តីមិនប្រមាទ ។

បុគ្គល រមែងកន្លងទុក្ខបាន ដោយសេចក្តីព្យាយាម ។

បុគ្គល រមែងបរិសុទ្ធិបាន ដោយបញ្ញា ។

ក្នុងបញ្ហាទាំងនោះ <u>លោកអធិប្បាយថា</u> អ្នកណាឆ្លងឱឃៈទាំង ៤ បាន អ្នកនុ៎ះរមែងឆ្លងផុតទឹក គឺសង្សារវដ្តបាន រមែងផុតទុក្ខក្នុងវដ្តបាន ហើយរមែងបរិសុទ្ធិចាកមន្ទិលគឺកិលេសបាន ទាំងនេះព្រោះអាស្រ័យសទ្ធា ព្រោះបុគ្គលមិនមានសទ្ធា រមែងមិនជឿមិនត្រាច់ទៅឆ្លងផុតទឹក ជាអ្នកប្រមាទ ដោយការបណ្តោយចិត្តទៅក្នុងកាមគុណ ៥ ។ រមែងមិនឆ្លងទឹក គឺសង្សារវដ្ត ព្រោះហេតុខ្លួនជំពាក់នៅក្នុងកាមគុណ ៥ មនុស្សខ្ជិលច្រអូសប្រឡូកប្រឡប់ ទៅដោយអកុសលធម៌ទាំងឡាយ រមែងរស់នៅជាទុក្ខ, មនុស្សមិនមានបញ្ញា

មិនដឹងផ្លូវទៅកាន់សេចក្តីបរិសុទ្ធិ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងធម៌ ដែលត្រូវគ្នានឹងសទ្ធា ទើបត្រាស់ថា បុគ្គល រមែងឆ្លងឱឃៈ(អន្លង់)បានដោយសទ្ធា ឯសទ្ធាជាឥន្ទ្រីយ៍នោះ រមែងជាហេតុជិតឲ្យកើតអង្គនៃសោតាបន្ន ៤ យ៉ាងគឺ (សោតាបត្តិយង្គៈ) ចូលទៅគប់រកជាមួយបណ្ឌិត១, ស្តាប់ធម៌របស់លោក១, ពិចារណាធម៌ដែលស្តាប់ហើយដោយឧបាយ១, បដិបត្តិធម៌ដ៏សមគួរដល់ធម៌ គឺបដិបត្តិសតិប្បដ្ឋាន ៤ ដ៏សមគួរ ដល់លោកុត្តរធម៌ ឬបដិបត្តិពោធិ-បក្ខិយធម៌ ដ៏សមគួរដល់លោកុត្តរធម៌ ១ ។

ព្រះដ៏មានព្រះភាគប្រកាស នូវការឆ្លងទិដ្ឋោឃៈរបស់សោតា-បត្តិមគ្គដោយពាក្យថា បុគ្គលរមែងឆ្លងឱឃៈ គឺទិដ្ឋោឃៈ ដោយសទ្ធា ព្រោះហេតុលោកជាព្រះសោតាបន្ន រមែងមិនប្រមាទ រមែងអប់រំកុសលធម៌ទាំងឡាយ ឲ្យជាប់តគ្នាដោយមិនប្រមាទ ត្រេកអរហើយក្នុងសកទាគាមិមគ្គ ទើបឆ្លងភវោឃៈ ដែលសោតាបត្តិមគ្គឆ្លងពុំបាន ត្រូវត្រឡប់មកកាន់លោកនេះម្តង ទៀតព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបប្រកាសការឆ្លងភវោឃៈ ដោយសកទាគាមិមគ្គ ។

ព្រោះហេតុព្រះសកទាគាមី ត្រេកអរហើយក្នុងមគ្គទី ៣ គឺ អនាគាមិមគ្គ អាស្រ័យសេចក្តីព្យាយាម ទើបអាចកន្ទងទុក្ខដែលជាទីតាំងនៃកាមោឃៈ ដែលសកទាគាមិមគ្គ លៈមិនទាន់បាន ព្រោះដូច្នោះព្រះដ៏មានព្រះភាគទើបទ្រង់ប្រកាសការលះកាមោឃៈ ដោយ អនាគាមិមគ្គ ព្រោះហេតុ អនាគាមិមគ្គត្រេកអរក្នុងមគ្គទី ៤ ដែល បរិសុទ្ធចាកកិលេសតែម្យ៉ាង ដោយបញ្ញាដ៏បរិសុទ្ធិព្រោះប្រាសចាក កក់ជ្រាំ គឺកាម លះមន្ទិលដ៏ល្អិត គឺអវិជ្ជោឃៈ ដែលអនាគាមិមគ្គ លះមិនទាន់បាន ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ប្រកាស ការឆ្លងអវិជ្ជោឃៈដោយអរហត្តមគ្គដោយបទថា បុគ្គលបរិសុទ្ធិបាន ដោយបញ្ញា ។

ក្នុងទីបំផុតនៃការទូលសួរបញ្ហា ៨ នេះ អាឡវកយក្សតាំង នៅក្នុងសោតាបត្តិផលបញ្ហាទាំង៨នេះ អាឡវកយក្សធ្លាប់បានស្តាប់ មកអំពីមាតាបិតា ដែលបានរៀនមកអំពីសំណាក់ព្រះពុទ្ធកស្សបៈ តែអាឡវកយក្សភ្លេចពាក្យឆ្លើយអស់រលីង ចាំបានតែពាក្យសួរ ប៉ុណ្ណោះ ទើបបានយកមកទូលសួរ ព្រះដ៏មានព្រះភាគ ដោយគិតថា ព្រះដ៏មានព្រះភាគមិនអាចឆ្លើយបញ្ហានេះបាន ដូចសមណព្រាហ្មណ៍

ឯទៀតដែលខ្លួនធ្លាប់សួរមកហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់មានជ័យជំនះលើអាឡវកយក្សអ្នកមានឫទ្ធិ ជាជ័យជំនះប្រការទី២ ដែលពោលទុកក្នុងព្រះគាថាទីពីរមានដើមថាពាហុំ ដោយប្រការដូច្នេះ ។

កាលអាឡវកយក្ស បានសម្រេចព្រះសោតាបន្នហើយ បានកាន់យកនូវបញ្ហានោះ ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងគាថាថា បុគ្គល រមែង បរិសុទ្ធិបានដោយបញ្ញា មកតាំងជាបញ្ហាសួរព្រះដ៏មានព្រះភាគតទៅទៀត ដោយបដិភាណរបស់ខ្លួនថា បុគ្គលរមែងបានបញ្ញា តើដូចម្ដេច? រមែងរកទ្រព្យបាន តើដូចម្ដេច? រមែងមានឈ្មោះល្បី តើដូចម្ដេច? រមែងចងមិត្តទាំងឡាយបាន តើដូចម្ដេច? បុគ្គលលាចាកលោកនេះទៅកាន់លោកដទៃ រមែងមិនសោកសៅ តើដូចម្ដេច? ។

ព្រះដ៏មានព្រះភាគត្រាស់តបថា បុគ្គលជឿធម៌របស់ព្រះអរហន្តទាំងឡាយ ដើម្បីលុះព្រះនិញ្វន ជាអ្នកមិនប្រមាទ មានបញ្ញាជាគ្រឿងត្រួតពិនិត្យ, ស្ដាប់ដោយល្អ រមែងបានបញ្ញា, បុគ្គលអ្នកមានធុរៈដ៏សមគួរមានសេចក្ដីខ្ជាប់ខ្ជួន រមែងរកទ្រព្យបាន, បុគ្គលមានឈ្មោះល្បីព្រោះសច្ចៈអ្នក ឲ្យរមែងចងមិត្តទុកបាន, អ្នកណាមានសទ្ធា គ្រប់

គ្រង៍ផ្ទះមានធម៌៤ប្រការ គឺ សច្ចៈ ធម្មៈ ធិតិ ចាគៈ អ្នកនុ៎ះលុះចាកលោកនេះទៅហើយ រមែងមិនសោកសៅ ។

កាលព្រះដ៏មានព្រះភាគត្រាស់ដូច្នេះហើយ ទ្រង់ត្រាស់តទៅថា បើហេតុនៃការល្បីឈ្មោះ លើសជាង៍សច្ចៈក្តី ហេតុនៃការចង៍មិត្ត លើសជាង៍ចាគៈក្តី ហេតុនៃការរកទ្រព្យបានលើសជាង៍ធិតិក្តី មាននៅក្នុង៍លោកនេះ អញ្ជើញលោកសួរសមណព្រាហ្មណ៍ជាច្រើនមើលចុះ ។

<u>រួមសេចក្តីថា</u> អាឡវកយក្ស ក្រោយពីបានសួរបញ្ហា៨ ដែលខ្លួនរៀនមកអំពីមាតាបិតា តែភ្លេចពាក្យឆ្លើយអស់ លុះបានជួបនឹង៍ព្រះដ៏មានព្រះភាគ ហើយបានស្តាប់ពាក្យឆ្លើយច្បាស់លាស់ទាល់តែកើតបញ្ញា បានធម្មចក្ខុឃើញធម៌ បានលុះជាព្រះសោតាបន្នហើយ អាស្រ័យពាក្យថា **បញ្ញា** ក្នុង៍ពាក្យឆ្លើយរបស់ព្រះដ៏មានព្រះភាគ បានសួរបញ្ហាថ្មីទៀត តាមដោយបដិភាណរបស់ខ្លួន៦ទៀត រួមជាមួយបញ្ហាដើម ដែលព្រះដ៏មានព្រះភាគ ត្រាស់ឆ្លើយហើយ៨ខ ទើបត្រូវជាបញ្ហា១៤ខ ចំណែកពាក្យអធិប្បាយបញ្ហា៦ខ ក្រោយនេះមានដូចតទៅនេះគឺ:

*បញ្ហាដំបូងសួរថា* បុគ្គល រមែងបានបញ្ញា តើដូចម្តេច?

*ឆ្លើយថា* បុគ្គលជឿធម៌របស់ព្រះអរហន្តទាំងឡាយ ដើម្បីលុះព្រះនិព្វាន ជាអ្នកមិនប្រមាទ មានបញ្ញាជាគ្រឿងធ្លុះបញ្ចាំងស្តាប់ដោយល្អរមែងបានបញ្ញា។

ពាក្យឆ្លើយនេះ *មានអធិប្បាយថា* ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និងសាវ័កទាំងឡាយ ជាព្រះអរហន្ត បានលុះព្រះនិព្វានដោយធម៌ណា មាន ធម៌ដែលប្រកបដោយកាយសុចរិតជាដើម ជាដំបូងប្រកបដោយធម៌ គឺពោធិបក្ខិយធម៌ ក្នុងវេលាតមក បានលុះព្រះនិព្វាន បុគ្គលជឿនូវធម៌ដែលជាហេតុឲ្យដល់នូវនិព្វាននោះដោយសទ្ធា រមែងបានលោកិយបញ្ញា និងលោកុត្តរបញ្ញា តែគេបានបញ្ញាគឺលោកុត្តរបញ្ញា ដោយសទ្ធាតែម្យ៉ាងក៏ទេ គឺព្រោះហេតុគេមានសទ្ធាហើយ ចូលទៅរកព្រះអរហន្តទាំងឡាយ ចូលទៅអង្គុយ ជិតផ្ទៀងសោតាស្តាប់ធម៌របស់លោក ដោយយកចិត្តទុកដាក់តាំងពីដើមដល់អវសាន ទើបគេបានបញ្ញា ព្រោះគេស្តាប់ដោយគោរព គឺតាំងចិត្តស្តាប់តាំងពីដើមដល់ចប់ ទើបឈ្មោះថា ជាអ្នកមិនប្រមាទ ជាអ្នករស់នៅដោយសតិ ឈ្មោះថា ជាអ្នកមានបញ្ញាជាគ្រឿងធ្លុះបញ្ចាំង

ពិនិត្យពិចារណាដោយរៀបរយ យល់ទាំងពាក្យសុភាសិត និងមិនមែនសុភាសិត ទើបបានបញ្ញា ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថាជាអ្នកមិនប្រមាទ មានបញ្ញាជាគ្រឿងផ្ទុះបញ្ចាំង ព្រោះហេតុបុគ្គលដូច្នេះ បដិបត្តិតាមខបដិបត្តិ ប្រព្រឹត្តទៅដើម្បីបានបញ្ញាដោយសទ្ធាយ៉ាងនេះ ទើបព្រមស្តាប់ធម៌ដោយគោរព លុះស្តាប់ហើយទើបចាំធម៌នោះទុក ពិចារណាធម៌ដែលខ្លួនចាំនោះ ទើបធ្វើឲ្យជាក់ច្បាស់នូវបរមត្ថធម៌ជាលំដាប់ ទើបលុះនិព្វានបាន ។

បញ្ហាទី២ សួរថា បុគ្គល រមែងរកទ្រព្យបានតើដូចម្តេច?

ព្រះដ៏មានព្រះភាគត្រាស់ថា បុគ្គលអ្នកមានធុរៈត្រូវធ្វើដោយសមគួរ មានសេចក្តីឧស្សាហ៍ព្យាយាម រមែងរកទ្រព្យបាន ។

មានអធិប្បាយថា អ្នកណាមិនធ្វើប្រយោជន៍ទាំងឡាយ ធ្វើពេលវេលាឲ្យខូច រកឧបាយដ៏សមគួរ ដើម្បីសម្រេចប្រយោជន៍ជាលោកិយៈ និងលោកុត្តរៈ អ្នកនោះឈ្មោះថា **បដិរូបការី** អ្នកមានប្រក្រតីធ្វើរបស់ដែលគួរ ពោលគឺអ្នកមិនដាក់ធុរៈ ដោយអំណាចសេចក្តីព្យាយាមផ្លូវចិត្ត ជាអ្នកដល់ព្រមដោយសេចក្តីឧស្សាហ៍ មិន

រាថយ ដោយអំណាចសេចក្តីព្យាយាមផ្លូវកាយ គឺមិនខ្លាចនឿយលំបាក ដែលត្រូវបានទទួលផ្លូវកាយ មានការឈឺចាប់រោយស្រពន់ជាដើម លោកលើកឧទាហរណ៍ថា បុគ្គល រមែងបានលោកិយ-សម្បត្តិដូចអ្នកបំរើរបស់ចូឡកសេដ្ឋី ដែលរកទ្រព្យបាន២សែនក្នុងពេលមិនយូរ ដោយត្រឹមតែកណ្តុរមួយ ហើយរមែងបានលោកុត្តរសម្បត្តិ ដូចព្រះមហាតិស្សៈជាមនុស្សចាស់ ដូចមានរឿងដំណាលថា:

ព្រះមហាតិស្សៈគិតថា អញនឹងប្រើឥរិយាបថ ដើរ ឈរ អង្គុយ ត្រឹមតែ៣ឥរិយាបថប៉ុណ្ណោះ ដោយលោកមិនដេកសោះ ហើយបានបដិបត្តិតាមការគិតនោះ ក្នុងពេលដែលកើតថីនមិទ្ធ គឺងងុយដេកកើតឡើង លោកធ្វើកម្រងផ្កាឲ្យទទឹក ហើយដាក់លើក្បាលចុះទៅក្នុងទឹកត្រឹមក ប្រឆាំងនឹងថីនមិទ្ធ លោកធ្វើដូច្នេះ ក្នុងពេលកើតថីនមិទ្ធ អស់ពេល១២ឆ្នាំ ទើបបាន លុះព្រះអរហន្ត ត្រូវនឹងពាក្យដែលថា បុគ្គលរកទ្រព្យបានដោយសេចក្តីព្យាយាម គឺមិនខ្ជិលច្រអូស ព្រះមហាថេរបានលោកុត្តរសម្បត្តិ ព្រោះអាស្រ័យ

សេចក្តីព្យាយាម អស់ពេល ១២ឆ្នាំ គ្មាននរណាធ្វើបានដូចព្រះអង្គ វៀរលែងតែអ្នកមានបារមីប៉ុណ្ណោះ ។

បញ្ហាទី៣ អាឡវកយក្សសួរថា បុគ្គលរមែងមានឈ្មោះល្បី តើដូចម្តេច? ព្រះដ៏មានព្រះភាគត្រាស់ថា បុគ្គលមានឈ្មោះល្បី ព្រោះសច្ចៈ ។

<u>អធិប្បាយថា</u> បុគ្គលពោលពាក្យ **សច្ចៈ** រមែងបានទទួលការសរសើរ ដោយការពោលពាក្យសច្ចៈនោះ តែបុគ្គល៣ពួក គឺព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ រមែងល្បីឈ្មោះ ទាំងវាចាសច្ចៈ និងបរមត្ថសច្ចៈ គឺការដល់ព្រះនិព្វានដែលជាបរមត្ថសច្ចៈ រួមសេចក្តី ថាអ្នកណាមានសច្ចៈដែលមិនមែនជាអកុសល អ្នកនុ៎ះរមែងល្បីឈ្មោះ មានអ្នកសរសើរ ។

បញ្ហាទី៤ អាឡវកយក្សទូលសួរថា បុគ្គលរមែងចងមិត្តទុកបានតើយ៉ាងណា? ព្រះដ៏មានព្រះភាគត្រាស់តបថា អ្នកឲ្យរមែងចងមិត្តទុកបាន ។

*មានន័យថា* បុគ្គលឲ្យរបស់អ្វីមួយ ដល់អ្នកដែលគេត្រូវការ បុគ្គលអ្នកឲ្យនោះរមែងចងមេត្រីភាពទុកបាន បានទូវសេចក្តីស្រលាញ់ ជាមិត្តអំពីអ្នកទទួល ។ ម្យ៉ាងទៀតលោកពោលថា អ្នកឲ្យរបស់ដែល គេឲ្យបានដោយកម្រ គឺរបស់ដែលខ្លួនស្រលាញ់ដែលខ្លួនហួងហែង ទុក ដាច់ចិត្តឲ្យដល់អ្នកដទៃ អ្នកនុ៎ះរមែងចងមេត្រីភាពទុកបាន ។ ម្យ៉ាងទៀតសង្គហវត្ថុ៤ មានទាន បិយវាចា អត្ថចរិយា និង សមានត្តតា លោកថាជាការចងមេត្រីភាពទុកបាន ដោយលើកយក ទាន ការឲ្យជាធំ ព្រះដ៏មានព្រះភាគទ្រង់វិសជ្ជនាបញ្ហា ដែលលាយ ដោយលោកិយៈ និងលោកុត្តរៈ៤បញ្ហា ជាទូទៅដល់បព្វជិត និង គ្រហស្ថយ៉ាងនេះ ។

បញ្ហាទី៩ អាឡវកយក្សទូលសួរថា បុគ្គលលះចាកលោកនេះ ទៅកាន់បរលោក ហើយរមែងមិនសោកសៅ តើដូចម្តេច? ព្រះពុទ្ធ អង្គត្រាស់ថាអ្នកមានសទ្ធានៅគ្រប់គ្រងផ្ទះ មានធម៌៤ប្រការគឺ សច្ចៈ ធម្មៈ ធិតិ ចាគៈ អ្នក នុ៎ះឯងលះលោកនេះ ហើយរមែងមិនសោកសៅ ។

សេចក្តីពិតធម៌ទាំង៤ប្រការនេះ ព្រះអដ្ឋកថាចារ្យ អធិប្បាយ ទុក តាំងពីខាងដើមហើយ គឺសច្ចៈ បានដល់វាចាសច្ចៈ និងបរមត្ថ-

សច្ចៈ ធម្មៈ លោកពោលហើយក្នុងសេចក្តីថា បុគ្គលស្តាប់ដោយល្អ រមែងបានបញ្ញា ។

**ធម្មៈ** ក្នុងទីនេះ ជាឈ្មោះរបស់បញ្ញា ដូចបានពោលហើយ ។

**ធិតិ** គឺសេចក្តីព្យាយាម ដែលលោកពោលទុកក្នុងពាក្យថា បុគ្គលរមែងរកទ្រព្យបាន ដោយសេចក្តីព្យាយាម គឺសេចក្តីឧស្សាហ៍ព្យាយាមជា ឈ្មោះរបស់ធិតិនុ៎ះឯង ។

ចំណែក **ចាគៈ** ការលះ លោកពោលទុកហើយក្នុងឃ្លាដែលថា បុគ្គលអ្នកឲ្យរមែងចងមេត្រីទុកបាន ការឲ្យនិងការលះក្នុងទីនេះគឺដូចគ្នា ។

ពាក្យថា អ្នកមានសទ្ធាគ្រប់គ្រងផ្ទះ ក៏លោកបានពោលហើយក្នុងគាថា ថាអ្នកណាជឿធម៌របស់ព្រះអរហន្តទាំងឡាយ ដើម្បីលុះនិព្វាន ពាក្យថា **ជឿ** និពាក្យថា **សទ្ធា** គឺដូចគ្នា អ្នកគ្រប់គ្រងផ្ទះបានដល់អ្នកស្វែងរកកាមគុណទាំង ៥ ឬគ្រហស្ថអ្នកបរិភោគកាម អ្នកប្រកបដោយធម៌៤ប្រការ គឺសច្ចៈ ធម្មៈ ធិតិ និងចាគៈ កាលនៅមានជីវិត រមែងមិនសោសោកកាល បើលះលោកនេះទៅហើយ

ក៏ធម៌៤ប្រការនោះ ហៅផ្សាយៗតាមអដ្ឋកថា ក៏គឺ សច្ចៈ បញ្ញា ព្យាយាម និងចាគៈ ។

កាលព្រះដ៏មានព្រះភាគត្រាស់ដូច្នេះហើយ ព្រះអង្គបានត្រាស់ទៀតថា បើពាក្យរបស់ព្រះអង្គ មិនប្រព្រឹត្តទៅតាមដូច្នេះទេ មានពាក្យដទៃដែលត្រឹមត្រូវជាងនេះ ក៏សូមឲ្យអាឡវកយក្សទៅសួរសមណព្រាហ្មណ៍ឯទៀតចុះ ក្នុងកាលសមណព្រាហ្មណ៍ទាំងនោះប្ដេជ្ញាខ្លួនថា ជាសព្វញ្ញូ ដឹងច្បាស់ នូវរបស់ទាំងពួង ។

កាលព្រះដ៏មានព្រះភាគត្រាស់ដូច្នេះ អាឡវកយក្សទូលតបដោយសេចក្ដី ដែលអ្នកជាព្រះសោតាបន្នគ្រប់គ្នា ត្រូវតែតបយ៉ាងនេះថា ឥឡូវនេះ ខ្ញុំ ព្រះអង្គគប្បីទៅសួរដល់សមណព្រាហ្មណ៍ណាទៀត ថ្ងៃនេះខ្ញុំព្រះអង្គបានជ្រាបច្បាស់ប្រយោជន៍ ដែលប្រព្រឹត្តទៅអនាគតសម្រាប់ខ្ញុំព្រះអង្គហើយ ថ្ងៃនេះខ្ញុំព្រះអង្គបានជ្រាបច្បាស់នូវទក្ខិណេយ្យបុគ្គលដ៏កំពូល ដែលបុគ្គលថ្វាយទានមានផលច្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងស្មើដោយជីវិតតាំងពីថ្ងៃនេះទៅ ។ នេះជាសេចក្ដីក្នុងព្រះត្រៃបិដក ។

ចំណែកសេចក្តីក្នុងអដ្ឋកថា ថា អាឡវកយក្សជ្រាបច្បាស់អំពីប្រាជ្ញារបស់ព្រះដ៏មានព្រះភាគ តាំងពីបានស្តាប់ចំលើយដំបូង រួចហើយៗរឹងរឹតតែបានជ្រាបច្បាស់ឡើង កាលបានស្តាប់ពាក្យឆ្លើយតៗមក ដល់នូវសេចក្តីជឿប្រាកដក្នុងចិត្តដោយគ្មានអ្វីមកប្រែប្រួលបាន កាលយក្សបាននូវសោតាបន្ន ប្រកបដោយសេចក្តីជឿស្អិតនៅក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃយ៉ាងពិតប្រាកដ មិនប្រែប្រួលទោះបីត្រូវប្រហារជីវិត ក៏មិនលះបង់ជំនឿនោះ ឯយក្សដែលបានជាសោតាបន្ន ធ្វើឲ្យយក្សគិតឃើញថា ព្រះដ៏មានព្រះភាគ ស្តេចយាងមកកាន់ទីលំនៅរបស់អញ ក៏ដើម្បីប្រយោជន៍របស់អញដោយពិតគឺព្រះអង្គសង្គ្រោះដល់អញដោយពិត ធ្វើឲ្យយក្សជ្រួតជ្រាបក្នុងព្រះមហាករុណានោះយ៉ាងជ្រាលជ្រៅ ។

ដំណាលគ្នានឹងពេលដែលយក្សពោលគាថាចប់ គឺអរុណរះមានរស្មីប្រាកដ១, សំលេងសាធុការលាន់ឬឡើង១, រាជបុរសបាននាំយកព្រះរាជកុមារមកឲ្យយក្សស៊ី១, កើតឡើងព្រមៗគ្នា ក្នុងខណៈនុ៎ះ ។

ពួករាជបុរស ដែលនាំយកព្រះរាជកុមារបានស្តាប់សំលេងសាធុការនុ៎ះ ក៏គិតថា សំលេងសាធុការនេះ មិនដែលកើតឡើងដល់

អ្នកណាក្រៅអំពីព្រះពុទ្ធជាម្ចាស់ទេ ព្រោះហេតុនោះ ព្រះពុទ្ធជាម្ចាស់ប្រាកដជាស្តេចយាងមកទីនេះប្រាកដហើយៗ តមកពួករាជបុរសបានឃើញព្រះរស្មីរបស់ព្រះពុទ្ធដែលផ្សាយចេញទៅពួកគេ ទើបមិនបានឈប់នៅខាងក្រៅខេត្តរបស់ដើមជ្រៃ ដូចបានធ្លាប់ធ្វើមក គេបានបង្ហួសចូលទៅក្នុង ខេត្តម្ចប់ជ្រៃតែម្តង ទើបបានឃើញយក្សឈរផ្គងអញ្ជលី លុះឃើញហើយ បានពោលនឹងយក្សថា បពិត្រលោកម្ចាស់ ខ្ញុំបាននាំព្រះរាជកុមារនេះមកដើម្បីពលិកម្មចំពោះលោកអញ្ជើញលោកទំពារស៊ីព្រះរាជកុមារនេះ ឬធ្វើដូចម្តេច តាមត្រូវការព្រោះហេតុយក្សបានជាព្រះសោតាបន្ន បានឬពាក្យដូច្នោះ ក៏កើតមានសេចក្តីអៀនខ្មាស ព្រោះថា ព្រះសោតាបន្នមិនហ៊ានកន្លងល្មើសសីល៥ ដែលមានបាណាតិបាតជាដើមឡើយ ។ ដោយត្រង់កាលពួករាជបុរស ពោលពាក្យនេះ ចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគយក្សក៏កើតសេចក្តីអៀនខ្មាសយ៉ាងក្រៃលែង បានលាដៃទៅទទួលព្រះរាជកុមារទុំះមក ហើយបង្អោនព្រះរាជកុមារនេះ ថ្វាយព្រះដ៏មានព្រះភាគក្រាបទូលថា ព្រះរាជាទ្រង់បញ្ជូនព្រះកុមារនេះមក ដើម្បីឲ្យខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គសូមបង្អោនថ្វាយព្រះកុមារនេះ ចំពោះព្រះដ៏មានព្រះភាគ ព្រោះថាព្រះពុទ្ធជាម្ចាស់ទាំងឡាយ,ទ្រង់អនុគ្រោះដល់

សត្វទាំងឡាយ បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន សូមព្រះមានព្រះភាគ ចូរទទួលយកព្រះកុមារនេះ ដើម្បីជាប្រយោជន៍ដើម្បីសេចក្តីសុខដល់ព្រះកុមារផងចុះ។

យក្សក្រាបទូលយ៉ាងនេះហើយ ក៏បានពោលគាថាតទៅទៀតថា ខ្ញុំព្រះអង្គមានចិត្តរីករាយ សូមថ្វាយព្រះកុមារនេះ ដែលមានលក្ខណៈ នៃបុណ្យ១០០មានអវយវៈទាំងពួងបរិបូណ៌ ព្រមដោយអនុព្យញ្ជនៈដល់ព្រះអង្គ បពិត្រព្រះអង្គ អ្នកមានបញ្ញាចក្ខុ សូមព្រះអង្គទទួលព្រះកុមារនេះទុកដើម្បី ប្រយោជន៍ដល់សត្វលោក ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលព្រះកុមារនោះ ទុក ហើយទ្រង់សំដែងគាថាជាគ្រឿងការពារ ដើម្បីជាសិរីមង្គលដល់យក្ស និងព្រះកុមារនោះក៏ពោលគាថា ថា សូមឲ្យព្រះកុមារមានអាយុយឺនយូរដល់ ៣ដង ក្នុងខណៈដែលព្រះដ៏មានព្រះភាគត្រាស់ព្រះគាថា ថា សូមឲ្យព្រះ កុមារ ចូរមានអាយុយឺនយូរ ម្នាលយក្ស សូមឲ្យលោកមានសេចក្តីសុខផងសូមឲ្យលោកទាំងពីរប្រាសចាករោគភ័យ ស្ថិតនៅដើម្បីជាប្រយោជន៍ដល់ សត្វលោក។

កាលនឹងឲ្យព្រះកុមារ ដល់ត្រៃសរណគមន៍ យក្សពោលថា សូមឲ្យព្រះកុមារ ដល់នូវព្រះពុទ្ធជាម្ចាស់ ជាសរណៈ សូមឲ្យព្រះកុមារដល់នូវព្រះ

ធម៌ជាសរណៈ សូមឲ្យព្រះកុមារដល់នូវព្រះសង្ឃជាសរណៈ កាលយក្សពោលដូច្នេះហើយ ព្រះដ៏មានព្រះភាគទ្រង់បញ្ជូនព្រះកុមារឲ្យពួករាជបុរសទាំងឡាយ ព្រមទាំងត្រាស់ថា សូមលោកទាំងឡាយ ចិញ្ចឹមព្រះកុមារនេះទុក កាលបើធំហើយយកមកឲ្យតថាគតវិញ ព្រះកុមារនោះ ទើបមានព្រះនាមថា **ហត្ថកអាឡវកៈ** ព្រោះហេតុទៅអំពីដៃរបស់រាជបុរសទៅកាន់ដៃរបស់យក្ស ចាកអំពីដៃរបស់យក្សទៅកាន់ព្រះហស្តរបស់ព្រះដ៏មានព្រះភាគទៅកាន់ដៃរបស់ព្រះរាជបុរស។ជនទាំងឡាយមានអ្នកស្រែ និងពួកកម្មករធ្វើ

ការនៅក្នុងព្រៃជាដើម បានឃើញរាជបុរស នាំព្រះរាជបុរសត្រឡប់វិញ ព្រោះ

នៅតូចពេកទេដឹង?ពួករាជបុរសពោលថាកុំខ្លាចឡើយតាំងពីថ្ងៃនេះទៅ យើង

ផុតភ័យហើយ ព្រោះព្រះដ៏មានព្រះភាគទ្រង់ស្តេចយាងមកជួយឲ្យផុតភ័យពោលរួចហើយក៏ដំណាល រឿងទាំងអស់ឲ្យបានជ្រាបគ្រប់គ្នា។

ពួកអ្នកក្រុងអាឡវីបានជ្រាបហើយក៏នាំគ្នាត្រេកអរនាំគ្នា បែរមុខទៅខាងទីលំនៅរបស់យក្ស ពោលថា សាធុ សាធុ ព្រមៗគ្នាឯយក្សនោះ កាលនៅមិនទាន់ដល់ពេលអាហារ ក៏បានកាន់បាត្រ និងចីវររបស់ព្រះដ៏មានព្រះ

ភាគ ដែលស្ដេចនឹងយាងចេញទៅបិណ្ឌបាតតាមផ្លូវដំណើរ ស្ដេចយាង ទៅបានពាក់កណ្ដាលផ្លូវ ទើបត្រឡប់ទៅវិញ។

ព្រះដ៏មានព្រះភាគ ស្ដេចយាងចូលទៅបិណ្ឌបាតក្នុងក្រុង លុះទ្រង់សោយព្រះក្រយាររួចហើយ ទ្រង់គង់ប្រថាប់នៅលើបវរអាសនៈ ដែលគេក្រាលទុកនៅក្រោមម្លប់ឈើមួយដើមសម្រាប់ព្រះអង្គ នៅជិតទ្វារនគរព្រះរាជា និងពលរដ្ឋព្រមដោយពួកជនជាច្រើន បានមករួបរួមគ្នាចូលគាល់ព្រះដ៏មានព្រះភាគថ្វាយបង្គំរួចហើយ នាំគ្នាអង្គុយព័ទ្ធជុំវិញព្រះមានព្រះភាគព្រមទាំងក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ទូន្មានយក្ស អ្នកកាចសាហាវ បានជ័យជំនះហើយឬ?ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ក្នុង អាឡវកសូត្រ ឲ្យមហាជនទាំងនោះស្ដាប់ តាំងពីការប្រយុទ្ធគ្នា រហូតដល់ការដោះស្រាយបញ្ហាដែលយក្សទូលសួរ ក្នុងទីបំផុតនៃព្រះធម៌ទេសនា ការត្រាស់ដឹងធម៌មានដល់សត្វ៨៤០០០។

តអំពីនោះ អ្នកនគរក៏ធ្វើទីលំនៅឲ្យដល់យក្សក្នុងទីជិតភពរបស់ស្ដេចវេស្សវណ្ណ ហើយបានធ្វើពលិកម្មដោយផ្កា និងគ្រឿងក្រអូបជាដើមជាប់ជានិច្ច កាលព្រះកុមារចំរើនវ័យ អ្នកនគរក៏បានទូលថា ព្រះអង្គបានអាស្រ័យព្រះដ៏មានព្រះភាគ ទើបបានរស់រានមានជីវិតមកដល់សព្វថ្ងៃនេះ ចូរព្រះអង្គដល់នូវព្រះដ៏មានព្រះភាគជាទីពឹង ចូរចូលទៅអង្គុយជិតព្រះភិក្ខុសង្ឃ

អាឡវកកុមារនោះកាលចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឃ មិនយូរប៉ុន្មាន ក៏បានលុះព្រះអនាគាមីបានរៀនយកនូវព្រះពុទ្ធវចនៈទុកបាន

ទាំងអស់ ជាអ្នកមានឧបាសក៥០០ជាបរិវារ ហើយព្រះដ៏មានព្រះភាគទ្រង់តាំងអាឡវកកុមារទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយហត្ថអាឡវកៈនេះ ជាកំពូលរបស់ឧបាសកនៃតថាគត អ្នកសង្គ្រោះបរិស័ទដោយសង្គហវត្ថុ៤ប្រការ គឺទាន បិយវាចា អត្ថចរិយា និង សមានត្តតា ។

ជាទីបញ្ចាប់អាឡវកសូត្រ ដែលជារឿងរ៉ាវរបស់អាឡវកយក្ស តាមព្រះសូត្រ និងអដ្ឋកថា ដែលលើកយកមកពណ៌នា ប្រកបសេចក្ដីក្នុងបទគាថាទីពីរ ឬពុទ្ធជយមង្គល គាថាទី២ ដែលសំដែងអំពីព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនៈ លើអាឡវកយក្សអ្នកកាចសាហាវឃោឃៅយ៉ាងក្រៃលែង។

ចប់ពុទ្ធជយមង្គលទី២

ជ័យជំនះលើកទី៣

ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើដំរីឈ្មោះនាឡាគីរី

នាឡាគិរឹ គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ។

<u>ប្រែថា</u> ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា

គិរីវរគជា ដ៏ហានក្លាចុះប្រេងព្រេច។

សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច

មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកាំអសនី។

ដោយព្រះពិធីស្រព ស្រោចទឹកអប់គឺបារមី

មេត្តាព្រះជិនស្រី ញ៉ាំងដំរីឲ្យជ្រះថ្លា។

វិជ័យមង្គល ចូរមានដល់អ្នករាល់គ្នា

ដោយតេជៈជ័យា ព្រះឈ្នះនាឡាគិរី។

រឿងដំរីនាឡាគិរីនេះ មានដំណាលទុកក្នុងព្រះត្រៃបិដក គឺក្នុងព្រះ វិន័យបិដក ចុល្លវគ្គ សង្ឃភេទខន្ធកៈថា

សម័យនោះ នៅក្រុងរាជគ្រឹះ មានដំរីមួយឈ្មោះនាឡាគិរីជាដំរីកាចសំលាប់មនុស្ស ពេលនោះ ព្រះទេវទត្តបានចូលទៅកាន់ក្រុងរាជគ្រឹះហើយបានកាន់រោងដំរី បាននិយាយនឹងពួកហ្មដំរីថាយើងត្រូវជាញាតិ នឹងព្រះរាជាអាចតែងតាំងអ្នកដែលនៅក្នុងតំណែងទាប ឲ្យទៅកាន់តំណែងខ្ពស់បានអាច ទាំងបន្ថែមប្រាប់ខែឲ្យបានខ្ពស់ផងដែរម្នាលហ្មដំរី បើដូច្នេះពេលណាសម- ណគោតម ធ្វើដំណើរមកត្រង់កន្លែងនេះ ពេលនោះ ចូរលោក

លែងដំរីនា ឡាគិរីឲ្យដេញព្រេច សមណគោត្តមនោះចុះ ឯពួកហ្មដំរីទទួលពាក្យទេវទត្ត ហើយ លុះថ្ងៃតមកវេលាព្រឹក ព្រះដ៏មានព្រះភាគ ទ្រង់គ្រងអន្តរវាសកៈ កាន់បាត្រនិងចីវរ ស្តេចយាងចូលទៅកាន់ក្រុងរាជគ្រឹះ ព្រមជាមួយភិក្ខុជា ច្រើន ទ្រង់ធ្វើដំណើរមកដល់ច្រកនេះ នាយហ្មដំរីទាំងនោះបានឃើញព្រះដ៏ មានព្រះភាគ ស្តេចយាងចូលមកក្នុងច្រកនេះ ទើបលែងដំរីនាឡាគិរីឲ្យ ចូលទៅក្នុងច្រកនេះដែរ ដំរីឃើញព្រះដ៏មានព្រះភាគស្តេចធ្វើដំណើរមកអំ ពីចម្ងាយ បានលើកប្រមោយឡើងសំកាំងត្រចៀកន្ទុយបះឡើងរត់រ៉េទៅតាម ព្រះដ៏មានព្រះភាគ ពួកភិក្ខុតាមស្តេចមកជាមួយបានឃើញដូច្នោះ ក្រាប ទូលព្រះដ៏មានព្រះភាគឲ្យស្តេចយាងត្រឡប់ទៅវិញដោយទូលថា បពិត្រ ព្រះអង្គដំរីនាឡានេះ កាចណាស់ អាក្រក់ណាស់ សំលាប់មនុស្សអ្នកធ្វើ ដំណើរមកកន្លែងនេះអស់ជាច្រើនសូមព្រះដ៏មានព្រះភាគ ស្តេចយាងត្រឡប់ វិញ សូមព្រះសុគតត្រង់យាងត្រឡប់វិញ។

ព្រះដ៏មានព្រះភាគ ស្តេចពុំបានយាងត្រឡប់វិញឡើយ ទ្រង់ត្រាស់ថាភិក្ខុនាំគ្នាមកចុះ លោកកុំខ្លាចឡើយ សេចក្តីដែលបុគ្គលផ្តាច់ជីវិតតថាគតដោយសេចក្តីព្យាយាមរបស់អ្នកដទៃនោះ មិនមែនជាឋានៈ មិនមែនជាឱកាសឡើយ ព្រោះព្រះតថាគតទាំងឡាយ មិនបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់អ្នកដទៃឡើយ។ភិក្ខុទាំងឡាយ បានក្រាបទូលតឿនឲ្យស្តេចយាង

ត្រលប់វិញ អស់វារៈ ៣ដង តែព្រះដ៏មានព្រះភាគ ត្រាស់ពាក្យដើមដដែល គ្រានោះមនុស្សទាំងឡាយ រត់ឡើងទៅលើប្រាសាទខ្លះ លើផ្ទះរ៉ាង ខ្លះលើដំបូលផ្ទះខ្លះ ពួកមនុស្សទាំងនោះ ពួកដែលគ្មានសទ្ធា មិនជ្រះថ្លាខ្លះ បញ្ញាបានពោលដូច្នេះថា ពួកយើងទាំងឡាយព្រះមហាសមណគោតមមានរូបស្រស់ស្អាត បានត្រូវដំរីព្រេចសម្លាប់ឥឡូវហើយ គ្រានោះព្រះដ៏មានព្រះភាគ ទ្រង់ផ្សាយមេត្តាចិត្តទៅកាន់ដំរីនាឡាគិរី រីឯដំរីនាឡាគិរី លុះបានសម្ផស្សព្រះមេត្តាចិត្តរបស់ព្រះមានព្រះភាគ ហើយក៏ទំលាក់ប្រមោយចុះហើយដើរចូលទៅរកព្រះដ៏មានព្រះភាគ ហើយឈរនៅចំពោះព្រះភក្ត្ររបស់ព្រះដ៏មានព្រះភាគ។

ខណៈនោះ ព្រះដ៏មានព្រះភាគ ទ្រង់លើកព្រះហស្តស្តាំស្ទាបអង្អែលពោងដំរីនាឡាគិរី ទ្រង់ត្រាស់នឹងដំរីដោយព្រះគាថា (ថាម្នាលកុញ្ជរ អ្នកកុំចូលទៅរកព្រះពុទ្ធនាគដោយចិត្តគិតនឹងសម្លាប់ដែលជាហេតុឲ្យកើតទុក្ខអ្នក សម្លាប់ព្រះពុទ្ធនាគ អំពីជាតិនេះទៅកាន់ជាតិអនាគត មិនមានសុគតិឡើយ អ្នកកុំស្រវឹង និងប្រមាទមនុស្សពួកនោះប្រមាទហើយនឹងទៅកាន់សុគតិពុំ

បានឡើយអ្នកឯងហ្នឹងហើយដែលនឹងធ្វើនូវប្រការដែលទៅកាន់សុគតិ ឲ្យទាល់តែបាន។

លំដាប់នោះ ដំរីនាឡាគិរីយកប្រមោយ (ដៃ)ស្ទាបអង្អែលល្អងធុលីព្រះបាទរបស់ព្រះដ៏មានព្រះភាគ ហើយព្រួសដាក់លើសិរសា រួចហើយបន្ទន់ខ្លួន ដកថយចេញទៅមួយរយៈ សំលឹងមកព្រះដ៏មានព្រះភាគ ហើយធ្វើដំណើរទៅកាន់រោងដំរី ហើយបានឈរនៅស្ងៀមក្នុងទីរបស់ខ្លួន ក៏ឯដំរីនាឡាគិរីដែលកាចសាហាវជាសត្វដែលព្រះដ៏មានព្រះភាគ ព្រះពុទ្ធនាគទ្រង់ ទូន្មានហើយដោយប្រការដូច្នេះ។ សម័យនោះឯង មនុស្សទាំងឡាយស្រែក ពោលគាថានេះថា(មនុស្សមួយពួក រមែងហ្វឹកហាត់ដំរី និងសេះដោយ ប្រើដំបងខ្លះ កំណាត់ឈើខ្លះ ដោយកង្វេរខ្លះ ប្រើខ្សែតី ត្មោងខ្លះ ចំណែក ព្រះពុទ្ធជាម្ចាស់អ្នកស្វែងរកគុណដ៏ធំ ទ្រង់ទូន្មានដំរីដោយមិនបាច់ប្រើដំបង ឬរំពាត់ មិនបាច់ប្រើសស្ត្រា)។

តាំងពីថ្ងៃនោះមកមនុស្សទាំងឡាយបានឃើញទោស ទិតៀនព្រះទេវទត្តៈថា ទេវទត្តនេះជាមនុស្សមានបាប គ្មានបុណ្យ ព្រោះព្យាយាមធ្វើគត់ព្រះសមណគោតមអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន លាភសក្ការៈរបស់ទេវទត្តវិនាសចុះអស់ ចំណែករបស់ព្រះដ៏មានព្រះភាគ រុងរឿងចំរើនឡើងនេះជារឿងរ៉ាវរបស់ដំរីនាឡាគិរីតាមដែលមានមកក្នុងព្រះវិន័យបិដក។

តែក្នុងអដ្ឋកថា និយាយពិស្តារជាងនេះ ដូចលើកមកដំណាល មានសេចក្តីដូចតទៅនេះ ពោលគឺកាលព្រះដ៏មានព្រះភាគទ្រង់គង់ប្រថាប់នៅវត្ត

វេឡុវ៉ន ជិតក្រុងរាជគ្រឹះ ព្រះអង្គទ្រង់ប្រារព្ធព្រះអានន្ទដែលថ្វាយជីវិត ដើម្បីជួយព្រះអង្គឲ្យផុតពីគ្រោះថ្នាក់ដំណើរសេចក្តី តាំងពីទេវទត្តបង់គំនុំដោយឈឺចិត្តនឹងព្រះដ៏មានព្រះភាគ កាលដែលប្រើនាយខ្មាន់ធ្នូ៤នាក់ ឲ្យទៅសម្លាប់ព្រះដ៏មានព្រះភាគ តែក៏មិនបានសម្រេចដូចសេចក្តីប្រាថ្នា ទើបរក ឱកាសឡើងទៅលើកំពូលភ្នំគិជ្ឈកូដ ប្រមៀលដុំថ្មទំលាក់ចុះមក ដោយ ប្រាថ្នាចង់ឲ្យដុំថ្មនោះរមៀលមកសង្កត់ព្រះដ៏មានព្រះភាគ តែដុំថ្មនោះ បាន បះខ្ទប់នឹងដុំថ្មឯទៀតបែកខ្ចាត់ខ្ចាយ ធ្វើឲ្យកំទេចថ្មនោះប៉ះខ្ទប់នឹងម្រាមព្រះបាទធ្វើឲ្យព្រះលោហិតពុះពង់ឡើង លោកគ្រូពេទ្យជីវកោមារភត្យ បានវះកាត់លាងជំរះលោហិត ដែលដក់ខន់នោះចេញហើយបានព្យាបាលដាក់ថ្នាំផ្សះថ្វាយព្រះអង្គ តមកទេវទត្តបានចូលទៅជួបព្រះបាទអជាតសត្តុ សូមឲ្យព្រះអង្គបញ្ជាហ្មដំរី ឲ្យដំរីនាឡាគិរីផឹកស្រា១៦ក្អម ខុសប្រក្រតី តាមធម្មតាដំរីនាឡាគិរី ជាព្រះទីនាំងរបស់ព្រះបាទអជាតសត្តុ ហើយធ្លាប់ផឹកស្រាមួយថ្ងៃតែ៨ក្អមតែក្នុងដែលប្រទូសរាយនឹងព្រះដ៏មានព្រះភាគនោះឲ្យដំរីផឹកស្រា១៦ក្អមតាមបញ្ជារបស់ព្រះបាទអជាតសត្តុ ដែលទ្រង់ធ្វើតាមពាក្យញុះញង់របស់ព្រះទេវទត្ត លុះដល់ពេលដែលព្រះដ៏មានព្រះភាគ ស្តេចយាងចេញទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ហ្មដំរីបានលែងដំរីដែលកំពុងតែស្រវឹងស្រាឲ្យ

ដេញព្រេចព្រះអង្គ ពួកភិក្ខុជាបុថុជ្ជន នាំគ្នាភ័យខ្លាចយ៉ាងក្រៃលែង ក្រាបទូលសូមឲ្យព្រះដ៏មានព្រះភាគស្តេចយាងត្រឡប់ទៅវត្តវិញ។

បណ្តាសាវ័កទាំងឡាយ មានព្រះសារីបុត្រជាដើម ម្នាក់ៗក៏ទទួលយកអាសា ដើម្បីទូន្មានដំរីនាឡាគិរី តែព្រះដ៏មានព្រះភាគត្រាស់ថា ការទូន្មានដំរីនាឡាគិរី មិនមែនជាវិស័យរបស់ព្រះសាវ័កគឺជាវិស័យរបស់ព្រះ ពុទ្ធទើបព្រះអង្គត្រង់ហាម, គ្រានោះព្រះអានន្ទទ្រង់មានស្វាមីភ័ក្តចំពោះព្រះសស្តាយ៉ាងក្រៃលែង បានឈានចេញទៅឈរពីខាងមុខព្រះដ៏មានព្រះភាគដោយគិតថា សូមឲ្យដំរីសម្លាប់យើងចុះ ខ្ញុំនឹងបរិច្ចាគជីវិតធ្វងគុណរបស់ព្រះដ៏មាន ព្រះភាគ ដោយស្លាប់ជំនួសព្រះអង្គ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហាមថា អានន្ទចូរចៀសចេញ ព្រះអង្គត្រាស់ហាមដល់៣ដង តែព្រះអានន្ទពុំបាន ចៀសចេញឡើយ លោកនៅតែឈរពាំងពីខាងមុខ ពេលនោះព្រះដ៏មាន ព្រះភាគទ្រង់បង្ក្រាបដំរីនោះបានដោយមេត្តា ពេលនោះមានស្ត្រីមានកូនខ្ចី ម្នាក់ បានឃើញដំរីរត់មកចំក៏ភ័យខ្លាំងបានដាក់កូនចោលរួចរត់យកតែរួចខ្លួន ដំរីដេញស្ត្រីនោះមិនទាន់ បានត្រឡប់មកវិញបានដើរក្រវែលជុំវិញទារកនោះ ឯទារកនោះភិតភ័យយ៉ាងខ្លាំង ព្រះដ៏មានព្រះភាគទ្រង់មានព្រះមហាករុណា ដល់ទារកនោះ ទើបត្រាស់ហៅដំរីនាឡាគិរីឲ្យត្រឡប់មករកព្រះអង្គវិញដោយ ព្រះសូរសៀងដ៏ពីរោះប្រកបដោយព្រះមេត្តា ដំរីនោះបាន

ស្តាប់ហើយ ក៏កើត សេចក្តីខ្មាសបាបត្រឡប់មកក្រាបទៀបព្រះបាទាព្រះដ៏មានព្រះភាគ។

ព្រះដ៏មានព្រះភាគទ្រង់ស្ទាបអង្អែលពោងដំរីនោះ ដោយត្រាស់ទូន្មានថា ម្នាលដំរីនាឡាគិរី អ្នកឯងនេះជាសត្វតិរច្ឆានមានឱកាសបានជួបនឹងតថាគតពេលនេះជាកុសលយ៉ាងក្រៃលែង តថាគតនេះឧបមាដូចស្តេចដំរីដ៏ប្រសើរ ប្រកបដោយគុណរបស់ព្រះអរហន្តជាកំពូលមកុដក្នុងត្រៃលោក ចាប់តាំងពីថ្ងៃនេះទៅអ្នកឯងកុំកាចសាហាវដេញព្រេចមនុស្ស ចូរមានមេត្តា ចូរមានចិត្តសោមនស្សកុំប្រកបដោយទោស ចូរឧស្សាហ៍ចំរើនមេត្តាឲ្យបានច្រើនឡើង អ្នកឯងលុះក្ស័យជិវិតហើយ នឹងបានទៅកើតក្នុងស្ថានសួគ៌ជាប្រាកដ។

ដំរីនាឡាគិរីបានស្តាប់ ក៏មានចិត្តរីករាយសោមនស្ស បើជាតិជាមនុស្សវិញ ក៏នឹងបានសម្រេចព្រះសោតាបត្តិផលជាពុំខាន តែនេះព្រោះជាតិជាតិរច្ឆាន ទើបមិនអាចសម្រេចមគ្គផលបាន មនុស្សទាំងឡាយបានឃើញអានុភាពអស្ចារ្យរបស់ព្រះដ៏មានព្រះភាគដូច្នោះ ក៏កើតបីតិសោមនស្ស នាំគ្នាបាចផ្កា និងគ្រឿងក្រអូបបូជាថ្វាយព្រះអង្គ ខ្លះក៏ដោះគ្រឿងអលង្ការ និងសំពត់ស្បៃស្បង់ដាក់បូជាកំពស់ស្មើនឹងតួដំរីនាឡាគិរី ហើយចាប់តាំងពីថ្ងៃនោះមក ដំរីនោះក៏បានឈ្មោះថា **ដំរីធនបាល**។

កាលដំរីថ្វាយបង្គំត្រឡប់កាន់ទីលំនៅរបស់ខ្លួនហើយ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះថា មនុស្សទាំងឡាយដែលបានឃើញសេចក្តីអស្ចារ្យក្នុងពេលនេះមានច្រើនណាស់ បើតថាគតចូលទៅបិណ្ឌបាត ក៏ត្រូវបានអាហារច្រើនលើសលប់ តែអាហារនោះមិនមែនជាកប្បិយៈ ព្រោះបានមកដោយការសំដែងអានុភាពអស្ចារ្យ ណ្ហើយចុះ តថាគតមិនគប្បីចេញទៅបិណ្ឌបាតឡើយ លុះព្រះអង្គទ្រង់ព្រះតម្រិះដូច្នោះហើយ ក៏ទ្រង់នាំព្រះភិក្ខុសង្ឃត្រឡប់ទៅវត្តវេឡុវ័នវិញ ចំណែកឧបាសក ឧបាសិកា ជាសម្មាទិដ្ឋិ ក៏បបួលគ្នាទៅកាន់វត្តវេឡុវ័ន បានថ្វាយអាហារបិណ្ឌបាតចំពោះព្រះដ៏មានព្រះភាគនិងព្រះភិក្ខុសង្ឃ។

លុះវេលាល្ងាច ពួកភិក្ខុទាំងឡាយ បានមកប្រជុំសន្ទនាគ្នានៅធម្មសភាសាលា អំពីដំណើរដែលព្រះអានន្ទលះបង់ជីវិតដើម្បីការពារព្រះដ៏មានព្រះភាគឲ្យផុតពីគ្រោះថ្នាក់ ពេលនុះព្រះដ៏មានព្រះភាគស្តេចយាងមកត្រាស់

សួរថា តើភិក្ខុទាំងឡាយនិយាយគ្នាពីរឿងអ្វី? ភិក្ខុទាំងឡាយក្រាបទូលថានិយាយគ្នាពីរឿងនេះ ទើបព្រះអង្គត្រាស់ថា ពីអតីតកាល អានន្ទក៏ធ្លាប់លះបង់ជីវិតដើម្បីការពារតថាគតដែរ រួកហើយទ្រង់លើករឿងរ៉ាវក្នុងជាតកមកដំណាលដូចតទៅនេះ៖

ក្នុងអតីតកាលកន្លងទៅហើយ ក្នុងសម័យព្រះបាទព្រហ្មទត្តគ្រងរាជ្យក្នុងក្រុងពារាណសីដោយទសពិធរាជធម៌ មាននាយព្រានម្នាក់មានមុខរបរចិញ្ចឹមជីវិត ជាអ្នកដាក់អន្ទាក់សត្វបក្សីមានផ្ទះនៅមិនឆ្ងាយប៉ុន្មានពីរាជធានីនៅជិតទីក្រុងនោះ មានស្រះធំមួយដេរដាសទៅដោយផ្កាឈូក ពួកបក្សីទាំងឡាយបាននាំគ្នាមកអាស្រ័យនៅទីនោះនាយព្រានបានដឹងដូច្នោះ ក៏មកដាក់អន្ទាក់ជង់នៅទីនោះដែរ គ្រានោះមានស្តេចហង្ស១ ឈ្មោះធតរដ្ឋ មានបរិ វារ៩មឺន ដោយមានហង្សឈ្មោះ សុមុខៈ ជាសេនាបតី ហង្សឈ្មោះសុមុខៈ បាននាំបរិវារ៣នាក់ ទៅកាន់ទីស្រះនោះ ដើម្បីស្វែងរកអាហារ ដែលជាទី រីករាយចិត្ត រួចហើយបានហើរមកកាន់ភ្នំគិជ្ឈកូដ ដែលជាទីលំនៅរបស់ ស្តេចហង្សបាននិយាយរៀបរាប់អំពីស្រះនោះថា ជាទីគួរឲ្យរីករាយនិងបរិ បូណ៌ដោយអាហារ គួរណាស់តែពួកហង្សទាំងឡាយនាំគ្នាទៅកាន់ទីនោះ ដើម្បីស្វែងរកអាហារ ស្តេចហង្សពោលថា ធម្មតាទីណាដែលមានមនុស្ស ចូលចិត្តទៅទីនុះរមែងមានគ្រោះថ្នាក់ដល់ពួកសត្វទាំងឡាយ អ្នកទាំងឡាយ កុំគប្បីទៅកាន់ទីនោះឡើយ រីឯពួកហង្សជាបរិវារបានអង្វរករ ឲ្យស្តេចហង្ស នាំទៅលេងស្រះនោះរឿយៗ ឯស្តេចហង្សគឺជាតួពោធិសត្វ ស៊ូទ្រាំនឹង សេចក្តីអង្វរករពុំបានក៏បាននាំបរិវារទៅលេងស្រះនោះ១ថ្ងៃ ថ្ងៃនោះស្តេច ហង្ស មានសេចក្តីប្រមាទ មិនបានពិចារណាជាមុន ដើរទៅជាន់អន្ទាក់ នាយព្រាន រើបម្រះ

យ៉ាងណាក៏មិនរបូត រើបម្រះខ្លាំង អន្ទាក់នោះរឹតកាន់តែ ខ្លាំងទាល់តែមុនដាច់សាច់ មុតដល់ឆ្អឹងឈាមហូរ ស្តេចហង្សគិតថា បើ អញស្រែក ខ្លាចហង្សទាំងឡាយឬហើយភិតភ័យ នឹងធ្លាក់ទៅក្នុងដីភក់ គិត ដូច្នោះហើយ ក៏ស៊ូទ្រាំអត់ធន់នូវទុក្ខវេទនា រង់ចាំហ្វូងហង្សបរិភោគឲ្យឆ្អែត ស្កប់ស្កល់រៀបរយហើយ ទើបស្រែកឡើង ឯពួកហង្សទាំងអស់ក៏ភិតភ័យនាំ គ្នាស្ទុះស្ទារហើរឡើងសំដៅទៅកាន់ភ្នំគិជ្ឈកូដ ដែលជាទីលំនៅ។

ចំណែកសុមុខៈ សេនាបតីហង្ស គិតថា ប្រហែលជាមានគ្រោះថ្នាក់អ្វីមួយកើតឡើងដល់ស្តេចហង្ស ទើបបានហោះហើរត្រួតរកមើលគ្រប់ចន្លោះមិនឃើញស្តេចហង្ស នៅក្នុងក្បួនដែលហែរនោះ ក៏បានហើរត្រឡប់ទៅក្រោយវិញ លុះទៅដល់ស្រះនោះ ក៏បានឃើញស្តេចហង្សជាប់អន្ទាក់នៅលើដីភក់ បានសោយនូវទុក្ខវេទនា គួរឲ្យអាណិត ហង្សសុមុខៈក៏លួងលោមថា លោកកុំទោមនស្សឡើយ ខ្ញុំនឹងលះបង់ជីវិតស្លាប់ជំនួសលោក មិនឲ្យលោកគ្រោះថ្នាក់ជាដាច់ខាត ពោលរួចហើយ ក៏ទំនៅទីនោះ។

ស្តេចហង្សបានស្តាប់ហើយ ក៏មានចិត្តត្រេកអរ តែបាននិយាយសាកល្បងមើលចិត្តថា ម្នាលសុមុខៈ បរិវាររបស់យើងមានដល់៩មឺន តែគ្មានអ្នកណាអាឡោះអាល័យត្រឡប់មករកយើងទេ ម្នាក់ៗភិតភ័យរត់ចោលយើង

អស់រលីង ចុះខ្លួនលោក មកគិតខ្ញុំធ្វើអី ចូរលោករត់ឲ្យរួចខ្លួនទៅចុះ ព្រោះថា អន្ទាក់នាយព្រានរឹតយើងរើលែងរួច លោកមកនៅកំដរយើងឲ្យបានជាគ្នានោះ តើបានប្រយោជន៍អ្វី? សូមឲ្យលោកប្រញាប់ចេញទៅ កុំឲ្យគ្រោះថ្នាក់ទាន់ បើលោកមិនជឿខ្ញុំទេ លោកមុខជាស្លាប់ជាមួយខ្ញុំមិនខាន។

សុមុខៈសេនាបតី ពោលជាធម្មៈថា(បពិត្រលោកដ៏ចំរើន ខ្ញុំម្ចាស់នេះប្រព្រឹត្តធម្មៈដោយសុចរិត សំលឹងឃើញប្រយោជន៍ដ៏ធំទៅអនាគត ធម្មតាបុគ្គលឆ្លៀវឆ្លាត រមែងគោរពការប្រព្រឹត្តធម៌ ខ្ញុំព្រះអង្គពិចារណាដោយបញ្ញាហើយ ឃើញថាការរក្សាសុចរិតធម៌ រមែងបានផលលុះកាលបានបដិបត្តិធម៌សុចរិតនោះ ដោយហេតុនេះខ្ញុំម្ចាស់ទើបព្រមលះបង់នូវជីវិត ដើម្បីការពារលោក ពុំបានរត់គេចទៅរកសេចក្ដីសុខសាន្តម្នាក់ឯង ខ្ញុំសូមនៅជាមួយលោកខ្ញុំម្ចាស់ពុំខ្លាចនាយព្រានទេ។ ថាហើយក៏ឈរក្នុងទីជិតនឹងស្ដេចហង្សពុំបានរត់ទៅណាទេ។

ខណៈដែលហង្សទាំងពីរសន្ទនាគ្នានោះ នាយព្រានបានឃើញស្ដេចហង្សជាប់អន្ទាក់របស់ខ្លួន ក៏ដើរលបៗចេញមកមិនឲ្យឬសំលេង ហង្សទាំងពីរឃើញនាយព្រានក៏មិនញាប់ញ័រកោតខ្លាច ពុំបានស្រែកយំសោកសៅឡើយ នាយព្រានបានឃើញដូច្នោះ ចំឡែកក្នុងចិត្តទើបសួរថា(ម្នាលលោកទាំងពីរ ពួកហង្សទាំងពួង គេនាំគ្នាហើរទៅអស់ហើយ ហេតុម្ដេចទើបលោក

ទាំងពីរ មិនហើរទៅ? សុមុខៈសេនាបតីពោលថា(ម្នាលនាយព្រាន ស្តេចហង្សជានាយចៅហ្វាយរបស់យើង ជាប់អន្ទាក់របស់អ្នក ហើរទៅមិនរួច) ចំនែកនាយព្រានពោលថា ខ្ញុំនេះនឹកចំឡែកក្នុងចិត្តពេកណាស់ គឺលោកមិនបានជាប់អន្ទាក់របស់យើង ចុះហេតុដូចម្តេច បានជាលោកមកនៅចាំស្តេចហង្ស ម្តេចមិនហើរតាមពួកហង្សទាំងពួងទៅ? សុមុខៈហង្សសេនាបតីពោលថា(ម្នាលនាយព្រាន សូមលោកទុកជីវិតឲ្យយើងចុះ) នាយព្រានពោលថា (យើងមិនត្រូវការជីវិតរបស់លោកទេ ចូរលោកហើរទៅចុះ)។

សុមុខៈសេនាបតីក៏ពោលថា(លោកនាយព្រាន រីឯស្តេចហង្សនេះ ជាចៅហ្វាយនាយរបស់យើង ជាប្រធានរបស់ហង្សទាំងពួង កាលពួកហង្សជាបរិវារនាំគ្នាស្ទុះហើរគេចទៅអស់ យើងជាសេនាបតីមានចិត្តស្វាមីភក្តិចំពោះចៅហ្វាយនាយពុំបានរត់គេចសូម្បីជីវិតរបស់យើងក៏មិនស្តាយ, មានសេចក្តីត្រេកអរលះបង់ជីវិតជំនួសចៅហ្វាយនាយបាន ម្នាលនាយព្រាន សូមលោកដោះលែងស្តេចហង្ស ឲ្យលោកទៅចុះហើយយកជីវិតខ្ញុំម្ចាស់ជំនួសវិញចុះ។

នាយព្រានក៏ពោលថា (ធម្មតាសត្វទាំងឡាយ កាលណាកើតបានរាងកាយមកហើយ គេស្រលាញ់ណាស់ ហើយខ្លាចសេចក្តីស្លាប់ណាស់)កាលណាមានគ្រោះថ្នាក់ ក៏ព្យាយាមរកផ្លូវដោះស្រាយធ្វើយ៉ាងណាឲ្យផុតគ្រោះថ្នាក់ តែចំពោះខ្លួនលោកនេះ មិនខ្លាចសេចក្តីស្លាប់ សុខចិត្តលះបង់ជីវិតប្តូរ

ឲ្យចៅហ្វាយនាយ។ លោកគឺជាបុគ្គលគួរសេពគប់ យើងស្រលាញ់លោក ដែលមានកិតញ្ញូកតវេទីណ្ហើយចុះ យើងទុកជីវិតឲ្យស្តេចហង្សតាមសំណូមពររបស់លោក)ថាហើយនាយព្រាន ក៏ស្រាយអន្ទាក់ពីជើងស្តេចហង្សចេញ យកទឹងលាងជើង និងមុខរបួសឲ្យ ចំណែកស្តេចហង្សក៏បានទទួលសេចក្តីសប្បាយរីករាយដោយអំណាចរបស់មេត្តា។

ចំណែកសុមុខៈសេនាបតី ក៏ពោលនឹងស្តេចហង្សថា បពិត្រលោកដ៏ចំរើននាយព្រាននេះ មានគុណានឹងយើងច្រើនណាស់ យើងគប្បីតបស្នងសងគុណរបស់គេសិន រួចហើយសិមត្រឡប់ទៅកាន់ទៅលំនៅវិញ ស្តេចហង្សបានស្តាប់ក៏យល់ស្រប ទើបពោលនឹងនាយព្រានថា ម្នាលលោក យើងទាំងពីរចង់ធ្ងងគុណលោក សូមលោកនាំយើងទៅកាន់សំណាក់របស់ព្រះចៅពារាណសី លោកនឹងបានរង្វាន់ច្រើន នាយព្រានពោលថា (សូមលោកត្រឡប់ទៅគ្រប់គ្រងបរិវាររបស់លោកចុះ)។ស្តេចហង្សពោធិ៍សត្វពោលថាយើងទាំងពីរតាំងចិត្ត ចង់តបស្នងសងគុណដល់លោក បើលោកនាំយើងចូលទៅក្នុងនគរពេលណា ពេលនោះ លោកនឹងបានលាភច្រើនសូមលោកជឿខ្ញុំចុះ ដូច្នេះសូមលោកនាំយើងទាំងពីរ ចូលទៅក្នុងនគរចុះ។ នាយព្រានបានស្តាប់ហង្សពោលដូច្នោះ ក៏ចាំបាច់ត្រូវតែនាំហង្សទាំងពីរចូលទៅក្នុងព្រះនគរ ដោយដាក់ហង្សនុះឲ្យនៅក្នុងសង្រ្រែកម្ខាងមួយ រួចហើយដាក់ដងវ៉ែ

កវែក ចូលទៅក្នុងព្រះនគរ មហាជនទាំងឡាយបានឃើញនាយព្រានវែក ហង្សមក ក៏ស្រែកហៅគ្នាថា នរណាមិនដែលឃើញស្តេចហង្ស ក៏ចូរមក មើលឲ្យធាប់។

លុះនាយព្រានវែកស្តេចហង្សមកហើយ មនុស្សទាំងឡាយក៏នាំគ្នា មកមើល ស្តេចហង្សយ៉ាងណែនណាន់តាន់តាប់ ព្រោះស្តេចហង្សនោះជាស្តេចហង្ស មាស ទើបមនុស្សរីករាយសប្បាយចិត្ត ចំណែកនាយព្រានវែកហង្សទាំង ពីរ ចូលទៅ សូមចូលគាល់ព្រះរាជា ព្រះបាទព្រហ្មទត្តបានឃើញ ស្តេច ហង្ស មាស ក៏ត្រេកអរ បានព្រះរាជទានភោគទ្រព្យ ដំរី សេះ គោ ក្របី និងពួកបាវ ព្រាវជាច្រើននាយព្រានបានទទួលលាភយ៉ាងច្រើន ព្រោះស្តេច ហង្សដោយ ប្រការដូច្នោះ។

ព្រះចៅក្រុងពារាណសី ទ្រង់មានបដិសណ្ឋារជាមួយស្តេចហង្ស ដោយធម្មសាកច្ឆាជាច្រើន ហើយទ្រង់អញ្ជើញឲ្យស្តេចហង្សនិងសេនាបតី ឡើង អង្គុយលើតាំងមាស ដើម្បីសំដែងធម៌ ស្តេចហង្សក៏សំដែងធម៌ ឲ្យស្តេ ចតាំង នៅក្នុងសីល៥និងទសពិធរាជធម៌ ព្រះចៅពារាណសី ទ្រង់រីករាយ សប្បាយ ព្រះហឫទ័យយ៉ាងក្រៃលែងទ្រង់មានព្រះទ័យចង់ថ្វាយរាជសម្បត្តិ ដល់ស្តេចហង្សមាស តែស្តេចហង្សមាសមិនព្រមទទួល បានថ្វាយបង្គំលាត្រ

ឡប់ទៅ កាន់ភ្នំគិជ្ឈកូដដូចដើមវិញ បន្ទាប់ពីព្រះចៅក្រុងពារណសីទ្រង់ប្រទានពរជ័យ

សិរីសួស្តី។ កាលហង្សទាំងពីរត្រឡប់មកដល់ទីលំនៅ បរិវារទាំងឡាយបានជ្រាបរឿងនុះក៏នាំគ្នាសរសើរសុមុខៈសេនាបតីយ៉ាងច្រើន។

ព្រះសាស្តាលុះទ្រង់ដំណាលរឿងពីអតីតជាតក យ៉ាងនេះហើយក៏ទ្រង់ពោលថា អានន្ទ នឹងបានលះបង់ជីវិតដើម្បីតថាគតតែក្នុងជាតិនេះក៏ ទេ កាលកើតជាសុមុខៈសេនាបតី ក៏បានលះបង់ជីវិតដើម្បីតថាគត ក្នុង កាលកើតជាស្តេចហង្សមាសក្នុងគ្រានោះមកហើយដែរ។ ហើយទ្រង់ប្រជុំ ជាតកថា នាយព្រានក្នុងកាលនោះ បានមកកើតជានាយឆន្នៈ ព្រះចៅពារា-ណសី បានកើតជាព្រះសារីបុត្រ, សុមុខៈជាព្រះអានន្ទ, ចំណែកស្តេចហង្សមាស គឺអង្គអញតថាគតហ្នឹងឯង, ក៏បញ្ចប់រឿងរ៉ាវ ដែលសំដែងអំពី សេចក្តីស្វាមីភក្តិរបស់ព្រះអានន្ទ ដែលទាក់ទងនឹងការលះបង់ជីវិតដើម្បីព្រះដ៏មានព្រះភាគក្នុងគ្រាដែលព្រះទេវទត្តបញ្ជាឲ្យហ្មលែង ដំរីនាឡាគិរីប្រទូសរាយ ចេញព្រេចព្រះពុទ្ធអង្គតែត្រឹមប៉ុណ្ណោះ ចប់មង្គលគាថាទី៣ ដែលសំដែងអំពីជ័យជំនះព្រះដ៏មានព្រះភាគបង្រ្កាបដំរីនាឡាគិរីបានដោយព្រះមេត្តា តែត្រឹមប៉ុណ្ណោះ។

**ចប់ពុទ្ធជយមង្គលទី៣**

ជ័យជំនះលើកទី៤

គាថាទី៤

ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើអង្គុលីមាលចោរ

ឧក្ខិតខគ្គមតិ ហត្ថសុទារុណន្តំ

ធាវន្តិយោជនប ថង្គុលីមាលវន្តំ

ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ។

ប្រែថា ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ

ផ្ចាញ់ចោរអង្គុលីមាល៍ មានកម្រងគឺម្រាមដៃ។

នៃមនុស្សដែលគាត់កាត់ មកដោតចាត់ជាមាល័យ

អង់អាចអំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ។

កាន់ដាវផាវគ្រវី ដេញព្រះមុនីសាស្តាចារ្យ

ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា។

រីជយមង្គល ចូរមានដល់អ្នកពល់គ្នា

ដោយតេជៈជ័យា ព្រះឈ្នះអង្គុលីមាល៍។

រឿងរ៉ាវរបស់អង្គុលីមាលនេះ មានពោលទុកទាំងក្នុងព្រះត្រៃបិដក

និង

អដ្ឋកថា ដែលបានលើកមកពោលប្រកបគ្នាផ្ដើមដោយរឿងរ៉ាវរបស់លោក, មុនដែលមកធ្វើចោរ តើលោកគឺជាអ្នកណា?មានរឿងរ៉ាវដូចម្ដេច? រឿងរ៉ាវត្រង់នេះ មានពោលទុកក្នុងអដ្ឋកថា បបញ្ចសូទនីវគ្គ ដែលកែអង្គុលីមាលសូត្រ តាមពិតឈ្មោះរបស់អង្គុលីមាល តាមព្រះបាលី និងអដ្ឋកថានោះ គឺ **អង្គុលីមាល៍** តែអ្នកស្រុកនាំគ្នាហៅថា **អង្គុលីមាល៍** មកទាល់តែធ្លាប់មាត់ ក្នុងទីនេះសូមសរសេរជា អង្គុលីមាល៍ តាមដែលប្រើជាទូទៅ។

ក្នុងអដ្ឋកថាពោលថា លោកជាបុត្រ នាងមន្តានី ដែលជាភរិយា របស់បុរោហិតនៃព្រះចៅបសេនទិកោសល ក្នុងពេលដែលសម្រាលជាវេលា កណ្ដាលអាធ្រាត្រ និងជាវេលាស្របគ្នានឹងសព្វាវុធទាំងឡាយក្នុងព្រះនគរប្រាកដមានពន្លឺភ្លឺរុងរឿង សូម្បីតែព្រះសែងលំពែង និងព្រះសែងព្រះខ័នរបស់ព្រះចៅបសេនទិកោសល ដែលទុកក្បែរគ្រែព្រះបន្ទំបំភ្លឺរន្ទាលដូច អណ្ដាតភ្លើង ព្រាហ្មណ៍ បុរោហិត ជាបិតា ទើបស្ទុះចេញពីផ្ទះទៅមើល ផ្កាយឃើញថា បុត្ររបស់ខ្លួនកើតដោយរឹក្សរបស់ផ្កាយចោរ ទើបប្រញាប់ ទៅគាល់ព្រះបាទបសេនទិកោសល ក្រាបទូលសួរអំពីសេចក្ដីសុខក្នុងព្រះ បន្ទំ ព្រះចៅបសេនទិកោសលត្រាស់ថា មិនមានសេចក្ដីសុខឡើយ ព្រោះ អាវុធជាមង្គលរបស់ព្រះអង្គ បានភ្លឺទ្រលោមដូចភ្លើង ព្រះអង្គមានការក្រែង កើតភ័យអន្តរាយដល់រាជសម្បត្តិ ឬដល់ជីវិតរបស់ព្រះអង្គ លោកបុរោហិត ក្រាប

ទូលថា សូមព្រះអង្គកុំខ្លាច កុំភ័យអ្វីឡើយអន្តរាយពុំមានដល់ព្រះអង្គ និង រាជសម្បត្តិរបស់ព្រះអង្គឡើយដែលអាវុធទាំងឡាយ ភ្លឺរន្ទាលរុងរឿងដូចអណ្ដាតភ្លើងនោះ ព្រោះថា យប់មិញនោះ មានទារកកើតឡើងនៅផ្ទះទូលបង្គំ អាវុធទាំងអស់នោះ បានភ្លឺឡើងដោយអានុភាគនៃទារកនោះ។

ព្រះរាជាបសេនទិកោសល ត្រាស់សួរថា បើដូច្នោះទារកនោះនឹងទៅជាយ៉ាងម៉េច? បុរោហិតក្រាបទូលថា ទារកនោះក្លាយជាចោរ ព្រះរាជាសួរទៀតថា វាជាចោរប្លន់អ្នកស្រុក ឬជាចោរប្លន់រាជសម្បត្តិ បុរោហិតក្រាប ទូលថា ជាចោរប្លន់អ្នកស្រុក ចោរកម្មចំពោះឯកជន លុះក្រាបទូលដូច្នេះ ហើយមានបំណងចង់ឲ្យព្រះរាជា សព្វព្រះហឫទ័យ ទើបក្រាបទូលសូម ឲ្យយកទារកនុះទៅសំលាប់ចោល ព្រះរាជាត្រាស់ថា ចោរមនុស្សតែម្នាក់ តើវាធ្វើអ្វីកើតប្រៀបដូចស្រូវសាលីមួយក្ដួ នៅកណ្ដាលស្រែដែលមាន ទំហំ មួយពាន់ករីស ព្រោះដូច្នោះ លោកចូរចិញ្ចឹមទារកនោះទុកចុះ ព្រោះហេតុ នោះលោកបុរោហិត ទើបដាក់ឈ្មោះកូនរបស់ខ្លួនថា អហិង្សកុមារ ដែល ប្រែថា កុមារមិនបៀតបៀនគេ ព្រោះហេតុថា អាវុធទាំងឡាយដែលភ្លឺរុង រឿងនោះមិនបានបៀតបៀនអ្នកណាឡើយ។

តមកអហិង្សកុមារ មានវ័យចំរើនធំឡើង មាតាបិតាបានបញ្ជូនឲ្យទៅសិក្សា សិល្បវិទ្យា នៅជាមួយអាចារ្យទិសាបាមោក្ខនៅទីក្រុងតក្កសិលា អហិ

ង្សកុមារនោះ ប្រព្រឹត្តធ្វើខ្លួនបានយ៉ាងល្អ ស្តាប់បង្គាប់ពាក្យទូន្មានរបស់ អាចារ្យមិនឲ្យឃ្នើសចិត្ត អហិង្សកុមារបានជាទីស្រលាញ់របស់អាចារ្យមិន យូរប៉ុន្មាន អាចារ្យចាត់តាំងអហិង្សកុមារឲ្យបំរើផ្ទាល់ជាសិស្សថ្នាក់ខាងក្នុង ឯសិស្សឯទៀតៗជាសិស្សថ្នាក់ខាងក្រៅ ឯសិស្សថ្នាក់ខាងក្រៅទាំងឡាយនាំ គ្នាច្រណែនឫស្យានឹងអហិង្សកុមារ ទើបប្រឹក្សាគ្នា គិតធ្វើយ៉ាងណាឲ្យអហិ-ង្សកុមារបែកចេញពីគ្រូអាចារ្យបាន លុះគិតទៅឃើញថា មិនអាចបំបែកបានដោយងាយឡើយ ព្រោះអហិង្សកុមារជាមនុស្សឆ្លាត មានប្រាជ្ញាលើសពួកយើង យើងមិនអាចញុះញង់បំបែកចេញពីអាចារ្យបានទេ ព្រោះអហិស្សកុ-មារ ជាមនុស្សសំបូរដោយចំណេះដឹង និងសេចក្តីប្រព្រឹត្តល្អ កើតក្នុងត្រកូលខ្ពស់ មិនដឹងថា នឹងរកហេតុអ្វីទៅញុះញង់អាចារ្យឲ្យបែកចិត្តចេញពីអហិង្ស-កុមារបាន។

តែរឿងរបស់មនុស្សអាក្រក់ វារកផ្លូវធ្វើសេចក្តីអាក្រក់ទាល់តែបាន ពួកសិស្សដែលមានចិត្តឫស្យាដូចគ្នា បានរកឧបាយទាល់តែបាន គឺបណ្តាសិស្សទាំងនោះ មានសិស្សម្នាក់មានបញ្ញាបានពោលថា យើងអាចធ្វើឲ្យអ-ហិង្សកុមារបែកចេញពីអាចារ្យបាន ហើយបានបែងគ្នាចែកជា៣ពួក ពួកទី១ នាំគ្នាចូលទៅរកអាចារ្យ នាំគ្នាឈរព្រងើយៗបើអាចារ្យសួរថា តើមានរឿងអ្វី? ពួកនោះត្រូវពោលថា ពួកយើងបានដឹងរឿងមួយកើតឡើងនៅក្នុងផ្ទះ

នេះ បើអាចារ្យសួរថា តើរឿងអ្វី? ត្រូវតបថា ពួកយើងបានដឹងថា អហិង្សកុមារគិតក្បត់នឹងលោកអាចារ្យ លុះអាចារ្យបានឮ ក៏កុហកថា ពួកឯងជាមនុស្សថោកទាប មកកាច់មួលដាក់កូនអញចេញទៅវិញឱ្យឆាប់ កាលពួកទី ១ ចេញទៅហើយ ពួកទី២ទី៣ នាំគ្នាចូលទៅទៀតប្រាប់អាចារ្យដូចរឿង មុនព្រមទាំងប្រាប់ថា បើលោកអាចារ្យមិនជឿទេចូរពិចារណាមើលចុះ អា- ចារ្យបានគិតថា ពួកសិស្សទាំងអស់នេះ ស្រលាញ់អញដែរ ទើបមកប្រាប់ឲ្យបានដឹង បើដូច្នោះចាំបាច់អញត្រូវតែសំលាប់អហិង្សកុមារចោលតែត្រឡប់គិតឃើញថា បើអញសំលាប់អហិង្សកុមារចោល មនុស្សទាំងឡាយក៏ល្បីថាអាចារ្យទិសាបាមោក្ខសំលាប់កូនសិស្សឯង អំណើះតទៅក៏គ្មានអ្នកណា មករៀនសូត្រក្នុងសំណាក់របស់អញ រីឯលាភ សក្ការៈ ក៏ត្រូវដាច់សូន្យ បើដូច្នោះ អញត្រូវតែរកឧបាយឱ្យអ្នកដទៃសំលាប់ជំនួសអញវិញ លុះគិតដូច្នោះហើយ ទើបហៅអហិង្សកុមារមកប្រាប់ថា (កូនឯងរៀនសិល្បៈជិតសម្រេចហើយ ដូច្នេះកូនឯងត្រូវតែសំលាប់មនុស្សឲ្យបាន ១ពាន់នាក់ ទើបសិល្បៈនោះសម្រេច)។

អហិង្សកុមារពោលថា (ខ្ញុំម្ចាស់កើតក្នុងត្រកូលដែលមិនបៀតបៀនអ្នកណា ខ្ញុំម្ចាស់ទើបមិនអាចសំលាប់មនុស្សបានទេ) អាចារ្យពោលថា (បើកូនឯងមិនសំលាប់មនុស្សឲ្យបាន១ពាន់ទេ សិល្បៈក៏មិនបានសម្រេច)អហិ-

*ង្សកុមារគិតថា ពាក្យពោលរបស់អាចារ្យជាសេចក្ដីពិត ដោយសេចក្ដីប្រាថ្នាចង់ឲ្យសម្រេចសិល្បៈទើបធ្វើតាមពាក្យរបស់អាចារ្យ ដោយការចូលទៅកាន់ព្រៃ ព្រមជាមួយអាវុធ៥យ៉ាង ដើម្បីស្ទាក់ចាំសំលាប់មនុស្សដែលចូលមកក្នុងព្រៃខ្លះ ដែលនៅក្នុងព្រៃខ្លះ ដែលចេញពីព្រៃខ្លះ តែកាលសំលាប់មនុស្សរួចហើយ ក៏មិនបានធ្វើអ្វីជាគ្រឿងសំគាល់ បានគ្រាន់តែចំណាំទុកថា សំលាប់រួចហើយបានប៉ុន្មាននាក់ លុះយូរៗទៅក៏ភ្លេច ព្រោះចិត្តរបស់អ្នកធ្វើបាណាតិបាត រមែងរសាប់រសល់មិនខ្ជាប់ខ្ជួន តមកទៀតកាលសំលាប់មនុស្សបាន ទើបកាត់ម្រាមដៃរបស់មនុស្សដែលសំលាប់រួចហើយ ក្នុងម្នាក់ម្រាមដៃ១តែម្រាមដៃនោះធ្លាក់បាត់ទៅម្ដង១ម្ដង២ ទើបមិនអាចកំណត់បានថា សំលាប់មនុស្សបានប៉ុន្មាននាក់ហើយម្ដងនេះ ទើបគេក្រងម្រាមដៃទុកធ្វើជាកួងមាល័យពាក់ទុកនឹងក តមកទើបមនុស្សទាំងឡាយនាំគ្នាហៅថា **អង្គុលីមាលចោរ** <u>ប្រែថា</u> ចោរអ្នកមានម្រាមដៃក្រងជាកួងមាល័យ ។*

*មនុស្សល្អសុទ្ធសាធ ប្រែជាខូចបាន ព្រោះអាចារ្យត្រចៀកស្រាល ខ្វះយោនិសោមនសិការៈ ហើយនឹងសេចក្ដីឫស្យាច្រណែនរបស់មិត្តភ័ក្ដ តែបើតាមពិត សេចក្ដីច្រណែនរបស់សិស្សគ្នាឯងមិនអាចធ្វើអ្វីកើតទេ បើគ្រូកុំធ្វើត្រចៀកស្រាលមានការពិចារណាឲ្យដិតដល់ មានគ្រូបែបនេះគួរឲ្យខ្លាច ធម្ម*

តាគ្រូល្អ ដឹកនាំសិស្សទៅកាន់ឋានសួគ៌ តែលោកគ្រូនេះ បែរជានាំសិស្ស ឲ្យធ្លាក់នរកទៅវិញ ។

កាលអង្គុលីមាលដើរសំលាប់មនុស្សដែលមកក្នុងព្រៃ តមកមិនយូរប៉ុន្មាន មនុស្សទាំងឡាយក៏ខ្លាចរអា មិនមានអ្នកណាហ៊ានចូលទៅក្នុងព្រៃនោះទៀតឡើយ ព្រោះហេតុនោះ អង្គុលីមាល៍ ទើបចេញពីព្រៃក្នុងវេលាយប់ ចូលទៅក្នុងភូមិ គាស់ទ្វារផ្ទះចូលទៅសំលាប់មនុស្ស ដែលកំពុងដេកលក់ ហើយកាត់យកម្រាមដៃ១ ក្នុងមនុស្សម្នាក់ រួចហើយរត់ទៅបាត់ ពួកអ្នកស្រុកក៏ផ្អើលនាំគ្នារត់ទៅជ្រកក្នុងមន្ទីរស្រុក ឯអង្គុលីមាល៍ ក៏ចូលទៅតាមសំលាប់ក្នុងមន្ទីរស្រុកទៀត មនុស្សទាំងឡាយក៏នាំគ្នារត់ទៅជ្រកក្នុងក្រុងសាវត្ថីប្រជាជនទាំងឡាយ ក៏នាំគ្នាចូលទៅក្រាបទូលព្រះរាជាបសេនទិកោសល ចំណែកបុរោហិតបានដឹងរឿងនោះ ក៏យល់ច្បាស់ថា ជាកូនរបស់ខ្លួន ទើបប្រាប់ភរិយាថា ចោរដែលឈ្មោះថា អង្គុលីមាល៍នេះ គឺជាអហិង្សកុមារ ជាកូនរបស់យើងពិតប្រាកដ ព្រះរាជាប្រើទាហានឱ្យទៅចាប់ខ្លួនយកមក តើយើងគិតធ្វើយ៉ាងណា? ភរិយាប្រាប់ឲ្យស្វាមីទៅនាំយកបុត្រមក។ ស្វាមីក៏ពោលថា ខ្ញុំមិនទៅទេ ព្រោះថា ការទុកចិត្តក្នុងមនុស្ស៤ពួក រមែងមិនមាន, ឯមនុស្ស៤ពួក គឺចោរ១ សហាយ១ ព្រះរាជា១ ស្ត្រី១ ។ចំណែកនាងព្រាហ្មណី ជាមាតាដោយសេចក្តីស្នេហាបុត្រក៏ពោលថា បើដូច្នោះខ្ញុំនឹងទៅ

តាមកូនខ្ញុំយកមកវិញ ថាហើយនាងក៏ប្រញាប់ប្រញាល់ធ្វើដំណើរចេញទៅពី ក្រុងសាវត្ថី។

ក្នុងវេលាជិតភ្លឺក្នុងថ្ងៃនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រួតមើលសត្វលោកដោយព្រះញាណ ទ្រង់ឃើញអង្គុលីមាល៍ប្រាកដក្នុងសំណាញ់ព្រះញាណ ទ្រង់ពិចារណាជ្រាបថា(កាលបើតថាគតយាងទៅ សិរីសួស្ដីនឹងមានដល់ចោរនោះ ព្រោះថា កាលបើគេបានស្ដាប់ពាក្យរបស់តថាគតហើយ គេនឹងសូមបួសក្នុងសំណាក់របស់តថាគតហើយបានអភិញ្ញា ៦ ផង តែបើតថាគតមិនទៅទេ គេនឹងសំលាប់មាតាហើយនឹងធ្លាក់ទៅក្នុងអវីចីមហានរក) ដោយហេតុនោះព្រះពុទ្ធអង្គទើបស្ដេចយាងចេញទៅពីក្រុងសាវត្ថី ដើម្បីសង្គ្រោះអង្គុលីមាល៍។

ទាំងអស់ដែលបានលើកមកនេះ ជារឿងដែលមានក្នុងអដ្ឋកថា នៃអង្គុលីមាលសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសកៈ ដែលពោលពីអង្គុលីមាល៍ធ្វើចោរហើយមានសេចក្ដីថាៈ

ក្នុងសម័យដែលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន គ្រានោះក្នុងដែនកោសល មានចោរម្នាក់ឈ្មោះអង្គុលីមាល៍ជាមនុស្សអាក្រក់ជួរជាតិ មានបាតដៃប្រឡាក់ដោយឈាម មានចិត្តសាហាវក្នុងការសំលាប់ វាយដំប្រំធាក់គ្មានចិត្តករុណា ចំពោះសត្វទាំងឡាងឡើយ អង្គុលីមាល៍ចោរនោះ

ធ្វើភូមិឲ្យស្ងាត់ ធ្វើនិគមឲ្យស្ងាត់ ធ្វើជនបទឲ្យស្ងាត់ គេសំលាប់មនុស្ស ហើយ គាត់យកម្រាមដៃដោតក្រងធ្វើជាភួងមាលា គ្រានោះជាវេលាព្រឹកព្រះ ដ៏មានព្រះភាគស្ដេចយាងទៅបិណ្ឌបាតក្នុងនគរសាវត្ថី ក្រោយពីបច្ឆាភត្ត ស្ដេចយាងចេញពីបិណ្ឌបាតហើយស្ដេចទ្រង់រៀបចំទុកដាក់សេនាសនៈ ទ្រង់កាន់បាត្រ និងចីវរ ស្ដេចយាងទៅតាមផ្លូវដែលអង្គុលីមាលចោរ ជ្រកពួន ពួកអ្នកឃ្វាលគោ ពួកឃ្វាលបសុសត្វអ្នកស្រែដែលធ្វើដំណើរបានឃើញព្រះដ៏មានព្រះភាគស្ដេចយាងទៅតាមផ្លូវដែលអង្គុលីមាលចោរពួន ទើបក្រាបទូលមិនឲ្យព្រះដ៏មានព្រះភាគ ស្ដេចយាងទៅតាមផ្លូវនោះ ព្រមទាំងក្រាបទូលថា បពិត្រព្រះសមណៈ ពួកបុរស១០នាក់ក្ដី ២០នាក់ក្ដី ៣០នាក់ក្ដី ៤០នាក់ក្ដី រួមគ្នាជាពួក ជាក្រុមទើបហ៊ានដើរតាមផ្លូវនេះ ពួកបុរសទាំង នោះ ក៏ដល់នូវសេចក្ដីវិនាសជីវិត ព្រោះតែស្នាដៃរបស់អង្គុលីមាលចោរ កាលពួកមនុស្សទាំងឡាយក្រាបទូលដូច្នេះ ព្រះដ៏មានព្រះភាគទ្រង់ស្ងៀម ស្ដេចបានយាងទៅហើយ មនុស្សទាំងនោះ ក៏បានក្រាបទូលអំពីសេចក្ដីកាច សាហាវរបស់ចោរ ក្រាបទូលមិនឲ្យស្ដេចយាងទៅ តាមផ្លូវនោះ ដល់៣ ដង តែព្រះដ៏មានព្រះភាគ ទ្រង់តុណ្ហីភាគ រួចស្ដេចយាងទៅហើយ។

ចំណែកអង្គុលីមាលចោរ បានឃើញព្រះដ៏មានព្រះភាគស្ដេចយាងពីចម្ងាយ ទើបគិតថា គួរឲ្យអស្ចារ្យណាស់ហ្ន៎! មិនធ្លាប់មាន ពួកបុរស១០ នាក់

ក្តី ២០នាក់ក្តី ៣០នាក់ក្តី ៤០នាក់ក្តី រួមគ្នាជាពួកដើរតាមផ្លូវនេះ បុរស ពួកនោះ ក៏ដល់នូវសេចក្តីវិនាសព្រោះស្នាដៃអញ អើចុះសមណៈនេះ ដើរ មកម្នាក់ឯងគ្មានគ្នា ប្រហែលមកសំឡុតអញទេដឹង បើដូច្នោះអញគប្បីសំ លាប់សមណៈនេះចុះ។

កាលអង្គុលីមាលចោរគិតដូច្នោះ ទើបកាន់ដាវចង្រ្កវាត់ដេញតាមព្រះដ៏មានព្រះភាគ ពីខាងព្រះប្រឹស្តាង្គ គ្រានោះព្រះដ៏មានព្រះភាគទ្រង់ បណ្តាលឥទ្ធាភិសង្ខារ ដោយប្រការដែលអង្គុលីមាលចោររត់ដេញតាមទាល់តែអស់កំលាំងក៏មិនអាចរត់ទាន់ព្រះដ៏មានព្រះភាគ ដែលព្រះអង្គយាងតាមធម្មតា គ្រានោះអង្គុលីមាលចោរគិតថា គួរឲ្យអស្ចារ្យណាស់ហ្ន៎! មិនធ្លាប់មានមកពីមុន ព្រោះថាកាលមុន ដំរីពុងរត់ សេះកំពុងរត់ រថកំពុងរត់ម្រឹគកំពុងរត់ អញរត់តាមចាប់បាន តែនេះអញរត់ទាល់តែអស់កំលាំង មិនអានរត់ទាន់សមណៈនេះ ដែលលោកគ្រាន់តែដើរធម្មតា គិតដូច្នេះហើយទើបឈប់ឈរនិយាយនឹងព្រះដ៏មានព្រះភាគថាសមណៈ ចូរឈប់សិនសមណៈ ចូរឈប់សិន។

ព្រះដ៏មានភាគត្រាស់ថា (តថាគតឈប់ហើយ អង្គុលីមាល៍ នៅតែលោកមិនទាន់ឈប់)។គ្រានោះអង្គុលីមាលចោទថា (សមណសក្យបុត្រពួក

នេះ ច្រើនជាមនុស្សនិយាយពិត មានបេ្តជ្ញាពិត តែសមណៈនេះ នៅតែដើរ ទៅត្រឡប់និយាយថា តថាគតឈប់ហើយ អង្គុលីមាល៍នៅតែលោកមិនទាន់ ឈប់ តើរឿងនេះ វាយ៉ាងណា អញគប្បីសួរសមណៈនេះ)។គ្រានោះអង្គុលី មាលចោរ បានក្រាបទូលព្រះដ៏មានព្រះភាគដោយគាថា សេចក្តីថា (ម្នាល សមណៈលោកកំពុងដើរទៅ តែលោកពោលថា យើងឈប់ហើយ លោក នៅមិនឈប់ តែពោលនឹងខ្ញុំដែលជាអ្នកឈប់ហើយ ថាមិនឈប់ទៅវិញ ម្នាលសមណៈខ្ញុំសូមសួរសេចក្តីនេះនឹងលោក ដែលលោកឈប់ហើយនោះ តើយ៉ាងណា?ដែលខ្ញុំមិនទាន់ឈប់ តើយ៉ាងណា?ព្រះដ៏មានព្រះភាគត្រាស់ ថា ម្នាលអង្គុលីមាល៍ តថាគតដាក់អាជ្ញាក្នុងពពួកសព្វសត្វបានហើយ ទើប ឈ្មោះថា ឈប់ហើយគ្រប់កាល។ ចំណែកលោក មិនសង្រួមក្នុងសត្វទាំង ឡាយ ព្រោះដូច្នោះ យើងទើបឈប់ហើយ តែលោកមិនទាន់ឈប់។

អង្គុលីមាល៍ចោរទូលថា(ម្នាលសមណៈ លោកគឺមនុស្សនិងទេវតាបូ ជាហើយ ជាអ្នកស្វែងរកគុណដ៏ធំ មកដល់ព្រៃធំ ដើម្បីសង្គ្រោះដល់ខ្ញុំព្រះ ករុណាអស់កាលដ៏យូរ ខ្ញុំព្រះករុណានឹងប្រព្រឹត្តលះបាប ព្រោះស្តាប់គាថា ដែលប្រកបដោយធម៌របស់លោក។

អង្គុលីមាលចោរ ពោលយ៉ាងនេះ រួចហើយបានទំលាក់ដាវនិងអាវុធទៅក្នុងជ្រោះដ៏ជ្រៅ ដែលមាននៅក្បែរនោះ អង្គុលីមាលចោរ បានថ្វាយ បង្គំព្រះបាទទាំងពីររបស់ព្រះសុគត ហើយបានទូលសូមបព្វជ្ជា នឹងព្រះសុគតក្នុងទីនោះឯង រីឯព្រះពុទ្ធជាម្ចាស់ទ្រង់ប្រកបដោយព្រះមហាករុណាទ្រង់ស្វែងរកគុណដ៏ធំ ព្រះអង្គជាព្រះសាស្តានៃមនុស្សនិងទេវតា បានត្រាស់នឹងអង្គុលីមាល៍ក្នុងខណៈនោះថា (លោក ចូរជាភិក្ខុមកចុះ) នេះឯងជាភិក្ខុ ភាវៈរបស់អង្គុលីមាលចោរនោះ គ្រានោះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ ដោយមានព្រះអង្គុលីមាល៍ជាបច្ឆាសមណៈ ស្តេចចារឹកទៅតាមផ្លូវ ទៅនគរ សាវត្ថីស្តេចចារឹកទៅដោយលំដាប់ បានស្តេចយាងដល់នគរសាវត្ថីហើយ។

ក្នុងសេចក្តីដែលថា ព្រះដ៏មានព្រះភាគទ្រង់ឥទ្ធាភិសង្ខារមិនឲ្យអង្គុលីមាល៍អ្នករត់ពេញកំលាំង ហើយតាមព្រះអង្គដែលធ្វើដំណើរធម្មតាមិនទាន់នោះតាមអដ្ឋកថា លោកពោលថា ព្រះដ៏មានព្រះភាគ ទ្រង់បណ្តាលឲ្យផែនដីនេះ ក្លាយដូចជាកូននៀលគឺប៉ះរអិលហើយទ្រង់បណ្តាលឲ្យផែនដី ជាទីលានធំទូលាយនៅពីខាងមុខ ព្រះដ៏មានព្រះភាគទ្រង់គង់ប្រថាប់នៅចំទីកណ្តាលទីលាននោះ ចំណែកអង្គុលីមាល៍ រត់តាមរឹមខាងលាននោះ ហើយគិតថា អញនឹងដេញតាមចាប់ឲ្យទាន់ ហើយរត់ដេញយ៉ាងពេញកំលាំង ឯព្រះដ៏មានព្រះភាគក៏ប្រាកដ ព្រះអង្គនៅទីបំផុតលានខាងមុខ ចោរអង្គុលី

មាល់ទៅដល់បានតែត្រឹងកណ្តាលប៉ុណ្ណោះ ហើយគេគិតថា នឹងដេញតាម ចាប់ឲ្យទាន់ហើយក៏រត់តទៅ........។

ព្រះដ៏មានព្រះភាគទ្រង់បណ្តាលឲ្យមានជាទឹកខ្វះ ជាភក់ជ្រៅខ្វះ ជាដីរអិលខ្វះ នៅពីខាងមុខអង្គុលីមាល៍ជាប់រហូតចម្ងាយ ៣ យោជន៍ គេមានសេចក្តីនឿយហត់ខ្លាំង ទាល់តែស្ងួតទឹកមាត់មានញើសហូរចេញពីក្លៀកទាំង

សង់ខាង ដោយហេតុនោះ ទើបគេដឹងខ្លួនថា អស្ចារ្យ ដោយតាមព្រះដ៏មានព្រះភាគមិនទាន់។

កាលព្រះដ៏មានព្រះភាគត្រាស់ថា តថាគតឈប់ហើយលោកនៅមិនទាន់ឈប់ ក្នុងអដ្ឋកថា ថា ព្រះដ៏មានព្រះភាគឈប់ពីការបៀតបៀនសត្វទាំងពួងហើយ ដោយមេត្តា ខន្តី បដិសង្ខា (ការពិចារណា)អវិហិង្សា សេ-ចក្តីមិនបៀតបៀន សារាណីយធម៌ (ធម៌ជាគ្រឿងរលឹកដល់គ្នា)។ ចំណែកខ្លួនលោកសំលាប់មនុស្សរាប់ពាន់មិនមានមេត្តា មិនមានខន្តី មិនមានបដិ សង្ខា មិនមានអវិហិង្សា មិនមានសារាណីយធម៌ ព្រោះដូច្នោះ ទើបថាមិន ទាន់ឈប់ ទោះបីលោកឈប់ដោយឥរិយាបថឈរនៅពេលនេះក្តី លោកក៏ ត្រូវរត់ទៅរកនរក តិរច្ឆាន ប្រេត អសុរកាយនៅខាងមុខ កាលអង្គុលីមាល៍ បានស្តាប់ដូច្នោះទើបគិតថា លោកនេះប្រាកដជាព្រះពុទ្ធជាម្ចាស់ ពិតប្រា កដ

ឥឡូវនេះព្រះអង្គស្តេចយាងមកប្រោសអញហើយ (ហេតុនេះទើបក្រាប ទូលថា បពិត្រព្រះសមណៈ លោក គឺទេវតា និងមនុស្សបូជាហើយ លោកជាអ្នកស្វែងរកគុណដ៏ធំ ស្តេចយាងមកកាន់ព្រៃនេះ ដើម្បីសង្គ្រោះខ្ញុំ ព្រះករុណាក្នុងគ្រានេះ ខ្ញុំព្រះករុណានឹងលះបង់នូវបាប ព្រោះបានស្តាប់ ធម៌របស់លោក កាលក្រាបទូលយ៉ាងនេះហើយ ទើបក្រាបទូលសូមបួសក្នុងសំណាក់របស់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះដ៏មានព្រះភាគទ្រង់ឲ្យបួសដោយឯហិភិក្ខុឧបសម្បទា អង្គុលីមាល៍ ក៏បានជាឯហិភិក្ខុ ទ្រទ្រង់បរិក្ខារ៨ ដែលសម្រេចដោយឫទ្ធិ ដែលកើតឡើងអំពីវាសនាបារមី ដែលបានសន្សំទុកពីអតីតៈ ហើយបានតាមព្រះដ៏មានព្រះភាគទៅកាន់វត្តជេតពនចំណែកមាតារបស់អង្គុលីមាល៍ ដែលចេញទៅព្រៃ ដើម្បីទៅនាំបុត្ររបស់ខ្លួន ចូលគាល់ព្រះបាទបសេនទិកោសល កាលមិនបានជួបអង្គុលីមាល៍ ក៏ត្រឡប់ទៅផ្ទះវិញក្នុងថ្ងៃនោះឯង។

ទាំងអស់នេះ ជាសេចក្តីនៅក្នុងអដ្ឋកថា ដល់មកត្រង់នេះ សូមត្រឡប់មកដំណាលរឿង តាមអង្គុលីមាលសូត្រតទៅ ក្នុងព្រះសូត្រពោលថាៈ

បានឮមកថា ព្រះដ៏មានព្រះភាគ ស្តេចត្រឡប់មកប្រថាប់នៅក្នុងវត្តជេតពនជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ក្នុងក្រុងសាវត្ថី ហើយក៏ក្នុងសម័យនោះ ពួកមហាជនមកប្រជុំគ្នានៅមុខទ្វារនៃព្រះរាជវាំងរបស់ព្រះចៅបសេ

នទិកោសល បានស្រែកសូរស័ព្ទទ្រហឹងថា (បពិត្រព្រះសម្មតិទេព ក្នុងនគរព្រះអង្គ មានចោរឈ្មោះអង្គុលីមាល៍ ជាមនុស្សអាក្រក់ជួរជាតិ មានបាតដៃប្រឡាក់ដោយឈាមដក់ចិត្តក្នុងការសំលាប់វាយដំច្រំជាក់ គ្មានចិត្តករុណាចំពោះមនុស្សសត្វទាំងឡាយ អង្គុលីមាលចោរនោះ ធ្វើភូមិឲ្យស្ងាត់ ធ្វើនិគមឲ្យស្ងាត់ ធ្វើជនបទឲ្យស្ងាត់ គេសំលាប់មនុស្សយកម្រាមដៃក្រងជាភួងមាល័យពាក់នឹងក សូមព្រះអង្គកំចាត់វាចោលទៅ។

គ្រានោះព្រះចៅបសេនទិកោសល ស្តេចយាងចេញពីនគរសាវត្ថីដោយក្បួនសេះ ៥០០ ស្តេចបានយាងចូលទៅក្នុងព្រះអារាមតែក្នុងមួយថ្ងៃយាងទៅដោយយានទាល់តែផុតភូមិ ដែលយានទៅលែងរួច ទើបស្តេចចុះពីយាន ធ្វើដំណើរដោយព្រះបាទ ចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ព្រះអង្គបានថ្វាយបង្គំព្រះដ៏មានព្រះភាគរួចហើយទ្រង់គង់ក្នុងទីមួយ

ដ៏សមគួរ ព្រះដ៏មានព្រះភាគបានត្រាស់នឹងព្រះចៅបសេនទិកោសលថា មហាបពិត្រ ព្រះចៅផែនដីមគធៈកំពូលសេនា ទ្រង់ព្រះនាម ពិម្ពិសារ ទ្រង់ធ្វើឲ្យព្រះអង្គខ្វាល់ឬ? ឬថាព្រះចៅលិច្ឆវីក្រុងវេសាលី ឬក៏ថាព្រះចៅផែនដី បដិបក្សដទៃ ធ្វើឲ្យព្រះអង្គខ្វាល់?

*កាលព្រះដ៏មានព្រះភាគត្រាស់សួរដូច្នេះ ព្រះចៅបសេនទិកោសល ក្រាបទូលថា (បពិត្រព្រះអង្គដ៏ចំរើន ព្រះចៅផែនដីមគធៈជាកំពូលសេនា ទ្រង់ព្រះនាម ពិម្ពិសារ មិនបានធ្វើឲ្យទូលព្រះបង្គំខ្វាល់ទេ ឯព្រះចៅលិច្ឆវី ក្រុងវេសាលី ក៏មិនបានធ្វើឲ្យទូលព្រះបង្គំខ្វល់ដែរ ឯព្រះរាជា ជាបដិបក្ស ដទៃ ក៏មិនបានធ្វើឲ្យទូលព្រះបង្គំខ្វាល់ដែរ បពិត្រព្រះអង្គដ៏ចំរើន ក្នុងនគរ របស់ទូលព្រះបង្គំ មានចោរម្នាក់ឈ្មោះអង្គុលីមាហ៍ ជាមនុស្សអាក្រក់ជួរជាតិ មានបាតដៃប្រឡាក់ឈាម ដក់ចិត្តក្នុងការសំលាប់ វាយដំប្រំជាក់ គ្មាន សេចក្ដីករុណាក្នុងមនុស្សសត្វទាំងឡាយ អង្គុលីមាលចោរនោះ ធ្វើភូមិឲ្យ ស្ងាត់ធ្វើ និគមឲ្យស្ងាត់ ធ្វើជនបទឲ្យស្ងាត់គេសំលាប់មនុស្សហើយ គេកាត់ យកម្រាមដៃមកក្រងពាក់នឹងក ទូលព្រះបង្គំនឹងកំចាត់វាចោល។ ព្រះដ៏មាន ព្រះភាគ ត្រាស់ថា (មហាបពិត្រ បើព្រះអង្គបានទតឃើញអង្គុលីមាល៍អ្នក កោរសក់ កោរពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញពីផ្ទះ មកបួសជា បព្វជិត វៀរចាកការសំលាប់សត្វវៀរចាកការលួចទ្រព្យ វៀរចាក ការនិយាយ កុហក ឆាន់ភត្តាហារមួយថ្ងៃតែមួយដង ប្រព្រឹត្តព្រហ្មចរិយៈ តើ មហាបពិត្រ នឹងធ្វើយ៉ាងណាចំពោះគេ)។*

*ព្រះចៅបសេនទិកោសលត្រាស់ថា បពិត្រព្រះអង្គដ៏ចំរើនទូលព្រះ បង្គំ គប្បីថ្វាយបង្គំ គប្បីក្រោកទទួល គប្បីនិមន្តឲ្យឡើងអាសនៈ គប្បីទំនុកបំ*

រុង គេដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជបរិក្ខារ និងគប្បី ចាត់ការ ថែរក្សាគ្រប់គ្រងការពារ ដ៏ប្រកបដោយធម៌ បពិត្រព្រះអង្គដ៏ចំរើន តែអង្គុលីមាលពេលនេះគេជាមនុស្សទ្រុស្តសីល មានបាបធម៌ តើគេមាន សេចក្តីសង្រួមដោយសីលពីកាលណា?។ នេះជាសេចក្តីក្នុងព្រះសូត្រ ដែល ព្រះអដ្ឋកថា កែសេចក្តីត្រង់នេះទុកថា ការដែលព្រះចៅបសេនទិកោសល ទៅគាល់ព្រះដ៏មានព្រះភាគព្រមដោយក្បួនសេះ ៥០០ នោះ ដោយព្រះអង្គមានព្រះតម្រិះថា បើចោរចាញ់ក៏នឹងដេញចាប់បាន បើចោរឈ្នះក៏ទ្រង់ជិះសេះរត់ឲ្យយ៉ាងលឿន ដែលគួរឲ្យសង្ស័យ គឺកាលព្រះអង្គស្តេចទៅចាប់ចោរ ហេតុអ្វី ទើបទៅគាល់ព្រះដ៏មានព្រះភាគមុនព្រះអដ្ឋកថា លោកកែសេចក្តីសង្ស័យទុកថា ព្រះចៅបសេនទិកោសលទ្រង់ខ្លាចចោរមិនបានទ្រង់មានព្រះបំណងនឹងបង្ក្រាបចោរ តែដែលព្រះអង្គទៅ គឺទៅទាំងបង្ខំចិត្ត ខ្លាចត្រូវទិតៀន ដោយហេតុនេះទើបស្តេចយាងទៅគាល់ព្រះដ៏មានព្រះភាគមុនសិន ដោយទ្រង់ត្រិះរិះថា កាលបើព្រះដ៏មានព្រះភាគត្រាស់សួរ អំពីដំណើរយាងមកព្រមដោយកងកំលាំងប្រដាប់អាវុធ ព្រះអង្គក៏ក្រាបទូលព្រះដ៏ មានព្រះភាគឲ្យទ្រង់ជ្រាប ហើយព្រះដ៏មានព្រះភាគក៏ទ្រង់សង្គ្រោះព្រះអង្គ ដោយប្រយោជន៍បច្ចុប្បន្ន រីជ័យជំនះក៏នឹងមានដល់ព្រះអង្គ ពោលគឺ បើព្រះអង្គ មានជ័យជំនះ ព្រះដ៏មានព្រះភាគក៏ទ្រង់អនុញ្ញាតឲ្យព្រះអង្គ យាងទៅតែ បើស្តេ

ចទៅហើយចាញ់ ព្រះដ៏មានព្រះភាគទ្រង់ហាមមិនឲ្យ ស្តេចយាង៍ម ហាជន ក៏ជ្រាបថា ព្រះរាជាស្ដេចចេញទៅចាប់ចោរហើយ តែព្រះដ៏មានព្រះ ភាគ ទ្រង់ហាម កាលបើដូច្នោះព្រះអង្គក៏រួចផុតអំពីពាក្យទិតៀន ព្រះអង្គទ្រង់ ត្រិះរិះយ៉ាងនេះ ទើបស្ដេចយាងទៅគាល់ព្រះដ៏មានព្រះភាគជាមុនសិន។

នេះជាពាក្យអធិប្បាយរបស់ព្រះអដ្ឋកថា ហើយតទៅទៀតជាសេចក្ដីក្នុងព្រះសូត្រៈ

ក៏ក្នុងសម័យនោះ ព្រះអង្គុលីមាល៍ អង្គុយនៅទីមិនឆ្ងាយប៉ុន្មានពីព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគទ្រង់លើកព្រះហស្តស្ដាំចង្អុលត្រាស់ប្រាប់ព្រះចៅបសេនទិកោសលថា (បពិត្រមហារាជនុះហ្នំអង្គុលីមាល៍)។ លំដាប់នោះ ព្រះចៅបសេនទិកោសល មានសេចក្ដីខ្លាច ទ្រង់ញាក់សាច់ព្រឺរោមព្រឺស្បែក ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ព្រះចៅបសេនទិកោសល ទ្រង់ញាប់ញ័រខ្លាច ទើបត្រាស់ថា»សូមមហារាជ កុំខ្លាចឡើយ ការភ័យដែលកើតអំពីអង្គុលីមាហ៍នេះ មិនមានដល់មហាបពិត្រឡើយ. គ្រានោះព្រះចៅ បសេនទិកោសល ទ្រង់រម្ងាប់សេចក្ដីខ្លាចសេចក្ដីញាប់ញ័រ សេចក្ដីព្រឺរោម ព្រឺស្បែកអស់ហើយ ទើបស្ដេចយាងចូលទៅរកព្រះអង្គុលីមាល៍ថា ដល់ទីលំនៅ រួចហើយទ្រង់ត្រាស់នឹងអង្គុលីមាល៍ថា លោកម្ចាស់ដ៏ចំរើនព្រះអង្គុ លី

មាល៍ជាម្ចាស់របស់ខ្ញុំ ព្រះអង្គុលីមាល៍ ថ្វាយព្រះពរថា តើយ៉ាងដូច្នោះ ឬមហារាជ។

ព្រះចៅបសេនទិកោសល ត្រាស់សួរទៀតថា (បិតារបស់លោកម្ចាស់មានគោត្រ ដូចម្តេច? មាតារបស់លោកម្ចាស់មានគោត្រដូចម្តេច? ព្រះអង្គុលីមាល៍ថ្វាយព្រះពរថា "មហាបពិត្រ បិតាឈ្មោះគគ្គៈ មាតាឈ្មោះមន្តានី" ព្រះចៅបសេនទិត្រាស់តទៅថា "លោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ គគ្គ មន្តានីបុត្រ ចូរអភិរម្យចុះ ខ្ញុំព្រះករុណានឹងខ្វល់ខ្វាយ ដើម្បីចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជបរិក្ខារដល់លោកម្ចាស់គគ្គមន្តានីបុត្រចុះ"។

ក៏ក្នុងសម័យនោះ ព្រះអង្គុលីមាល៍ ប្រព្រឹត្តការនៅព្រៃជាវត្តប្រើសំពត់បង្សុកូលជាវត្ត ប្រើត្រៃ៣ជាវត្ត បានថ្វាយព្រះពរព្រះចៅបសេនទិកោសលថា "កុំអីមហារាជ ត្រៃចីវររបស់អត្មាភាពបរិបូណ៌ហើយ"។

ក្នុងរឿងថ្វាយសំពត់នេះ ព្រះអដ្ឋកថាពោលថា ព្រះចៅបសេនទិ-កោសល មិនបានពោលតែមាត់ប៉ុណ្ណោះទេ ទ្រង់បានដោះសំពត់ក្រវាត់ពោះថ្វាយព្រះអង្គុលីមាល៍ផង តែព្រះអង្គុលីមាល៍មិនទទួលព្រោះលោកកាន់យកសំពត់បង្សុកូលជាវត្ត មិនទទួលចីវរពីអ្នកថ្វាយទាំងកាន់យកសំពត់៣ផ្ទាំងជា វត្តផង មិនទទួលសំពត់ពីអ្នកដទៃទៀត ហេតុនោះ ទើបលោកពោលថា "ត្រៃចីវររបស់អាត្មាភាគមានបរិបូណ៌ហើយ"។

តទៅជារឿងរ៉ាវ ដែលដំណាលទុកក្នុងអង្គុលិមាលសូត្រថា គ្រានោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះដ៏មានព្រះភាគដល់កន្លែងប្រថាប់ បានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីមួយដ៏សមគួរ ហើយបានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើនគួរឲ្យអស្ចារ្យណាស់ របស់មិនធ្លាប់មានមកពីមុន ដែលព្រះដ៏មានព្រះភាគទ្រង់ទូន្មានបុគ្គល ដែលគ្មាននរណាអាចទូន្មានបានគ្មាននរណាធ្វើឲ្យស្ងប់បាន គ្មាននរណារលត់បាន តែព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានបាន ធ្វើឲ្យស្ងប់បាន រំលត់បាន ព្រោះថាទូលព្រះបង្គំ ទូន្មានទាល់តែប្រើអាជ្ញា ប្រើសស្ត្រា ប្រើរំពាត់ ដំបង ។ល។ តែព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានបុគ្គលមិនបាច់ប្រើអាជ្ញា មិនបាច់ប្រើ សស្ត្រា ។ល។ បពិត្រព្រះអង្គដ៏ចំរើន ទូលព្រះបង្គំសូមក្រាបថ្វាយបង្គំ ត្រឡប់ទៅវិញឥឡូវនេះ ព្រោះទូលព្រះបង្គំមានភារកិច្ចច្រើនមានករណីយ កិច្ចច្រើន។

ព្រះដ៏មានព្រះភាគត្រាស់ថា "សូមមហាបពិត្រ ចូរជ្រាបនូវកាលដ៏គួរឥឡូវនេះចុះ" លំដាប់នោះ ព្រះបាទបសេនទិកោសលស្តេចក្រោកចាកទីប្រថាប់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចហើយស្តេចចៀសចេញទៅ។

រឿងរ៉ាវរបស់ព្រះអង្គុលិមាល ដែលលើកមកដំណាលទាំងក្នុងព្រះសូត្រ និងព្រះអដ្ឋកថានេះ ជាការនាំមកប្រកបក្នុងពុទ្ធជយមង្គលគាថា ឬ

បទពាហុំ ដែលពោលអំពីជ័យជំនះរបស់ព្រះពុទ្ធ ដែលទ្រង់មានចំពោះអង្គុ-លីមាល៍ចោរ ជាការសំដែងអំពីព្រះពុទ្ធានុភាពរបស់ព្រះពុទ្ធជាម្ចាស់ ដែលគ្មាននរណាប្រៀបស្មើគ្មាន ក្នុងការបង្ក្រាបចោរកាចសាហាវ ដោយមិនបាច់ប្រើសស្ត្រាវុធផ្សេងៗទ្រង់ប្រើតែធម្មាវុធ គឺព្រះមេត្តាប៉ុណ្ណោះ ក្នុងចំនួនជ័យជំនះយ៉ាងសំខាន់៨ដង ជ័យជំនះដែលមានជាមួយអង្គុលីមាល៍ចោរ ជាជ័យជំនះលើកទី២ តែរឿងរ៉ាវរបស់លោកមិនទាន់ចប់ទេ សូមលើកយកមកដំណាលឲ្យចប់ ដើម្បីសំដែងឲ្យជ្រាបថា កម្មដែលអង្គុលីមាល៍ បានសម្លាប់មនុស្សជាច្រើនក្នុងជាតិនេះ តើបានតាមមកឲ្យផលដល់លោកដូចម្ដេចខ្លះ ទាំងនេះសូមដំណាលតាមដែលព្រះអានន្ទបានដំណាលទុក ក្នុងអង្គុលីមាល៍ សូត្រតទៅនេះ។

គ្រានោះ ជាវេលាព្រឹកព្រហាម ព្រះអង្គុលីមាល៍គ្រងអន្តរវាសកៈហើយ កាន់បាត្រ និងចីវរចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីកំពុងដើរបិណ្ឌ-បាតតាមច្រកល្ហកក្នុងក្រុងសាវត្ថី បានឃើញស្ត្រីម្នាក់ទ្រង់គភ៌គ្រប់ខែ លោកមានតម្រិះថា "សត្វទាំងឡាយ រមែងសៅហ្មងហ្ន៎! គ្រានោះព្រះអង្គុលីមាល៍ដើរបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះធ្វើភត្តកិច្ចរួចហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគដល់កន្លែងប្រថាប់ថ្វាយបង្គំហើយ អង្គុយក្នុងទីមួយដ៏សមគួរ

ហើយបានក្រាបទូលរឿងដែលលោកចេញទៅបិណ្ឌបាតបានជួបស្ត្រីទ្រង់គភ៌

គ្រប់ខែនិងសេចក្តីត្រិះរិះរបស់លោក ដែលថា សត្វទាំងឡាយមានសេច- ក្តីសៅហ្មង់ឲ្យព្រះដ៏មានព្រះភាគទ្រង់ជ្រាប។

ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលអង្គុលីមាល៍ បើដូច្នោះចូរលោកចូលទៅរកស្ត្រីនោះ ហើយពោលនឹងស្ត្រីនោះថា ម្នាលប្អូនស្រី តាំងពីយើងកើតមកហើយ បានដឹងថា យើងក្លែងសំលាប់សត្វផ្តាច់ជីវិតសត្វ ពុំមាន. ដោយសច្ចវាចានេះ សូមសិរីសួស្តី ចូរមានដល់អ្នក សូមសិរីសួស្តីចូរមាន ដល់គភ៌របស់អ្នកចុះ។

ព្រះអង្គុលីមាល៍ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើនអាកប្បកិរិយាដូច្នោះ គឺខ្ញុំព្រះករុណាពោលពាក្យកុហក ដោយដឹងខ្លួនជាប្រាកដព្រោះថាខ្ញុំព្រះករុណា ក្លែងសំលាប់សត្វបំបាត់ជីវិតគេច្រើនណាស់។

ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលអង្គុលីមាល៍ បើដូច្នោះចូរលោកចូលទៅរកស្ត្រីនោះ ហើយពោលនឹងស្ត្រីនោះយ៉ាងនេះថា ម្នាលប្អូនស្រី តាំងពីយើងបានកើតហើយក្នុងអរិយជាតិ បានដឹងថាយើងពុំបានក្លែង សំ លាប់សត្វផ្តាច់ជីវិតគេ ដោយសច្ចវាចានេះ សូមសិរីសួស្តី ចូរមានដល់អ្នក សូមសិរីសួស្តី ចូរមានដល់គភ៌របស់អ្នកចុះ។

ព្រះអង្គុលីមាល៍ទទួលព្រះពុទ្ធដីកាពីព្រះដ៏មានព្រះភាគហើយ បានចូលទៅរកស្ត្រីនោះ ដល់ទីលំនៅ ហើយពោលនឹងស្ត្រីនោះថា: ម្នាលប្អូន ស្រី តាំងពីខ្ញុំបានកើតហើយក្នុងអរិយជាតិ ពុំបានក្លែងសំលាប់សត្វ បំបាត់ជី វិតគេឡើយ. ដោយសច្ចវាចានេះ សូមសិរីសួស្តី ចូរមានដល់អ្នកសូមសិរីសួ. ស្តី ចូរមានដល់គភ៌របស់អ្នកចុះ គ្រានោះឯងសិរីសួស្តី បានមានដល់ស្ត្រី នោះ សិរីសួស្តីបានមានដល់គភ៌របស់ស្ត្រីនោះ។

តាមរឿងក្នុងព្រះសូត្រ លោកមិនបានពោលថា ព្រះអង្គុលីមាល៍ ទៅជួបស្ត្រីមានគភ៌គ្រប់ខែ មានសេចក្តីលំបាកយ៉ាងណាលោកគិតថា សត្វទាំងឡាយមានសេចក្តីសៅហ្មងហ្ន៎! តែក្នុងអដ្ឋកថា លោកពោលថា ព្រះអង្គុលីមាល៍ទៅបិណ្ឌបាត ហើយបានជួបស្ត្រីនោះ សំរាលបុត្រមិនចេញ លោកបានឃើញកើតសេចក្តីករុណាដោយអានិសង្សនៃបព្វជ្ជា ទាំងក្នុងកាល

មុនដែលលោកមិនទាន់បានបព្វជ្ជា លោកមិនធ្លាប់មានករុណាដល់អ្នកណាសោះឡើយ មានតែសេចក្តីត្រូវការជីវិតគេប៉ុណ្ណោះ ដូច្នោះកាលលោកកើតករុណាហើយនាំយកសេចក្តីនោះមកក្រាបទូលព្រះដ៏មានព្រះភាគ ឲ្យទ្រង់ជ្រាបព្រះដ៏មានព្រះភាគទ្រង់ប្រដៅ ឲ្យលោកតាំងសច្ចវាចាដល់ស្ត្រីនោះ កាលលោកធ្វើតាមសិរីសួស្តី ក៏កើតមានដល់ស្ត្រីនោះ និងទារកដែលនៅ ក្នុង

គក៏បានសម្រាល ចេញមកបានដោយសុវត្ថិភាគ នេះដោយអំណាច សច្ចវាចា។

សេចក្តីក្នុងព្រះសូត្រមានតទៅទៀតថា គ្រានោះ ព្រះអង្គុលីមាល៍បានគេចចេញអំពីពួកក្រុម ទៅសម្ងំនៅម្នាក់ឯងក្នុងទីស្ងាត់ជាអ្នកមិនប្រមាទមានសេចក្តីព្យាយាម មានខ្លួនបានបញ្ជូនទៅហើយមិនយូរប៉ុន្មាន ក៏ធ្វើឲ្យជាក់ច្បាស់នូវទីបំផុតព្រហ្មចរិយៈ ដែលមិនមានធម៌ឯទៀតក្រៃលែង ជាងដែលកុលបុត្រទាំងឡាយអ្នកចេញចាកផ្ទះមកបួសជាបព្វជិត ត្រូវការបញ្ញាដ៏ក្រៃលែងក្នុងបច្ចុប្បន្ន បានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយបាននៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិន មានឡើយដូច្នេះអង្គុលីមាល៍ បានជាព្រះអរហន្តមួយអង្គ ក្នុងចំនួនព្រះអរ-ហន្តទាំងឡាយ ។

គ្រានោះជាវេលាព្រឹកព្រហាម ព្រះអង្គុលីមាល៍ ស្លៀកស្បង់ហើយៗកាន់បាត្រ និងចីវរ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ក្នុងពេលនោះ ដុំដីកំណាត់ឈើ ដុំថ្ម ដុំក្រួស ដែលបុគ្គលចោលទៅសំដៅអង្គុលីមាល៍តាមផ្លូវផ្សេងៗធ្លាក់ត្រូវកាយព្រះអង្គុលីមាល៍ ត្រូវសិរសាបែកហូរឈាម បាត្រក៏បែកអស់ សង្ឃាដ៏ក៏រហែក បានចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ព្រះដ៏មានព្រះភាគ បានទតឃើញព្រះអង្គុលីមាល៍ដើរមកអំពីឆ្ងាយ ហើយ

បានត្រាស់ថា "លោកចូរអត់ធន់ចុះ ព្រាហ្មណ៍ចូរលោកអត់ធន់ចុះ លោកបានសោយផលកម្ម ដែលជាហេតុឲ្យលោកឆេះក្នុងនរកអស់ឆ្នាំជាច្រើន រហូតរយឆ្នាំ រហូតពាន់ឆ្នាំជាច្រើនឥឡូវគ្រាន់ទទួលផលកម្ម (បន្តិចបន្តួច) ក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះ។

រឿងផលរបស់កម្មនេះ ក្នុងអដ្ឋកថា លោកអធិប្បាយថា កម្មដែលជាឧបបជ្ជវេទនីយកម្ម ដែលឲ្យផលក្នុងជាតិបន្ទាប់ និងអបរាបរិយវេទនីកម្ម ដែលឲ្យផលក្នុងជាតិតៗទៅនោះ គឺលោកកាត់ផ្តាច់អស់ហើយដោយអរហត្តមគ្គ នៅសល់តែទិដ្ឋធម្មវេទនីយកម្ម ដែលត្រូវឲ្យផលដោយក្នុងជាតិនេះប៉ុណ្ណោះ រីឯទិដ្ឋធម្មវេទនីយកម្មនេះ ក៏បានឲ្យផលដល់លោកក្នុងជាតិនេះហើយ គឺឲ្យលោកត្រូវដំបងខ្វះ ដុំដីខ្វះ ដុំថ្មខ្វះ ដុំក្រួសខ្វះ ដែលមនុស្សទាំងឡាយ តាមផ្លូវទាំងសងខាងចោលសំដៅទៅលោកត្រូវសិរសាបែកហូរឈាមជោកខ្លួន បាត្រក៏បែកអស់ សង្ឃាដីក៏រហែកអស់ ព្រះដ៏មានព្រះភាគថា លោកត្រូវសោយផលកម្មដែលលោកធ្វើ ត្រូវទៅឆេះក្នុងនរកអស់កាលយូរតែត្រឹមបច្ចុប្បន្នជាតិនេះប៉ុណ្ណោះព្រោះថា លោកអស់ជីវិត បរនិព្វានទៅលោកក៏មិនកើតទៀត កាលបើមិនកើតទៀត កម្មដែលលោកធ្វើទុកក៏ត្រូវ ជាអហោសិកម្ម។

គ្រានោះ ព្រះអង្គុលីមាល៍ បានទៅក្នុងទីស្ងាត់ សម្ងំសោយវិមុត្តិសុខ បានបញ្ចេញឧទានវាចាក្នុងពេលនោះថា "អ្នកឯណាកាលពីមុនប្រមាទ លុះក្រោយមកអ្នកនុះមិនប្រមាទ គេរមែងញុំាងលោកនេះឲ្យភ្លឺ ដូចព្រះចន្ទ្រដែលផុតស្រលះហើយអំពីពពកដូច្នោះ អ្នកណាធ្វើកម្មដែលជាបាបហើយ រមែងបិទចេញបានដោយកុសល អ្នកនុះរមែងញុំាងលោកនេះឲ្យភ្លឺ ដូចព្រះចន្ទ្រដែលផុតហើយអំពីដុំពពកដូច្នោះ ភិក្ខុឯណានៅជាកម្លោះ រមែងខ្វល់ខ្វាយក្នុងព្រះពុទ្ធសាសនាភិក្ខុនុះ រមែងញុំាងលោកនេះឲ្យភ្លឺស្វាង ដូចព្រះ ចន្ទ្រដែលផុតអំពីដុំពពកដូច្នោះ សូមឲ្យសត្រូវរបស់យើងខ្វល់ខ្វាយក្នុងព្រះពុទ្ធសាសនាចុះ សូមមនុស្សទាំងឡាយដែលជាសត្រូវរបស់យើង ចូរគប់រកសប្បុរស អ្នកបបួលឲ្យគោរពធម៌ចុះ សូមចូរគប់រកសេចក្ដីផូរផង់ គឺខន្តី សេចក្ដីសរសើរ គឺមេត្តាចុះ សូមចូរស្ដាប់ធម៌តាមកាល ចូរធ្វើតាមធម៌នោះ ចុះ អ្នកដែលជាសត្រូវនោះ មិនគប្បីបៀតបៀនយើង ឬអ្នកដទៃឡើយ អ្នក ដល់នូវសេចក្ដីស្ងប់យ៉ាងក្រៃលែង គប្បីរក្សាទុកនូវសត្វដែលខ្លាចយ៉ាងខ្ជាប់ ខ្ជួន អ្នកទប់ទឹក រមែងទប់ទឹកទុកបានជាងឈើ រមែងពត់កូនសរឲ្យត្រង់បាន ជាងឈើរមែងអារឈើឲ្យត្រង់បាន បណ្ឌិត រមែងទូន្មានខ្លួនបាន មនុស្សខ្លះ រមែងហ្វឹកហាត់សត្វដោយដំបងរំពាត់ខ្លះ ដោយជន្ទួញ កង្វេរខ្លះ យើងជា អ្នកដែលព្រះដ៏មានព្រះភាគហ្វឹកហើយ ដោយមិនប្រើសស្ត្រា។

កាលពីមុនយើងមានឈ្មោះអហិង្សក: តែនៅតែបៀតបៀនសត្វ ថ្ងៃនេះយើងមានឈ្មោះស្របនឹងសេចក្តីពិត យើងមិនបៀតបៀនអ្នកណាឡើយ កាលពីមុនយើងជាចោរ ឈ្មោះថាអង្គុលីមាល័ត្រូវកិលេសញាំងញី ដូចជារទឹកធំហូរក្តួចនាំទៅ បានដល់ព្រះពុទ្ធជាម្ចាស់ជាសរណៈហើយកាលពីមុនអញមានដៃប្រឡាក់ឈាម ឈ្មោះអង្គុលីមាល៍ ដល់ព្រះពុទ្ធជាសរណៈ ទើបដកតណ្ហា ដែលកសាងភពចេញ បានអញធ្វើកម្មដែលនាំទៅកាន់ទុគតិទុកជាច្រើន វិបាករបស់កម្មប៉ះពាល់ហើយជាអ្នកមិនមានបំណុលដែលបរិភោគ ភោជនៈ។

ពួកជនពាល មានបញ្ញាថោកទាប រមែងប្រកបនូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញទាំងឡាយ រមែងរក្សាសេចក្តីមិនប្រមាទទុក ដូចទ្រព្យដ៏ប្រសើរបំផុត ហេតុនោះ អ្នកទាំងឡាយចូរកុំប្រកបនូវសេចក្តីប្រមាទ ចូរកុំប្រកបតាមសេចក្តីស្និទ្ធស្នាល ត្រេកអរក្នុងកាម ព្រោះថាអ្នកមិនប្រមាទ រមែង ពិនិត្យ រមែងដល់នូវសេចក្តីសុខដ៏បរិបូណ៌ ដែលយើងមកកាន់ព្រះពុទ្ធសា សនានេះ ជាការមកល្អណាស់ មិនប្រាសចាកប្រយោជន៍ មិនមានការខុស បណ្តាធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ចែកទុកល្អហើយ អញក៏បានចូលដល់ធម៌ដ៏ប្រសើរហើយ ការដែលអញបានចូលដល់ធម៌ដ៏ប្រសើរបំផុតនោះ

ជាការដល់ល្អហើយ មិនប្រាសចាកប្រយោជន៍ មិនមានការខុសវិជ្ជា៣ អញបានលុះហើយ ពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ អញបានធ្វើហើយដូច្នេះ។

ទាំងអស់នេះ ជាពាក្យឧទានរបស់ព្រះអង្គុលីមាល៍ ដែលលោកបញ្ចេញក្នុងខណៈសម្ងំសោយវិមុត្តិសុខ គឺសេចក្ដីសុខដែលកើតអំពីការសណ្ដកផុតអំពីកិលេសទាំងមូល ពាក្យឧទាននេះឃើញថា ដែលឈ្មោះថាសេចក្ដីសុខ មិនមានសេចក្ដីសុខឯណាប្រសើរស្មើវិមុត្តិសុខ គឺសុខដែលសណ្ដក ផុតពីកិលេស អ្នកដែលគ្មានកិលេស រមែងមិនមានទុក្ខ ព្រោះហេតុអ្វី។ ឡើយ ទោះបីកាយរបស់មានទុក្ខធ្ងន់ តែចិត្តរបស់លោកមិនមានទុក្ខទៅតាម កាយ ហេតុនេះ សេចក្ដីមិនមានរោគ គឺកិលេសទើបប្រសើរបំផុត ។

ចប់រឿងអង្គុលីមាល៍ត្រឹមប៉ុណ្ណោះ ចប់ជយមង្គលគាថាដែលព្រះដ៏មានព្រះភាគទ្រង់មានជ័យជំនះ លើអង្គុលីមាល៍ត្រឹមប៉ុណ្ណោះ។

**ចប់ពុទ្ធជយមង្គលទី៤**

ជ័យជំនះលើកទី៥

គាថាទី៥

**ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើនាងចិញ្ចាមាណវិកា**

កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា

ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ

សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ។

<u>ប្រែថា</u> ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រង់ស្ដពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើលពោះ។
យកឈើធ្វើជាកូន ព័ន្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលណោះ ដោយសមាចារពិធី។
រម្ងាប់ពាក្យចណ្ឌាល នាកណ្ដាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី គឺសច្ចំពាក្យសត្យា។
វីជ័យមង្គល ចូរមានដល់អ្នកពល់គ្នា
ដោយតេជៈជ័យា ព្រះសាស្ដាឈ្នះចិញ្ចា។

រឿងនាងចិញ្ចាមាណវិកានេះ មិនឃើញមានមកក្នុងព្រះសូត្រឡើយ ព្រោះហេតុនោះ សូមរៀបរាប់តាមព្រះអដ្ឋកថា ដែលមាននៅក្នុងអដ្ឋកថាធម្មបទ ដែលមានសេចក្ដីថាៈ

សម័យមួយព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធរឿងនាងចិញ្ចាមាណវិកាឲ្យជាហេតុ ត្រាស់រឿងនេះថា ក្នុងបឋមពោធិកាល គឺក្នុងកាលដែលព្រះដ៏មានព្រះភាគដែលព្រះអង្គទើបនឹងត្រាស់ដឹងពីដំបូងនោះ ព្រះអង្គមានសាវ័កជាច្រើន ទាំងសាវ័កដែលជាមនុស្ស និងទេ-

វតា ទាំងជាព្រះអរិយៈទាំងបុថុជ្ជន កាលបើព្រះកិត្តិគុណរបស់ព្រះដ៏មានព្រះភាគល្បីខ្ចរខ្ចាយទៅឆ្ងាយ លាភសក្ការៈក៏កើតឡើងច្រើន ពួកអន្យតិរ្ថីយ៍ក៏វិនាសសាបសូន្យលាភសក្ការៈអស់រលីងនាំគ្នាទៅឈរតាមថ្នល់ស្រែកសុំថា "ព្រះសមណគោតមមិនមែនជាព្រះពុទ្ធ តែម្នាក់ឯងទេ ឯយើងក៏ជាព្រះពុទ្ធដែរ ទានដែលថ្វាយដល់ព្រះសមណៈគោតមនោះឬមានផលច្រើន? ឯទានដែលថ្វាយដល់ពួកយើងមានផលច្រើនដូចគ្នា លោកទាំងឡាយចូរឲ្យទានដល់ពួកយើងខ្លះផង ចូរធ្វើសក្ការបូជាដល់យើងខ្លះផង។តែក៏នៅតែមិនបានលាភសក្ការៈ លុះមិនបានដូច្នោះ ក៏ប្រជុំគ្នាជាសម្ងាត់ គិតធ្វើយ៉ាងណាឲ្យមានសេចក្តីវិនាសកើតឡើង ដល់ព្រះដ៏មានព្រះភាគ ដែលជាហេតុឲ្យព្រះ ដ៏មានព្រះភាគវិនាស ចាកលាភសក្ការៈ។

គ្រានោះមាននាងបរិព្វាជិកា រូបស្អាតដូចទេពអប្សរា.ម្នាក់ឈ្មោះចិញ្ចាមាណវិកា, តិរ្ថីយ៍ម្នាក់មានយោបល់ គិតប្រើឲ្យនាងចិញ្ចាមាណវិកា ដើរតួក្នុងការទំលាយលាភសក្ការៈរបស់ព្រះដ៏មានព្រះភាគ។ អង្គប្រជុំទាំងមូលក៏យល់ស្រប ដូច្នោះកាលនាងទៅកាន់អារាមរបស់ពួកតិរ្ថីយ៍នាងថ្វាយបង្គំហើយនៅឈរ ឯពួកតិរ្ថីយ៍មិនស្តីរក នាងក៏សួរអំពីកំហុសដែលធ្វើឲ្យពួកតិរ្ថីយ៍ មិននិយាយរកដល់ ៣ ដង ពួកតិរ្ថីយ៍ទើបនិយាយរឿងដែលពួកខ្លួនវិនាសចាក

លាភសក្ការៈ ព្រោះតែព្រះដ៏មានព្រះភាគ ឲ្យនាងស្តាប់ នាងស្តាប់ហើយក៏សួរថា តើឲ្យនាងខ្ញុំជួយយ៉ាងណា? ពួកតិរ្ថិយ៍ក៏ពោលថា បើនាងចង់ឲ្យពួកយើងបានសេចក្តីសុខ ជួយធ្វើយ៉ាងណាឲ្យព្រះដ៏មានព្រះភាគខូចឈ្មោះឲ្យវិនាសចាកលាភសក្ការៈ នាងក៏ទទួលភារៈជួយធ្វើឲ្យព្រះដ៏មានព្រះភាគខូចឈ្មោះ សូមពួកតិរ្ថិយ៍ទាំងឡាយកុំព្រួយឡើយ នាងទទួលយកអាសា។

តាំងពីថ្ងៃ ដែលនាងទទួលយកអាសាដល់ពួកអន្យតិរ្ថិយ៍រួចហើយ នាងចិញ្ចាមាណវិកាក៏ធ្វើដំណើរទៅកាន់វត្តជេតពនរាល់ថ្ងៃគឺទៅក្នុងពេលដែល

អ្នកនគរសាវត្ថី នាំគ្នាទៅស្តាប់ធម៌ហើយត្រឡប់ទៅផ្ទះវិញ, ពេលនោះនាងចិញ្ចាមាណវិកា ក៏ដណ្តប់សំពត់ពណ៌ស្វាបកំភេម កាន់យកគ្រឿងក្រអូប និងផ្កា ធ្វើដំណើរប្រាសទិសគ្នាឆ្ពោះទៅកាន់វត្តជេតពន កាលមនុស្សទាំងឡាយសួរថា ទៅណា? នាងក៏ពោលថា ទៅណា មកណា មិនមែនជាការងារ អ្នកឯងទេ!ទៅណា មកណា គឺជាការងាររបស់ខ្ញុំ រួចហើយនាងក៏ធ្វើដំណើរហួសទៅដេកក្នុងអារាមរបស់ពួកតិរ្ថិយ៍ ដែលនៅជិតៗនឹងវត្តជេតពន លុះព្រឹកឡើង កាលឧបាសក ឧបាសិកា ចេញពីភូមិធ្វើដំណើរទៅកាន់វត្តជេតពន ដើម្បីថ្វាយបង្គំព្រះដ៏មានព្រះភាគ នាងក៏ធ្វើដំណើរប្រាសទិសចូលទៅក្នុងនគរ ក្នុងខណៈដែលមនុស្សទាំងឡាយដើរចេញពីនគរ ឯវត្តជេតពន

នោះនៅក្រៅព្រះនគរសាវត្ថី កាលអ្នកស្រុកសួរនាងថា តើនាងអញ្ជើញមកពីណា? នាងក៏ថា មិនមែនជាការងាររបស់អ្នកឯងទេ ! កុំចង់ដឹងអី!នាងធ្វើដូច្នេះ អស់ពេល២,៣ខែ ក៏ត្រូវគេសួរអស់ពេល ២,៣ខែនាងក៏មិនប្រាប់ អស់ពេល២,៣ខែ ក្រោយមកទើបនាងប្រាប់ថា ទៅដេកនៅក្នុងគន្ធកុដិរបស់ព្រះដ៏មានព្រះភាគនៅវត្តជេតពន មនុស្សទាំងឡាយ ក៏កើតសង្ស័យថា តើជាការពិតឬទេ? លុះកន្លងទៅបាន៣,៤ខែ នាងក៏យកសំពត់កណ្តាចមករុំពោះធ្វើដូចជានាងមានគភ៌ មនុស្សទាំងឡាយដែលល្ងង់ខ្លៅ ក៏យល់ថា នាងមានគភ៌ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះកន្លងបាន៨,៩ខែ នាងបានយកឈើមូលៗ ចងភ្ជាប់នឹងពោះ ហើយដណ្តប់សំពត់ឲ្យមនុស្សយកឈើដំដៃ ដំជើងឲ្យហើម ធ្វើដូចមនុស្សគ្រប់ខែ ជិតសម្រាលៗ

ថ្ងៃមួយ កាលព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់សំដែងធម៌ទេសនាក្នុងវេលាល្ងាច នាងបានចូលទៅឈរនៅចំពោះព្រះភ័ក្ត្ររបស់ព្រះដ៏មានព្រះ

ភាគ ហើយទូលថា "លោកសំដែងធម៌ដល់មហាជនសូរសៀងពីរោះណាស់បបូរមាត់របស់ព្រះអង្គក្រហមទុំល្អ តែខ្ញុំព្រះករុណាមានគភ៌ ក៏ពីព្រោះលោកឥឡូវនេះគ្រប់កំណត់ខែជិតសម្រាលហើយ រីខ្លួនលោកពុំបានត្រៀមអ្វីទុកសោះ ថែមទាំងមិនបានប្រាប់ឲ្យឧបដ្ឋាករបស់លោកដែលមាន នាងវិសាខា

ឬអនាថបិណ្ឌិកជាដើម ឲ្យត្រៀមសម្ភារៈសម្រាប់ធ្វើងទន្ទេឲ្យ រីឯខ្លួនលោកនេះបានតែត្រេកត្រអាលរីករាយសប្បាយប៉ុណ្ណោះ គ្មានចេះថែរក្សាគភ៌ឲ្យប្រពន្ធឡើយ )នាងបានចោទដាក់ទោសព្រះដ៏មានព្រះភាគក្នុងកណ្តាលទីប្រជុំជនដូច្នេះ។

ព្រះដ៏មានព្រះភាគ ទ្រង់ផ្អាកការសំដែងធម៌ទេសនាហើយទ្រង់ត្រាស់ថា ពាក្យពេចន៍ដែលនាងពោលនោះពិត ឬមិនពិតយ៉ាងណាទុះមានតែយើង ២ នាក់ប៉ុណ្ណោះទើបដឹង,នាងក៏ពោលថា"ត្រូវហើយរឿងនេះមានតែយើង២ នាក់ប៉ុណ្ណោះទើបដឹង។

គ្រានោះព្រះទែន ដែលជាទីប្រថាប់របស់ស្តេចសក្កៈជាកំពូលទេវតាសំដែងអាការៈក្តៅខុសប្រក្រតី កាលស្តេចសក្កៈត្រួតពិនិត្យមើលក៏ទ្រង់ជ្រាបថា នាងចិញ្ចមាណវិកាបានពោលដាក់ទោសព្រះដ៏មានព្រះភាគ ដោយពាក្យ

មិនពិត ទើបស្តេចយាងចុះមក ព្រមជាមួយទេវបុត្រ៤ អង្គ ដើម្បីជម្រះរឿងនេះ ឯទេវបុត្រ៤អង្គ បាននិម្មិតកាយជាកូនកណ្តុរ ចូលទៅកាត់ខ្សែដែលចងឈើភ្ជាប់នឹងពោះរបស់នាងដាច់ឈើធ្លាក់ត្រូវជើងនាងចិញ្ចមាណវិកាបែក

ហូរឈាមមនុស្សទាំងឡាយឃើញដូច្នោះ ក៏ស្មុះស្រែកទ្រហឹងអឹងកង ថា "មីចោរកាឡកណ្ណី មកជេរមដាមឲ្យព្រះពុទ្ធ,ៗ ហើយក៏នាំគ្នាចាប់ដំបង ព្រនង់ ដីដុំ ដេញវាយ ចោលបណ្តេញឲ្យចេញទៅខាងក្រៅវត្ត។

លុះនាងចេញទៅផុតខ្សែ ព្រះនេត្ររបស់ព្រះដ៏មានព្រះភាគធរណីក៏ស្រូបនាងចុះទៅកាន់អណ្តាតភ្លើង ដែលផុសឡើងមកពីអវីចីមហានរក។

ដោយហេតុនោះ លាភសក្ការៈរបស់ព្រះដ៏មានព្រះភាគ ក៏រឹតតែទ្វេឡើង រីឯខាងពួកតិរ្ថិយ៍ ក៏រឹតតែថយចុះទៅៗ លុះព្រឹកឡើងភិក្ខុទាំងឡាយ អង្គុយប្រជុំសន្ទនាគ្នា នៅក្នុងធម្មសភាសាលាថា នាងចិញ្ចមាណវិកា បានជេរប្រទេចព្រះពុទ្ធជាម្ចាស់ អ្នកមានគុណដ៏ក្រៃលែង សមគួរដល់ទក្ខិណាទើបគួរដល់សេចក្តីវិនាសធំ កាលព្រះដ៏មានព្រះភាគ ស្តេចយាងមកត្រាស់សួរអំពីរឿងដែលភិក្ខុទាំងឡាយសន្ទនាគ្នា ភិក្ខុទាំងឡាយក៏ក្រាបទូល ឲ្យព្រះដ៏មានព្រះភាគទ្រង់ជ្រាប ព្រះដ៏មានព្រះភាគទើបត្រាស់ថា នាងចិញ្ចមាណវិកាមិនបានពោលដាក់ទោសតថាគតដោយពាក្យមិនពិតក្នុងជាតិនេះ ប៉ុណ្ណោះ

ទេ ក្នុងអតីត: ក៏បានពោលទោស ហើយដល់នូវសេចក្តីវិនាសមកហើយ ដូចគ្នា រួចហើយទើបត្រាស់រឿងក្នុងមហាបទុមជាតកក្នុងទ្វាទសកនិបាតថា:

គ្រានោះ នាងចិញ្ចមាណវិកា បានជាស្រីរួមស្វាមី ជាមួយមាតារបស់ព្រះពោធិសត្វ ដែលមានព្រះនាមថា មហាបទុមកុមារដែលជាព្រះមហេសីរបស់ព្រះរាជា អ្នកជាព្រះរាជបិតា បានបបួលព្រះពោធិសត្វប្រព្រឹត្តក្នុងផ្លូវខុស កាលព្រះមហាបទុមមិនព្រម នាងក៏ធ្វើអាការៈវិបរិត ចូលទៅក្រាប ទូលមូលបង្កាច់ព្រះពោធិសត្វថាព្រះរាជឱរសបានចាប់ព្រះនាងរំលោភ តែ ព្រះនាងមិនព្រមចុះសម្រុងជាមួយ ព្រះរាជាទ្រង់ខ្ញាល់ បញ្ជាឲ្យយកព្រះពោធិសត្វទៅទំលាកចោលក្នុងជ្រោះ ជាទីកន្លែងដែលគេទំលាក់ចោរ ។គ្រានោះទេវតាដែលស្ថិតនៅក្នុងជ្រោះភ្នំ បានទទួលយកទុកហើយដាក់លើពពាររបស់ស្តេចនាគ។ ឯស្តេចនាគបានយកទៅទុក ឯក្រុងនាគបានបូជាសម្បត្តិពាក់កណ្តាល ព្រះពោធិសត្វនៅក្រុងនាគបាន១ឆ្នាំ ទ្រង់មានបំណងចង់ បព្វជ្ជា ទើបលាស្តេចនាគទៅនៅព្រៃហិមពាន្ត ទ្រង់បព្វជ្ជាហើយ ទ្រង់ចំរើនអភិញ្ញាសមាបត្តិកើតឡើង តមកមានព្រានព្រៃម្នាក់បានទៅជួប បានស្គាល់ទើបនាំសេចក្តីមកក្រាបទូលព្រះរាជាបានជ្រាប ព្រះរាជាទ្រង់ស្តេចយាងទៅជួបបានសាកសួរជ្រាបសេចក្តីពិតហើយទើបអញ្ជើញឲ្យស្តេចយាងទៅសោយ

រាជសម្បត្តិ តែព្រះពោធិសត្វត្រាស់ថា ព្រះអង្គមិនត្រូវការរាជសម្បត្តិឡើយ សូមព្រះអង្គគ្រងរាជ្យប្រកបដោយធម៌ចុះ សូមព្រះអង្គតាំងនៅក្នុងទសពិធ

រាជធម៌ លះបង់អគតិចោល ព្រះរាជបិតា ទ្រង់សោយសោកហើយស្ដេចត្រឡប់ទៅព្រះនគរវិញ ទៅតាមផ្លូវបានត្រាស់សួរអោមាត្យថា ព្រះអង្គព្រាត់ប្រាសព្រះរាជបុត្រ ដែលទ្រទ្រង់គុណធម៌ល្អ ដូច្នេះតើព្រោះនរណា? អាមាត្យក្រាបទូលថា ព្រោះព្រះអគ្គមហេសី ទើបព្រះរាជាត្រាស់ឲ្យយកព្រះ អគ្គមហេសីទៅទំលាក់ក្នុងជ្រោះដែលទំលាក់ចោរ ហើយទ្រង់គ្រងរាជ្យប្រកបដោយធម៌តរៀងមក ឯព្រះអគ្គមហេសីនោះបានមកកើតជានាងចិញ្ចមាណវិកាឥឡូវនេះឯង។

កាលព្រះដ៏មានព្រះភាគ ត្រាស់រឿងនេះចប់ហើយ ទើបត្រាស់ថា "ឈ្មោះថា បាបកម្ម ដែលមនុស្សទាំងឡាយ លះបង់ធម៌យ៉ាងឯក គឺពាក្យសត្យ ហើយតាំងនៅក្នុងមុសាវាទ អ្នកមិននិយាយដល់លោកខាងមុខ មិនធ្វើមិនមាន"ហើយបានត្រាស់ព្រះគាថា ថា អ្នកកន្លងធម៌យ៉ាងឯក អ្នកនិយាយកុហក អ្នកឈានកន្លងលោកខាងមុខ ឈ្មោះថាបាបកម្ម មិនអោយផល មិនមានឡើយ ។

មានន័យថា អ្នកដែលមិននិយាយពាក្យពិត និយាយតែពាក្យកុហក ព្រោះមិនសំលឹងឃើញសម្បត្តិទាំង៣ គឺសម្បត្តិមនុស្ស សម្បត្តិទេវតា សម្ប

ត្តិព្រះនិព្វាន ដល់ទៅខាងចុងនោះអ្នកដែលមិនធ្វើបាបកម្មនោះ រមែងមិន មាន ក៏ជាការបញ្ចប់រឿងនាងចិញ្ចមាណវិកាដែលជាការសំដែងអំពីជ័យជំនះ

របស់ព្រះដ៏មានព្រះភាគ ជាម្ចាស់ម្តងទៀត តាមដែលលោកពោលទុកក្នុង ពុទ្ធជយមង្គល ឬបទពាហុំត្រឹមប៉ុណ្ណោះ។

សេចក្តីពិត ក្នុងពុទ្ធជយមង្គលគាថា សំដែងតែរឿងដែលព្រះពុទ្ធជាម្ចាស់ មានជ័យជំនះលើនាងចិញ្ចមាណវិកាប៉ុណ្ណោះ តែក្នុងដីកាពាហុំ បាន ពោលអំពីនាងសុន្ទរី ទុកក្នុងមង្គលគាថានេះផងដែរ ហើយបាននាំមកពោល ទុកក្នុងទីនេះ រឿងរបស់នាងសុន្ទរីនោះ មានមកក្នុងព្រះត្រៃបិដក ខុទ្ទក និកាយ ឧទាន សន្ទរីសូត្រថា

សម័យមួយព្រះដ៏មានព្រះភាគ គង់ប្រថាប់នៅក្នុងវត្តជេតពនរបស់ ព្រះអនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ក្នុងសម័យនោះព្រះដ៏មានព្រះភាគ ត្រូវបានមហាជនធ្វើសក្ការៈ គោរពបូជា កោតក្រែងទ្រង់បរិបូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជប្បច្ច័យ សូម្បីតែភិក្ខុសង្ឃ ក៏ត្រូវ មហាជនធ្វើសក្ការៈបូជា កោតក្រែង បរិបូណ៌ដោយចីវរ បិណ្ឌបាត សេនា ស នៈ និងគិលានភេសជ្ជបរិក្ខារដែរ។ ចំណែកពួកអន្យតិរ្ថិយ៍បរិព្វាជក ជាពួក ដែលមហាជនមិនធ្វើសក្ការៈគោរពរាប់អាន បូជា កោតក្រែង មិនបាននូវចីវរ

បិណ្ឌបាត សេនាសនៈ និងគិលានភេសជ្ជបរិក្ខារ, គ្រានោះពួកអន្យតិរ្ថិយ៍ បរិញ្វជក អត់ធន់នឹងសក្ការៈរបស់ព្រះដ៏មានព្រះភាគ នឹងសក្ការៈរបស់ភិក្ខុសង្ឃមិនបានមានសេចក្ដីប្រណែនឈ្នានីស ឫស្យា បានចូលទៅជួបនាងសុន្ទរី បរិញ្វជិកាដល់ទីលំនៅ បានពោលនឹងនាងថាម្នាលប្អូនស្រី នាងអាចដើម្បីធ្វើប្រយោជន៍ដល់ពួកញាតិទាំងឡាយបានឬទេ? នាងសុន្ទរីសួរថាតើឲ្យ

នាងខ្ញុំធ្វើអ្វី លោកម្ចាស់?នាងខ្ញុំអាចដើម្បីធ្វើបានទាំអស់ សូម្បីតែជីវិតរបស់នាងខ្ញុំ ក៏លះបង់ដើម្បីប្រយោជន៍ដល់ញាតិទាំងឡាយបាន ពួកអន្យតិរ្ថិយ៍ពោលថា ម្នាលប្អូនស្រី បើដូច្នេះនាងចូរអញ្ជើញទៅកាន់វត្តជេតពន ឲ្យបានរឿយៗចុះ នាងសុន្ទរីបរិញ្វជិកាទទួលពាក្យរបស់ពួកអន្យតិរ្ថិយ៍ទាំងនោះ ហើយបានធ្វើដំណើរទៅកាន់វត្តជេតពនរឿយៗ ពួកអន្យតិរ្ថិយ៍ជ្រាបថា មានមនុស្សបានឃើញ នាងសុន្ទរីបរញ្វជិកាទៅកាន់វត្តជេតពនរឿងៗយ៉ាងញឹកញាប់, កាលនោះ ក៏បានជួលអ្នកលេងឲ្យទៅប្រហារជីវិតនាង ហើយកប់ទុកក្នុងគូព័ទ្ធជុំវិញវត្តជេតពននុះឯង ហើយនាំគ្នាចូលទៅគាល់ព្រះចៅបសេនទិកោសល ដល់ទីប្រថាប់ហើយបានក្រាបទូលថា សូមថ្វាយព្រះពរនាងសុន្ទរីបរិញ្វជិការបស់អាត្មាភាពបាត់ខ្លួន ព្រះចៅបសេនទិកោសលត្រាស់ថា

លោកម្ចាស់ទាំងឡាយសង្ស័យនៅកន្លែងណា? ពួកអន្យតិត្ថិយ៍ទូលថាស- ង្ស័យក្នុងវត្តជេតពនសូមថ្វាយព្រះពរ! ព្រះចៅបសេនទិកោសលត្រាស់ថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយស្រាវជ្រាវក្នុងវត្តជេតពនចុះ។

គ្រានោះពួកអន្យតិរ្ថិយ៍ទាំងនោះ បានស្រាវជ្រាវរកពេញក្នុងទីវត្តជេតពន ហើយបានជីកយកសពនាងសុន្ទរីបរិព្វាជិកា តាមដែលខ្លួនបញ្ជាឲ្យកប់ទុកចេញពីគូ លើកដាក់លើគ្រែ ហើយយកចូលទៅក្រុងសាវត្ថី ដើរចេញ ពីថ្នល់ខាងនេះ ទៅថ្នល់ខាងនោះ ចេញពីច្រកនេះទៅច្រកខាងនោះ ហើយឲ្យមនុស្សស្រែកថ្កោលទោសថា អញ្ជើញអស់លោកទាំងឡាយមើលចុះ នេះជាអំពើដ៏អាក្រក់បំផុតរបស់ពួកសមណសក្យបុត្រ, រីឯសមណសក្យបុត្រនេះ មិនមានសេចក្តីអៀនខ្មាស ពួកទ្រុស្តសីល មានធម៌ថោកទាប និយាយកុហក មិនប្រព្រឹត្តព្រហ្មចរិយៈ សមណសក្យបុត្រនេះ ប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តសមធម៌ស្មើគ្នា ប្រព្រឹត្តព្រហ្មចរិយៈ និយាយពិត មានសីលមានធម៌ល្អ អំពើជាសមណៈ របស់សមណសក្យបុត្រពួកនេះ ពុំមានទេ សេចក្តីជាសមណៈរបស់ពួកនេះវិនាសអស់ហើយ សេចក្តីជាព្រហ្មរបស់ពួក នេះនឹងមានពីណា?។

ពាក្យថ្កោលទោសនេះធ្ងន់ធ្ងរណាស់ ព្រោះត្រូវចោទថា មិនមែនជាសមណៈ បើមិនមែនសមណៈ គឺគ្រាន់តែជាបុរស់ប៉ុណ្ណោះកាលបានខ្លួននាង

សុន្ទរីហើយ ចង់បិទបាំងអំពើអាក្រក់របស់ខ្លួន ដូចម្តេចបានជាសំលាប់នាងសុន្ទរីបំបាត់ភស្តុតាង។

ក៏ក្នុងសម័យនោះឯង មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីបានឃើញភិក្ខុទាំងឡាយហើយ ក៏នាំគ្នាស្រែកជេរប្រទេចផ្តាសា ដៀមដាមក្រោធខឹង បៀតបៀនដោយពាក្យគំរោះគំរើយ មិនមែនជាវាចាសប្បុរសគឺពោលថា ពួកសមណសក្យបុត្រទាំងនេះ គ្មានសេចក្តីអៀនខ្មាស់ ទ្រុស្តសីល មានធម៌ថោកទាប និយាយកុហក មិនប្រព្រឹត្តព្រហ្មចរិយៈ ជាដើម។

គ្រានោះជាវេលាព្រឹក ភិក្ខុជាច្រើនអង្គបាននាំគ្នាស្លៀកស្បង់ កាន់បាត្រ និងចីវរ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់ពីបិណ្ឌបាតធ្វើភត្តកិច្ចរួចហើយ នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ បានក្រាបទូលព្រះដ៏មានព្រះភាគឲ្យទ្រង់ជ្រាប អំពីពាក្យជេរប្រទេច ពាក្យត្មះតិះដៀលរបស់មនុស្សទាំងនោះ។

ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយសំលេងនោះ មានមិនយូរទេ គឺមានតែ៧ថ្ងៃប៉ុណ្ណោះ ហួសពី៧ថ្ងៃនឹងបាត់សូន្យទៅឯង ម្នាលភិក្ខុទាំងឡាយ បើដូច្នោះលោកទាំងឡាយ ចូរតបតនឹងមនុស្សទាំងឡាយដែលគ្រាន់តែឃើញភិក្ខុទាំងឡាយ ហើយជេរត្មះតិះដៀល ក្រោធខឹង បៀតបៀនដោយវាចាគំរោះគំរើយ មិនមែនជាវាចាសប្បុរសដោយគាថាយ៉ាងនេះ

ថា” មនុស្សដែលនិយាយពាក្យមិនពិត ឬមនុស្សធ្វើបាបកម្ម ហើយនិ- យាយ ថា មិនបានធ្វើរមែងចូលដល់នរក មនុស្សទាំង២ពួកនោះ មានកម្ម ថោកទាប លះបង់ទៅហើយ រមែងស្មើគ្នាក្នុងលោកខាងមុខ”។

លំដាប់នោះ ភិក្ខុទាំងនោះ រៀនគាថានេះ ក្នុងសំណាក់ព្រះដ៏មាន ព្រះភាគរួចហើយ រមែងតបតនឹងពួកមនុស្សទាំងឡាយ ដែលគ្រាន់តែឃើញ ភិក្ខុទាំងឡាយហើយជេរត្មះតិះដៀលក្រោធខឹង បៀតបៀនដោយវាចាគ្រោត គ្រាត មិនមែនវាចាសប្បុរសដោយគាថានេះថា “អ្នកដែលនិយាយមិនពិត ឬ អ្នកដែលធ្វើបាបកម្មហើយ និយាយថា មិនបានធ្វើ រមែងចូលដល់នរក សូម្បី អ្នកទាំងពីរពួកនោះ មានកម្មថោកទាបលះបង់ទៅហើយ រមែងស្មើគ្នា ក្នុង លោកខាងមុខ” មនុស្សទាំងឡាយដែលបានឮពាក្យតបតរបស់ភិក្ខុទាំង ឡាយ បាននាំគ្នាគិតថា “សមណសក្យបុត្រទាំងនេះ មិនបានធ្វើខុស មិន បានធ្វើបាប” សំលេងជេរប្រទេចនោះមានតែ៧ថ្ងៃប៉ុណ្ណោះ លុះកន្លង៧ថ្ងៃ ក៏ បាត់សូន្យទៅ។

គ្រានោះឯង ភិក្ខុជាច្រើន នាំគ្នាទៅគាល់ព្រះដ៏មានព្រះភាគដល់ទី ប្រថាប់ ថ្វាយបង្គំហើយ អង្គុយក្នុងទីមួយដ៏សមគួរ រួចហើយបានក្រាបទូល ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើនគួរឲ្យអស្ចារ្យណាស់ បពិត្រ ព្រះអង្គដ៏ចម្រើន ដែលមិនធ្លាប់មានពីមុនមកដែលព្រះដ៏មានព្រះភាគបាន

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំលេងនោះ មានមិនយូរកន្លង៧ថ្ងៃ សំ លេង នោះបាត់ទៅ ហើយព្រះករុណា។ លំដាប់នោះព្រះដ៏មានព្រះភាគទ្រង់ ជ្រាបសេចក្តី នេះហើយបានទ្រង់បន្លឺឧទាននេះក្នុងពេលនោះថា "ជនអ្នក មិនសង្រួម រមែងចាក់ដោតជនដទៃដោយវាចា ដូចពួកទាហានដែលជា សត្រូវចាក់ច្រំកុញ្ជរចូលសមរភូមិសង្គ្រាមដោយកូនសរដូច្នោះ ភិក្ខុអ្នកមាន ចិត្តមិនប្រទូសរាយ ស្តាប់ពាក្យដ៏គ្រោតគ្រាត ដែលជនទាំងឡាយប- ញ្ចេញ ឡើងហើយ គប្បីអត់សង្កត់។

ជាទីបញ្ចប់រឿងរ៉ាវរបស់នាងសុន្ទរី តាមដែលមានមកក្នុងព្រះសូត្រ ត្រឹមប៉ុណ្ណេះ រឿងរ៉ាវនាងសុន្ទរីនេះ ព្រះដីកាចារ្យ បានរួបរួមទុកថា ជាជ័យ ជំនះរបស់ព្រះមានព្រះភាគ ដែលមានចំពោះពួកអន្យតិរ្ថិយ៍ ដោយរួបរួមទុក ក្នុងរឿងរបស់នាងចិញ្ចមាណវិកា ដែលដំណាលរួចហើយនោះឯង ទាំងក្នុង គាថាពាហុំពុំបានពោលដល់រឿងរបស់នាងសុន្ទរីឡើយ ពោលតែរឿងរបស់ នាងចិញ្ចមាណវិកាតែមួយ ដែលគួរឲ្យចំលែក ដែលថារឿងរបស់នាងចិញ្ច មា ណវិកាមានមកត្រឹមតែក្នុងអដ្ឋកថា តែមិនមានក្នុងព្រះត្រៃបិដក តែត្រ ឡប់ មកប្រាកដក្នុងគាថាពាហុំទៅវិញ ចំណែករឿងរបស់នាងសុន្ទរី មានមក ក្នុងព្រះត្រៃបិដក តែត្រឡប់មិនប្រាកដក្នុងគាថាពាហុំ មិនដឹងថា លោកអ្នក តែងមានហេតុផលយ៉ាងណា?។

រឿងរ៉ាវរបស់នាងសុន្ទរី តាមព្រះសូត្រចប់ ដូចពោលមកហើយ តែក្នុងអដ្ឋកថាសុន្ទរីសូត្រ នៅមានសេចក្តីដែលគួរលើកយកមកដំណាលទៀតពោលគឺ កាលមហាជនទាំងឡាយ បានស្តាប់ពាក្យឆ្លងឆ្លើយ ដែលភិក្ខុទាំងឡាយពោលតបតនឹងអ្នកដេរប្រទេចផ្តាសាពួកភិក្ខុហើយ ក៏យល់ច្បាស់ថា ពួកសមណសក្យបុត្រ មិនបានសម្លាប់នាងសុន្ទរីទេ ព្រះចៅបសេនទិ-កោសលទ្រង់បញ្ជូនរាជបុរសឲ្យទៅស៊ើបយកការណ៍រកសេចក្តីពិត ចំណែកពួកអ្នកលេងដែលស៊ីឈ្នួលសម្លាប់នាងសុន្ទរី លុះបានប្រាប់មកហើយ ក៏នាំគ្នាទៅលេងសុរា នៅរានលក់ស្រាមួយ លុះស្រវឹងកើតឈ្លោះគ្នា អ្នកលេងម្នាក់ពោលថា គឺអញទេតើសម្លាប់នាងសុន្ទរី កប់ទុកក្នុងគំនរសំរាមទើបបានប្រាក់មកទិញស្រាផឹក មិនគួរអ្នកណាមកអួតអាងថា គ្រាន់បើជាងអញទេ! ពួករាជបុរសបានស្តាប់ ក៏នាំគ្នាសម្រុកចូលទៅចាប់ចងបណ្តើរយកទៅថ្វាយព្រះចៅបសេនទិកោសល ព្រះអង្គទ្រង់សាកសួរ បានសេចក្តីថា ពួកអន្យតិរ្ថិយ៍ជួលអ្នកលេងទាំងនេះឲ្យសម្លាប់នាងសុន្ទរី ទើបត្រាស់ឲ្យទៅចាប់ពួកអន្យតិរ្ថិយ៍មកសាកសួរបានសេចក្តីពិត ក៏ត្រាស់ឲ្យពួកតិរ្ថិយ៍ ដើរប្រកាសទូទាំងព្រះនគរថា យើងទាំងឡាយជាឃាតករ សម្លាប់នាងសុន្ទរី ដើម្បីទំលាក់កំហុសទៅលើសមណគោតម រីឯទោសមិនមានដល់សមណគោតមនឹងសាវ័ករបស់សមណគោតមទេ គឺមានដល់ពួកយើងប៉ុណ្ណោះ ពួកតិរ្ថិយ៍

*តាមព្រះរាជបញ្ជា ជនទាំងឡាយ ទើបជ្រាបសេចក្តីពិត ទើបនាំគ្នាតិទៀន ពួកតិរ្ថិយ៍ជាអនេក លុះពួកតិរ្ថិយ៍ប្រកាសទូទាំងព្រះនគរហើយ ទើបពួកពេជ្ឈ ឃាតបណ្តើរទៅសម្លាប់ចោល ព្រមទាំងពួកអ្នកលេងដែលស៊ីឈ្នួលសម្លាប់ នាងសុន្ទរី ចាប់ដើមពីនោះមក លាភសក្ការៈ ក៏កើតមានដល់ព្រះពុទ្ធជា ម្ចាស់ នឹងព្រះសាវ័កយ៉ាងច្រើន ។*

*រឿងដែលព្រះដ៏មានព្រះភាគត្រូវថ្កោលទោស ពីនាងសុន្ទរីនេះ ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងអបទានថា កាលពីអតីតៈព្រះអង្គសោយព្រះជាតិជាអ្នកលេងឈ្មោះ **បុនាលិ** បានឃើញព្រះបច្ចេកពុទ្ធព្រះនាម **សុរភី**កំពុងគ្រងចីវរ ដើម្បីចូលទៅបិណ្ឌបាត ខណៈនុះមានស្ត្រីម្នាក់ដើរចេញមកពីទីជិត នឹងទីដែលព្រះបច្ចេកពុទ្ធកំពុងឈរគ្រងចីវរ អ្នកលេងនោះបានឃើញហើយ ក៏ពោលថា សមណៈនេះ ដាច់ព្រហ្មចារីហើយ ដោយកម្មដែលថ្កោលដាក់ ទោសព្រះបច្ចេកពុទ្ធដោយពាក្យមិនពិត ជាហេតុឲ្យធ្លាក់នរគអស់កាលយ៉ាង*

*យូរ កាលបានត្រាស់ជាព្រះពុទ្ធហើយដោយអំណាចបាបកម្ម នៅសេសសល់ក៏នៅត្រូវចោទប្រកាន់ពីនាងសុន្ទរីទៀត។*

*នេះជាបាបកម្មក្នុងអតីតៈ ដែលជាហេតុឲ្យព្រះអង្គ ត្រូវចោទប្រកាន់ពីនាងសុន្ទរី គ្រានេះមកដល់រឿងដែលថា ហេតុដូចម្តេចបានជានាងសុន្ទរី*

ពោលថ្កោលទោសព្រះដ៏មានព្រះភាគ រឿងនេះ មានពោលទុកក្នុងជាតក ព្រះដីកាចារ្យលើកមកដំណាលទុកថា. ព្រះដ៏មានព្រះភាពត្រាស់ដំណាល ថា រីនាងសុន្ទរី នឹងបានពោលមុសាតែក្នុងជាតិនេះក៏ទេ កាលពីអតីតៈ ក៏ នាង ធ្លាប់មុសាដាក់កំហុសមកលើតថាគតដែរ ហើយទ្រង់លើករឿងក្នុង អតីតមក ដំណាលថាៈ

ក្នុងសម័យព្រះបាទព្រហ្មទត្ត គ្រប់គ្រងក្រុងពារាណសី ព្រះពោធិ សត្វបានកើតជាបុត្របុរោហិត កាលបិតាក្ស័យជីវិត ក៏បានជាបុរោហិតជំនួស បិតា ព្រះបាទព្រហ្មទត្តនោះ ទ្រង់មានព្រះអគ្គមហេសីជាទីស្រលាញ់យ៉ាង ក្រៃលែងមួយព្រះអង្គ តមកមានសត្រូវចូលមកលុកលុយព្រះនគរ ពួកទា ហានបាននាំគ្នាប្រយុទ្ធទប់ទល់ ក៏មិនឈ្នះពួកខ្មាំង ទើបផ្ញើសំបុត្រមកក្រាប ទូលព្រះបាទព្រហ្មទត្តឲ្យទ្រង់ជ្រាបទើបព្រះអង្គចាំបាច់ត្រូវលើកទ័ពចេញ ទៅធ្វើសង្គ្រាម មុនស្តេចយាងចេញទៅ បានត្រាស់ប្រាប់ឲ្យព្រះមហេសី គង់ នៅក្នុងព្រះរាជវាំងឲ្យជាសុខ ឯព្រះមហេសីសូមតាមព្រះអង្គទៅផង ព្រះអង្គ មិនទ្រង់អនុញ្ញាត ព្រះមហេសីទើបទូលថា បើដូច្នោះ ព្រះនាងជ្រាបបាន យ៉ាងណាថា ព្រះស្វាមី ជាសុខ ឬជាទុក្ខដូចម្តេច? បើដូច្នោះ សូមព្រះអង្គ ប ញ្ជូនអាមាត្យមកប្រាប់ដំណឹង ឲ្យបានជ្រាបម្តងមួយនាក់ផងព្រះបាទព្រហ្ម-ទត្តក៏ទទួលបណ្តាំនោះ ព្រមទាំងផ្តាំឲ្យបុរោហិតនៅគាល់ចាំព្រះនគរ លុះ

ព្រះរាជាយាងទៅបានមួយយោជន៍ ក៏ទ្រង់បញ្ជូនឲ្យអាមាត្យម្នាក់ នាំដំណឹងមកក្រាបទូលព្រះមហេសីថា ព្រះអង្គសុខសប្បាយទេ ហើយព្រះអង្គក៏យាងតទៅទៀត ចំណែកព្រះនាងបានទតឃើញអាមាត្យដែលនាំដំណឹងមក ក៏កើតមានចិត្តស្នេហាទើបទ្រង់ប្រព្រឹត្តខុសប្រពៃណីជាមួយអាមាត្យនោះ។

ចំណែកព្រះបាទព្រហ្មទត្ត ទ្រង់បញ្ជូនអាមាត្យមកគាល់ព្រះមហេសីជាលំដាប់ៗរហូតតាមផ្លូវ ជាអាមាត្យចំនួន ៣២នាក់ ព្រះមហេសីទ្រង់ប្រព្រឹត្តខុសប្រពៃណីទាំង ៣២នាក់ លុះព្រះរាជាធ្វើសង្គ្រាមមានជ័យជំនះលើសត្រូវហើយ ក៏ស្តេចយាងត្រឡប់ទៅវិញ រៀងៗតាមផ្លូវដែលស្តេចយាងមកបានបញ្ជូនអាមាត្យឲ្យទៅក្រាបទូលព្រះមហេសី ទ្រង់ជ្រាបតាមលំដាប់ផ្លូវដូច កាលព្រះអង្គយាងទៅព្រះមហេសីទ្រង់ប្រព្រឹត្តខុសប្រពៃណីជាមួយអាមាត្យ ដែលព្រះរាជាបញ្ជូនមកទាំង ៣២នាក់ទៀត រួមទាំងទៅមក ទ្រង់ប្រព្រឹត្ត ខុសប្រពៃណីជាមួយអាមាត្យដល់ ៦៤នាក់ កាលព្រះរាជាស្តេចយាងមកជិត ដល់ព្រះនគរ ក៏ទ្រង់បញ្ជូនដំណឹងទៅឲ្យបុរោហិតតាក់តែងជួសជុលព្រះរាជ

វាំងទាំងខាងក្រៅទាំងខាងក្នុង ព្រះពោធិសត្វដែលជាបុរោហិត ទើបត្រូវចេញចូលក្នុងព្រះរាជវាំងរាល់ថ្ងៃ ថ្ងៃមួយបានជួបនឹងព្រះមហេសីៗ ទ្រង់ឃើញបុរោហិតមានរូបស្អាត ក៏កើតសេចក្តីស្នេហា ទ្រង់ហៅឲ្យចូលទៅក្នុង

ព្រះរាជតំណាក់ បំណងនឹងប្រព្រឹត្តខុសប្រពៃណីទៀត តែបុរោហិតមិនព្រម ទើបទទឹងទាស់នឹងព្រះសវនីយ៍ មិនបានចូលទៅក្នុងព្រះដំណាក់ព្រះមហេសី
ទ្រង់ព្រះពិរោធយ៉ាងខ្លាំង ទើបទ្រង់ធ្វើជាប្រឈួន។

លុះព្រះបាទព្រហ្មទត្តយាងមកដល់ ព្រះនាងក៏ក្រាបទូលចោទដាក់ទោសកំហុសទៅលើបុរោហិត ដោយចោទថា បុរោហិតចាប់នាងរំលោភគ្មានកោតក្រែងព្រះចេស្តាឡើយ ព្រះរាជាទ្រង់សំគាល់ថាជារឿងពិត ទ្រង់ព្រះពិរោធ បញ្ជាឲ្យចាប់បុរោហិតទៅប្រហារជីវិត បុរោហិតលោកជាអ្នកមាន បញ្ញា ក៏ប្រាប់នឹងអាមាត្យ សូមចូលគាល់ ព្រះរាជាសិនអាមាត្យក៏នាំចូល ទៅគាល់បុរោហិត ក៏ក្រាបទូលសេចក្តីពិតឲ្យព្រះរាជាទ្រង់ជ្រាប ទាំងក្រាប ទូលអំពីសេចក្តីដែលព្រះមហេសី ក្បត់ផិតព្រះអង្គ ធ្វើខុសប្រពៃណីជាមួយ អាមាត្យដែលរត់សារ ដល់៦៤នាក់ ព្រះរាជាត្រាស់សួរយកសេចក្តីពិតអំពី អាមាត្យទាំង ៦៤នាក់ នឹងព្រះមហេសីទៅប្រហារជីវិត តែបុរោហិតទូលសុំ ព្រះរាជទានអភ័យទោសទុកជីវិត ។

អ្នកប្រាជ្ញក៏មានយ៉ាងនេះ ដែលគិតបៀតបៀនអ្នកដទៃឲ្យក្តៅក្រហាយ

នោះមិនមាន គឺមានតែមេត្តា សូម្បីតែអ្នកគិតអាក្រក់មកលើខ្លួន ដោយ ផល នៃមេត្តានោះ ខ្លួនឯងក៏ផុតភ័យ បុរោហិតនោះក៏ដូច្នោះ កាលសំដែង ធម៌ឲ្យព្រះរាជាស្តាប់ហើយ ក៏ថ្វាយបង្គំលាទៅបួសកាលបានព្រះរាជានុញ្ញាតហើយ ក៏ត្រឡប់ទៅផ្ទះយកទ្រព្យទៅចែកចាយជាទានដល់អ្នកក្រខ្សត់ រួចហើយទើបទៅបួសនៅព្រៃហិមពាន្តញុំាងឈានសមាបត្តិឲ្យកើតឡើង លុះអស់ជីវិតក៏ទៅកើតក្នុងព្រហ្មលោក ។

កាលព្រះដ៏មានព្រះភាគ ត្រាស់ដំណាល ពីអតីតជាតិរបស់ព្រះអង្គហើយទ្រង់ប្រជុំតកថា ព្រះបាទព្រហ្មទត្តក្នុងកាលនោះគឺព្រះអានន្ទក្នុងពេលនោះព្រះមហេសី គឺនាងសុន្ទរីបរិព្វាជិកា, បុរោហិត គឺអង្គអញតថាគត។

ដោយហេតុនេះ ទើបយើងជ្រាបថា នាងសុន្ទរី មិនបានពោលពាក្យកាច់មួលព្រះដ៏មានព្រះភាគ ដោយពាក្យមិនពិត តែក្នុងបច្ចុប្បន្នជាតិនេះប៉ុណ្ណោះ សូម្បីក្នុងអតីតៈ ក៏នាងបានធ្វើមកហើយព្រោះដូច្នោះ ទង្វើរបស់យើងម្តងៗទើបជារឿងសម្ខាន់ ព្រោះអាចជាបច្ច័យឲ្យយើងធ្វើកម្មនោះស្ទួនទៀត បើជាកម្មល្អ ក៏គ្មានអ្វីឲ្យក្តៅក្រហាយ តែបើជាកម្មអាក្រក់ ក៏រមែង ក្តៅក្រហាយក្នុងជាតិនេះ និងក្នុងជាតិតៗទៅ ដូចរឿងរបស់នាងសុន្ទរី ដូចពោលមកហើយ ក៏សន្មតថាចប់រឿង របស់នាងសុន្ទរី ឯរំ តែប៉ុណ្ណេះ។

**ចប់ពុទ្ធជយមង្គលទី ៥**

ជ័យជំនះលើកទី ៦

គាថាទី ៦

**ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើសច្ចកនិគ្រន្ថ**

សច្ចំ វិហាយ មតិសច្ចកវាទកេតុំ
វាទាភិរោបិតមនំ អតិអន្ធភូតំ
បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ។

<u>ប្រែថា</u> ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈជា និគ្រន្ថក្រៅពុទ្ធវិន័យ។
អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់។
បង្កើតមោហ៍ងងឹង ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កំចាត់បង់ ដោយប្រទីបគឺបញ្ញា។
រីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជ័យា ព្រះឈ្នះសច្ចកៈនិគ្រន្ថ។

រឿងរ៉ាវរបស់សច្ចកនិគ្រន្ថនេះ មានតំណាលទុកនៅក្នុងព្រះត្រៃបិដក ចូឡសច្ចកសូត្រ និងមហាសច្ចកសូត្រ មជ្ឈិមនិកាយមូលបណ្ណាសកៈ ព្រម

ទាំងអដ្ឋកថា ដែលបានលើកយកមកតំណាលទាំង២សូត្រ តែមុនដែលតំណាលតាមព្រះសូត្រ សូមតំណាលពីប្រវត្តិរបស់សច្ចកនិគ្រន្ថ តាមអដ្ឋកថាចូឡសច្ចកសូត្រ ជាមុនសិនដើម្បីឲ្យបានជ្រាបថា គេជាអ្នកណា មកពីណា ក្នុងអដ្ឋកថាពោលថា:

ពីមុននោះមាននីគ្រន្ថប្រុសម្នាក់ ស្រីម្នាក់ រៀនវាទៈបានម្នាក់៥០០ ហើយនាំគ្នាដើរទៅសព្វទិសទីក្នុងជម្ពូទ្វីប ដើម្បីចោទឆ្លើយឆ្លងជាមួយអ្នកដទៃ លុះធ្វើដំណើរមកដល់ក្រុងវេសាលីរបស់ពួកក្សត្រលិច្ឆវី ឯស្តេចលិច្ឆវីបញ្ជាឲ្យអ្នកទាំងពីរចោទឆ្លើយគ្នា តែគ្មានអ្នកណាឈ្នះ គ្មានអ្នកណាចាញ់ ស្តេចលិច្ឆវី ទើបឲ្យអ្នកទាំងពីររៀបការនឹងគ្នា តមកគេបានធីតា៤នាក់ គឺឈ្មោះនាងសច្ចា១ នាងលោលា១ នាងបដាចាលា១ នាងសិលាវេតកា១ លុះធំឡើងនាងទាំង ៤នាក់ ក៏បានរៀនវាទៈ ជាមួយមាតាបិតាទាល់តែអស់ មាតាបិតាបានបញ្ជានាងធីតាថា បើកូនធ្វើជាកិរិយារបស់អ្នកដទៃ ដែលគេគ្រាន់តែឲ្យមាសប្រាក់ជាដើមនោះ មិនអាចប្រព្រឹត្តទៅបានទេ ព្រោះបុរសទាំងនោះ មិនអាចឆ្លើយឆ្លងនឹងកូនបានទេ ដូច្នោះសូមឲ្យកូនព្រមធ្វើជាបាទបរិច្ចាគរបស់អ្នកបួសណា ដែលអាចឆ្លើយឆ្លងយកឈ្នះលើកូនបាន ហើយចូរកូនបួសនៅក្នុងសំណាក់របស់អ្នកបួសនោះចុះធីតាទាំង ៤នាក់ ក៏បាន

ចេញបួស ហើយក៏ដើរស្វែងរកអ្នកប្រាជ្ញដែលអាចឆ្លើយឆ្លងជាមួយខ្លួនបាន ដោយកាន់យកនូវមែកព្រីងធ្វើជាសញ្ញា កាលបើដើរទៅដល់ស្រុកណា ក៏យកមែកព្រីងទៅដោតទុកនៅមាត់ទ្វារ ឬដោតលើពំនូកខ្សាច់ ដោតទង់ជាគ្រឿងសំគាល់ដោយប្រកាសថា បើអ្នកណាក្លាហានចង់ពោលវាទៈ ឆ្លើយឆ្លងជាមួយខ្ញុំ ចូរកាច់មែកព្រីងនេះចោលចុះ នាងបានប្រព្រឹត្តធ្វើដូច្នេះជាច្រើនឆ្នាំ ក៏គ្មានអ្នកណាហ៊ានយកជ័យជំនះលើនាងទាំង ៤នាក់នេះបាន លុះនាងធ្វើដំណើរមកដល់ក្រុងសាវត្ថី ក្នុងខណៈដែលព្រះដ៏មានព្រះភាគរបស់យើង ព្រមទាំងព្រះភិក្ខុសង្ឃដែលគង់នៅក្នុងទីក្រុងនោះ។

ក្នុងថ្ងៃនោះ ព្រះសារីបុត្រ និងពួកភិក្ខុ បាននិមន្តចេញទៅបិណ្ឌបាត បានឃើញមែកព្រីង ដែលគេដោតនៅមាត់ទ្វារចេញចូលក៏សួរពួកក្មេងៗ ដែលលេងនៅទីនោះថា មែកឈើដែលមានដោតទង់នេះ នរណាគេធ្វើ គេមានប្រាថ្នាយ៉ាងណា?ក្មេងៗក៏ក្រាបទូលឲ្យបានជ្រាប ព្រះសារីបុត្រ ទើបឲ្យក្មេងកាច់មែកព្រីងនោះចោលចំណែកនាងទាំង៤នាក់ បានជ្រាបរឿងនោះហើយ ក៏ប្រកាសឲ្យមនុស្សទាំងឡាយបានជ្រាបថា ថ្ងៃនេះយើងដេញដោលឆ្លើយឆ្លងជាមួយសារីបុត្រ ដែលជាសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ដូច្នេះ សូមលោកទាំងឡាយ នាំគ្នាទៅស្តាប់ចុះ ពួកអ្នកនគរសាវត្ថី បានជ្រាបហើយ ក៏

នាំគ្នាទៅកាន់វត្តជេតពន រួមទាំងនាង៤នាក់នោះផង ព្រះសារីបុត្រគិតថា ការអនុញ្ញាតឲ្យស្ត្រីចូលមកក្នុងទីលំនៅរបស់លោកជាការមិនសមគួរ ទើបលោកចេញទៅអង្គុយនៅកណ្តាលវត្ត នាងទាំង ៤នាក់ ក៏ចូលទៅសួរលោកថា តើលោកជាអ្នកកាច់មែកព្រីងមែនឬ?ព្រះសារីបុត្រទទួលថា មែន! នាងទាំង៤នាក់ បើដូច្នោះពួកនាងចូរសួរមុនចុះ! នាងទាំង៤នាក់ ក៏បានបំបែកគ្នា ទៅឈរនៅគ្រប់ទិសទាំង៤ បានលើកបញ្ហា១០០០ខ ដែលខ្លួនបានរៀនមកអំពីមាតាបិតា ហើយសួរព្រះសារីបុត្រ ឯព្រះសារីបុត្រ ក៏បានឆ្លើយដោះស្រាយបានគ្រប់ខហើយយ៉ាងជាក់ច្បាស់យ៉ាងឈ្លាសវៃ ដូចបុគ្គលកាត់ដើមឈូកដោយព្រះខ័នដ៏មុតថ្វាដូច្នោះ លុះអស់ហើយព្រះសារីបុត្របានប្រាប់ថា សូមឲ្យនាងសួរទៅទៀត នាងទាំង៤ ក៏ពោលថា ខ្ញុំព្រះករុណា ចេះតែត្រឹមប៉ុណ្ណឹងឯងព្រះថេរះទើបសួរថា ពួកនាងសួរយើង យើងក៏បាន ឆ្លើយអស់ហើយ ឥឡូវនេះយើងសួរ នាងវិញម្តង គឺសួរតែ ១ បញ្ហាប៉ុណ្ណោះ សូមនាងឆ្លើយឲ្យបានជ្រាបផង នាងទាំង ៤ នាក់បានឃើញសេចក្តីឈ្លាសវៃរបស់លោក ទើបមិនហ៊ានពោលថា សូមអារាធនានិមន្តសួរចុះ ខ្ញុំនឹងឆ្លើយបានគ្រាន់តែពោលថា សូមនិមន្តសួរចុះ បើខ្ញុំព្រះករុណាចេះ ខ្ញុំព្រះករុណានឹងឆ្លើយ។

ព្រះសារីបុត្តត្ថេរបានសួរបញ្ហា អំពីកុលបុត្រអ្នកចេញបួស ដែលត្រូវសិក្សាមុន គឺសួរថា"អ្វីឈ្មោះថា មួយ"នាងទាំង៤នាក់ មើលមិនឃើញខាងដើម នឹងខាងចុងរបស់បញ្ហានោះ ទើបនៅស្ងៀម ព្រះថេរៈតឿនឲ្យឆ្លើយ នាងទាំង៤នាក់ ក៏ថាខ្ញុំព្រះករុណាមើលមិនឃើញខាងដើម នឹងខាងចុងនៃបញ្ហានេះ ព្រះសារីបុត្រទើបពោកថា នាងសួរយើងទាំងពាន់បញ្ហាយើងក៏ឆ្លើយឲ្យនាងរួចអស់ហើយ យើងសួរនាងវិញតែមួយបញ្ហា នាងមិនអាចឆ្លើយប្រាប់យើងបាន បើដូច្នេះ តើអ្នកណាឈ្នះ អ្នកណាចាញ់?នាងទាំង ៤ នាក់ពោលថា ពួកខ្ញុំព្រះករុណាជាអ្នកចាញ់ ព្រះសារីបុត្រ ក៏ពោលថា បើនាងជាអ្នកចាញ់ តើធ្វើយ៉ាងណា?នាងទាំង ៤នាក់ក៏ប្រាប់ថា មាតាបិតារបស់ខ្ញុំព្រះករុណាប្រាប់ថា បើអ្នកណាអាចដោះស្រាយបញ្ហារបស់ខ្ញុំព្រះករុណាបាន ឲ្យពួកខ្ញុំព្រះករុណាបួសក្នុងសំណាក់របស់លោកនោះ ព្រះសារីបុត្រក៏ពោលថា ពួកនាងជាស្ត្រី មិនអាចបួសក្នុងសំណាក់យើងបានទេ ចូរនាងទៅបួសក្នុងសំណាក់របស់នាងភិក្ខុនីចុះ ឯនាងទាំង ៤នាក់ ក៏នាំគ្នាទៅបួសក្នុងសំណាក់របស់នាងភិក្ខុនីហើយ ជាអ្នកមិនប្រមាទ បានបំពេញសមណធម៌មិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្ត។

ចំណែកសច្ចកនិគ្រន្ថ គឺជាប្អូនប្រុសតូចរបស់នាងទាំង ៤ មានប្រាជ្ញាយ៉ាងខ្លាំងក្លាលើសនាងទាំង ៤ បានរៀនបញ្ហាអំពីមាតាបិតាហើយ

នៅទៅរៀនពីអាចារ្យដទៃៗទៀត ព្រមទាំងរៀនសិល្បវិទ្យាទៀត បានធ្វើជាអាចារ្យបង្រៀនសិល្បវិទ្យាដល់ព្រះកុមារស្តេចលិច្ឆវី ក្នុងក្រុងវេសាលី គេប្រកាន់ក្នុងចំណោះដឹងរបស់ខ្លួន បានយកបន្ទះដែកចងរឹតពោះទុក ខ្លាចក្រែងបែកពោះ ព្រោះគេយល់ថាពោះរបស់គេពេញទៅដោយប្រាជ្ញា នេះជាប្រវត្តិរបស់សច្ចកនិគ្រន្ថតាមដែលអដ្ឋកថាដំណាល ចំណែករឿងរ៉ាវក្នុងព្រះសូត្រសូមរៀបរាប់តាមចូឡសច្ចកសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសកៈព្រះអានន្ទពោលថាៈ

សម័យមួយ ព្រះដ៏មានព្រះភាគប្រថាប់នៅ កូដាគារសាលាព្រៃមហាវ័ន ក្រុងវេសាលី គ្រានោះសច្ចកនិគ្រន្ថជានិគន្ថបុត្រអាស្រ័យនៅក្រុងវេ-សាលី ជាវាគ្មិនអ្នកឆ្លើយឆ្លង និយាយលើកខ្លួនថា ជាអ្នកប្រាជ្ញពួកជនជា ច្រើលើកតំកើងថា ជាអ្នកចេះដឹងជ្រៅជ្រះជាងគេ បានពោលវាចានៅទីប្រជុំជនក្រុងវេសាលីថា យើងមើលមិនឃើញសមណៈ ឬព្រាហ្មណ៍ដែលជាប្រធាននៃពួកគណៈ ជាគណាចារ្យដែលប្តេជ្ញាខ្លួនថា ជាព្រះអរហន្ត ជាព្រះស-ម្មាសម្ពុទ្ធ ប្រាថ្នាចង់ចោទឆ្លើយឆ្លងជាមួយយើងដែលមិនតក់ស្លុត មិនរំភើបញាប់ញ័រ មិនមានញើសហូរចេញពីក្លៀក សូម្បីតែម្នាក់គ្មានឡើយ បើអញប្រាជ្ញាចោទឆ្លើយឆ្លងជាមួយសសរដែលគ្មានចិត្ត ឯសសរនោះក៏តក់ស្លុត រំភើបញាប់ញ័រ ចាំពោលទៅថ្វីសល់មនុស្សសេចក្តីត្រឹមប៉ុណ្ណោះ ក៏អាចជ្រាប

បានថា សច្ចកនិគ្រន្ថនេះលើកតម្កើងខ្លួន មានមានៈខ្លាំងរកអ្នកណាប្រៀបផ្ទឹមស្មើគ្មានឡើយ ។

គ្រានោះឯង ព្រះអស្សជិតត្ថេរ បានស្លៀកស្បង់ ហើយកាន់បាត្រ និងចីវរនិមន្តទៅបិណ្ឌបាត្រក្នុងក្រុងវេសាលី ពេលព្រឹកសច្ចកនិគ្រន្ថបានដើរកន្ទែកជើងទីមទាមចូលទៅក្រុងវេសាលី បានឃើញព្រះអស្សជិដើរមកអំពីឆ្ងាយ ទើបចូលទៅរកជួបប្រាស្រ័យជាមួយលោក លុះបានយល់អធ្យាស្រ័យគ្នាហើយ សច្ចកនិគ្រន្ថ បានឈរនៅក្នុងទីមួយដ៏សមគួរ បានទូលសួរព្រះអស្សជិថា "ម្នាលអស្សជិដ៏ចម្រើន ព្រះសមណគោតម បានប្រៀនប្រដៅ សាវ័កដូចម្តេច ឯពាក្យប្រៀនប្រដៅរបស់សមណគោតម មានផ្នែកដូចម្តេចដែលប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក"ព្រះអស្សជិតបថា ព្រះដ៏មានព្រះភាគទ្រង់ប្រៀនប្រដៅសាវ័កទាំងឡាយយ៉ាងនេះ ឯពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ មានផ្នែកយ៉ាងនេះ ដែលប្រព្រឹត្តទៅច្រើន ក្នុងសាវ័កទាំងឡាយថាៈ

"ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង. វេទនាមិនទៀង,សញ្ញាមិនទៀង. សង្ខារទាំងឡាយមិនទៀង.វិញ្ញាណមិនទៀង.រូបមិនមែនខ្លួន.វេទនាមិនមែនខ្លួន.សញ្ញាមិនមែនខ្លួន. សង្ខារទាំងឡាយមិនមែនខ្លួន. វិញ្ញាណមិនមែនខ្លួន. ធម៌ទាំងឡាយមិនមែនខ្លួន. ម្នាលអគ្គិវេសនៈ ព្រះដ៏មានព្រះភាគទ្រង់ប្រៀន

ប្រដៅសាវ័កទាំងឡាយយ៉ាងនេះ ឯពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ មានផ្នែកយ៉ាងនេះ ដែលប្រព្រឹត្តទៅច្រើនក្នុងសាវ័កទាំងឡាយ។

សច្ចកនិគ្រន្ថ ស្ដាប់ហើយក៏ពោលថា "ម្នាលអស្សជិដ៏ចម្រើន ខ្ញុំព្រះករុណាបានស្ដាប់ថា ព្រះសមណគោតមមានវាទៈយ៉ាងនេះ គឺខ្ញុំព្រះករុណាស្ដាប់ មិនពីរោះសោះឡើយ តែបើយ៉ាងណាជួនកាលខ្ញុំព្រះករុណា អាចជួបនឹងព្រះសមណគោតមដ៏ចំរើននោះ បើបានសន្ទនាគ្នា ទោះបីយ៉ាងណា ខ្ញុំព្រះករុណាជួយរំដោះ ព្រះសមណគោតមចេញអំពីសេចក្ដីយល់ឃើញដ៏ថោកទាបនុះ។

គ្រានោះស្ដេចលិច្ឆវីប្រមាណ៥០០អង្គ បានប្រជុំគ្នានៅក្នុងអាគារដែល ជាទីប្រជុំដោយករណីយកិច្ចអ្វីមួយ សម័យនោះសច្ចកនិគ្រន្ថ បានចូលទៅ ជួបស្ដេចលិច្ឆវីទាំងនោះ លុះចូលទៅហើយបានពោលថា "សូមស្ដេចលិច្ឆវី ទាំងឡាយ ទៅជាមួយគ្នា ថ្ងៃនេះខ្ញុំព្រះករុណានឹងសន្ទនាជាមួយព្រះសម- ណគោតម បើព្រះសមណគោតមតាំងនៅមាំ ដូចពាក្យដែលព្រះអស្សជិភិក្ខុ ដែលជាសាវ័កមួយអង្គល្បីឈ្មោះ បានបញ្ជាក់នឹងខ្ញុំព្រះករុណា។ នឹងអូស ទាញនូវពាក្យពេចន៍របស់ព្រះសមណគោតម មកតាមពាក្យរបស់ខ្ញុំព្រះករុ- ណាឲ្យដូចបុរសដែលមានកំលាំងចាប់ចៀមដែលមានរោមវែង ហើយអូស ទាញទៅមកៗដូច្នោះ ឬពុំនោះដូចមនុស្ស កម្មករធ្វើការក្នុងរោង

សុរាដែល មានកំលាំងខ្លាំង ដាក់កន្ទេលសំរាប់ត្រងស្រាសុរាមួយផ្ទាំងធំក្នុងទឹកជ្រៅ

ហើយចាប់ជាយកន្ទេលបោកគក់ត្រឡប់ចុះឡើងៗទៅមកដូច្នោះ ខ្ញុំព្រះករុណានឹងញីញក់ពាក្យពេចន៍របស់សមណគោតមឲ្យដូចបុរសដែលមានកំលាំង ដែលជាអ្នកលេងសុរា ចាប់ពែងត្រង់ត្រចៀកហើយគ្រវាត់ទៅមកដូច្នោះ ខ្ញុំ ព្រះករុណាសាកល្បងជាមួយព្រះសមណគោតម ដូចអ្នកលេងកីឡាឈ្មោះ

សាណធោវិត ដូចដំរីដែលមានវ័យកន្លង៦០ឆ្នាំ ថយកំលាំង ចុះក្នុងស្រះដែលមានទឹកជ្រៅ ហើយលេងកីឡាឈ្មោះ សាណធោវិក "ទាញខ្សែផ្ទៃ" ដូច្នោះសូមស្តេចលិច្ឆវីទាំងឡាយ ចូរទៅជាមួយគ្នា សូមស្តេចលិច្ឆវីទាំងឡាយចូរទៅជាមួយគ្នា ថ្ងៃនេះខ្ញុំនឹងសន្ទនា ជាមួយព្រះសមណគោតម។

ក្នុងបណ្តាក្សត្រលិច្ឆវីទាំងនោះ ពួកខ្លះពោលថា "ហេតុអ្វីព្រះសមណគោតម ចង់លើកពាក្យលោកសច្ចកៈ" ពួកខ្លះក៏ពោលថា "តើលោកសច្ចកៈមានរឿងអ្វីទើបចង់លើកពាក្យរបស់ព្រះដ៏មានព្រះភាគទៅបាន បើតាមពិតមានតែព្រះដ៏មានព្រះភាគទេ ត្រូវលើកពាក្យរបស់លោកសច្ចកៈ "មកវិនិ- ច្ឆ័យ"។

គ្រានោះសច្ចកនិគ្រន្ថ ដែលមានក្សត្រលិច្ឆវី ៥០០ហែហមអមដំណើរ ចូលទៅកាន់កូដាគារសាលាព្រៃមហាវ័ន វាលស្រលះសច្ចកនិគ្រន្ថចូលទៅ សួរថា "លោកដ៏ចម្រើន ឥឡូវនេះព្រះសមណគោតមនៅឯណា?ពួកខ្ញុំព្រះ ករុណាចង់ជួប" ភិក្ខុទាំងឡាយប្រាប់ថា "ម្នាលអគ្គិវេស្សនៈ ព្រះដ៏មានព្រះ ភាគ ព្រះអង្គយាងចូលទៅកាន់ព្រៃមហាវ័ន ព្រះអង្គទ្រង់សម្រាកនៅក្រោម ដើមឈើមួយ" លំដាប់នោះសច្ចកនិគ្រន្ថព្រមទាំងស្តេចលិច្ឆវីជាច្រើន បាន ចូលទៅកាន់ព្រៃមហាវ័ន ទាល់តែដល់ទីដែលព្រះដ៏មានព្រះភាគគង់ប្រថាប់ ហើយបានទូលប្រាស្រ័យជាមួយព្រះដ៏មានព្រះភាគ លុះធ្វើកាត់ការប្រា-ស្រ័យរលឹកគ្នារួចហើយទើបអង្គុយក្នុងទីមួយដ៏សមគួរ ឯពួកក្សត្រលិច្ឆវីទាំង ឡាយពួកខ្លះ ក៏ថ្វាយបង្គំ ពួកខ្លះ ក៏និយាយប្រាស្រ័យគ្នា ពួកខ្លះគ្រាន់តែប្រ ណម្យដៃ ពួកខ្លះប្រកាសឈ្មោះ និងគោត្ររបស់ខ្លួនក្នុងសំណាក់ព្រះដ៏មាន ព្រះភាគ ពួកខ្លះអង្គុយស្ងៀម រួចហើយម្នាក់ៗ អង្គុយក្នុងទីមួយដ៏សមគួររៀ ងៗខ្លួន ឯសច្ចកនិគ្រន្ថនោះ លុះអង្គុយហើយ ទើបទូលសួរព្រះដ៏មាន ព្រះ ភាគ"ខ្ញុំព្រះករុណា សូមទូលសួរព្រះគោតមបន្តិច តើព្រះគោតមមានឱ-កាសដើម្បី ដោះស្រាយបញ្ហារបស់ខ្ញុំព្រះករុណាបានទេ?" ព្រះដ៏មានព្រះ ភាគត្រាស់ថា "ម្នាលអគ្គិវេស្សនៈ លោកចង់សួរអ្វី ចូរសួរចុះ"។

សច្ចកនិគ្រន្ថទូលសួរថា "តើព្រះគោតម ប្រៀនប្រដៅពួកសាវ័កដូចម្តេច ឯពាក្យប្រៀនប្រដៅរបស់ព្រះគោតមមានផ្នែកដូចម្តេច ដែលប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក"។

ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលអគ្គិវេស្សនៈ តថាគតប្រៀនប្រដៅសាវ័កទាំងឡាយយ៉ាងនេះ ឯពាក្យប្រៀនប្រដៅរបស់តថាគត មានផ្នែកយ៉ាងនេះ ដែលប្រព្រឹត្តទៅច្រើនក្នុងសាវ័កទាំងឡាយថា រូបមិនទៀង វេទនាមិនទៀង,សញ្ញាមិនទៀង.សង្ខារមិនទៀង.វិញ្ញាណមិនទៀង.រូបមិនមែនតួខ្លួន

វេទនាមិនមែនតួខ្លួន.សង្ខារមិនមែនតួខ្លួន,វិញ្ញាណមិនមែនតួខ្លួន, សង្ខារទាំងឡាយទាំងពួង មិនមែនតួខ្លួន ធម៌ទាំងឡាយទាំងពួង មិនមែនតួខ្លួនដូច្នេះ ម្នាលអគ្គិវេស្សនៈ តថាគតប្រៀនប្រដៅសាវ័កយ៉ាងនេះ ឯពាក្យប្រៀនប្រដៅរបស់តថាគត មានផ្នែកយ៉ាងនេះ ប្រព្រឹត្តទៅច្រើនក្នុងសាវ័កទាំងឡាយ។

សច្ចកនិគ្រន្ថទូលថា "ព្រះគោតម សូមឧបមាឲ្យបានជាក់ច្បាស់ដល់ខ្ញុំព្រះករុណា" ព្រះដ៏មានព្រះភាគត្រាស់ថា "ឧបមានោះចូរជាក់ច្បាស់ដល់លោកចុះ" សច្ចកនិគ្រន្ថទូលថា "ព្រះគោតម ដូចពូជរុក្ខជាតិអ្វីមួយ ដែលចម្រើនលូតលាស់បរិបូណ៌ ពូជនោះទាំងអស់ ត្រូវអាស្រ័យផែនដី តាំងនៅលើផែនដី ទើបដល់នូវការចម្រើនលូតលាស់បរិបូណ៌បាន ឬដូចការងារអ្វី

មួយដែលត្រូវធ្វើដោយកម្លាំង ដែលបុគ្គលកំពុងធ្វើ ការងារនោះទាំងអស់ បុគ្គលត្រូវអាស្រ័យផែនដី ទើបធ្វើបានយ៉ាងណាមិញ បុរសបុគ្គលនោះមាន រូបជាដើម មានវេទនាជាដើម មានសញ្ញាជាដើម មានសង្ខារជាដើម មាន វិញ្ញាណជាដើម ត្រូវតាំងនៅក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ទើប បាន ប្រសព្វផលបុណ្យ ផលបាបដូច្នោះ"។

កាលបើសច្ចកនិគ្រន្ថទូលដូច្នេះ ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាល អគ្គិវេស្សនៈ សេចក្តីនុះ លោកពោលយ៉ាងនេះថា រូបជាខ្លួនរបស់អញ វេទ នាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារជាខ្លួនរបស់អញ វិញ្ញា ណជាខ្លួនរបស់អញ មែនឬទេ"។

សច្ចកនិគ្រន្ថទូលថា "ព្រះគោតម ខ្ញុំព្រះករុណាពោលយ៉ាងនោះ ប្រ ជុំជនជាច្រើនក៏ពោលយ៉ាងនោះ" ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលអគ្គិវេ ស្សនៈប្រជុំជនជាច្រើនធ្វើអ្វីដល់លោក ម្នាលអគ្គិវេស្សនៈ អញ្ជើញលោកប្រ កាន់ជាប់ពាក្យពេចន៍របស់លោកចុះ"សច្ចកនិគ្រន្ថក៏ប្រកាន់ជាប់ថា រូបជាខ្លួន របស់អញជាដើម ព្រះដ៏មានព្រះភាគត្រាស់ថា"ម្នាលអគ្គិវេស្សនៈ បើដូច្នោះ តថាគតនឹងសួរលោកក្នុងរឿងនេះចុះ លោកឃើញថា គួរយ៉ាងណាលោក គប្បីកែយ៉ាងនោះ ម្នាលអគ្គិវេស្សនៈ លោកសំគាល់សេចក្តីនុះដូចម្តេច អំ ណាចរបស់ព្រះរាជាអ្នកអភិសេកហើយ ដូចព្រះចៅបសេនទិកោសល និង ព្រះ

ចៅមគធៈអជាតសត្រូវវេទេហីបុត្រ អាចសំលាប់មនុស្សដែលគួរសម្លាប់ រឹបអូសរាជសម្បត្តិ ពីមនុស្សដែលគួររឹបអូស និរទេសមនុស្សដែលគួរនិរទេស គប្បីឲ្យប្រព្រឹត្តទៅបានក្នុងព្រះរាជអាណាខេត្តរបស់ព្រះអង្គមែនឬ ? សច្ចកនិគ្រន្ថទូលថា“ព្រះគោតមអំណាចរបស់ព្រះរាជាអ្នកបានអភិសេកហើយដូចព្រះចៅបសេនទិកោសលនិងព្រះចៅមគធៈ អជាតសត្រូវវេទេហីបុត្រ អាចសម្លាប់មនុស្សដែលគួរសម្លាប់ រឹបអូសរាជសម្បត្តិពីមនុស្សដែលគួររឹបអូសនិរទេសមនុស្សដែលគួរនិរទេស ដែលគប្បីឲ្យប្រព្រឹត្តទៅក្នុងព្រះរាជាណាខេត្តរបស់ព្រះអង្គ សូម្បីតែអំណាចរបស់ពួក គណៈទាំងនេះគឺ វជ្ជីមល្លៈ ក៏អាចសម្លាប់មនុស្សដែលគួរសម្លាប់រឹបអូសទ្រព្យពីមនុស្សគួររឹបអូសនិរទេសមនុស្ស

ដែលគួរនិរទេសនៅប្រព្រឹត្តទៅក្នុងនគររបស់ខ្លួនរៀងៗខ្លួន ហេតុអ្វីទៅអំណាចរបស់ព្រះរាជាអ្នកអភិសេកហើយនោះ ត្រូវឲ្យប្រព្រឹត្តទៅបានផងគួរតែប្រព្រឹត្តទៅបានផង”។កាលសច្ចកនិគ្រន្ថពោលយ៉ាងនេះ ព្រះដ៏មានព្រះភាគត្រាស់ថា“ម្នាលអគ្គិវេស្សនៈ តើលោកសំគាល់សេចក្ដីនោះថា ដូចម្ដេចត្រង់ដែលលោកពោលថា រូបជាខ្លួនរបស់យើង អំណាចរបស់លោកប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញ់ ចូរជាយ៉ាងនោះចុះដូច្នេះឬ?” កាលព្រះដ៏មានព្រះភាគត្រាស់សួរដូច្នេះ សច្ចកនិគ្រន្ថនៅស្ងៀមដល់២ដង លំដាប់នោះ

ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលអគ្គិវេស្សនៈ ពេលនេះសូមលោកឆ្លើយ មិនមែនពេលត្រូវនៅស្ងៀមទេ ម្នាលអគ្គិវេស្សនៈ អ្នកណាដែលតថាគតសួរ បញ្ហាដ៏សមគួរដល់ហេតុដល់ ៣ដង មិនបានឆ្លើយក្បាលអ្នកនោះត្រូវបែក ជា ៧ ភាគក្នុងទីនេះ"។

ខណៈនោះស្ដេចវជិរបាណីសក្កទេវរាជ កាន់ដំបងពេជ្រដែលភ្លើងឆេះ ទ្រលោម អណ្ដែតនៅក្នុងអាកាសវេហាស៍ ពីលើក្បាលរបស់សច្ចកនិគ្រន្ថ

ប្រកាសថា បើសច្ចកនិគ្រន្ថនេះ ព្រះដ៏មានព្រះភាគត្រាស់សួរបញ្ហា ដ៏ត្រឹមត្រូវតាមគួរដល់ហេតុហើយ ដល់៣ដងហើយមិនបានឆ្លើយដោះស្រាយ បញ្ហា

នោះ អញនឹងសំពងក្បាលសច្ចកនិគ្រន្ថឲ្យបែកជា៧ភាគ ឯស្ដេចវជិរបាណី នោះ មានតែព្រះដ៏មានព្រះភាគនិងសច្ចកនិគ្រន្ថប៉ុណ្ណោះ ដែលបានមើល ឃើញរំពេចនោះ សច្ចកនិគ្រន្ថស្លុតខ្លាច ព្រឺរោម ព្រឺស្បែក ស្វែងរកព្រះដ៏ មានព្រះភាគជាទីទប់ទល់ការពារជាទីពឹង បានក្រាបទូលថា បពិត្រព្រះគោ-តមដ៏មានចម្រើន សូមព្រះអង្គទ្រង់សួរចុះ ខ្ញុំព្រះករុណានឹងឆ្លើយឥឡូវនេះ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ លោកសំគាល់សេចក្ដីនោះ

ថាដូចម្ដេច លោកពោលយ៉ាងនេះថា រូបជាខ្លួនរបស់យើងដូច្នេះ អំណាចរបស់អ្នកប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញចូរជាយ៉ាងចុះកុំជាយ៉ាងនេះ

ឡើយដូច្នេះឬ? សច្ចកនិគ្រន្ថទូលតបថា សេចក្ដីនេះមិនអាចប្រព្រឹត្តទៅបានឡើយ ព្រះគោតដ៏ចម្រើន។

កាលសច្ចកនិគ្រន្ថទូលតបយ៉ាងនេះ ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលអគ្គិវេស្សនៈ លោកចូរធ្វើទុកក្នុងចិត្តចុះ លុះធ្វើទុកក្នុងចិត្តហើយទើបពោលកែ ព្រោះពាក្យក្រោយនឹងពាក្យមុន ឬពាក្យមុននិងពាក្យក្រោយរបស់លោកមិនត្រូវគ្នា លោកអគ្គិវេស្សនៈលោកចូរសំគាល់សេចក្ដីនោះដូចម្ដេចលោកពោលយ៉ាងនេះថា "វេទនាជាខ្លួនរបស់អញ សង្ខារជាខ្លួនរបស់អញ វិញ្ញាណជាខ្លួនរបស់អញដូច្នេះ អំណាចរបស់លោកប្រព្រឹត្តទៅក្នុង វេទនា សញ្ញា សង្ខារទាំងឡាយ និងក្នុងវិញ្ញាណថា វេទនា សញ្ញា សង្ខារ ហើយ នឹងវិញ្ញាណរបស់អញ ចូរជាយ៉ាងនោះចុះ កុំឲ្យជាយ៉ាងនេះឡើយដូច្នេះ ឬ"។

សច្ចកនិគ្រន្ថទូលតបថា សេចក្ដីនោះប្រព្រឹត្តទៅមិនបានឡើយ បពិត្រព្រះគោតមដ៏ចម្រើន ព្រះដ៏មានព្រះភាគត្រាស់ថា អគ្គិវេស្សនៈលោកចូរធ្វើទុកក្នុងចិត្តចុះ លុះលោកធ្វើទុកក្នុងចិត្តហើយគប្បីពោលកែ ព្រោះពាក្យក្រោយ និងពាក្យមុន ឬពាក្យមុន និងពាក្យក្រោយរបស់លោកមិនត្រូវគ្នា,

ម្នាលអគ្គិវេស្សនៈ លោកនឹងសំគាល់សេចក្តីនោះដូចម្តេច រូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណ ទៀង ឬមិនទៀង សច្ចកនិគ្រន្ថទូលថា មិនទៀងទេ ព្រះគោត្តមដ៏ចំរើន! ព្រះដ៏មានព្រះភាគត្រាស់សួរថា របស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ?សច្ចកនិគ្រន្ថទូលថា របស់នោះជាទុក្ខ ព្រះអង្គ! ព្រះដ៏មានព្រះភាគត្រាស់ថា របស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែ ប្រួលជាធម្មតា គួរឬដែលឃើញរបស់នោះថា នុះជារបស់អញនោះជាខ្លួន របស់អញ! សច្ចកនិគ្រន្ថទូលថា ព្រះគោតមដ៏ចំរើនមិនគួរដើម្បីនឹងយល់ ឃើញយ៉ាងនោះទេៗ

ព្រះដ៏មានព្រះភាគត្រាស់សួរទៀតថា ម្នាលអគ្គិវេស្សនៈលោកសំគាល់សេចក្តីនោះថាដូចម្តេច អ្នកណាជាប់ទុក្ខ ចូលដល់ទុក្ខហើយ ស៊ូទ្រាំបៀមទុក្ខនោះ ហើយនៅតែយល់ថា នុះរបស់អញនុះជាអញ នោះជាខ្លួនរបស់អញ ដូច្នេះអ្នកនោះ កំនត់ដឹងទុក្ខបានខ្លួនឯង ឬធ្វើទុក្ខឲ្យអស់ទៅបានទើបរស់នៅមានខ្វះ ឬទេ?

សច្ចកនិគ្រន្ថទូលតបថា នឹងគប្បីមានបានព្រោះហេតុអ្វី សេចក្តីនេះមិនមានឡើយ ព្រះអង្គ!

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអគ្គីវេស្សនៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលលោកជាប់ទុក្ខ ចូលដល់ទុក្ខ ចូលដល់ទុក្ខ ស៊ូអត់ទ្រាំ ក្នុង

ទុក្ខហើយ នៅតែយល់ឃើញថា នុះរបស់អញ នុះជាអញ នុះជាខ្លួន របស់អញដូច្នេះ ឬទេ?

សច្ចកនិគ្រន្ថទូលថា មិនត្រូវទេព្រះអង្គ សេចក្តីនេះ មិនអាចជាយ៉ាងនោះឡើយ។

ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលអគ្គិវេស្សនៈ ប្រៀបដូចបុរសត្រូវការខ្លឹមឈើ ស្វែងរកខ្លឹមឈើ ហើយកំពុងស្វែងរកខ្លឹមឈើ កាន់យកដឹង ដ៏មុតចូលទៅកាន់ព្រៃ ហើយគេបានឃើញដើមចេកមួយដើមធំនៅក្នុងព្រៃនោះ មានដើមមូលត្រង់នៅជំទង់ គេកាត់ដើមចេកនោះត្រង់គល់ រួចហើយកាត់ចុងចោល ហើយសកយកស្រទបចេញ គេមិនបានឃើញស្រាយផង តើនឹងបានខ្លឹមមកពីណាយ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លោកគឺតថាគតសួរដេញដោលក្នុងពាក្យរបស់ខ្លួនឯងក៏ទទេ គឺលោកចាញ់ទៅឯង។ ។

លោកបានពោលវាចានេះ ក្នុងទីប្រជុំជនក្នុងវេសាលីថាយើងមិនបានឃើញសមណៈ ឬព្រាហ្មណ៍ដែលជាមេពួកគណៈ ជាគណាចារ្យដែលប្តេជ្ញាខ្លួនថាជាព្រះអរហន្ត ជាព្រះសម្មាសម្ពុទ្ធ ដែលប្រាថ្នាចង់ចោទឆ្លើយជាមួយនឹងយើង មិនគប្បីតក់ស្លុត មិនញាប់ញ័រ មិនមានញើសហូរចេញពីក្លៀក សូម្បីតែម្នាក់គ្មានឡើយ បើអញចោតឆ្លើយជាមួយសសរ ដែលគ្មានចិត្ត សសរនោះក៏តក់ស្លុតញាប់ញ័រ ចាំបាច់និយាយអ្វីដល់មនុស្សដូច្នេះ ម្នាលអគ្គិ វេស្ស

នៈដំណក់ញើសរបស់លោកស្រក់ចេញពីថ្ងាស ធ្លាក់លើសំពត់ដណ្ដប់ ហើយធ្លាក់ទៅលើដី ចំណែកញើសក្នុងកាយរបស់យើង ឥឡូវនេះមិនមាន ឡើយ ដូច្នេះហើយព្រះដ៏មានព្រះភាគទ្រង់បើកព្រះកាយមានព្រះឆវីដូច មាសក្នុងបរិស័ទនោះ កាលព្រះដ៏មានព្រះភាគត្រាស់ដូច្នេះហើយ សច្ចកនិគ្រន្ថនោះ អង្គុយស្ងៀមធ្វើព្រងើយ សំយុងកកើតខ្មាស ឱនមុនជ្រប់ អស់បដិភាណ។

ក្នុងលំដាប់នោះ ស្ដេចលិច្ឆវីមាននាមថា **ទុម្មុខៈ** បានជ្រាបថា សច្ចកនិគ្រន្ថនៅស្ងៀមកើតខ្មាស មានមុខសំយុងចុះ អស់បដិភាណហើយ ទើបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគសេចក្ដីឧបមា រមែងជាក់ច្បាស់ដល់ខ្ញុំព្រះអង្គ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលទុម្មុខៈឧបមានោះ ចូរជាក់ច្បាស់ដល់លោកចុះ ស្ដេចលិច្ឆវីទូលថា ប្រៀបដូចក្នុងទីជិតភូមិ ឬនិគម មានស្រះបោក្ខរណីមួយក្នុងស្រះនោះមានក្ដាមមួយក្មេង ប្រុសស្រីជាច្រើន ចេញពីភូមិនិគមនោះ ទៅដល់ស្រះបោក្ខរណីនោះហើយ ក៏ចុះចាប់ក្ដាម ស្រង់ពីទឹកដាក់លើគោក ហើយក្ដាមលាដង្កៀបទៅខាងមុខ ក្មេងទាំងនោះក៏នាំគ្នាគ្ពឹសវាយដង្កៀបក្ដាមនោះដោយឈើខ្លះ ដោយអំបែងក្បឿងខ្លះ ក្ដាមនោះក៏បាក់ដង្កៀបជើងអស់ហើយ កាលក្ដាមនោះមានជើង និង ដង្កៀបបាក់អស់ហើយ មិនអាចវារចុះស្រះបោក្ខរណីនោះបានដូចមុនឡើយ

យ៉ាងណាមិញ រីឯទិដ្ឋិជាចំរូងបន្ទា នាំឲ្យយល់ខុសវិវក់ដូចសច្ចកនិគ្រន្ថដែលព្រះអង្គកាច់បំបាក់ហើយ តអំពីនេះទៅសច្ចកនិគ្រន្ថ មិនអាចចូលមកជិតព្រះអង្គបានឡើយ កាលបើមានប្រាថ្នាចង់ចោទឆ្លើយឆ្លងនឹងព្រះអង្គទៀត កាលស្ដេចលិច្ឆវីទុម្មុខៈពោលដូច្នេះហើយ សច្ចកនិគ្រន្ថក៏និយាយថា នែចៅទុម្មុខៈ លោកឈប់និយាយទៅ!លោកឯងនេះ និយាយច្រើនណាស់ ខ្ញុំមិនបាននិយាយជាមួយលោកឯងទេ! ខ្ញុំនិយាយតែជាមួយព្រះគោតមប៉ុណ្ណោះ លុះពោលយ៉ាងនេះហើយ ទើបក្រាបទូលថា បពិត្រព្រះគោតមសេចក្ដីដែលនិយាយនោះជារបស់ខ្ញុំព្រះករុណា និងពួកសមណព្រាហ្មណ៍ដ៏ទៃលើកចោលចុះ ទុកជាពាក្យពោយរាយឥតប្រយោជន៍។ ទើបសច្ចកនិគ្រន្ថទូលសួរថា តើព្រោះហេតុអ្វី សាវ័ករបស់ព្រះគោតមទើបឈ្មោះថា ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ធ្វើត្រឹមត្រូវតាមឱវាទឆ្លងកាត់សេចក្ដីសង្ស័យចេញបានប្រាសចាកសេចក្តិសង្ស័យដែលជាហេតុឲ្យពោលថា សេចក្ដីនេះតើដូចម្ដេចដល់នូវសេចក្តិក្លៀវក្លា មិនត្រូវជឿអ្នកដទៃ តាំងនៅក្នុងពាក្យប្រដៅរបស់ សាស្ដាខ្លួន។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ សាវ័ករបស់តថាគតក្នុងធម្មវិន័យនេះ រមែងឃើញបញ្ចក្ខន្ធនោះដោយបញ្ញាដ៏ប្រពៃ តាមសេចក្ដី

ពិតយ៉ាងនេះថា រូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណឯណានីមួយ ដែលកន្លងទៅហើយ ដែលនៅមិនទាន់មកដល់ទាំងដែលកើតឡើងចំពោះមុខ ដែលជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ប្រណីតក្តី ក្នុងទីឆ្ងាយក្តី ទីជិតក្តី ទាំងអស់នេះក៏គ្រាន់តែជារូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណប៉ុណ្ណោះ នុះមិនមែនរបស់អញ អញមិនមែនជា របស់នោះ នុះមិនមែនខ្លួនរបស់អញដូច្នេះ ម្នាលអគ្គិវេស្សនៈ ដោយហេតុប៉ុណ្ណោះឯងសាវ័ករបស់តថាគត ទើបឈ្មោះថា ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅធ្វើត្រឹមត្រូវតាមឱវាទ ឆ្លងសេចក្តីសង្ស័យចេញបាន ប្រាសចាកសេចក្តីឆ្ងល់ ជាហេតុពោលថា សេចក្តីនេះ តើយ៉ាងណាដល់ភាពក្បៀវក្លា មិនជឿអ្នកដទៃ នៅក្រោមឱវាទរបស់សាស្តាខ្លួន។

សច្ចកនិគ្រន្ថទូលថា "បពិត្រព្រះគោតម ដោយហេតុយ៉ាងណា ភិក្ខុឈ្មោះថាជាព្រះអរហន្ត មានអាសវៈអស់ហើយ នៅចប់ព្រហ្មចរិយៈហើយ មានកិច្ចត្រូវធ្វើ បានធ្វើរួចហើយ ដាក់ភារៈចុះហើយ មានប្រយោជន៍ខ្លួនដល់ហើយដោយលំដាប់ មានសំយោជនៈដែលនាំទៅកាន់ភពអស់ហើយរួចផុតយ៉ាងវិសេសហើយព្រោះដឹងប្រពៃ ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលផុតវិសេសហើយនេះឯង ប្រកបដោយគុណដ៏កំពូល៣ប្រការ គឺ

១ សេចក្តីយល់ឃើញដ៏កំពូល

២ សេចក្តីប្រតិបត្តិដ៏កំពូល

៣ សេចក្តីរួបផុតដ៏កំពូល

កាលមានចិត្តរួចផុតវិសេសហើយ រមែងសក្ការៈគោរពរាប់អានបូជាតថាគតថា ព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់ដឹងហើយរមែងសំដែងធម៌ដើម្បីឲ្យត្រាស់ដឹង ព្រះដ៏មានព្រះភាគព្រះអង្គនោះទ្រង់ហ្វឹកហាត់ព្រះអង្គ ទ្រង់សំដែងធម៌ដើម្បីហ្វឹកហាត់ ព្រះដ៏មានព្រះភាគ ព្រះអង្គនោះស្ងប់ហើយរមែងសំដែងធម៌ដើម្បីស្ងប់ ព្រះដ៏មានព្រះភាគ ព្រះអង្គឆ្លងផុតហើយរមែងសំដែងធម៌ដើម្បីឆ្លងផុត ព្រះដ៏មានព្រះភាគ ព្រះអង្គនោះ ទ្រង់រលត់ស្និទ្ធហើយរមែងទ្រង់សំដែងធម៌ ដើម្បីសេចក្តីរលត់ស្និទ្ធ។

កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ សច្ចកនិគ្រន្ថក្រាបទូលថា បពិត្រព្រះគោតម ខ្ញុំព្រះករុណា ជាមនុស្សចាំតែកំចាត់គុណរបស់អ្នកដទៃ ជាមនុស្សមាត់ដាច រពឹសវាចា បានសំគាល់ពាក្យពេចន៍របស់ព្រះគោតមថា ខ្លួនអាចរុករានបានដោយពាក្យពេចន៍របស់ខ្លួន តែបុរសមកជួបនឹងដំរីចុះប្រេងក្តី ជួបនឹងគំនរភ្លើងដែលកំពុងឆេះសន្ធោសន្ធៅក្តី នៅល្មមយកខ្លួនរួចបានខ្លះ តែលុះមកជួបព្រះគោតម មិនអាចយកឲ្យរួចខ្លួនបានឡើយ បពិត្រព្រះគោតម ខ្ញុំព្រះករុណាជាមនុស្សចាំតែកំចាត់គុណអ្នកដទៃ

ជាមនុស្សរពឹសវាចា បានតាមលំដាប់សំគាល់ពាក្យពេចន៍របស់ព្រះគោតម ថា ខ្លួនអាចរុករកបានដោយពាក្យពេចន៍របស់ខ្លួន ដូច្នេះសូមព្រះគោតម ព្រម

ដោយភិក្ខុសង្ឃ ចូរទទួលនិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ។

ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព លំដាប់នោះសច្ចកនិគ្រន្ថជ្រាបថា ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តហើយ ទើបប្រាប់ពួកស្តេចលិច្ឆវីទាំងអស់ដែលមកជាមួយថា ស្តេចលិច្ឆវីទាំងឡាយ ចូរស្តាប់ខ្ញុំ ព្រះគោតម ព្រមទាំងភិក្ខុសង្ឃ ខ្ញុំបាននិមន្តហើយដើម្បីឆាន់ថ្ងៃស្អែក ពួកលោកនាំយកអាហារណាមកដើម្បីខ្ញុំ ចូរលើកអាហារដ៏គួរសមដល់ព្រះគោតមចុះ កាលកន្លងរាត្រីនុះទៅហើយស្តេចលិច្ឆវីទាំងអស់ បាននាំភត្តាហារមកប្រមាណ៥០០សំរាប់ទៅឲ្យសច្ចកនិគ្រន្ថ, សច្ចកនិគ្រន្ថ បានឲ្យចាត់ចែងរបស់ឆាន់ដ៏ប្រណីត ក្នុងអារាមរបស់ខ្លួនរួចហើយ ទើបឲ្យមនុស្សក្រាបទូលប្រាប់កាលដល់ព្រះដ៏មានព្រះភាគជម្ចាស់ថា បពិត្រព្រះគោតម ពេលនេះជាកាលគួរ រីកត្តាហាររួចស្រេចអស់ហើយ។

កាលនោះ ជាពេលព្រឹក ព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកស្បង់រួចហើយទ្រង់កាន់បាត្រ និងចីវរ ស្តេចយាងទៅកាន់អារាមរបស់សច្ចកនិគ្រន្ថ ទ្រង់គង់ប្រថាប់លើអាសនៈដែលគេក្រាលទុកថ្វាយព្រះអង្គ ព្រមដោយភិក្ខុ

សង្ឃ គ្រានោះសច្ចកនិគ្រន្ថ បានអង្គាសភិក្ខុសង្ឃ ដោយមានព្រះពុទ្ធជាម្ចាស់ជាប្រធាន មានខាទនីយ ភោជនីយាហារ ដ៏ប្រណីតដោយដៃខ្លួនឯងឲ្យឆ្អែតស្កប់ស្កល់ស្រួលបួលហើយ កាលព្រះដ៏មានព្រះភាគទ្រង់សោយរួចព្រះអង្គយកព្រះហស្ថចេញអំពីបាត្រហើយ សច្ចកនិគ្រន្ថ កាន់យកអាសនៈទាប អង្គុយក្នុងទីមួយដ៏សមគួរ បានទូលថា "បពិត្រព្រះគោតម សូមបុណ្យនិងផលបុណ្យក្នុងទាននេះ ចូរមានដើម្បីសេចក្តីសុខដល់ទាយកចុះ"។

ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលអគ្គិវេស្សនៈបុណ្យនិងផលបុណ្យក្នុងទាននេះ អាស្រ័យទក្ខិណេយ្យបុគ្គល.ដែលនៅមិនទាន់អស់រាគៈ ទោសៈ មោហៈ ដូចលោក នឹងមានដល់ទាយកទាំងឡាយ ចំណែកបុណ្យ និងផលបុណក្យ អាស្រ័យទក្ខិណេយ្យបុគ្គលដែលអស់ រាគៈ ទោសៈ មោហៈ ដូចតថាគត និងមានដល់លោកដូច្នេះឯង ទាំងអស់ដែលពោលមក ជារឿនរ៉ាវរបស់សច្ចកនិគ្រន្ថតាមដែលមានមកក្នុងចូឡសច្ចកសូត្រ។

លោកអ្នកអានបានជ្រាបអំពីសេចក្តី អួតក្អេងក្អាងរបស់សច្ចកនិគ្រន្ថថា ទោះបីចាញ់ហេតុផល និងសេចក្តីពិត ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ព្រមទាំងនិមន្តព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឃឲ្យទៅទទួលភត្តាហារក្នុងទីអារាមរបស់ខ្លួនហើយ រីឯសច្ចកនិគ្រន្ថក៏នៅមិនបានសូមដល់

ត្រៃសរណគមន៍ ហៅថានៅមិនទាន់ជ្រះថ្លាយ៉ាងពិប្រាកដ តែហេតុអ្វី.ទើប ព្រះដ៏មានព្រះភាគ សំដែងធម៌ដល់មនុស្សរបៀបនេះ គួរឲ្យឆ្ងល់ ក្នុងអដ្ឋក ថាលោកកែសេចក្ដីសង្ស័យទុកខាងចុងព្រះសូត្រ ដែលនាំមកពោលគឺក្នុង មហាសច្ចកសូត្រ ព្រោះដូច្នោះ សូមតាមដានដូចតទៅ:

អដ្ឋកថា លោកអធិប្បាយអំពីការឲ្យទានរបស់សច្ចកនិគ្រន្ថថា ត្រង់ ដែលសច្ចកនិគ្រន្ថទូលព្រះដ៏មានព្រះភាគថា សូមបុណ្យនិងផលរបស់ បុណ្យ ក្នុងទាន ដែលគេថ្វាយដល់ព្រះដ៏មានព្រះភាគសូមឲ្យមានសេចក្ដី សុខដល់ ទាយកគឺអ្នកឲ្យទាំងឡាយនោះ មានន័យថា សូមឲ្យបុណ្យ និង ផលបុណ្យ នោះ ចូរមានដល់ពួកស្ដេចលិច្ឆវីទាំងឡាយ ដែលនាំរបស់មក ឲ្យគេ សម្រាប់ ឲ្យគេយកទៅថ្វាយដល់ព្រះដ៏មានព្រះភាគ ទាំងនេះ ព្រោះ គេយល់ថា ខ្លួន គេនោះក៏ជាអ្នកបួសដែរ គឺពួកនិគ្រន្ថនោះក៏ជាអ្នកបួសមួយ ពួកដែរ កាល ដែលអ្នកបួស យករបស់ដែលគេឲ្យខ្លួន ហើយខ្លួនយករបស់ នោះទៅឲ្យដល់

អ្នកដទៃ ជាការពុំសមគួរ ទើបគេសូមឲ្យផលបុណ្យនោះ ចូរឲ្យមានដល់ ស្ដេ ចលិច្ឆវីៗ

តែព្រះដ៏មានព្រះភាគថា ទាននោះជារបស់ស្ដេចលិច្ឆវីទាំងឡាយឲ្យ ដល់សច្ចកនិគ្រន្ថ មិនបានឲ្យដល់ព្រះអង្គទេ រីឯសច្ចកនិគ្រន្ថបាននាំមក

ថ្វាយព្រះអង្គទៀត ឯសច្ចកនិគ្រន្ថនោះជាអ្នកនៅមានកិលេស នៅមិនទាន់អស់រាគៈ ទោសៈ មោហៈដោយហេតុនោះព្រះដ៏មានព្រះភាគ ទើបត្រាស់ ថា បុណ្យ និងផលបុណ្យក្នុងទាននេះអាស្រ័យទក្ខិណេយ្យបុគ្គលដែលមិន ទាន់អស់រាគៈ ទោសៈ មោហៈ ដូចលោកនឹងមានដល់ទាយកទាំងឡាយ គឺ ពួកស្តេចលិច្ឆវីទាំងឡាយ។

ចំណែកបុណ្យ និងផលបុណ្យដែលសច្ចកនិគ្រន្ថ ថ្វាយទានដល់ព្រះដ៏មានព្រះភាគដែលអស់រាគៈ ទោសៈ មោហៈ វីបុណ្យនោះ ត្រូវកើតមានដល់សច្ចកនិគ្រន្ថ ដែលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះ ក៏ព្រោះព្រះអង្គទ្រង់ប្រគល់ទក្ខិណា ដែលគេថ្វាយដល់ព្រះអង្គឲ្យជាវាសនាបារមីដល់សច្ចកនិគ្រន្ថទៅអនាគតហៅថា ឲ្យជានិស្ស័យប្បច្ច័យទៅអនាគត ដើម្បីបានលុះ និញ្វានទោះឯង។

តទៅរឿងរបស់សច្ចកនិគ្រន្ថ ក្នុងមហាសច្ចកសូត្រ ដែលព្រះអានន្ទពោលថាៈ សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់ប្រថាប់នៅកូដាគារសាលា ព្រៃមហាវ័ន នគរវេសាលី គ្រានោះពេលព្រឹក ព្រះដ៏មានព្រះភាគទ្រង់ ស្លៀកស្បង់រៀបរយហើយ ទ្រង់កាន់បាត្រ និងចីវរមានព្រះពុទ្ធបំណងស្តេច យាងទៅបិណ្ឌបាតក្នុងក្រុងវេសាលី ពេលនោះសច្ចកនិគ្រន្ថ ជានិគន្ថបុត្រ កំពុងដើរដើម្បីឲ្យធូរសរសៃដៃជើងឲ្យស្រួលខ្លួន បានចូលទៅកូដាគារ

សាលា ព្រៃមហាវ័ន ព្រះអានន្ទបានឃើញសច្ចកនិគ្រន្ថមកអំពីឆ្ងាយ ទើបក្រាបទូល ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សច្ចកនិគ្រន្ថនេះជាអ្នកសួរ

ឆ្លើយឆ្លង និយាយលើកខ្លួនថា ជាអ្នកប្រាជ្ញពួកជនជាច្រើនបានលើកតម្កើងថា ជាអ្នកចេះដឹងច្រើន គេមានបំណងចង់ទិតៀន ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គប្រទានព្រះវរោកាស សូមព្រះដ៏មានព្រះភាគទ្រង់ព្រះករុណាគង់ប្រថាប់បានមួយស្របក់សិនចុះព្រះដ៏មា ព្រះ

ភាគ ទើបប្រថាប់នៅលើអាសនៈ ដែលគេក្រាលថ្វាយ ខណៈនុះសច្ចកនិ គ្រន្ថ ចូលទៅដល់ទីប្រថាប់របស់ព្រះដ៏មានព្រះភាគ រួចហើយបានទូលប្រាស្រ័យល្មមរលឹកដល់គ្នាហើយ ទើបអង្គុយក្នុងទីដ៏សមគួរមួយ សច្ចកនិគ្រន្ថអង្គុយរួចហើយទើបទូលថា ព្រះគោតម មានសមណៈ និងព្រាហ្មណ៍មួយពួកឧស្សហ៍ប្រកបកាយភាវនា តែពុំបានប្រកបចិត្តភាវនាទេ សមណព្រា- ហ្មណ៍ពួកនោះ រមែងប្រសព្វទុក្ខវេទនាដែលកើតក្នុងសរីៈរាងកាយ ព្រះគោតម រឿងធ្លាប់មានមកហើយ កាលបុគ្គលត្រូវទុក្ខវេទនាដែលកើតក្នុងសរីរៈរាងកាយប៉ះខ្ទប់ហើយ ហទយៈនឹងបែកខ្លះ ឈាមក្តៅនឹងខ្ពុរចេញពីមាត់ខ្លះ "ពួកដែលបំពេញកាយភាវនានោះ"នឹងដល់នូវការកើតឆ្កួតខ្លះ មានចិត្តវាយ

មាយខ្លះ ចិត្តរមែងរេទៅតាមកាយរបស់អ្នកនោះ ក៏ប្រព្រឹត្តទៅតាមអំណាចកាយនុះ កើតព្រោះអ្វី កើតព្រោះមិនអប់រំចិត្ត។

សច្ចកនិគ្រន្ថទូលសួរតទៅថា ព្រះគោតម រឿងធ្លាប់មានមកហើយ កាលបុគ្គលត្រូវទុក្ខវេទនា ដែលកើតក្នុងចិត្តប៉ះខ្ទប់ហើយសេចក្តីទាស់ចិត្តមានខ្លះ ហទយៈបែកខ្លះ ឈាមក្តៅខ្ពុរចេញពីមាត់ខ្លះ ពួកបំពេញចិត្តភាវនានោះ នឹងដល់នូវការកើតឆ្កួត មានចិត្តរាយមាយ កាយរមែងរេទៅតាមចិត្តរបស់អ្នកនោះ ប្រព្រឹត្តទៅតាមអំណាចចិត្ត នេះកើតព្រោះមិនអប់រំកាយ, ព្រះគោតម ខ្ញុំព្រះករុណា មានតម្រិះថា ពួកសាវ័ករបស់ព្រះគោតម រមែងឧស្សាហ៍ប្រកបចិត្តភាវនាយ៉ាងពិតប្រាកដ តែពុំបានឧស្សាហ៍ប្រកបកាយភាវនាទេ។

កាលសច្ចកនិគ្រន្ថ ទូលយ៉ាងនេះ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលអគ្គិវេស្សនៈ កាយភាវនា ដែលលោកស្តាប់មកហើយ តើយ៉ាងណា?

សច្ចកនិគ្រន្ថថា ព្រះគោតម លោកនន្ទ វច្ឆគោត្រ លោកកិស្សៈ សង្កិច្ចគោត្រ លោកមក្ខលិគោសាល ក៏លោកទាំងនោះជាអ្នកអាក្រាតកាយបោះបង់ចរិយាមារយាទចោល ជូតឧច្ចារៈដែលបន្ទោបង់ដោយដៃ មិនទៅទទួលភិក្ខា តាមផ្ទះដែលគេអញ្ជើញ មិនឈប់តាមកន្លែងដែលគេអញ្ជើញឲ្យឈប់ មិនត្រេកអរ នឹងភិក្ខាដែលគេយកមកឲ្យ មិនត្រេកអរភិក្ខាដែលគេឲ្យចំ

ពោះមិនត្រេកអរនឹងការនិមន្ត មិនទទួលភិក្ខាដែលគេឲ្យពីមាត់ឆ្នាំង,មិនទទួលភិក្ខាដែលគេឲ្យពីមាត់ជាល មិនទទួលភិក្ខាក្នុងទីដែលមានធរណី និងកំណាត់ឈើ ឬមានអង្រ្គែនៅចន្លោះ កណ្តាលមិនទទួលភិក្ខារបស់មនុស្ស២នាក់ ដែលកំពុងស៊ីមិនទទួលភិក្ខារបស់ស្រ្តី. មានភគ៌របស់ស្រ្តី កំពុងបំបៅកូន របស់ស្រ្តីដែលមានសហាយ មិនទទួលភិក្ខារដែលគេណាត់គ្នាធ្វើ ក្នុងទីដែលគេចិញ្ចឹមសុនខ និងក្នុងទីដែលរុយរោមមិនទទួលត្រី មិនទទួលសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកដែលគេត្រាំ ដោយសម្ភារៈទទួលភិក្ខាក្នុងផ្ទះតែមួយខ្លះ ទទួលតែមួយពំនូតខ្លះ ទទួលក្នុងផ្ទះ ២ខ្នងខ្លះ ទទួលតែ ២ពំនូតខ្លះ ។ល។ទទួលក្នុងផ្ទះ៧ខ្នងខ្លះ ទទួលត្រឹម៧ពំនូតខ្លះ លៀងខ្លួនដោយភិក្ខាតែមួយមុខខ្លះ២មុខខ្លះ។ល។៧មុខខ្លះ លេបអាហារ មានចន្លោះថ្ងៃ១ខ្លះ។ល។ ៧ថ្ងៃខ្លះ ឧស្សាហ៍ប្រកបរឿយៗ ក្នុងការស៊ីភត្តតាមវារៈ ទោះ បីមានវារៈកន្លះខែ ឃើញជាក់ស្តែង រមែងមានដូច្នេះ។

ព្រះដ៏មានព្រះភាគ ត្រាស់សួរថា ម្នាលអគ្គីវេស្សនៈ បុគ្គលទាំងនោះលៀងខ្លួនដោយភត្តនោះ តែ១មុខឬ?។

សច្ចកនិគ្រន្ថទូលថា មិនមែនដូច្នោះទេ ព្រះគោតមជួនកាលលោកទាំងអស់នោះ បរិភោគអាហារភោជនយ៉ាងឆ្ងាញ់ ស៊ីភក្សរបស់យ៉ាងឆ្ងាញ់ ផឹកទឹកបរិសុទ្ធល្អៗធ្វើឲ្យរាងកាយមានកំលាំង ធាត់ដុះពោះស្អុយ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ ពួកទាំងនោះលះទុក្ករកិច្ចនោះហើយបំរុងកាយនេះ ជាខាងក្រោយ កាលបើដូច្នោះកាយនេះក៏មានសេចក្តីចំរើន និងសេចក្តីវិនាសទៅ ហើយព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលអគ្គិវេស្សនៈ ចិត្តភាវនា លោកបានស្តាប់មកហើយ តើយ៉ាងណា? សច្ចកនិគ្រន្ថ ព្រះដ៏មានព្រះភាគត្រាស់សួរក្នុងចិត្តភាវនា មិនអាចទូលប្រាប់ បាន។

ខណៈនោះព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈកាយភាវនាមុននោះ លោកចំរើនហើយ ឯកាភាវនានោះមិនប្រកបដោយធម៌ក្នុងវិន័យរបស់ព្រះអរិយៈលោកនៅមិនទាន់ដឹងកាយភាវនាផង តើឲ្យដឹងចិត្តភាវនាមកពីណា?ម្នាលអគ្គិវេស្សនៈ បុគ្គលដែលមានកាយមិនបានអប់រំហើយមានចិត្តអប់រំហើយ នឹងដែលមានកាយអប់រំហើយ មានចិត្តអប់រំហើយ កើត បានដោយហេតុយ៉ាងណា?លោកចូរស្តាប់ហេតុនោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងពោល,សច្ចកនិគ្រន្ថ ព្រមទទួលពីព្រះដ៏មានព្រះភាគហើយ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ ក៏បុគ្គលដែលមានកាយមិនបានអប់រំ មានចិត្តមិនបានអប់រំ តើដូចម្តេច?ម្នាលអគ្គិវេស្សនៈ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មានសុខវេទនាកើតឡើង គេត្រូវសុខវេទនាប៉ះខ្ទប់ហើយ មានសេចក្តីត្រេកអរខ្លាំងក្នុងសុខវេទនាផង ដល់នូវ

សេចក្តីជាអ្នកត្រេកអរខ្លាំងក្នុងសុខវេទនាផង សុខវេទនារបស់គេនោះ រមែងរលត់ទៅ ព្រោះសុខវេទនារលត់ ក៏មានទុក្ខវេទនាកើតឡើង គេត្រូវទុក្ខវេទនាប៉ះខ្ទប់ហើយ ក៏សៅសោកលំបាកចិត្ត កន្ទក់កន្ទេញ គក់ទ្រូង កើតវង្វេង សូម្បីសុខវេទនានោះ កើតឡើងហើយដល់គេ ក៏គ្រប់សង្កត់ចិត្តព្រោះហេតុមិនបានអប់រំកាយ ទោះបីទុក្ខវេទនាកើតឡើងហើយ គ្រប់សង្កត់ចិត្តព្រោះហេតុមិនបានអប់រំចិត្ត ម្នាលអគ្គិវេស្សនៈ ទោះបីសុខវេទនាកើតឡើងដល់បុថុជ្ជន អ្នកណាមួយ ក៏គ្រប់សង្កត់ចិត្តតាំងនៅ ព្រោះហេតុដែលមិនបានអប់រំកាយ ទោះបីទុក្ខវេទនាកើតឡើងហើយ ក៏គ្រប់សង្កត់ចិត្តតាំងនៅព្រោះហេតុដែលបានអប់រំចិត្តទាំងពីរយ៉ាងនេះដូច្នេះ ម្នាលអគ្គិវេស្សនៈ បុគ្គលដែលមានកាយមិនបានអប់រំ មានចិត្តមិនបានអប់រំ ក៏យ៉ាងនេះឯង សម្រាប់បុគ្គលដែលមានកាយអប់រំហើយ មានចិត្តអប់រំហើយនោះ តើយ៉ាងណា?។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអគ្គិវេស្សនៈ ក៏បុគ្គលដែលមានកាយអប់រំហើយ មានចិត្តអប់រំហើយ តើយ៉ាងណា? ម្នាលអគ្គិវេស្សនៈ អរិយសាវ័កក្នុងធម្មវិន័យនេះ អ្នកបានស្តាប់ មានសុខវេទនាកើតឡើង គេត្រូវសុខវេទនាប៉ះខ្ទប់ហើយ មិនមានសេចក្តីត្រេកអរក្នុងសុខវេទនា មិនដល់

នូវសេចក្ដីជាអ្នកត្រេកអរខ្លាំងក្នុងសុខវេទនាផង សុខវេទនារបស់គេនោះ រមែងរលត់ទៅ ព្រោះសុខវេទនារលត់ ក៏មានទុក្ខវេទនាកើតឡើង គេត្រូវទុក្ខវេទនាប៉ះខ្ទប់ហើយ ក៏មិនសៅសោក មិនលំបាកចិត្ត មិនខ្សឹបខ្សួល មិនកន្ទក់កន្ទេញ គក់ទ្រូង មិនវង្វេង ទោះបីសុខវេទនានោះកើតឡើង ដល់អរិយសាវ័ក ក៏មានគ្រប់សង្កត់ចិត្តតាំងនៅ ព្រោះហេតុតែអប់រំកាយ ទោះបីទុក្ខវេទនាកើតឡើង ក៏មិនគ្រប់សង្កត់ចិត្ត និងតាំងនៅ ព្រោះហេតុបានអប់រំចិត្ត ម្នាលអគ្គិវេស្សនៈ ទោះបីសុខវេទនាកើតឡើង ដល់អរិយសាវ័កណាមួយ ក៏មិនគ្រប់ចិត្តតាំងនៅ ព្រោះលោកបានអប់រំកាយ ទោះបីទុក្ខវេទនាកើតឡើង ក៏មិនគ្រសង្កត់ចិត្តតាំងនៅ ព្រោះហេតុបានអប់រំចិត្តទាំងឡាយយ៉ាងនេះដូច្នេះ, ម្នាលអគ្គិវេស្សនៈ បុគ្គលដែលមានកាយអប់រំហើយ មានចិត្តអប់រំហើយយ៉ាងនេះឯង។

សច្ចកនិគ្រន្ថទូលថា បើដូច្នេះ ខ្ញុំព្រះករុណា ជ្រះថ្លាចំពោះព្រះគោតម មានកាយអប់រំហើយ មានចិត្តអប់រំហើយ។

ព្រះដ៏មានព្រះភាគត្រាស់ថា វាចានេះ លោកយកមកនិយាយប្រៀនធៀបជាមួយតថាគតដោយពិត តែថាតថាគតប្រាប់ដល់លោក , ម្នាលអគ្គិវេស្សនៈ កាលណាតថាគត កោរសក់ និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសា

វពស្ត្រចេញបួសជាបព្វជិត កាលនោះចិត្តរបស់តថាគត ត្រូវសុខវេទនាកើតឡើងគ្របសង្កត់តាំងនៅនេះ មិនមែនជាឋានៈដែលនឹងគប្បីមានបានឡើយ។

សច្ចកនិគ្រន្ថទូលថា សុខវេទនាដែលកើតឡើង ល្មមគ្របសង្កត់ចិត្តតាំងនៅ ឬទុក្ខវេទនាដែលកើតឡើងល្មមគ្របសង្កត់ចិត្តតាំងនៅ វេទនាដូចនេះ រមែងមិនកើតឡើងដល់ព្រះគោតមដ៏ចម្រើនដោយពិត។

កាលសច្ចកនិគ្រន្ថទូលយ៉ាងនេះព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលអគ្គិវេស្សនៈ ដូចម្តេចវេទនាទាំង២នោះ មិនគប្បីមានដល់តថាគត ម្នាលអគ្គិវេស្សនៈ តថាគតនឹងថ្លែងឲ្យស្តាប់ .....កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹង មុនត្រាស់ដឹងបានមានតម្រិះថា ឃរាវាសជាទីចង្អៀតចង្អល់ ជាផ្លូវហូរមកនៃធូលីបព្វជ្ជាជាផ្លូវទំនេរ ការដែលតថាគត នៅគ្រប់គ្រងផ្ទះ ចង់ប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ និងបរិសុទ្ធ ដូចស័ង្ខ ខាត់មិនមែនធ្វើបានដោយងាយ តើដូចម្តេច បានជាតថាគត កោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាវពស្ត្រចេញបួសជាបព្វជិតក្នុងសម័យតមកតថាគតកំពុងនៅជាកម្លោះ មានកេសាខ្មៅស្រិប នៅជាសម្លោះរឹងបឹងតាំងនៅក្នុងបឋមវ័យ កាលព្រះមាតាព្រះបិតាមិនប្រាថ្នាចង់ឲ្យបួស មានព្រះភក្ត្រជោកដោយទឹកព្រះនេត្រទ្រង់ព្រះកន្សែង បានកោរសក់ និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ចេញបួសជាបព្វជិតកាលបួសរួច

ហើយ ក៏ស្វែងរកធម៌ថា អ្វីជាកុសល កាលស្វែងរកផ្លូវដ៏ស្ងប់យ៉ាងប្រសើរ ទើបចូលទៅដល់សំណាក់អាឡារតាបសកាលាមគោត្រ ហើយពោលថា លោកកាលាមៈ ខ្ញុំនឹងប្រព្រឹត្តព្រហ្មចរិយៈ ក្នុងធម្មវិន័យនេះកាលតថាគត ពោលដូច្នេះហើយ លោកអាឡារតាបសកាលាមគោត្រ ទើបពោលនឹងតថា-គតថា អញ្ជើញលោកនៅចុះធម៌ដែលវិញ្ញូជនគប្បីលុះព្រោះធ្វើឲ្យជាក់ច្បាស់

ដោយសេចក្តីដឹងយ៉ាងក្រៃលែងដោយខ្លួនឯង តាមបែបអាចារ្យរបស់ខ្លួនអស់កាលមិនយូរនេះដូចគ្នា តថាគតសិក្សាធម៌នោះបានយ៉ាងរហ័សមិនយឺតយូរមួយខណៈហាមាត់និយាយប៉ុណ្ណោះ ក៏ពោលបាននូវញាណវាទៈ និងថេរ វាទៈហើយ ទាំងតថាគត និងអ្នកដទៃ ក៏ជ្រាបច្បាស់ថា តថាគតដឹង តថាគតឃើញ។

ព្រះដ៏មានព្រះភាគ ត្រាស់ទៅថា តថាគតទើបត្រិះរិះតទៅថា លោកអាឡារតាបសកាលាមគោត្រ មិនប្រាប់ធម៌នេះថា យើងធ្វើជាក់ច្បាប់ដោយសេចក្តីដឹងដ៏ក្រៃលែងខ្លួនឯង ហើយចូលដល់ដោយហេតុគ្រាន់តែសេចក្តីជឿតែម្យ៉ាង តាមពិតអាឡារតាបសកាលាមគោត្រ ក៏ដឹងឃើញធម៌នេះស្រាប់ គ្រានោះតថាគតបានចូលទៅរកអាឡារតាបសកាលាមគោត្រ ហើយសួរថា លោកកាលាមៈលោកធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយសេចក្តីដឹងក្រៃលែង

ដោយខ្លួនឯង បានលុះហើយ ទើបប្រាប់ដោយហេតុប៉ុន្មាន? កាលតថាគត សួរយ៉ាងនេះ លោកអាឡារតាបស ក៏ប្រាប់សមាបត្តិថ្នាក់អាកិញ្ចញ្ញាយតនៈ តថាគតទើបត្រិះរិះថា មិនមែនមានសទ្ធា វីរិយៈ សតិ សមាធិ និងបញ្ញា តែលោកអាឡារតាបសកាលាមគោត្រប៉ុណ្ណោះ សូម្បីតថាគតក៏មានសទ្ធា វីរិយៈ សតិ សមាធិ និងបញ្ញាដូចគ្នា ទោះបីយ៉ាងណា យើងគប្បីព្យាយាយដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលលោកអាឡារតាបសកាលាមគោត្រប្រាប់ថា យើងអាចធ្វើឲ្យជាក់ច្បាស់ដោយសេចក្ដីដឹងក្រៃលែងបាន យើងក៏ធ្វើឲ្យជាក់ ច្បាស់នូវធម៌នោះដោយសេចក្ដីដឹងដ៏ក្រៃលែង ចូលដល់យ៉ាងឆាប់មិនបាន យឺនយូរ គ្រានោះតថាគតចូលទៅរកលោកអាឡារតាបសកាលាមគោត្រ ហើយសួរថា លោកកាលាមៈ លោកធ្វើឲ្យជាក់ច្បាស់នូវធម៌នេះដោយ សេចក្ដីដឹងដ៏ក្រៃលែងខ្លួនឯង លុះហើយទើបប្រាប់ដោយហេតុប៉ុណ្ណោះឬ? លោកអាឡារតាបសក៏ប្រាប់ថា ម្នាលលោកដ៏មានអាយុ យើងធ្វើឲ្យជាក់ ច្បាស់នូវធម៌នេះ ដោយសេចក្ដីដឹងដ៏ក្រៃលែងដោយខ្លួនឯង បានលុះហើយ ទើបប្រាប់ដោយហេតុប៉ុណ្ណោះឯង ទើបយើងប្រាប់ថា ម្នាលលោកដ៏មាន អាយុ សូម្បីខ្ញុំព្រះករុណា ក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយសេចក្ដីដឹងដ៏ក្រៃលែងដោយខ្លួនឯង លុះហើយដោយហេតុប៉ុណ្ណោះ។

លោកអាឡារតាបស ពោលតទៅថា ម្នាលលោកដ៏មានអាយុជាលាភរបស់ពួកយើង ពួកយើងល្អហើយដែលបានឃើញសព្រហ្មចារីល្អដូចលោក យើងធ្វើឲ្យជាក់ច្បាស់នូវធម៌ណា ដោយសេចក្តីដ៏ក្រៃលែងខ្លួនឯង.លុះហើយ

ទើបប្រាប់ បានលោកក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយសេចក្តីដឹងក្រៃលែងខ្លួនឯង លុះហើយទើបប្រាប់ដោយប្រការដូច្នេះ។ យើងដឹងធម៌ណា លោកក៏ដឹងធម៌នោះ គឺថាយើងដូចម្តេច លោកក៏ដូច្នោះ លោកដូចម្តេច យើងក៏ដូច្នោះ ដោយប្រការដូច្នោះ មកចុះឥឡូវនេះយើងទាំងពីរនៅរួម រស់ជាមួយគ្នា គ្រប់គ្រងគណៈនេះ។ ម្នាលអគ្គិវេស្សនៈ លោកអាឡារតាបស កាលាមគោត្រ ទាំងជាអាចារ្យយើង ក៏លើកតម្កើងយើងជាសិស្សស្មើនឹងខ្លួនផង បូជាយើងដោយការបូជាយ៉ាងល្អផង យើងទើបមានសេចក្តីប្រាកដក្នុងចិត្តថា ធម៌នេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីសេចក្តីប្រាសចាចតម្រេក ដើម្បីសេចក្តីរលត់ ដើម្បីសេចក្តីស្ងប់ ដើម្បីសេចក្តីដឹងដ៏ក្រៃលែង ដើម្បីសេចក្តីត្រាស់ដឹងព្រម ដើម្បីនិព្វានត្រឹមតែប្រព្រឹត្តទៅដើម្បីចូលដល់អាកិញ្ចញ្ញាយតនៈភពប៉ុណ្ណោះ តថាគតមិនពេញចិត្តធម៌នោះ ទើបជៀសចេញទៅ។

ម្នាលអគ្គិវេស្សនៈ យើងខំស្វែងរកថា តើអ្វីជាកុសល កាលស្វែង រកផ្លូវស្ងប់យ៉ាងប្រសើរដល់កំពូល តថាគតទើបចូលទៅដល់សំណាក់ឧទក-តាបសរាមបុត្រ ហើយពោលថា លោករាមៈ ខ្ញុំមានប្រាថ្នាចង់ប្រព្រឹត្តព្រហ្ម ចរិយៈនៅក្នុងធម្មវិន័យនេះ កាលតថាគតពោលយ៉ាងនេះហើយ លោកឧទ- កតាបសរាមបុត្រ ទើបពោលនឹងតថាគតថា អញ្ជើញលោកនៅចុះ ធម៌ដែលវិញ្ញូជន គប្បីលុះនៅព្រោះធ្វើឲ្យជាក់ច្បាស់នូវសេចក្ដីដឹងដ៏ក្រៃលែងខ្លួនឯងតាមបែបអាចារ្យរបស់ខ្លួនអស់កាលមិនយូរនេះក៏ដូចគ្នា យើងសិក្សាធម៌នេះឆាប់រហ័សមិនយូរ មួយខណៈហាមាត់ចរចាប្រាស្រ័យប៉ុណ្ណោះ ក៏ពោលបាននូវញាណវាទៈ និងថេរវាទៈ ហើយទាំងយើង ទាំងអ្នកដទៃក៏ជ្រាបច្បាស់ថាយើងដឹងយើងឃើញ យើងទើបត្រិះរិះថា លោករាមៈមិនប្រាប់ធម៌នេះថាយើងធ្វើឲ្យជាក់ច្បាស់ដោយសេចក្ដីដឹងដ៏ក្រៃលែងខ្លួនឯង ហើយចូលដល់នូវដោយហេតុគ្រាន់តែសេចក្ដីជឿតែម្យ៉ាង ដោយពិតលោករាមៈ ក៏ដឹងឃើញធម៌នេះ។

គ្រានោះតថាគត ចូលទៅរកឧទកតាបសរាមបុត្រហើយសួរថា.លោករាមៈ លោកធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយសេចក្ដីដឹងដ៏ក្រៃលែងខ្លួន ឯងលុះហើយប្រាប់ដោយហេតុប៉ុន្មាន ? កាលតថាគតសួរយ៉ាងនេះហើយ ឧទកតាបសរាមបុត្រ ក៏ប្រាប់សមាបត្តិថ្នាក់នេវសញ្ញានាសញ្ញាយតនៈ តថា

គតទើបត្រិះរិះថា មិនមែនមានសទ្ធា វិរិយៈ សតិ សមាធិ និងបញ្ញា តែ លោករាមៈប៉ុណ្ណោះទេ ទោះបីយើងក៏មានសទ្ធា វិរិយៈ សតិ សមាធិ និង បញ្ញាដូចគ្នា បើទោះបីយ៉ាងណាយើងគប្បីព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលលោករាមៈប្រាប់ថា យើងធ្វើឲ្យជាក់ច្បាស់ដោយសេចក្តីដឹងដ៏ក្រៃលែងខ្លួនឯង ហើយបិតនៅ តថាគតក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយសេចក្តីដឹងដ៏ក្រៃលែងខ្លួនឯង ដោយឆាប់រហ័សមិនយឺតយូរ គ្រានោះតថា គតចូលទៅរកឧទកតាបសរាមបុត្រ ហើយសួរថា លោករមៈ លោកធ្វើឲ្យ ជាក់ច្បាស់នូវធម៌នេះ ដោយសេចក្តីដឹងដ៏ក្រៃលែងខ្លួនឯង លុះហើយទើប ប្រាប់ដោយហេតុប៉ុណ្ណោះឬ? លោកឧទកតាបសក៏ប្រាប់ថា ម្នាលលោកដ៏ មានអាយុយើងធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយសេចក្តីដ៏ក្រៃលែងខ្លួនឯង លុះហើយ ទើបប្រាប់ដោយហេតុត្រឹមប៉ុណ្ណោះ យើងទើបប្រាប់ថា លោកដ៏ មានអាយុទោះបីខ្ញុំម្ចាស់ក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នេះដោយសេចក្តីដឹងដ៏ក្រៃលែងខ្លួនឯង លុះហើយដោយហេតុប៉ុណ្ណោះ។

ឧទកតាបសពោលថា ម្នាលលោកដ៏មានអាយុ ជាលាភរបស់ពួកយើង ល្អហើយដែលពួកយើងបានឃើញសព្រហ្មចារីដូចលោកហើយធ្វើឲ្យជាក់ច្បាស់នូវធម៌ឯណា ដោយសេចក្តីដឹងដ៏ក្រៃលែងខ្លួនឯង លុះហើយ

ទើបប្រាប់បាន លោកក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយសេចក្តីដឹងដ៏ក្រៃលែងខ្លួនឯង លុះហើយឋិតនៅ លោកធ្វើឲ្យជាក់ច្បាស់នូវធម៌ឯណា ដោយសេចក្តីដឹងដ៏ក្រៃលែងខ្លួនឯងលុះហើយឋិតនៅ យើងក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយសេចក្តីដឹងដ៏ក្រៃលែងហើយប្រាប់ដោយប្រការដូច្នោះ។ យើងដឹងនូវធម៌ឯណា លោកក៏ដឹងនូវធម៌នោះ លោកដឹងនូវធម៌ឯណា យើងដឹងនូវធម៌នោះ គឺថា យើងដូចម្តេច លោកក៏ដូច្នោះ លោកដូចម្តេច យើងក៏ដូច្នោះដោយប្រការដូច្នេះ។ មកចុះឥឡូវនេះយើងទាំង២នាក់ នៅរួមរស់ជាមួយគ្នាគ្រប់គ្រងគណៈនេះ ម្នាលអគ្គិវេស្សនៈ លោកឧទកតាបសរាមបុត្រទាំងជាអាចារ្យ យើងក៏លើកតម្កើងយើងជាសិស្សស្មើដោយខ្លួនផងបូជាយើងផង ការបូជាយ៉ាងល្អផង យើងទើបមានសេចក្តីប្រាកដក្នុងចិត្តថា ធម៌(គឺ នេវសញ្ញានាសញ្ញាយតនៈ)នេះ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីសេចក្តីប្រាសចាកតម្រេក ដើម្បីសេចក្តីស្ងប់ ដើម្បីសេចក្តីរលត់ ដើម្បី សេចក្តីដឹងដ៏ក្រៃលែង ដើម្បីសេចក្តីត្រាស់ដឹងព្រម ដើម្បីនិព្វាន ត្រឹមតែប្រ ព្រឹត្តទៅដើម្បីចូលដល់នេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះ តថាគតមិន ពេញចិត្តក្នុងធម៌នោះ រអាក្នុងធម៌នោះ ទើបបានចៀសចេញទៅ។

ព្រះដ៏មានព្រះភាគត្រាស់ អំពីការស្វែងរកផ្លូវត្រាស់ដឹងរបស់ព្រះអង្គមុនដែលយើងបានជាព្រះពុទ្ធ តទៅថា ម្នាលអគ្គិវេស្សនៈ តថាគតស្វែងរក

ថា អ្វីជាកុសល កាលស្វែងរកផ្លូវស្ងប់យ៉ាងប្រសើរដល់កំពូល ទើបចារិក ទៅកាន់មគធជនបទ ដោយលំដាប់ក៏លុះដល់តំបន់ឧរុវេលាសេនានិគមបាន ឃើញភូមិភាគជាទីគួររីករាយដងព្រៃខៀវស្រស់បំព្រង មានទឹកហូរមានស្ទឹង ទឹកថ្លាស្អាត មានកំពង់រាបស្មើគួរជាទីរីករាយ គោចរគ្រាមក៏តាំងនៅដោយជុំវិញ ទើបទ្រង់តម្រិះថា ភូមិភាគនេះ សមគួរបំពេញសេចក្ដីព្យាយាម ទើបអង្គុយក្នុងទីនោះ ដោយគិតថា ទីនេះសមគួរដល់ការបំពេញព្យាយាម។

ម្នាលអគ្គិវេស្សនៈ គ្រានោះឧបមា ៣ ខ ដែលមិនគួរអស្ចារ្យដែលតថាគតមិនធ្លាប់បានឬមកពីមុន មកប្រាកដជាក់ច្បាស់ដល់តថាគត:

ឧបមា ខ ទី១ ថា ប្រៀបដូចឈើស្រស់មានជ័រ គេដាក់ត្រាំក្នុងទឹក បុរសកាន់យកឈើកោសភ្លើង មកកោសដោយសង្ឃឹមថា អញនឹងញុំាងឲ្យភ្លើងប្រាកដឡើង ម្នាលអគ្គិវេស្សនៈ តើលោកសម្គាល់សេចក្ដីនោះដូចម្ដេច បុរសនោះយកឈើកោសភ្លើង កោសលើឈើស្រស់មានជ័រ គេត្រាំងក្នុងទឹក គប្បីញុំាងភ្លើងឲ្យកើតប្រាកដបានខ្លះឬទេហ្ន៎! សច្ចកនិគ្រន្ថទូលថា រឿងនេះប្រព្រឹត្តទៅមិនបានឡើយ ព្រះគោតមដ៏ចម្រើន ពីព្រោះអ្វី ព្រោះថា ឈើស្រស់នោះមានជ័រ ទាំងត្រាំងនៅក្នុងទឹកបុរស់នោះមានតែសេចក្ដីនឿយហត់លំបាកទទេ។ ម្នាលអគ្គិវេស្សនៈយ៉ាងនេះដូចគ្នាដែរ សមណព្រាហ្មណ៍ឯណានីមួយ នៅមិនទាន់ចៀសចេញចាកកាមដោយកាយ នៅមានសេចក្ដី

ស្រលាញ់ស្នេហា ពេញចិត្តសេចក្ដីវង្វេង សេចក្ដីស្រេកឃ្លាន សេចក្ដីក្រវល់ក្រវាយព្រោះកាម ក្នុងកាមទាំងឡាយនៅមិនទាន់លះ នៅមិនរម្ងាប់ សមណព្រាហ្មណ៍អ្នកចម្រើនទាំងនោះ ទោះបីសោយទុក្ខវេទនាខ្លាំងក្លា គ្រោតគ្រាតក្តៅក្រហាយដែលកើតព្រោះ សេចក្ដីព្យាយាមក្ដី ឬមិនបានសោយទុក្ខវេ ទនាដូច្នោះក្ដី ក៏ជាអ្នកមិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីសេចក្ដីត្រាស់ដឹង ដ៏ប្រសើរនេះឯង ឧបមាទី១ ដែលមិនគួរអស្ចារ្យ ដែលតថាគតមិនធ្លាប់ស្ដាប់មកពីកាលមុន មកប្រាកដជាក់ច្បាស់ហើយដល់តថាគត។

ឧបមា ២ ទី២ ថា ប្រៀបដូចឈើស្រស់មានជ័រ ដែលគេដាក់នៅលើគោកឆ្ងាយពីទឹក បុរសកាន់យកឈើកោសភ្លើង មកកោសជាមួយគ្នា សង្ឃឹមថាអញនឹងញ៉ាំងភ្លើងឲ្យប្រាកដឡើង ម្នាលអគ្គិវេស្សនៈ អ្នកសម្គាល់ សេចក្ដីនោះដូចម្ដេច បុរសនោះយកឈើកោសភ្លើង កោសលើឈើស្រស់ ដែលគេដាក់នៅគោក ឆ្ងាយពីទឹក តើធ្វើឲ្យភ្លើងប្រាកដបានខ្លះឬទេ ?សច្ចក និគ្រន្ថទូលថា រឿងនេះប្រព្រឹត្តទៅមិនបានឡើង ព្រះគោតមដ៏ចម្រើន ពី ព្រោះអ្វី ព្រោះឈើនៅស្រស់ មានជ័រ ហើយគេដាក់នៅលើគោកឆ្ងាយពី ទឹក បុរសនោះមានតែសេចក្ដីនឿយហត់ទទេ ព្រះដ៏មានព្រះភាគត្រាស់ថា ហេតុនោះដូចគ្នាដែរ សមណព្រាហ្មណ៍ឯណា ទោះបីចេញចាកកាមដោយ កាយហើយក៏ដោយ តែបើចិត្តនៅមានស្នេហាស្រលាញ់វង្វេង ក្តៅក្រហាយ

ក្រវល់ក្រវាយ ព្រោះថាក្នុងកាមទាំងឡាយ នៅមិនទាន់បានលះ មិនទាន់បានរម្ងាប់ សមណព្រាហ្មណ៍អ្នកចម្រើនទាំងនោះ ទើបសោយទុក្ខវេទនាយ៉ាងចាស់ក្លាយ៉ាងក្តៅផ្សា ដែលកើតព្រោះសេចក្តីព្យាយាមក្តី ឬមិនបានសោយទុក្ខវេទនាដូច្នោះក្តី ក៏ជាអ្នកមិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងដ៏ប្រសើរ នេះជា ឧបមា ៖ ទី២ ដែលមិនគួរអស្ចារ្យ ដែលតថាគតមិនធ្លាប់បានស្តាប់ពីមុន មកប្រាកដជាក់ច្បាស់ដល់តថាគត។

ឧបមា ៖ ទី៣ ថា ប្រៀបដូចឈើស្ងួត ដែលគេទុកលើគោកឆ្ងាយពីទឹក បុរសកាន់យកឈើកោសភ្លើង មកកោសដោយសង្ឃឹមថា អញនឹង ញុំាងឲ្យភ្លើងកើតប្រាកដ ម្នាលអគ្គិវេស្សនៈ អ្នកសម្គាល់សេចក្តីនោះថា ដូចម្តេច បុរសនោះយកឈើកោសភ្លើង កោសដាក់លើឈើស្ងួត ដែលគេ ដាក់លើគោកឆ្ងាយពីទឹក គប្បីញុំាងឲ្យភ្លើងកើតឡើងប្រាកដបានខ្លះ ឬទេ ហ្ន៎! សច្ចកនិគ្រន្ថទូលថា បើយ៉ាងនោះព្រះគោតមដ៏ចម្រើន កើតភ្លើងបាន ព្រោះឈើស្ងួតគេនៅលើគោកឆ្ងាយពីទឹក ព្រះដ៏មានព្រះភាគត្រាស់ថា ដូច គ្នាអញ្ចឹងដែរសមណព្រាហ្មណ៍រូបណាមួយ ចៀសចេញចាកកាមដោយកាយ ហើយទាំងលះនិងរម្ងាប់ សេចក្តីពេញចិត្ត សេចក្តីស្នេហា សេចក្តីវង្វេង សេចក្តីស្រេកឃ្លាន សេចក្តីក្រវល់ក្រវាយ ព្រោះតែកាមក្នុងកាមទាំងឡាយ ជាខាងក្នុងហើយ សមណព្រាហ្មណ៍ អ្នកចម្រើនទាំងនោះ ទោះបីសោយ ទុក្ខវេទនា

យ៉ាងខ្លាំងក្លាយ៉ាងគ្រោតគ្រាតយ៉ាងខ្លោចផ្សា ដែលកើតអំពីសេ ចក្តីព្យាយាម ក្តី មិនបានសោយក្តី ក៏ជាអ្នកដើម្បីដឹង ដើម្បីឃើញ ដើម្បី សេចក្តីត្រាស់ដឹងដ៏ប្រសើរនេះឯង ជាឧបមាដែលមិនគួរអស្ចារ្យ ដែលតថា គតមិនធ្លាប់បានឬបានស្តាប់មកពីមុន ប្រាកដជាក់ច្បាស់ដល់តថាគត ឧបមាដែលមិនគួរអស្ចារ្យទាំង៣ខ នេះ តថាគតមិនធ្លាប់បានស្តាប់មកពីមុន មក ប្រាកដជាក់ច្បាស់ដល់តថាគត។

តទៅព្រះដ៏មានព្រះភាគទ្រង់ដំណាលអំពីការបំពេញទុក្ករកិរិយា របស់

ព្រះអង្គថា: ម្នាលអគ្គិវេស្សនៈតថាគតទ្រង់តម្រិះថា ប្រសិនណាអញ យកធ្មេញខាំនឹងធ្មេញ យកអណ្តាតទល់ពិតានទប់ទុកឲ្យណែន យកចិត្តអត់សង្កត់ចិត្តឲ្យក្តៅ(ប្រហែលបានត្រាស់ដឹង)ពេលនោះ តថាគតក៏ខាំធ្មេញជាមួយធ្មេញ យកអណ្តាតទល់ពិដានទុកឱ្យណែន យកចិត្តសង្កត់ចិត្តឱ្យក្តៅ កាលតថាគតធ្វើដូច្នេះ ញើសក៏ហូរស្រក់ចេញពីក្លៀកទាំងពីរ ប្រៀបដូច បុរសមានកំលាំងខ្លាំង ចាប់បុរសដែលមានកំលាំងខ្សោយ ត្រង់ក្បាល ឬត្រង់ក ហើយច្របាច់រឹតទុកឲ្យណែនដូច្នោះ។

ម្នាលអគ្គិវេស្សនៈ តថាគតប្រារព្ធសេចក្តីព្យាយាម មិនបានបន្ធូរបន្ថយ មានសតិតម្កល់មាំ មិនរវើរវាយ តែមានកាយក្រវល់ប្រវាយមិនស្ងប់

រម្ងាប់ ព្រោះសេចក្តីព្យាយាមដែលអត់ធន់បានដោយកម្រ ចុកសៀត តែទុក្ខវេទនាដែលកើតឡើងនោះ មិនបានគ្របសង្កត់ចិត្តតថាគតឡើង តថាគតតាំងនៅបាន។

ម្នាលអគ្គិវេស្សនៈ តថាគតមានតម្រិះថា អញនឹងចម្រើនឈាន ដែលមិនមានខ្យល់ក្នុងប្រាណ គិតដូច្នោះហើយ តថាគតក៏អត់ដង្ហើមចេញនិងដង្ហើមចូលតាមមាត់ តាមច្រមុះ ឯខ្យល់នោះក៏ចេញតាមត្រចៀកទាំង សងខាងមានសំឡេងឬអ៊ូអរ ដូចសំឡេងស្នប់ជាងទង ដែលគេកំពុងសប់ដូច្នោះ។ ម្នាលអគ្គិវេស្សនៈ តថាគតប្រារព្ធសេចក្តីព្យាយាម មិនបន្ធូរបន្ថយ មានសតិតម្កល់មាំ មិនវង្វេងវាយតែមានកាយក្រវល់ក្រវាយ មិនស្ងប់រម្ងាត់ ព្រោះសេចក្តីព្យាយាមដែលអត់ធន់បានដោយកម្រ ចុកសៀត តែទុក្ខវេទនាដែលកើតឡើងនេះ មិនបានគ្របសង្កត់ចិត្តតថាគតឡើង អាចតាំងនៅបាន។

ម្នាលអគ្គិវេស្សនៈ តថាគតមានតម្រិះថា បើដូច្នោះ អញគប្បីចម្រើនឈាន ដែលមិនមានខ្យល់ប្រាណចុះ តថាគតដ៏អត់ដង្ហើមចេញដង្ហើមចូលតាមមាត់ តាមច្រមុះ និងតាមប្រហោងត្រចៀក កាលបើតថាគតអត់ដង្ហើមចេញ ដង្ហើមចូល តាមមាត់ តាមច្រមុះ តាមប្រហោងត្រចៀកពេលនោះខ្យល់ជាច្រើនក៏ចុកសៀត ក្បាលដូចបុរសដែលមានកម្លាំងខ្លាំង យកកាំបិតកោរយ៉ាងមុត អារក្បាលដូច្នោះ។

ម្នាលអគ្គិវេស្សនៈ តថាគតប្រារព្ធសេចក្ដីព្យាយាមមិនបន្ធូរបន្ថយមានសតិតម្កល់មាំ មិនវង្វេងវង្វាយ តែមានកាយក្រវល់ក្រវាយមិនស្ងប់រម្ងាប់ ព្រោះសេចក្ដីព្យាយាមដែលអត់អន់បានដោយកម្រកំពុងចុកសៀត តែទុក្ខវេទនាដែលកើតឡើយនេះ មិនបានគ្របសង្កត់ចិត្តតថាគតឡើយ។

ម្នាលអគ្គិវេស្សនៈ តថាគតមានតម្រិះថា អញគប្បីចម្រើនឈានដែលមិនមានខ្យល់ប្រាណចុះ តថាគតក៏ប្រឹងអត់ដង្ហើមចេញដង្ហើមចូល តាមមាត់ តាមច្រមុះ តាមប្រហោងត្រចៀក កាលតថាគតអត់ដង្ហើមចេញ ដង្ហើមចូល តាមមាត់ តាមច្រមុះ តាមប្រហោងត្រចៀក ក៏មានទុក្ខវេទនាក្នុងក្បាលយ៉ាងខ្លាំង ដូចបុរសមានកម្លាំងយកខ្សែព្រ័ត្រចងរឹតនូវក្បាលដូច្នោះ។

ម្នាលអគ្គិវេស្សនៈ តថាគតប្រារព្ធសេចក្ដីព្យាយាម មិនបន្ធូរបន្ថយមានសតិតម្កល់មាំ មិនវង្វេងវង្វាយ តែមានកាយក្រវល់ក្រវាយមិនស្ងប់ស្ងាត់ ព្រោះសេចក្ដីព្យាយាមដែលអត់ធន់បានដោយកម្រកំពុងចុកសៀត តែទុក្ខវេ-ទនាដែលកើតឡើងនេះ មិនបានគ្របសង្កត់ចិត្តតថាគតឡើយ។

ម្នាលអគ្គិវេស្សនៈ តថាគតមានតម្រិះថា បើដូច្នោះអាត្មាអញគប្បីចម្រើនឈានដែលមិនមានខ្យល់ប្រាណចុះ ពេលនោះ តថាគត អត់ដង្ហើមចេញ និងអត់ដង្ហើមចូលតាមមាត់ តាមច្រមុះ តាមប្រហោងត្រចៀក ពេល

នោះមានខ្យល់ជាច្រើន បណ្តាលឲ្យឈឺពោះ ដូចនាយគោឃាតឬកូនសិស្ស របស់នាយគោឃាតដ៏ឆ្ងាត យកកាំបិតសម្រាប់ពន្វះសាច់គោដ៏មុតពន្វះពោះ ដូច្នោះ។

ម្នាលអគ្គិវេស្សនៈ តថាគតប្រារព្ធសេចក្តីព្យាយាម មិនបន្ធូរបន្ថយ មានសតិតម្កល់មាំ មិនវង្វេងវង្វាយ តែមានកាយក្រវល់ក្រវាយមិនស្ងប់រម្ងាប់ ព្រោះសេចក្តីព្យាយាមដែលអត់ធន់បានដោយកម្រកំពុងចុកសៀតទុក្ខវេទនា ដែលកើតឡើងនេះ មិនបានគ្របសង្កត់ចិត្តតថាគតឡើង។

ម្នាលអគ្គិវេស្សនៈ តថាគតមានតម្រិះថា អញនឹងចម្រើនឈាន ដែលមិនមានខ្យល់ប្រាណចុះ តថាគតក៏អត់ដង្ហើមដូច្នោះ កាលតថាគតអត់ដង្ហើម ដូច្នោះ ក៏មានសេចក្តីក្តៅផ្សាក្នុងរាងកាយយ៉ាងខ្លាំង ដូចបុរសមានកម្លាំង ២នាក់ ជួយគ្នាចាប់បុរសម្នាក់ ដែលមានកម្លាំងខ្សោយ ត្រង់ដៃទាំង២ ហើយ ឲ្យក្តៅអប់នៅជិតរណ្តៅ រងើកភ្លើងដូច្នោះ។

ម្នាលអគ្គិវេស្សនៈ តថាគតប្រារព្ធសេចក្តីព្យាយាម មិនបន្ធូរបន្ថយ មានសតិតម្កល់មាំ មិនវង្វេងវង្វាយ តែមានកាយក្រវល់ក្រវាយមិនស្ងប់រម្ងាប់ ព្រោះសេចក្តីព្យាយាមដែលអត់ធន់បានដោយកម្រកំពុងចុកសៀត តែទុក្ខវេទនាដែលកើតឡើងនេះ មិនបានគ្របសង្កត់ចិត្តតថាគតឡើយ។

ម្នាលអគ្គិវេស្សនៈ ទេវតាទាំងឡាយ បានឃើញតថាគតហើយនាំគ្នាពោលថា ព្រះសមណគោត្តម ធ្វើកាលៈហើយ ពួកខ្លះពោលថា នៅមិនទាន់ធ្វើកាលៈ ពួកខ្លះពោលថា ព្រះសមណៈគោតម នៅមិនទាន់ធ្វើកាលៈ តែ ក៏ជិតនឹងធ្វើកាលៈ ពួកខ្លះពោលថា ព្រះសមណៈគោតម មិនទាន់ធ្វើកាលៈ ទាំងមិនទាន់ជិតធ្វើកាលៈ ព្រះសមណគោតមនឹងបានជាព្រះអរហន្ត ការឃើញជាក់ស្ដែងនេះ ជាវិហារធម៌របស់លោកជាព្រះអរហន្ត ។

ម្នាលអគ្គិវេស្សនៈ តថាគតមានតម្រិះថា អត្មាអញគប្បីបដិបត្តិ អត់អាហារដោយប្រការទាំងពួងចុះ ពេលនោះពួកទេវតាចូលមកដល់តថាគតហើយពោលថា បពិត្រលោកអ្នកនិរទុក្ខ លោកកុំបដិបត្តិអត់អាហារ ដោយប្រការទាំងពួងឡើយ បើលោកបដិបត្តិអត់អាហារដោយប្រការទាំងពួងលោក នឹងបានញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយឱជាហារនោះ តថាគតមានតម្រិះ ថា អញប្ដេជ្ញាថា នឹងផ្ដាច់អាហារដោយប្រការទាំងពួង តែទេវតាទាំងនេះ នឹងដាក់ឱជាហារតាមរន្ធរោមរបស់អញ អញនឹងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយឱជាហារនោះ ការប្ដេជ្ញានោះក៏ជាមុសាដល់អាត្មាអញ តថាគតគប្បី ហាមទេវតាទាំងនោះថា រឿងនោះមិនគួរ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ តថាគតមានតម្រិះថា អញគប្បីបរិភោគអាហារ បន្ថយម្ដងបន្តិចៗដល់ត្រឹមមួយក្ដាប់ដៃខ្លះ ប៉ុន

គ្រាប់សណ្តែកបាយខ្វះ ប៉ុនគ្រាប់សណ្តែកខ្មៅខ្វះ ប៉ុនគ្រាប់ឈូកខ្វះ តថា គតបរិភោគអាហារ បន្ថយកាន់តែតិចទៅៗដូច្នោះទាន់តែមានរាងកាយស្គមកំព្រឹង នៅសល់តែអវយវៈតូចធំ ដូចវល្លិ៍មានមុខដំណាប្រើន និងវល្លិ៍មានថ្នាំងស្វិត សាច់ថ្គាល់គូថស្វិតដូចសត្វអូដ្ឋ សន្ទាក់ឆ្អឹងខ្នងផុសជាបន្ទា ដូច វល្លិ៍ជណ្តើរស្វា ឆ្អឹងជំនីរទាំងពីរខាងផុសរ៉ាង ដូចបង្កង់សាលាចាស់ គ្រាប់ ភ្នែកទាំងពីរលឹបគ្រលុង ដូចដួងតារានៅក្នុងអណ្តូងជ្រៅ មើលឃើញតែស្រមោល ស្បែកស្រោបលលាក្បាលក៏រួញស្វិត ដូចផ្លែឃ្លោកគេកាត់មកពី ទងកំពុងនៅខ្ចី ត្រូវក្តៅ ត្រូវខ្យល់ ក៏ស្វិតស្រពោន តថាគតស្ទាបអង្អែលពោះ ក៏ស្ទាបប៉ះឆ្អឹងខ្នង កាលណានឹកឃើញចង់ស្ទាបឆ្អឹងខ្នង ក៏ចាប់ដល់ ពោះ ព្រោះពោះរបស់តថាគតផតជាប់ដល់ឆ្អឹងខ្នង កាលនឹកថា ចត់បន្ទោ របង់ឧច្ចារៈ បស្សាវៈ ក៏ដើរទ្រេតទ្រោត ដួលទៅក្នុងទីនោះ កាលចង់ឲ្យ កាយសប្បាយខ្វះ យកដៃស្ទាបខ្លួន រោមទាំងឡាយដែលមានឫសស្អុយ ក៏ សណ្តកចាករាងកាយ ព្រោះថាអ្នកមានអាហារតិច មនុស្សទាំងឡាយបាន ឃើញតថាគត ក៏ពោលថា ព្រះសមណគោតមមានពណ៌ ខ្មៅពួកខ្វះនិយាយថា មិនខ្មៅ មិនជាំ គ្រាន់តែពពាល តថាគតធ្លាប់តែមានពណ៌សម្បុរបរិ- សុទ្ធផូរផង់តែខូចពណ៌សម្បុរទៅ ព្រោះជាអ្នកមានអាហារតិចនោះឯង។

ម្នាលអគ្គិវេស្សនៈ តថាគតមានតម្រិះថា សមណព្រាហ្មណ៍ឯណាមួយ ក្នុងអតីតៈ អនាគត ឬបច្ចុប្បន្ន ដែលសោយទុក្ខវេទនាខ្លាំងក្លា គ្រោត គ្រាត ដុតកំលោច កើតឡើងព្រោះសេចក្ដីព្យាយាមទុក្ខវេទនាយ៉ាងក្រៃលែង ក៏មានត្រឹមប៉ុណ្ណោះឯង មិនហួសពីនេះទៀតទេប៉ុណ្ណោះ តថាគតនៅតែមិនបានលុះញាណទស្សនៈដ៏វិសេសដល់ព្រះអរិយៈ ដ៏ក្រៃលែងលើសធម៌របស់មនុស្ស ដោយទុក្ខកិរិយាដ៏ក្ដៅផ្សានេះ ប្រហែលផ្លូវត្រាស់ដឹង គប្បីមានផ្លូវដទៃដឹង?។

តថាគតទើបមាន តម្រិះថា អញចាំបាន កាលបុណ្យច្រត់ព្រះនង្គ័លរបស់ស្ដេចសក្កាធិបតីដែលជាព្រះបិតា អញអង្គុយនៅក្រោមម្លប់ព្រីងដ៏ត្រជាក់បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានលុះបឋមជ្ឈាន មានវិតក្កៈ វិចារៈ បីតិ សុខៈ ដែលកើតអំពីវិវេក ផ្លូវនោះ ជាផ្លូវត្រាស់ដឹងទេដឹង? តថាគតមានវិញ្ញាណ រលឹកដោយសតិថា ផ្លូវនោះ ជាផ្លូវត្រាស់ដឹង តថាគតទើបមានតម្រិះថាអញខ្លាចសេចក្ដីសុខ ដែលវៀរ ចាកកាម និងអកុសលធម៌ទាំងឡាយឬ? ហើយតថាគតក៏ត្រិះរិះតទៅថា អញមិនខ្លាចសុខដូច្នោះឡើយម្នាលអគ្គិវេស្សនៈ តថាគតត្រិះរិះតទៅថា សេ ចក្ដីសុខនោះ អញតថាគតមាន កាយស្គមខ្លាំង មិនអាចដើម្បីបដិបត្តិឲ្យ បានលុះសច្ចធម៌ដោយងាយឡើយអញគប្បីបរិភោគអាហារគឺបាយ និងនំ

កុម្មាស ឲ្យបានឆ្អែតស្កប់ស្កល់ ឲ្យមានកម្លាំង តថាគតក៏បរិភោគអាហារ គឺបាយ និងនំកុម្មាស ឲ្យឆ្អែតស្កប់ស្កល់ គ្រានោះភិក្ខុទាំង៥រូប (គឺបញ្ចវគ្គីយ) ដែលនៅបំរើតថាគតដោយសង្ឃឹមថា ព្រះសមណគោតមបានលុះធម៌ពេល ណា នឹងប្រាប់ធម៌នោះដល់យើងទាំងឡាយលុះបានឃើញតថាគតបរិភោគ អាហារ គឺបាយធ្និន និង នំកុម្មាស កាលនោះភិក្ខុទាំង៥រូប ក៏អស់សង្ឃឹម ឈប់បំរើតថាគតនាំគ្នា ជៀសចេញទៅដោយគិតថា ព្រះសមណគោតម នេះលោកច្រើនឈប់ព្យាយាម វិលមកដើម្បីសេចក្តីលោកទៅវិញ។

ព្រះដ៏មានព្រះភាគត្រាស់ថាតទៅទៀតថា ម្នាលអគ្គិវេស្សនៈ តថាគតបរិភោគអាហារ ធ្វើឲ្យកាយមានកម្លាំងហើយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ លុះបឋមជ្ឈាបមានវិតក្កៈ វិចារៈ បីតិ សុខ កើតអំពីវិវេក សូម្បីសុខវេទនាដែលកើតឡើងឃើញច្បាស់ ក៏មិនបានគ្របសង្កត់ចិត្តតថាគត តថា គតលុះទុតិយជ្ឈាន មានសេចក្តីផូរផង់នៃចិត្ត ខាងក្នុងធម៌ឯកផុសឡើ ព្រោះវិតក្កៈ វិចារៈ ស្ងប់រម្ងាប់មិនមានវិតក្កៈ មិនមានវិចារៈ មានបីតិ និង សុខកើតអំពីសមាធិតថាគតមានឧបេក្ខា មានសតិ សម្បជញ្ញៈ សោយសុខដោយនាមកាយ ព្រោះបីតិអស់ទៅ បានលុះតតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយសរសើរថា អ្នកបានឈាននេះ ជាអ្នកមានឧបេក្ខា មានសតិ តថា

គតបានលុះចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខព្រោះលះសុខ និង ទុក្ខ និងរលត់សោមនស្ស ទោមនស្ស ក្នុងកាលមុនបាន មានឧបេក្ខាជា ហេតុឲ្យសតិបរិសុទ្ធ សុខវេទនា ដែលកើតឡើងនេះ ក៏មិនបានគ្របសង្កត់ ចិត្តរបស់តថាគតឡើង។

តថាគត កាលមានចិត្តជាសមាធិ បរិសុទ្ធិផូរផង់ មិនមានកិលេស ប្រាសចាកឧបកិលេស គួរដល់ការងារ តាំងមាំមិនញាប់ញ័រក៏បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញាណ តថាគតរមែងរលឹកជាតិដែលធ្លាប់នៅអាស្រ័យក្នុងកាលមុនបានច្រើន គឺរលឹកបាន១ជាតិខ្លះ ២ជាតិខ្លះ។ល។ រលឹកជាតិដែលអាស្រ័យនៅជាច្រើន ទាំងអាការៈទាំងឧទ្ទេស ដោយប្រការដូច្នេះ ម្នាលអគ្គិវេស្សនៈ ក្នុងបឋមយាមនៃរាត្រី តថាគតបានលុះនូវវិជ្ជាទី១នេះ កាលតថាគតមិនប្រមាទ មានសេចក្តីព្យាយាមបញ្ជូនចិត្តទៅអវិជ្ជាតថាគតកំចាត់ចោលហើយ វិជ្ជាកើតឡើងហើយ សេចក្តីងងឹតតថាគតកំចាត់បង់ហើយ ពន្លឺកើតឡើងហើយ សុខវេទនាដែលកើតឡើងហើយនេះ មិនបានគ្របសង្កត់ចិត្តតថាគតឡើយ។

ព្រះដ៏មានព្រះភាគ ត្រាស់តទៅថា តថាគតកាលចិត្តជាសមាធិ បរិសុទ្ធិផូរផង់ មិនមានកិលេស ប្រាសចាកឧបកិលេស គួរដល់ការងារ តាំងមាំ

មិនញាប់ញ័រយ៉ាងនេះ ក៏បង្អោនចិត្តទៅដើម្បីចុតូបបាតញ្ញាណ តថាគតឃើញពួកសត្វដែលកំពុងចុតិ កំពុងឧប្បត្តិ ថោកទាប ប្រណីត មានពណ៌សម្បុរល្អ មានពណ៌សម្បុរអាក្រក់ ស្តុកស្តម្ភ ក្រខ្សត់ ដោយទិព្វចក្ខុដ៏បរិ សុទ្ធិកន្លងលើសចក្ខុរបស់មនុស្ស រមែងដឹងច្បាស់នូវសត្វដែលប្រព្រឹត្តទៅ តាមកម្ម។ល។ ម្នាលអគ្គិវេស្សនៈ ក្នុងមជ្ឈិមយាមនៃរាត្រី តថាគតបានលុះ វិជ្ជាទី២ កាលតថាគតមិនប្រមាទ មានសេចក្តីព្យាយាម បញ្ជូនចិត្តទៅអវិជ្ជា តថាគតកំចាត់បង់ហើយ វិជ្ជាកើតឡើងហើយ សេចក្តីងងឹត តថាគតកំចាត់ បង់ហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ សុខវេទនាដែលកើតឡើងនេះមិន បានគ្របសង្កត់ចិត្តតថាគតឡើយ អាចតាំងនៅបាន។

តថាគតកាលចិត្តជាសមាធិ បរិសុទ្ធិផូរផង់ មិនមានកិលេសប្រាសចាកឧបកិលេសខ្សោយ គួរដល់ការងារ តាំងមាំមិនញាប់ញ័រយ៉ាងនេះ ក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ រមែងដឹងច្បាស់តាមពិតថា នេះទុក្ខនេះទុក្ខសមុទយះ នេះទុក្ខនិរោធៈនេះ ទុក្ខនិរោធគាមិនីបដិបទាទាំងនេះអា-សវៈ នេះអាសវសមុទយៈនេះ អាសវនិរោធៈ នេះអាសវនិរោធគាមិនីប ដិបទា កាលតថាគតដឹងឃើញយ៉ាងនេះ ចិត្តក៏សណ្តោកផុតហើយ ចាកកាមាសវៈ ចាកភវាសវៈចាកអវិជ្ជាសវៈ កាលចិត្តសណ្តោកផុតហើយ ក៏មានញាណដឹងថាផុតហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈបាននៅ

ចប់ហើយកិច្ចដែលគួរធ្វើ បានធ្វើរួចហើយ កិច្ចដទៃក្រៅពីនេះ មិនមានឡើង ម្នាលអគ្គិវេស្សនៈ ក្នុងបច្ឆិមយាមនៃរាត្រី តថាគតបានលុះវិជ្ជាទី៣នេះកាល តថាគតមិនប្រមាទ មានសេចក្ដីព្យាយាម បញ្ជូនចិត្តទៅអវិជ្ជាតថាគតកំចាត់ចេញហើយ វិជ្ជាកើតឡើងហើយ សេចក្ដីងងឹត តថាគតកំចាត់បង់ហើយ ពន្លឺភ្លឺស្វាងកើតឡើតហើយ សុខវេទនា ដែលកើតឡើងជាក់ស្ដែងនេះ មិន បាន គ្របសង្កត់ចិត្តរបស់តថាគតអាចតាំងនៅបាន។ព្រះដ៏មានព្រះភាគត្រាស់តទៅទៀតថា ម្នាលអគ្គិវេស្សនៈ តថាគតដឹងខ្លួនឯងថា ជាអ្នកសម្ដែងធម៌ដល់បរិស័ទទាំងឡាយ ច្រើនរយ សូម្បីតែបុគ្គលម្នាក់ៗ រមែងសម្គាល់ខ្លួនឯងយ៉ាងនេះថា ព្រះសមណគោតម សំដែងធម៌ប្រារព្ធខ្លួនអញប៉ុណ្ណោះ លោកកុំគប្បីយល់យ៉ាងនោះ ព្រះតថាគត រមែងសំដែងធម៌ដល់បុគ្គលទាំងអស់នោះដោយប្រពៃ ដើម្បីប្រយោជន៍ឲ្យដឹងច្បាស់តែម្យ៉ាង តថាគតផ្គងចិត្តស្ងប់ តាំងមាំ ធ្វើឲ្យជាសមាធិខាងក្នុង ក្នុងសមាធិនិមិត្តខាងដើម ទាល់តែ ចប់គាថានោះតែម្ដង តថាគត នៅដោយផលសមាធិ ជាសុញ្ញតៈរហូតជាប់ ជានិច្ច។

សច្ចកនិគ្រន្ថទូលថា រឿងនោះគួរជឿចំពោះព្រះគោតម អ្នកជាព្រះអរហន្តសម្មាសម្ពុទ្ធ តែព្រះគោតមរមែងដឹងថា ព្រះអង្គជាអ្នកលក់ក្នុកណ្ដាលថ្ងៃខ្លះឬ?។

ព្រះដ៏មានព្រះភាគត្រាស់ ម្នាលអគ្គិវេស្សនៈ តថាគតដឹងថា ក្នុងខែរដូវក្ដៅ តថាគតត្រឡប់ពីបិណ្ឌបាតក្រោយភត្ត ក្រាលសង្ឃាដិធ្វើជា៤ជាន់ ហើយជាអ្នកមានសតិសម្បជញ្ញៈ ឈានចូលសេចក្ដីលក់ ដោយបែរខាងស្ដាំ។

សច្ចកនិគ្រន្ថទូលថា ព្រះគោតមដ៏ចម្រើន សមណព្រាហ្មណ៍មួយពួក រមែងពោលសេចក្ដីនោះ ថាជាអ្នករស់នៅដោយសេចក្ដីវង្វេង ។ព្រះដ៏មានព្រះភាគត្រាស់ថា បុគ្គលជាវង្វេង រឺមិនវង្វេងដោយហេតុត្រឹមប៉ុណ្ណោះ មិនមាន, ក៏បុគ្គលជាអ្នកវង្វេង រឺមិនវង្វេងដោយហេតុណា លោកចូរធ្វើទុកក្នុងចិត្តឲ្យជាប់ចុះ តថាគតនឹងពោលឥឡូវនេះ សច្ចកនិគ្រន្ថទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគហើយ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ តើដូចម្ដេចបុគ្គលអ្នកវង្វេង អាសវៈទាំងឡាយ ដែលធ្វើឲ្យសៅហ្មង ឲ្យកើតក្នុងភពថ្មី ឲ្យមាន សេចក្ដីក្រវល់ក្រវាយ មានវិបាកទុក្ខ ឲ្យមានជាតិ ជរា មរណៈតទៅ បុគ្គល ណាមួយនៅលះមិនបាន តថាគតពោលថា អ្នកនោះជាអ្នកវង្វេង ព្រោះ ហេតុថានៅលះអាសវៈមិនបាន អាសវៈឡាំងឡាយដែលធ្វើឲ្យសៅហ្មង ឲ្យ កើតក្នុងភពថ្មី ឲ្យមានសេចក្ដីក្រវល់ក្រវាយ មានវិបាកទុក្ខ មានជាតិ ជរា មរណៈតទៅ។បុគ្គលណាមួយលះបានហើយ តថាគតពោលថា អ្នកនោះជា អ្នកមិន

វង្វេងបុគ្គលនោះរាប់ថាជាអ្នកមិនវង្វេង ព្រោះហេតុលះបង់បាននូវ អាសវៈទ្បាំងឡាយ។

ម្នាលអគ្គិវេស្សនៈ អាសវៈទាំងឡាយ ដែលធ្វើឲ្យសៅហ្មងឲ្យកើតក្នុងភពថ្មី ឲ្យមានសេចក្ដីក្រវល់ក្រវាយ មានវិបាកទុក្ខឲ្យមានជាតិ ជរា មរណៈតទៅ តថាគតលះបានហើយ មានឫសកាត់ផ្ដាច់ហើយ ធ្វើមិនឲ្យមានទីតាំង ដូចដើមត្នោតកំបុតចុងធ្វើមិនឲ្យកើតតទៅ មិនមានការកើតតទៅជាធម្មតា ដូចគ្នានឹងដើមត្នោត ដែលគេកាត់ចុងចេញហើយ មិនអាចលូតលាស់តទៅ។

កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ សច្ចកនិគ្រន្ថទូលថា ព្រះគោតមដ៏ចម្រើន រឿងដែលលោកពោលមកហើយនោះ គួរឲ្យអស្ចារ្យមិនធ្លាប់មាន ព្រះគោត្តដ៏ចម្រើន ខ្ញុំមកសន្ទនាប៉ះពាល់ទាំងសាកសួរដោយពាក្យដែលតាក់តែងមកយ៉ាងនេះ ក៏នៅតែមានពណ៌សម្បុរស្រស់ថ្លាទាំងមាន ទឹកមុខស្រស់បស់ ព្រោះលោកជាព្រះអរហន្តសម្មាសម្ពុទ្ធ. ព្រះគោតមដ៏ ចម្រើន ខ្ញុំព្រះករុណាចាំបានថា ខ្ញុំព្រះករុណាជាអ្នកប្រារព្ធចោទឆ្លើយវាទះ ជាមួយលោកបូរណកស្សបៈ ទោះបីលោកបូរណកស្សបៈនោះប្រារព្ធឆ្លើយ

ធ្វងវាទៈ ជាមួយខ្ញុំព្រះករុណាក៏លោកយករឿងដទៃមកនិយាយបំភាន់ត្រឡប់

ត្រឡិន ហើយដឹកនាំទាញឲ្យនិយាយរឿងផ្សេងទៅវិញ ទាំងធ្វើសេចក្ដីក្រោធឲ្យកើតប្រាកដ ព្រះគោតមដ៏ចម្រើន ខ្ញុំព្រះករុណាជាអ្នកប្រារព្ធចោទធ្វើយវាទៈជាមួយលោកមក្ខលិគោសាល...លោកអជិតកេសកម្ពលៈ.....លោកបកុធកច្ចាយនៈ...លោកសញ្ជ័យវេលដ្ឋបុត្រ លោកសច្ចកនិគ្រន្ថនាដបុត្រ ឯលោកនិគ្រន្ថនាដបុត្រ ប្រារព្ធធ្វើយធ្វងវាទៈជាមួយខ្ញុំព្រះករុណាក៏យករឿងដទៃមកនិយាយបន្ទប់ទៅវិញ ឲ្យទាក់ទាញឲ្យនិយាយរឿងក្រៅ ទាំងធ្វើសេចក្ដីក្រោធខឹងឲ្យកើតប្រាកដ ចំណែកព្រះគោតមដ៏ចម្រើន ខ្ញុំព្រះករុណាមកសន្ទនា ប៉ះពាល់ ទាំងសាកសួរដោយពាក្យដែលតាក់តែងមកយ៉ាងនេះ ក៏ព្រះអង្គនៅតែមានពណ៌សម្បុរស្រស់ថ្លា ទាំងមានទឹកមុខស្រស់បស់ ព្រោះលោកជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះគោតមដ៏ចម្រើន បើដូច្នោះខ្ញុំព្រះករុ-ណា សូមលាទៅឥឡូវនេះខ្ញុំព្រះករុណាមានកិច្ចច្រើនមានធុរៈត្រូវធ្វើច្រើនៗ

ព្រះដ៏មានព្រះភាគត្រាស់ថា លោកចូរសម្គាល់កាលដ៏សមគួរ ក្នុងឥឡូវនេះចុះ គ្រានោះសច្ចកនិគ្រន្ថរីករាយត្រេកអរ នឹងភាសារបស់ព្រះដ៏មានព្រះភាគ ក្រោកចាកអាសនៈហើយចេញទៅ ក៏សន្មតថាចប់រឿងរ៉ាវរបស់សច្ចកនិគ្រន្ថ តាមដែលដំណាលទុកក្នុងមហាសច្ចកសូត្រត្រឹមប៉ុណ្ណោះៗ

សច្ចកនិគ្រន្ថព្រមទទួលព្រះអង្គថា ជាព្រះអរហន្តសម្មាសម្ពុទ្ធ តែក៏មិនបានជ្រះថ្លា ជាការគួរសម ពោលទៅក៏មិនបានថ្វាយបង្គំ ឬធ្វើទក្សិណដូចអ្នកដទៃដែលជ្រះថ្លាទាំងឡាយ ទើបមានបញ្ហាថាហេតុអ្វី ព្រះដ៏មានព្រះភាគ ទើបទ្រង់សំដែងធម៌ដល់អ្នកដែលមិនជ្រះថ្លា?។

រឿងនេះព្រះអដ្ឋកថាពន្យល់ថា ដើម្បីឲ្យជាឧបនិស្សយប្បច្ច័យទៅអនាគត ព្រោះព្រះដ៏មានព្រះភាគទ្រង់ជ្រាបដោយព្រះញាណថាកាលព្រះអង្គបរិនិព្វានទៅបាន២០០ឆ្នាំជាង សាសនាព្រះអង្គ ត្រូវទៅតាំងនៅកោះលង្កាដល់បច្ចុប្បន្ននេះ ឯសច្ចកនិគ្រន្ថនឹងបានទៅកើតក្នុងទីនោះ បានរៀនព្រះត្រៃបិដក ហើយចេញបួសចម្រើនវិបស្សនា បានសម្រេចព្រះអរហន្តព្រមដោយបដិសម្ភិទាមានឈ្មោះថា ព្រះកាឡពុទ្ធរក្ខិត។

រឿងរ៉ាវក្នុងជាតិចុងក្រោយគឺ មានរឿងដំណាលថា កាលព្រះពុទ្ធសាសនា ទៅតាំងមាំក្នុងកោះលង្កាហើយ សច្ចកនិគ្រន្ថ បានចុតិអំពីទេវលោកចុះមកកើតជាបុត្ររបស់អាមាត្យម្នាក់ នៅក្នុងតំបន់មួយដែលជាទីគោចរបិណ្ឌបាតរបស់ភិក្ខុទាំងឡាយ ក្នុងវត្តទក្ខិណាគិរីវិហារ បានមានសេចក្តីជ្រះថ្លាក្នុងភិក្ខុទាំងឡាយនោះ ទើបចេញបួស បានសិក្សាព្រះត្រៃបិដកទាល់តែចប់ បានទទួលការលើកសរសើរ ឲ្យធ្វើជាអាចារ្យបង្រៀនភិក្ខុ សមណេរ ថ្ងៃមួយ

លោកអាចារ្យ បាននាំកិក្ខុជាច្រើនទៅសួរសុខទុក្ខឧបជ្ឈាយ៍ ព្រះឧបជ្ឈាយ៍គិតថា អញនឹងតឿនសិស្សឲ្យដឹងខ្លួនថា កិច្ចរបស់អ្នកបួសនោះ មិនមែនមានតែត្រឹមរៀនព្រះត្រៃបិដកប៉ុណ្ណោះទេ លោកទើបមិនស្ដីរក។

ព្រះកាឡពុទ្ធរក្ខិត គឺជាសច្ចកនិគ្រន្ថពីជាតិមុន បានសួរអាចារ្យថា លោកធ្វើអ្វីខុសទើបលោកអាចារ្យមិនស្ដីរក ព្រះឧបជ្ឈាយ៍ក៏តបថា លោកដែលមិនស្ដីរកព្រោះលោកយល់ថា ការបួសរបស់លោក ដល់ទីបំផុតហើយដោយរៀនចប់ព្រះត្រៃបិដក ព្រះកាឡពុទ្ធរក្ខិតសួរថា បើដូច្នោះលោកគួរ ធ្វើយ៉ាងណា ព្រះឧបជ្ឈាយ៍ទើបពោលថា លោកចូរលះបង់ពួកគណៈចេញហើយទៅចម្រើនសមណធម៌ ឯចេតិយបព៌តវិហារ ព្រះកាឡពុទ្ធរក្ខិត ក៏បដិបត្តតាមបានទៅចម្រើនសមណធម៌នៅឯចេតិយវិហារ ហើយបានសម្រេចជាព្រះអរន្ត ព្រមដោយបដិសម្ភិទាក្នុងគ្រានោះ ព្រះចៅតិស្សមហារាជស្ដេចយាងទៅចេតិយបព៌តវិហារក្នុងថ្ងៃឧបោសថ ព្រះកាឡពុទ្ធរក្ខិតក៏បានសំដែងធម៌ថ្វាយ ឲ្យព្រះចៅតិស្សមហារាជ ទ្រង់ជ្រះថ្លា នេះជារឿងរ៉ាវរបស់សច្ចកនិគ្រន្ថ ត្រង់ដែលជាព្រះកាឡពុទ្ធរក្ខិត ឥឡូវនេះលោកក៏បរិព្វានទៅហើយព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបទ្រង់សំដែងធម៌ដល់សច្ចកនិគ្រន្ថដែលមិនជ្រះថ្លាក្នុងគ្រានោះ ក៏ដើម្បីឲ្យបានជាឧបនិស្ស័យដល់ ការលុះជាព្រះអរហន្តក្នុងជាតិជាព្រះកាឡពុទ្ធរក្ខិតនោះឯង។

ក្នុងមហាសច្ចកសូត្រនោះ ព្រះដ៏មានព្រះភាគ ទ្រង់សំដែងការអប់រំកាយភាវនា និងចិត្តភាវនាដែលត្រឹមត្រូវ ចាប់ផ្តើមតាំងពីការចម្រើនបឋមជ្ឈានជាដើមទៅ ទាល់តែលុះអាសវក្ខយញ្ញាណជាទីបំផុត ដែលមាននៅក្នុងសាសនានេះប៉ុណ្ណោះ ទ្រង់សំដែងការបំពេញទុក្ករកិរិយា ដែលធ្វើបានដោយកម្រយ៉ាងក្រៃលែងទុកផងដើម្បីឲ្យជ្រាបថា ទុក្ករកិរិយាជាផ្លូវដែល
មិន
ត្រឹមត្រូវ មិនសមគួរដែលអ្នកដទៃ ជាសាវ័ករបស់ព្រះអង្គប្រព្រឹត្តតាម ព្រោះមិនមែនផ្លូវរួចផុតឡើយ។

**ចប់ពុទ្ធជយមង្គលលើកទី ៦**

ជ័យជំនះលើកទី ៧

គាថាទី ៧

**ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជំនះលើននោ្ទបនន្ទនាគរាជ**

នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ។

<u>ប្រែថា</u> ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច

ឲ្យប្លែងជានាគរាជ ទៅទូន្មានព្យសន៍កុជង្គ។
ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធរឿងឫទ្ធិរុង
ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន។
គឺឲ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា។
វីជ័យមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជ័យា ព្រះភគវាឈ្នះនាគហោង។

ព្រះពុទ្ធជយមង្គលគាថាក្នុងសេចក្តីតទៅ ពោលអំពីព្រះដ៏មានព្រះភាគទ្រង់មានជ័យជំនះលើនន្ទោបនន្ទនាគរាជ ដោយរឿងនេះក៏មិនប្រទះឃើញក្នុងព្រះសូត្រទើបសូមរៀបរាប់តាមដីកាពាហុំ។

ក្នុងដីកាពោលថា ព្រះដ៏មានភាគ ទ្រង់ញុំាងមហាមោគ្គល្លាន ឲ្យបង្ក្រាបស្តេចនាគដោយឫទ្ធិ ពោលគឺសម័យមួយព្រះដ៏មានព្រះភាគទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ក្រុងសាវត្ថី ក្នុងព្រឹកថ្ងៃមួយ មុនពេលដែលព្រះដ៏មានព្រះភាគ ស្តេចទៅទទួលភត្តាហារឯផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី វេលាជិតភ្លឺព្រះដ៏មានព្រះភាគទ្រង់ត្រួតពិនិត្យមើលសត្វលោក ក៏ទ្រង់ឃើញនន្ទោបនន្ទនាគរាជ ប្រាកដនៅក្នុងសំណាញ់ញាណរបស់ព្រះអង្គ ទើបទ្រង់ព្រះត-

ម្រិះថា នាគជាសត្វតិរច្ឆាន មិនអាចសម្រេចមគ្គផលបាន តែក៏អាចលះបង់ចេញចាកពីមិច្ឆាទិដ្ឋិបាន ហើយកើតសទ្ធាក្នុងព្រះពុទ្ធសាសនា ស្តេចនាគនេះ មានឫទ្ធិ និងអានុភាពខ្លាំងណាស់ ពិបាករកអ្នកណា ឲ្យទូន្មានបាន ហើយស្រេចនាគនេះជាសាវ័កវេនេយ្យ ពុំមែនជាពុទ្ធវេនេយ្យឡើយគឺជាអ្នកដែលសាវ័កអាចទូន្មានឱ្យលះបង់ព្យសន៍ ព្រះដ៏មានព្រះភាគទ្រង់ពិចារណាឃើញថា មានតែព្រះមហាគ្គលានប៉ុណ្ណោះទើបបង្ក្រាបបាន។

ក្នុងពេលព្រឹក ព្រះដ៏មានព្រះភាគត្រាស់នឹងព្រះអានន្ទ ឲ្យប្រាប់ដល់ភិក្ខុសង្ឃឲ្យបានជ្រាបថា ព្រះអង្គនឹងយាងទៅកាន់ទេវលោក បណ្តាព្រះមហាសាវ័កក៏នាំបរិវារបស់ខ្លួន រៀងៗខ្លួន មកចាំទទួលសម្តេចព្រះដ៏មានព្រះភាគ លុះព្រះដ៏មានព្រះភាគយាងមកដល់ព្រះអង្គក៏ទ្រង់ដឹកនាំព្រះសាវ័កទាំងឡាយនោះ ហោះទៅកាន់ទេវលោក។

គ្រានោះស្តេចនាគ និម្មិត្តកាយយ៉ាងស្អាត ដូចព្រះមហាក្សត្រគង់លើបល្ល័ង្កកែវ សំលឹងមើលរបស់សោយ និងសុរាដ៏មានរសដោយចិត្តរីករាយ លុះឃើញព្រះដ៏មានព្រះភាគ និងពួកព្រះសាវ័កកំពុងហោះមក ក៏ក្រោធខឹងថា សមណៈទាំងនេះ ប្រហែលទៅកាន់តាវតិង្ស តែបើទៅក៏ទៅចុះ កុំឲ្យហោះរំលងអញ ឃើញថាខុសចិត្តគ្នាជាប្រកដ អញក៏មានអានុភាពច្រើន បើសមណៈទាំងនេះ ហោះពីលើអញទៅ ល្អងធូលីដែលជាប់នឹងជើង ក៏រុះ

ធ្លាក់មកលើក្បាលអញ គួរតែអញឡើងទៅហាម កុំឲ្យហោះរំលងអញ គិតហើយក៏យកកន្ទុយរុំពទ្ធ័ភ្នំព្រះសុមេរុ ដែលមានកម្ពស់ ៨២០០០ យោជន៍បាន៧ជុំ បើកពពារឡើង បិទក្រុងតាវតិង្ស ដែលមានបរិវេណ ១២យោជន៍. ហើយប្រាកដខ្លួន នៅលើកំពូលភ្នំព្រះសុមេរុនោះ បណ្ដាលឲ្យមានពពក អណ្ដែកអ័ព្ទងងឹតទូទៅទាំងអស់។

លំដាប់នោះ ព្រះរដ្ឋបាលត្ថេរទូលសួរ អំពីសេចក្ដីអស្ចារ្យនោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យបានជ្រាប ព្រះរដ្ឋបាលបានជ្រាបហើយ ក៏ក្រាបទូលយកអាសាទៅបង្ក្រាបនាគនោះ ព្រះដ៏មានព្រះភាគទ្រង់ហាម ឯព្រះអរហន្តទាំងឡាយ ក៏ក្រាបទូលយកអាសាព្រះអង្គក៏ទ្រង់ហាមដូចគ្នា ដោយទ្រង់ជ្រាបថា មិនមែនជាវិស័យរបស់ព្រះអរហន្តទាំឡាយនោះឡើយ លុះកាលព្រះមហាមោគ្គល្លានក្រាបទូលយកអាសា ព្រះដ៏មានព្រះភាគទើបទ្រង់អនុញ្ញាត ព្រមទាំងទ្រង់ឲ្យពរឲ្យមានជ័យជំនះ លើស្ដេចនាគ។

ព្រះមហាមោគ្គល្លាន លុះបានទទួលពុទ្ធានុញ្ញាតហើយ ក៏គិតថា ស្ដេចនាគរាជនេះ យល់ថា កាយរបស់ខ្លួននោះ ធំហើយវែងលើសប្រមាណ គ្មាននរណាប្រៀបបាន ទើបមានគំនិតមិនល្អចំពោះព្រះដ៏មានព្រះភាគ ចាំអាត្មាអញទៅទូន្មានឲ្យអស់ព្យសន៍ លោកគិតដូច្នេះហើយ ក៏និម្មិត្តកាយជាស្ដេចនាគមានរាងកាយវែងហើយធំជាងស្ដេចនាគនន្ទោបនន្ទដល់២ដង

មាន ពពារប្រមាណមួយសែនកោដិប្រដាប់ ទៅដោយកែវ និងមាសយ៉ាងល្អ ហើយរឹតកាយរបស់ស្តេចនាគនោះ ឲ្យណែនផ្ទាប់ទៅនឹងភ្នំព្រះសុមេរុ មិនឲ្យកំរើករួច ចំណែកស្តេចនាគ បានត្រូវនាគព្រះមហាមោគ្គល្លានរឹតស្ទើរនឹងបែកឆ្អឹង ក៏ក្រោធខឹងខ្លាំងណាស់ ទើបព្រួសពិសឲ្យចេញជាផ្សែងផ្សាយទៅជុំវិញ ដល់មួយសែនកោដិចក្រវាឡ តែព្រះមហាមោគ្គល្លាន ក៏បណ្តាលឲ្យផ្សែងកើតឡើងច្រើនលើសពីនោះទៀត បង្ក្រាបឫទ្ធិរបស់ស្តេចនាគ ឯស្តេចនាគខឹងយ៉ាងក្រៃលែង បានព្រួសផ្សែងពិសចេញជាអណ្តាតភ្លើងក្តៅយ៉ាងខ្លាំង ដែលកើតអំពីអកុសលធម៌គឺទោសៈ ព្រះមហាមោគ្គល្លាន ក៏និម្មិត្តភ្លើងឲ្យក្តៅខ្លាំងជាងកើតឡើង ភ្លើងរបស់ស្តេចនាគ និងភ្លើងព្រះមហាមោគ្គ ល្លានប៉ះខ្ទប់គ្នាភ្លៃរុងរឿងទៅ ៨៤០០០យោជន៍ តាមធម្មតា អណ្តាតភ្លើង របស់ស្តេចនាគ បើព្រួសត្រូវអ្នកណា អ្នកនោះដល់នូវសេចក្តីស្លាប់ តែពុំ អាចធ្វើឲ្យអត្តរាយដល់ព្រះដ៏មហាមោគ្គល្លានបានឡើយ តែភ្លើងដែលព្រះម ហាមោគ្គល្លាននិមិត្តឡើងនោះ គ្រាន់តែរុំជុំវិញ ស្តេចនាគទាំងខាងក្នុងទាំង ក្រៅឲ្យក្តៅរសាប់រសល់ជាខ្លាំង ទើបស្តេចនាគគិតថា សមណអង្គនេះ ឈ្មោះអ្វីទើបមានឫទ្ធិខ្លាំងម៉្លេះ គិតហើយទើបសួរឈ្មោះ ព្រះមហាមោគ្គ ល្លាន ក៏ប្រាប់ឈ្មោះឲ្យជ្រាបថា អាត្មាជាសាវ័កឆ្វេងរបស់ព្រះដ៏មានព្រះភាគ ស្តេ

ចនាគក៏ពោលថា លោកជាសមណៈ ហេតុអ្វីមកធ្វើបាបខ្ញុំ ការធ្វើរបស់លោក មិនសមគួរជាសមណៈឡើយ។

ព្រះមហាមោគ្គល្លានតបថា អាត្មានេះ នឹងប្រកបដោយសេចក្តីក្រោធ ហើយដាក់ទោសលោកនោះមិនមានទេ តែមកទូន្មានលោកនោះ ក៏ប្រាថ្នា ដើម្បីរំដោះលោកចេញពីសេចក្តីយល់ខុស និងឲ្យអស់ព្យសន៍ពុតត្បុតឲ្យ លោកតាំងនៅក្នុងផ្លូវត្រូវវិញ គឺអរិយមគ្គ លោកកុំខឹងនឹងអាត្មាឡើយ ពោលហើយក៏ត្រឡប់គេទមកជាព្រះមហាមោគ្គល្លានវិញ ព្រមទាំងទូន្មានថាលោក នេះជាសត្វតិរច្ឆាន មានសេចក្តីប្រមាទ ពុំដឹងអ្វីជាបុណ្យ អ្វីជាបាប លោក មិនដឹងគុណរបស់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រហូតដល់គុណមាតាបិតា គ្រូ អាចារ្យ តើគួរលះបង់ឬទេ ដែលលោកមកមានសេចក្តីក្រោធខឹងក្នុងព្រះពុទ្ធ និងព្រះសាវ័កដែលហោះមកហើយ ទៅនិម្មិតកាយបិទបាំង ផ្លូវទៅរបស់ ព្រះអង្គ ប្រសិនបើល្អងធូលីព្រះបាទរបស់ព្រះធ្លាក់មកលើព្រះសិរសារបស់ លោក លោកក៏នឹងបាននូវមង្គលដ៏ក្រៃលែងពុំមែនជាអព្វមង្គលឡើយ។

ចំណែកទេវតាទាំងឡាយ និងមនុស្សទាំងពួងសុទ្ធតែប្រណម្យនមស្សការ តាំងសេចក្តីប្រាថ្នានិងបូជាព្រះបាទយុគលរបស់ព្រះដ៏មានព្រះភាគ។

ម្នាលស្តេចនាគរាជ បុគ្គលដែលកើតក្នុងលោកនេះកម្រនឹងបាន ឃើញព្រះពុទ្ធជាម្ចាស់ មនុស្សខ្លះកើតមក រាប់មឺនៗជាតិនៅតែមិនបានជួប កុំថា តែការបានជួបព្រះអង្គនោះ សូម្បីតែគន្ធព្រះបាទក៏កម្រនឹងបានជួប ផង ព្រោះថា ទេវតាទាំងឡាយ នាំគ្នាលុបស្នាមព្រះបាទចោលអស់ បើព្រះ អង្គ ទ្រង់អធិដ្ឋានទុក ទើបទេវតាមិនហ៊ានលុបចោល។

អ្នកណាជ្រះថ្លានឹងព្រះអង្គ រមែងបានផលានិសង្សយ៉ាងក្រៃលែងបាន សោយទិព្វសម្បត្តិក្នុងកាមាវចរទេវលោក ជាន់ណានីមួយក្នុង ៦ ជាន់នោះ លោកជាតិរច្ឆានថ្នាក់ទាប ថែមទាំងមានមិច្ឆាទិដ្ឋិមកពោលដាក់ទោស ព្រះ ពុទ្ធ ខ្លួនលោកនេះ នឹងត្រូវទទួលទុក្ខ ក្នុងអត្តភាពនេះ។

ថាហើយក៏ចូលទៅតាមប្រហោងត្រចៀកស្តាំ របស់ស្តេចនាគហើយ ចេញតាមប្រហោងត្រចៀកឆ្វេង រួចចូលតាមប្រហោងត្រចៀកឆ្វេង ចេញ តាមប្រហោងត្រចៀកស្តាំ ចូលតាមប្រហោងច្រមុះស្តាំ ចេញតាមប្រហោង ច្រមុះឆ្វេង ចូលតាមប្រហោងច្រមុះឆ្វេង ចេញតាមប្រហោងច្រមុះស្តាំ។

ស្តេចនាគត្រូវទូន្មានដូច្នោះ ក៏កើតទុក្ខវេទនាយ៉ាងខ្លាំងក្រៃលែង គិត ថាក្នុងពិភពនាគ ពុំទាន់មាននរណា មានឫទ្ធិស្មើនឹងអញទេ សមណៈអង្គ នេះបិត្តខ្មៅខ្លាំងណាស់ ទូន្មានអញ ទាល់តែអញអត់ទ្រាំលែងបាន ចាំអញ ឲ្យសមណៈនេះ ចូលទៅតាមប្រហោងមាត់របស់អញ អញនឹងទំពាស៊ីឲ្យ

ល្អិត គិតហើយក៏ពោលថា បពិត្រលោកម្ចាស់ ធម្មតាសមណៈ រមែងមាន តែមេត្តាករុណា បើធ្វើអ្វីគឺធ្វើតែរបស់ណាដែលប្រកបដោយធម៌ មិនដែល ខាន តែនេះលោកម្ចាស់ មកក្លែងទូន្មានខ្ញុំព្រះករុណាឱ្យកើតទុក្ខ ហើយ លោកម្ចាស់ពោលថា មិនបានក្រោធខឹងអ្វីនឹងខ្ញុំព្រះករុណា ហេតុដូចម្តេច ទើបដាក់ទោសដល់ខ្ញុំព្រះករុណាទៅវិញ ថាហើយទើបហាមាត់បញ្ចេញចង្កូម
ឲ្យប្រកដៗ

ចំណែកព្រះមហាមោគ្គល្លាន បានស្តាប់ហើយ ក៏មានចិត្តស្រណោះអាណិត ចាំបាច់ទូន្មាន ដើម្បីឲ្យលះសេចក្តីអាក្រក់ ដូចមាតាបិតាដាក់ ទោសបុត្រដោយមេត្តា ប្រាថ្នាឲ្យបុត្រកើតជាមនុស្សល្អលុះបុត្រមិនល្អក៏កើតទុក្ខក្តៅក្រហាយ នឹងបណ្តេញចេញក៏មិនកើត ទើបបានស្តីប្រដៅ ឬធ្វើទោសជាការទូន្មានប្រៀនប្រដៅ គ្មានចេតនាកាចឃោរឃៅចំពោះបុត្រឡើយ មាតាបិតាប្រាថ្នាសេចក្តីល្អចំពោះបុត្រយ៉ាងណា ព្រះមហាមោគ្គល្លាន ក៏ប្រាថ្នាសេចក្តីល្អដល់ស្តេចនាគដូច្នោះលោកពោលថាអាត្មានេះ ទូន្មានលោកដោយចិត្ត ករុណាតែចំពោះលោកវិញប្រាថ្នាចង់ចឹកខាំទំពាស៊ីអាត្មាឲ្យល្អិតការដែលអាត្មាទូន្មានលោកនោះ ព្រោះប្រាថ្នាចង់ឲ្យលោកមានសទ្ធា ក្នុង

ព្រះពុទ្ធជាម្ចាស់ នឹងបានជាឧបនិស្ស័យទៅអនាគត គ្មានស្អប់ខ្ពើម លោកប៉ុនសរសៃសក់ទេ ថាហើយក៏និមន្តចូលទៅក្នុងមាត់របស់ស្តេចនាគចូលទៅដើរចង្ក្រមក្នុងពោះរបស់ស្តេចនាគនោះ។

ព្រះដ៏មានព្រះភាគទ្រង់ជ្រាបដោយព្រះញាណថា ឥឡូវនេះស្តេចនាគ ចាលចាញ់ព្រះមហាមោគ្គល្លានបុត្ររបស់តថាគតហើយ ទ្រង់សំដែងឱភាស នៅពីលើអាកាស ត្រាស់តឿនព្រះមហាមោគ្គល្លានថា ស្តេចនាគនេះមាន ឫទ្ធិក្រៃលែង លោកចូរធ្វើនូវមនសិការឲ្យបានល្អ ព្រះមហាមោគ្គល្លានក្រាប ទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះករុណា បំពេញឥទ្ធិបាទ ៤មក ពុំបានខ្ជិល ច្រអូល ប្រារព្ធមិនឲ្យដាច់ខ្ញុំព្រះករុណាមិនខ្លាចស្តេចនាគនេះទេ ទោះបីថា មានស្តេចនាគដែលមានឫទ្ធិខ្លាំងជាងនេះមួយសែនដង ក៏ខ្ញុំព្រះករុណាមិន ខ្លាច។

ស្តេចនាគគិតថា សូមលោកម្ចាស់កុំបៀតបៀនខ្ញុំព្រះករុណាឡើយ ចូរចេញអំពីពោះខ្ញុំព្រះករុណាចុះ ព្រះមហាមោគ្គល្លានក៏ចេញមកអង្គុយនៅខាងក្រៅ ព្រោះលោកជ្រាបវារៈចិត្តរបស់ស្តេចនាគនោះ។

ចំណែកស្តេចនាគនៅមិនទាន់ព្យសន៍ គិតចង់របាយខ្យល់ចេញពីច្រមុះឲ្យខ្លាំង ទាល់តែត្រូវដើមឈើ ដើមឈើនោះ ក៏បាក់គល់ ព្រះមហាមោគ្គល្លានជ្រាបវារៈចិត្តសេចក្តីគិតនោះ លោកក៏ចូលសមាបត្តិរក្សាការពារខ្លួន

មិនឲ្យមានគ្រោះថ្នាក់ ស្ដេចនាគឃើញព្រះថេរៈមិនខ្លាច ក៏អន់ចិត្ត គិតថា សមណៈអង្គនេះ មានឫទ្ធីខ្លាំងណាស់ បើអញស៊ូតទៅទៀត ត្រូវបានទទួលសេចក្ដីលំបាកជាងនេះ អាចដល់សេចក្ដីស្លាប់ជាប្រាកដ បើដូច្នោះចាំអញរត់ចេញទៅឲ្យផុត ព្រះថេរៈជ្រាបសេចក្ដីដែលនាគគិតរត់ទៅ ទើបនិម្មិត្តកាយឲ្យជាស្ដេចនាគធំហោះជាប់តាមទៅ ស្ដេចនាគនិមិត្តកាយធ្វើជាសត្វផ្សេងៗ ធំខ្លះ តូចខ្លះ រត់ចេញទៅ ព្រះថេរៈ ដេញតាមជាប់មិនឲ្យឃ្លាត ស្ដេចនាគគិតឃើញថា នឹងរត់ក៏មិនផុត ទើបប្លែងកាយជាមាណពតូច ចូល ទៅក្រាបទៀបបាទាព្រះថេរៈ ពោលថា ខ្ញុំព្រះករុណាជាមិច្ឆាទិដ្ឋិ មានចិត្ត បាបអាក្រក់ មិនបានឃើញប្រយោជន៍ ដែលកើតដល់ខ្លួន មកជួបនឹងលោកម្ចាស់ ក៏ពុំបានថ្វាយបង្គំ សូមព្រះគុណម្ចាស់ ចូរជាទីពឹងរបស់ខ្ញុំព្រះករុណាផងចុះ ព្រះថេរៈពោលថាលោកចូរទៅកាន់សំណាក់របស់ព្រះពុទ្ធជាម្ចាស់ថាហើយ យើងក៏នាំទៅគាល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។

កាលទៅដល់ស្ដេចនាគក៏ឱនចុះក្រាបបង្គំ ហើយក្រាបទូលថា ខ្ញុំព្រះករុណាជាអ្នកមានមិច្ឆាទិដ្ឋិ ជាពាល មិនស្គាល់បាបបុណ្យគុណទោស ឥឡូវនេះខ្ញុំព្រះករុណាបានជ្រាបច្បាស់ហើយថា ព្រះអង្គជាស្រែបុណ្យរបស់ទាយកទាំងពួង ចាប់ដើមតាំងពីថ្ងៃនេះទៅ ខ្ញុំព្រះករុណាសូមលះបង់នូវរូបកាយនេះ បូជាព្រះរតនត្រៃ ដរាបដល់អស់ជីវិត។

ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះមហាករុណា ចំពោះស្តេចនាគនោះ ទ្រង់ប្រទានសីល៥ ឲ្យរក្សា ហើយក៏នាំព្រះសាវ័កត្រឡប់ទៅផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីលោកសេដ្ឋីទូលសួរថា ថ្ងៃនេះ ហេតុអ្វីទើបព្រះអង្គយាងមក ថ្ងៃជ្រុលហួសពីធម្មតា ព្រះដ៏មានព្រះភាគត្រាស់ថា ព្រោះព្រះមោគ្គល្លាន ធ្វើសង្គ្រាមជាមួយស្តេចនន្ទោបនន្ទនាគរាជ លោកសេដ្ឋីទូលសួរទៀតថា តើ អ្នកណាឈ្នះ អ្នកណាចាញ់ព្រះអង្គ?។

ព្រះដ៏មានព្រះភាគត្រាស់ថា ស្តេចនាគនោះចាញ់មោគ្គល្លានៗបាន ទូន្មានឲ្យស្តេចនាគនោះមានសទ្ធា ក្នុងព្រះពុទ្ធសាសនា លោកអនាថបិណ្ឌិកសេដ្ឋីបានស្តាប់ហើយ ក៏រីករាយសោមនស្សយ៉ាងក្រៃលែង បានធ្វើសក្ការៈបូជាព្រះអរហន្ត៥០០អង្គ ដោយមានព្រះពុទ្ធជាប្រធាន ប្រមាណ៧ថ្ងៃ ព្រះដ៏មានព្រះភាគទ្រង់សរសើរ ព្រះមហាមោគ្គល្លានថាមានឫទ្ធិលើសពីព្រះអរហន្តទាំងឡាយ។

ក៏សន្មតថា ចប់រឿងរបស់ស្តេចនាគរាជ ឈ្មោះ នន្ទោបនន្ទនាគត្រឹមប៉ុណ្ណោះ ឃើញថា ត្រឹមតែឫទ្ធិរបស់ព្រះមហាសាវ័ក ក៏អាចបង្រ្កាបស្តេចនាគ អ្នកមានឫទ្ធិច្រើនបាន ចាំបាច់ពោលទៅថ្វី ដល់ព្រះសាស្តា គឺព្រះពុទ្ធជាម្ចាស់ ដោយហេតុនោះក្នុងពុទ្ធជយមង្គលគាថា ទើបបានឈ្មោះថា ព្រះដ៏

មានព្រះភាគទ្រង់មានជ័យជំនះលើស្តេចនាគរាជ ជាលើកទី៧ របស់ព្រះ អង្គ។

**ចប់ពុទ្ធជយមង្គលលើកទី ៧**

ជ័យជំនះលើកទី ៨

គាថាទី ៨

ព្រះពុទ្ធជាម្ចាស់ទ្រង់មានជ័យជនះលើមហាព្រហ្មឈ្មោះពកា

ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ។

ប្រែថា.ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សម្គាល់ថាអត្មា រុងរឿងដោយគុណបរិសុទ្ធិ។
ដែកាន់អសិរ្ពិស គឺចិត្តទ្រឹស្តដ៍មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាក់លះបង់ប្រាណ។
ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា។
រីជយមង្គល ចូរមានដល់អ្នកពាល់គ្នា

ដោយតេជៈជ័យា ឈ្នះព្រហ្មាឥតមានហ្មង។

គ្រាចុងក្រោយនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់មានជ័យជំនះលើព្រហ្ម ឈ្មោះពកាព្រហ្ម ក្នុងព្រះសូត្រហៅថា ពកាព្រហ្មព្រះសូត្រដែលសំដែងរឿងរបស់ពកាព្រហ្មនោះ មាននៅក្នុងព្រហ្មនិមន្តនិកសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសកៈ សូមដំណាលតាមព្រះសូត្រនេះ ក្នុងព្រះសូត្រពោលថា សម័យមួយ កាលព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន គ្រានោះព្រះដ៏មានព្រះភាគត្រាស់ដំណាលឲ្យភិក្ខុទាំងឡាយស្តាប់ថា សម័យមួយព្រះអង្គ ទ្រង់ប្រថាប់ក្នុងព្រៃសុភគវ័នទៀបព្រៃរាំងដ៏ធំ គ្រានោះពកាព្រហ្ម ជាព្រហ្មមិច្ឆាទិដ្ឋិយល់ឃើញខុសថាព្រហ្មស្ថាននេះទៀង ឋិតថេរ រឹងមាំ មិនឃ្លៀងឃ្លាត ព្រហ្មស្ថាននេះ មិនកើត មិនចាស់ មិនស្លាប់ ក៏ហេតុ ជាទីចេញទៅចាកទុក្ខ ក្រៅពីព្រហ្មស្ថាននេះមិនមានទេ គឺគិតថាព្រះនិព្វាន មិនមាន ព្រះដ៏មានព្រះភាគទ្រង់ជ្រាប សេចក្តីគិតរបស់ពកាព្រហ្មនោះ ទើបបាត់ព្រះអង្គអំពីគល់រាំងទៅប្រាកដឯព្រហ្មលោកយ៉ាងរហ័សដូចលាដៃ
ចេញ
ហើយបត់ចូលវិញដូច្នោះ។

ពកាព្រហ្មបានឃើញព្រះដ៏មានព្រះភាគ ស្តេចយាងមកអំពីចម្ងាយក៏ ក្រាបទូលថា បពិត្រអ្នកនិរទុក្ខលោកមកល្អហើយ តែយឺតពេលហើយ

ដែល លោកទើបតែមកក្នុងទីនេះ លោកអ្នកនិរទុក្ខព្រហ្ម ស្ថាននេះទៀង ខ្ជាប់ខ្ជួន ឋិតថេរ មិនកើត មិនចាស់ មិនស្លាប់ ទីចេញចាកទុក្ខ ក្រៅពីព្រហ្ម ស្ថាន មិនមានទេ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលពកាព្រហ្ម ខ្លួនលោកនេះធ្លាក់ទៅ ក្នុងអវិជ្ជា សេចក្តីងងឹតហើយ ព្រោះលោកពោលរបស់មិនទៀងថាទៀង ជា ការពិត, អ្នកដែលកើតក្នុងព្រហ្មស្ថាន ក៏នៅតែកើតចាស់ ស្លាប់ មិនទៀង តែ លោកពោលថា ទៀងទៅវិញ។

ពេលនោះមារអ្នកមានចិត្តបាប បានចូលទៅសណ្ឋិតក្នុងកាយរបស់ ព្រហ្មបារិសជ្ជា ព្រហ្មនោះបានពោលនឹងព្រះដ៏មានព្រះភាគថា ម្នាលភិក្ខុ អ្នកកុំបៀតបៀន រុកទន្ទ្រានពកាព្រហ្មឬ! ព្រោះពកាព្រហ្មនេះ ជាមហាព្រហ្ម ជាធំ ដែលពួកព្រហ្មមិនអាចប្រព្រឹត្តល្មើលបាន ជាអ្នកញុំាងសព្វសត្វឲ្យប្រ ព្រឹត្តទៅក្នុងអំណាច ជាអ្នកសាងលោកនិម្មិត្តលោក ជាអ្នកតែងសត្វ ជាអ្នក ប្រើអំណាចជាបិតារបស់ពួកសត្វដែលកើតឡើងហើយ និងកំពុងកើត។ម្នាល ភិក្ខុ សមណព្រាហ្មណ៍មុនៗ ជាអ្នកតិទៀន ដី ទឹក ភ្លើង ខ្យល់ ជាអ្នក តិទៀន ស្អប់ខ្ពើមទេវតា ស្អប់ខ្ពើមព្រហ្មថា មិនទៀង កាលបែកធ្លាយរាង កាយ រមែង ធ្លាក់ទៅកាន់អបាយ។ ម្នាលភិក្ខុ ចំណែកសមណព្រាហ្មណ៍មុន លោកពួក ខ្លះ ជាអ្នកសរសើរ ដី ទឹក ភ្លើង ខ្យល់ សរសើរទេវតាព្រហ្មកាល ពេលស្លាប់

ទៅ រមែងចូលដល់ព្រហ្មលោកព្រោះដូច្នោះ លោកចូរធ្វើតាម ពាក្យរបស់ព្រហ្មកុំល្មើស។

កាលបើមារពោលដូច្នេះ ព្រះដ៏មានព្រះភាគត្រាស់ថា នៃមារ! តថា គតស្គាល់អ្នកឯងហើយ ពួកព្រហ្ម និងបរិសទ័របស់ព្រហ្មនៅក្រោមអំណាចរបស់អ្នកឯង លោកគិតថា សូម្បីតែសមណៈនេះ ក៏នៅក្រោមអំណាចរបស់អ្នក! តែតថាគតមិនបាននៅក្រោមអំណាចរបស់អ្នកឯងទេ។

ចំណែកពកាព្រហ្ម ក៏ពោលអំពីសេចក្ដីជាធំរបស់ខ្លួន សេចក្ដីមានឫទ្ធិរបស់ខ្លួន ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតស្គាល់ហើយពកាព្រហ្មទូលសួរថា តើស្គាល់យ៉ាងណា?។

ព្រះដ៏មានព្រះភាគត្រាស់ថាដួងព្រះចន្ទ្រនិងព្រះអាទិត្យ រមែងគោចរបំភ្លឺបានត្រឹមណា អំណាចរបស់លោកប្រព្រឹត្តទៅបានមួយពាន់ចក្រវាឡប៉ុណ្ណោះ ម្នាលព្រហ្ម តថាគតរមែងដឹងសេចក្ដីសម្រេច និងអានុភាពរបស់លោកតែ លោករមែងមិនដឹង មិនឃើញ កាយ៣យ៉ាង តែតថាគតដឹងតថាគតឃើញ កាយ៣យ៉ាង គឺកាយអកស្សរៈ កាយសុកកិណ្ហៈ កាយវេ ហប្ផលា ព្រោះដូច្នោះ តថាគតជាអ្នកមិនស្មើនឹងលោកក្នុងចំណេះដឹង គឺតថាគតចេះដឹងខ្ពស់ជាងលោក តថាគតដឹងពី ដី ទឹក ភ្លើង ខ្យល់ ដឹង សត្វទេវតា ព្រហ្ម គ្រប់ជាន់ ដឹងព្រះនិព្វាន ដឹងសព្វគ្រប់ទាំងអស់។

ពកាព្រហ្មពោលថា ខ្ញុំនឹងទៅឲ្យបាត់ពីព្រះអង្គ ព្រះដ៏មានព្រះភាគត្រាស់ថា ចូរឱ្យបាត់ទៅចុះ បើលោកអាចបាត់ទៅបាន។ តែពកាព្រហ្ម មិនអាចទៅឲ្យបាត់ពីព្រះអង្គបានឡើយ ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតនឹងទៅឲ្យបាត់ពីលោក ពកាព្រហ្មក៏ពោលថា ចូរបាត់ទៅចុះ លោកអ្នកមាឫទ្ធិ បើលោកអាចបាត់បាន គ្រានោះព្រះដ៏មានព្រះភាគទ្រង់បណ្តាលឲ្យព្រះអង្គបាត់ទៅដោយឫទ្ធិ ពួកព្រហ្ម ទើបមើលព្រះអង្គឃើញ បានឬតែសំលេងព្រះអង្គប៉ុណ្ណោះដែលត្រាស់ថា តថាគតឃើញភ័យក្នុងភព ហើយឃើញភពរបស់សត្វអ្នកស្វែងរកទីប្រាសចាកភព មិនពោលលើកសរសើរភព អ្វីឡើយ ទាំងមិនញុំាងសេចក្តីត្រេកអរឲ្យកើតឡើងផង គ្រានោះពួកព្រហ្ម កើតអស្ចារ្យក្នុងចិត្ត ដែលបានឃើញឫទ្ធិរបស់ព្រះអង្គ ហើយបានពោលសរ សើរថា កាលមុនពួកគេមិនធ្លាប់ឃើញព្រះអង្គ មានឫទ្ធិច្រើនមានអានុភាគ ច្រើន ដូចព្រះដ៏មានព្រះភាគជាម្ចាស់ ។

ពេលនោះ ស្រាប់តែមារចូលសណ្ឋិតក្នុងព្រហ្មបារិសជ្ជាហើយ ពោលនឹងព្រះដ៏មានព្រះភាគថា ម្នាលលោកអ្នកនិរទុក្ខ បើលោកចេះដឹងដូច្នេះត្រាស់ដឹងយ៉ាងនេះ សូមលោកកុំណែនាំ កុំប្រៀនប្រដៅ កុំសម្តែងធម៌ដល់សាវ័ក ឬដល់បព្វជិតទាំងឡាយ សូមអារាធនា លោកធ្វើជាអ្នកប្រាថ្នាតិច កុំប្រៀនប្រដៅសត្វឡើយ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមារ តថាគតស្គាល់អ្នកហើយអ្នកកុំគិតថា តថាគតមិនស្គាល់អ្នកឯង លោកឯងជាមារ គ្មានចិត្តអនុគ្រោះ សង្គ្រោះ ទើបបានហាមតថាគតសម្តែងធម៌ប្រៀនប្រដៅពួកសត្វដទៃ តាម ធម៌ដែលតថាគតត្រាស់ដឹង ព្រោះខ្លាចក្រែងគេកន្លងអំណាចរបស់លោក ម្នាលមារ តថាគតជាព្រះសម្មាសម្ពុទ្ធ កាលនឹងណែនាំសម្តែងធម៌ដល់សាវ័កក៏ត្រូវណែនាំសម្តែង តាមដែលតថាគតដឹងមក។

កាលព្រះដ៏មានព្រះភាគ ទ្រង់ទំលាយសេចក្តីគិតឃើញខុស របស់ ពកាព្រហ្មហើយ ក៏បានស្តេចយាងត្រឡប់វិញទាំងអស់នេះ ជារឿងដែល ព្រះដ៏មានព្រះភាគត្រាស់ ដំណាលឲ្យភិក្ខុទាំងឡាយស្តាប់ ដែលបានបំព្រួញ សេចក្តីមកពីព្រហ្មនិមន្តនិកសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសក ក៏បញ្ចប់ រឿងរបស់ពកាព្រហ្ម ដែលជាអ្នកមិច្ឆាទិដ្ឋិឲ្យប្រែចិត្ត បានព្រោះអាស្រ័យ ព្រះដ៏មានព្រះភាគ តែត្រឹមប៉ុណ្ណោះ។

តទៅនេះ ជាប្រវត្តិរបស់ពកាព្រហ្ម តាមអដ្ឋកថា លោកបានជ្រាបថា ហេតុអ្វីពកាព្រហ្ម ទើបមានគំនិតថា ព្រហ្មស្ថានជារបស់ទៀង ឋិតថេរ អដ្ឋ-កថាពោលថា កាលពីអតីត: តាំងពីព្រះពុទ្ធជាម្ចាស់ នៅមិនទាន់បានត្រាស់ដឹងនោះ ពកាព្រហ្មបានបួសជាឫសីចម្រើនកសិណទាល់តែបានឈានហើយ

បានទៅកើតក្នុងវេហប្ផលាព្រហ្ម ដែលជាចតុត្ថជ្ឈានភូមិ មានអាយុ៥០០កប្ប ហើយថយចុះមកកើតក្នុងសុភកិណ្ហព្រហ្មភូមិ ដោយអំណាចតតិយជ្ឈាន ត មកក៏ថយចុះមកកើតក្នុង អាភស្សរាព្រហ្មភូមិ ដោយអំណាចទុតិយជ្ឈាន ហើយក៏ថយចុះមកកើតជាស្តេចមហាព្រហ្ម ក្នុងបឋមជ្ឈានភូមិ ហៅថា វិនាសចាកឈានខ្ពស់បំផុត តាំងពីចតុត្ថជ្ឈាន ចុះមកទាល់តែដល់បឋមជ្ឈាន ដែលមានអាយុត្រឹមតែ១កប្ប ពេលដែលកើតថ្មីៗនៅរលឹកដល់កម្មក្នុងជាតិមុនៗ ថាធ្លាប់បានឈានអ្វីៗទៅកើតទីណាតែលុះយូរមកក៏ភ្លេចអស់ ទើបកើតសស្សតិទិដ្ឋិ ថាព្រហ្មលោកជារបស់ទៀង ឋិតថេរ ទីកន្លែងចេញចាកទុក្ខ ក្រៅពីព្រហ្មលោកមិនមាន ព្រះដ៏មានព្រះភាគទើបត្រាស់ថា ទីកន្លែងដែលតថាគតដឹង តថាគតឃើញ នៅមានទៀត ៣ កន្លែងគឺ អាភស្សរា សុភកិណ្ហា និងវេហប្ផលា តែទីកន្លែងទាំង ៣ នោះ លោកមិនដឹងមិនឃើញ ពកាព្រហ្ម ទើបគិតថា ព្រះដ៏មានព្រះភាគ ទ្រង់ដឹងដល់អតីតរបស់ខ្លួន ទើប ទូលសួរអំពីបុព្វកម្មដែលធ្វើឲ្យកើតជាព្រហ្ម ព្រះដ៏មានព្រះភាគ ក៏ទ្រង់ សម្តែងឲ្យស្តាប់ៗ

ព្រះដ៏មានព្រះភាគត្រាស់ថា ក្នុងគ្រានោះពកាព្រហ្មបានកើតជាមនុស្ស ឃើញទោសក្នុងកាមារម្មណ៍ទាំងឡាយ ហើយបានចេញបួសជាមហាឫសី ធ្វើសមាបត្តិឲ្យកើតឡើង បានសាងសាលានៅមាត់ឆ្នេរស្ទឹងគង្គា បាន ប

ណ្ដាលឲ្យទរទឹកបាញ់ឡើងមកពីក្នុងទន្លេគង្គា តម្រង់ទៅកាន់ផ្លូវកន្ដារអត់ទឹកមួយកន្លែង ដែលពួកឈ្មួញរទេះទាំង៥០០ និង ហ្វូងគោដែលទឹមរទេះកំពុងតែដាច់ទឹក ស្រេចទឹកយ៉ាងខ្លាំង ដើម្បីឲ្យទឹកជាទាន ដល់មនុស្ស និងសត្វទាំងនោះ។ មានគ្រាមួយទៀត បានជួយមនុស្ស និងសត្វផុតពីអំណាចមហាចោរដោយឫទ្ធិរបស់ខ្លួន ម្ដងក្រោយទៀតបានជួយមហាជន ឲ្យផុតពីអំណាចរបស់ស្ដេចនាគ ដែលកាចឃោរឃៅ ក្នុងជាតិកំណើតជាឫសី មានឈ្មោះថា កេសវឫសី ព្រះពុទ្ធជាម្ចាស់របស់យើង បានកើតជាកូនសិស្សរបស់កេសវឫសីនោះ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដំណាល ពីអតីតជាតិឲ្យពកាព្រហ្មស្ដាប់យ៉ាងនេះឯង ឯពកាព្រហ្មបានស្ដាប់ហើយក៏រលឹកជាតិបាន បានក្រាបទូលសរសើរព្រះដ៏មានព្រះភាគថាជាអ្នកដឹងពិត ឃើញពិតមាន អានុភាពច្រើន ធ្វើឲ្យព្រហ្មលោកភ្លឺស្វាងបាន ព្រោះហេតុនេះ ពកាព្រហ្ម ទើបលះបង់សេចក្ដីឃើញខុស ដែលពោលថា ព្រហ្មស្ថានជាកន្លែងទៀង បិតថេរ កាលដែលព្រះដ៏មានព្រះភាគទ្រង់ធ្វើឲ្យពកាព្រហ្មលះបង់សេចក្ដី ឃើញខុសបាននេះ ចាត់ជាជ័យជំនះរបស់ព្រះអង្គមួយប្រការទៀត ទើប ចប់រឿងរបស់ពកាព្រហ្មដោយបរិបូណ៌ត្រឹមប៉ុណ្ណេះ។

សរុបពុទ្ធជយមង្គល ជាគាថាដែលសម្ដែងអំពីជ័យជំនះរបស់ព្រះពុទ្ធដែលមានលើបុគ្គលទាំង ៨គឺ ស្ដេចមារ១. អាឡវកយក្ខ១. ដំរីនាឡាគីរី១.

អង្គុលីមាចោរ១.នាងចិញ្ចាមាណវិកា១.និងនាងសុន្ទរីបរិព្វាជិកា១. សច្ចកនិគ្រន្ថ១.នន្ទោបនន្ទនាគរាជ១. និងពកាព្រហ្ម១.រួមត្រូវជា៨នាក់។

លោកពោលពីអានិសង្ស ការចម្រើនពុទ្ធជយមង្គលគាថា ដោយចិត្តជ្រះថ្លាថា នឹងបានជាអ្នកមិនប្រមាទ និងបានរួចផុតពីអន្តរាយ និងញាំញីកិលេសចេញបាន បានលុះព្រះនិព្វានដែលមិនកើត មិនស្លាប់។

**ចប់ពុទ្ធជយមង្គលលើកទី ៨**

គាថាសម្តែងអំពីអានិសង្ស

(គាថាទី ៩)

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា
យោ វាចនោ ទិនទិនេ សរតេ មតន្ទី
ហិត្វាន នេកវិវិធា និចុបទ្វានិ មោក្ខំ
សុខំ អធិគមេយ្យ នរោ សបញ្ញោ។

<u>ប្រែថា</u> **យោ នរោ** ជនឯណា កបបញ្ញាប្រាសក្តិខ្ជិល
ឧស្សាហ៍សាងទានសីល សូត្ររំលឹកព្រះធម៌ថ្ងៃ។
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំសូត្រសព្វៗថ្ងៃ កើតមង្គលជានិរន្តរ៍។
**សោ នរោ** រីជននោះ បានរំដោះរោគអាសន្ន

ឧបទ្រព្យអនេកលន់ មានប្រការផ្សេងៗផង។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្ទង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ។

*គាថាទី១ ស្ដីអំពីការឈ្នះមារនោះ លោកពោលថា កាលបើភាវនាគាថានេះ សត្រូវនឹងចុះចាញ់ បើប្រើបណ្ដោញខ្មោច ឱ្យភាវនា ៣ ចប់ ឬធ្វើជាទឹកមន្ត ស្រោចក៏បាន។*

*គាថាទី២ ស្ដីអំពីការឈ្នះអាឡវកយក្ស គាថានេះ លោកឱ្យភាវនារាល់ល្ងាចព្រឹក វិសេសណាស់ លោកឱ្យប្រើសែកថ្នាំលាប ថ្នាំលេបគ្រប់ប្រភេទ កែរោគភ័យ ជម្ងឺតម្កាត់ បន្ថែមឫទ្ធិថ្នាំឱ្យរឹតតែខ្លាំងឡើង ប្រើធ្វើទឹកមន្តស្រោចក៏បាន។*

*គាថាទី៣ ស្ដីអំពីការឈ្នះដំរីនាឡាគិរី គាថានេះប្រើភាវនា ការពារ ខ្លាដំរី នឹងសត្វសហាវផ្សេងៗ លោកឱ្យភាវនាដើរក្នុងព្រៃ ពួកភូតបីសាចមិនហ៊ានបៀតបៀន ព្រមទាំងការពារជម្ងឺតម្កាត់ផង។*

*គាថាទី៤ ស្ដីអំពីការឈ្នះ អង្គុលីមាលចោរ គាថានេះ លោកឱ្យសែកទឹកលុបមុខ កើតសិរីសួស្ដីជោគជ័យមង្គល ការពារអំពើទាំងពួង។*

*គាថាទី៥ ស្ដីអំពីការឈ្នះនាងចិញ្ចមាណវិកា គាថានេះ លោកឱ្យសែកធ្វើទឹកមន្ត ប្រោះព្រំ ស្រោចក្បាល ការពារជម្ងឺរោគា។*

*គាថាទី៦* ស្ដីពីជ័យជំនះលើសច្ចកនិគ្រន្ថ លោកពោលថា បើមាន ទុក្ខភ័យកើតក្ដីក្ដាំ ឱ្យយកគាថានេះភាវនា នឹងមានជ័យជំនះ។

*គាថាទី៧* ស្ដីការមានជ័យលើនន្ទោបនន្ទនាគរាជ គាថានេះលោក ឱ្យភាវនារាល់ថ្ងៃ ការពារជម្ងឺសត្វសារពើ បើអាសិរ្ពិសដូចពស់ចឹក ឱ្យប្រើ គាថានេះ ផ្លុំពន្ទត់ពិសបាត់ភ្លាម។

*គាថាទី៨* ស្ដីពីការឈ្នះពកាព្រហ្ម ជាអ្នកសស្សតទិដ្ឋិ ភាវនាឱ្យបាន រាល់ថ្ងៃ ការពារបីសាច នឹងរោគធ្ងន់ទាំងពួង បើបណ្ដេញខ្មោចបីសាច ឱ្យពោលបទពាហុំ៣ចប់ បទមារាតិរេក៣ចប់ ទុគ្គាហ: ៣ចប់ ចង់បណ្ដេញខ្មោចទៅឱ្យអស់។

*គាថាទី៩* ជាគាថាសម្ដែងអានិសង្សរបស់ការសូត្រពុទ្ធជយមង្គល គាថាទាំង៨បទ គាថានេះ ប្រើស្ដោះ ព្រួសពិសទាំងពួងធ្វើទឹកមន្ត ស្រោចការពាររោគភ័យបានគ្រប់យ៉ាង ក៏សន្មត់ថាចប់ អានិសង្សក្នុងការប្រើគា ថាទាំង៨បទ ដោយបរិបូណ៌តែប៉ុណ្ណោះ។